រឿង

# បើសិននៅមានថ្ងៃស្អែក

ប្រលោមលោកមនោសញ្ចេតនា

និពន្ធ គូរគំនូរ និង រចនាក្របដោយ
អ្នកស្រី កែវ ចន្ទ័បូរណ៍

P.O.Box 600279
Saint Paul, MN 55119
USA
khmervissal@yahoo.com
www.angkorwat.com

សូមទាក់ទង
016-318-023
012-774-751

ខែឧសភា២០០៤
រក្សាសិទ្ធិគ្រប់យ៉ាង

CHANBOKEO.COM

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៍

| | |
|---|---|
| ១- រឿង សំនៀងស្នេហ៍កវី | ២- រឿង និស្ស័យស្នេហ៍ |
| ៣- រឿង ផ្កាយវង្វេងមេឃ | ៤- រឿង ស្នាមញញឹម |
| ៥- រឿង កុលាបស្ទឹងខៀវ | ៦- រឿង ក្លិនផ្កាមាលតី |
| ៧- រឿង លិខិតមរតកសម្ងាត់ | ៨- រឿង បំណុលជីវិត |
| ៩- រឿង ចរណៃដួងទ័យា | ១០- រឿង អំបែងអណ្តែត |
| ១១- រឿង ស្នែ្ហកចាកផុតទៅ | ១២- រឿង តន្ត្រីបេះដូង |
| ១៣- រឿង សារាណីយមាតា | ១៤- រឿង ទារុណដួងចិត្ត |
| ១៥- រឿង បើសិននៅមានថ្ងៃស្នែ្ហក | ១៦- រឿង លំអងផ្កាស្នេហ៍ |
| ១៧- រឿង ត្រៃមិត្ររតននារី | ១៨- រឿង ខ្នើយវាសនា |
| ១៩- រឿង បើសិនអាចបង្វិលផែនដី | ២០- រឿង លីវបុរេកាល |
| ២១- រឿង មេឃដ៏សក្តិសិទ្ធិ | ២២- រឿង មួយពាន់ទំព័រ |
| ២៣- រឿង អាមេរិកដែនដីមាស | ២៤- រឿង អាធ្រាតថ្ងៃរះ |
| ២៥- រឿង បក្សីសួនសុបិន | ២៦- រឿង ម្លប់អសោក |
| ២៧- រឿង ពិដេដ្ឋភានុមា | ២៨- រឿង ផ្ការីកក្រៅសួន |
| ២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ | ៣០- រឿង អនង្គលាភា |
| ៣១- រឿង ពណ្ណរាយពេជ្រ | ៣២- រឿង សារិកា |
| ៣៣- រឿង ផ្ការាជបឹងរាំង | ៣៤- រឿង នភាមណី |
| ៣៥- រឿង ស្រីនាថភ្លួងមាលា | ៣៦- រឿង វាយោដួងចិត្ត |

ISBN: 99950-79-00-3

CHANBOKEO.COM

# សូមឧទ្ទិសស្នាដៃនេះប្រគេននិងជូនចំពោះ

- ព្រះគ្រូសេងប៊ុនសង ព្រះគ្រូចៅអធិការម៉ឹងសាង ភិក្ខុវុំមភិរម្យ ភិក្ខុ គិមស៊ីវត្ថី ភិក្ខុ ជុំវិចិត្រ ភិក្ខុគង់សុជា វត្តមិនីសូតារាម រដ្ឋមិនីសូតា សហរដ្ឋអាមេរិក
- ព្រះចៅអធិការរតន៍សុខុម ភិក្ខុធន់សុគន្ធា ភិក្ខុមឹងវិបុល វត្តខ្មែរ រ៉ែឆេស្ទ័រ រដ្ឋមិនី សូតា សហរដ្ឋអាមេរិក ។
- លោក មេងស្នួងសុវណ្ណធី ជាស្វាមី និងកុមារី សុវណ្ណធីធម្មិកាបារមីបុណ្យជាបុត្រី
- លោកឪពុក ប៊ុនថង អ្នកម្តាយ កែវយឿង និងប្អូនទាំងបួនព្រមទាំងក្រុមគ្រួសារ
- លោកឪពុកក្មេក មេងស្នួង និងអ្នកម្តាយក្មេក កូវសារ៉ាន់ ព្រមទាំងកូនចៅ
- សាស្ត្រាចារ្យគិមមាសក្ខុយ រស់សាន់ អួននឿង ចាន់សុខា បណ្ឌិតយូគិមទូយ
- អ្នកស្រីនៅសារិម វិទ្យុ VOA សម្លេងសហរដ្ឋអាមេរិក
- លោក លីតាយហុង អ្នកគ្រូ ទូចសារៀង អ្នកគ្រូ កែវសុផុន លោករើនរស់ អ្នក ស្រីមាងបេងយង់ អ្នកស្រីប៉ក់ដារិនី លោក លេកស៊ីវហុង អ្នកស្រីអ៊ាបគិមណាង និងអ្នកគ្រូម៉ៀចសុខារី ។
- លោកខូតារាឫទ្ធិ នាយកកម្មវិធីសម្ភហកម្មអក្សរសិល្ប៍នូហាច ភ្នំពេញ
- សាស្ត្រាចារ្យ យូ សុភា មជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម

CHANBOKEO.COM



អ្នកស្រី កែវ ចន្ទ័បូរណ៏

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

# វាចាអ្នកនិពន្ធ

បើសិននៅមានថ្ងៃស្អែក ជាកម្រងរឿងពិតប្រឌិតផ្សំមួយដែល ជាបំណែកសាខារបស់រឿង
ចរណៃដួងច័យា ស្នាមញញឹម និង កុលាបស្ទឹងខៀវ ដែលបានចេញផ្សាយរួចមកហើយ ។
បើសិននៅ មានថ្ងៃស្អែក លាតត្រដាងពីជីវិតគ្រួសារមួយដែលបានព្រាត់ប្រាស
គ្នាដោយសាររបបខ្មែរក្រហមសម័យ១៩៧៥-១៩៧៩ ហើយគេក៏
ស្រវាស្រទេញតាមរកបំណែកសុភមង្គល និងសមាជិកគ្រួសារ របស់គេដែលឃ្លាតឃ្លាទៅនោះ
ឲ្យវិលត្រឡប់មកជួបជុំគ្នាវិញ សា ជាថ្មី ។ ប៉ុន្តែ តើសេចក្តីសុខថ្មីនោះ
មានការផ្លាស់ប្តូរប្លែកយ៉ាងណា ពីបំណាន់ផ្សងរបស់គេ ? តើគេត្រូវដោះស្រាយយ៉ាងណាចំពោះអ្វីៗ
ដែលខកបំណងនោះ ? តើការរង់ចាំ និងសេចក្តីសង្ឃឹមរបស់គេ
បានទទួលចម្លើយវិជ្ជមានដែរឬក៏យ៉ាងណា ?

សូមអោយអ្នកអានទាំងឡាយ បានទទួលនូវរសជាតិជីវិត និង
ខ្លឹមដួងចិត្តស្នេហ៍ភក្តីដ៏បរិសុទ្ធមួយ នៅក្នុងប្រលោមលោកមនោ សញ្ចេតនា
"បើសិននៅមានថ្ងៃស្អែក" នេះកុំបីខាន ។

នាងខ្ញុំអ្នកនិពន្ធ សូមទទួលនូវមតិយោបល់ពីប្រិយមិត្តអ្នកអាន តាមរយៈ
អាស័យដ្ឋានដូចខាងក្រោមនេះ :

Pannalai Khmer Vissal
P.O.Box 600279
Saint Paul, MN 55119, USA
Khmervissal@yahoo.com

អ្នកស្រី កែវ ចន្ទ័បូរណ៍
ខែឧសភា២០០៤

CHANBOKEO.COM

# ទំព័រកំណាព្យ

==================================================

## វិញ្ញាណម៉ែគោកធ្លក

ឱដែនគោកធ្លកជំរកក្សាន្ត    ម៉ែបានកាប់ឆ្ការច្បារដាំដុះ
សង់ភូមិសង់ផ្ទះប្រាសាទច្រុះ    កូនចៅច្រើនណាស់ជ្រកដេកពួន ។
ម៉ែចេញភ្ជួរស្រែបង្កើនស្រូវ    ចិញ្ចឹមញាតិផៅអស់ផងស្ងួន
គ្រប់យសគ្រប់ថ្នាក់ខ្ពស់ទាបជូន    ស្រូវម៉ែថែធួនរស់គ្រប់គ្នា ។
តែកូនបែរលួចម៉ែយកមាន    កាប់ចាក់បំពានឃ្លានភោគ្គា
កាប់ព្រៃដុតម៉ែមិនមេត្តា    ហែកដីមាតាលក់អោយគេ ។
រូបម៉ែធ្លាប់ឆ្លាក់ជាប់ប្រាសាទ    សែនល្អស្រស់ស្អាតឥតបើគ្មែរ
កូនកាត់ក្បាលម៉ែគ្មានសល់ទេ    ដៃជើងក៏ដែរពិការអង្គ ។
កូនខ្លះប្រតាយប្រតប់គ្នា    ដណ្តើមទ្រព្យាផ្សេងភ្លើងលង់
កូនមួយពឹងកើតមួយស្ទុះប្រឹង    ហៅខាងលិចរឹងចូលសង្វៀន ។
កូនម៉ែកាប់ចាក់ព្រោះលោភលន់    មិនស្តាល់ពាក្យគ្រាន់ដែលម៉ែប្រៀន
កូនអើយ! ម៉ែយំឥតខ្មាស់អៀន    ព្រោះកូនបែរហ៊ានផ្តើនម៉ែឯង ។
វិញ្ញាណម៉ែខ្មាសរឿងលោកីយ៍    កូនម៉ែប្រុសស្រីច្បាំងបែកផ្សេង
យាយីបងប្អូនឥតកោតក្រែង    ព្រលឹងម៉ែឯងក៏មិនអោយសល់...

CHANBOKEO.COM

# ដើមអំពិល

ដឹងថាគេបោចពេលខ្លួនលាស់ត្រួយ ចេញក្តិបមួយរយផ្លែទំមួយពាន់
អ្នកភូមិឡើងបេះធ្វើអាហារលាន់ អំពិលមិនទ្រាន់លាស់ត្រួយថែមទៀត ។
ជាដើមអំពិលមិនខ្ជិលផ្លែផ្កា ទាំងប្រាំងវស្សាបំរើផៅញាតិ
ស្លឹកខ្ចីបួតស្ល ស្លឹកចាស់បុកទៀត ធ្វើថ្នាំអស់ស្មៀតថ្នមអ្នកកូនខ្ចី ។
បោចណាស់លាស់ណាស់អំពិលដីស្រែ បំរើហូរហែជាតិខ្មែរប្រុសស្រី
មិនខុសអ្នកប្រាជ្ញបំរើតិចអី លាស់ចំណេះថ្មីចែកចាយមិនភ្លាត់ ។
បេះណាស់លាស់ណាស់អ្នកប្រាជ្ញបញ្ចេញ គ្មានថ្ងៃទោម្នេញទ្រោមដើមប្រាកដ
សិស្សតាមបេះបោចគំនិតមរកដ ចែកមួយមិនភ្លាត់លាស់ទៀតរយពាន់ ។
គំនិតអ្នកប្រាជ្ញមិនខុសអំពិល រាល់ថ្ងៃមិនខ្ជិលបញ្ចេញសម្ពន្ធ័
លាស់គំនិតថ្មីចែកចាយរួសរាន់ ជាតិខ្មែរលែងភន្តត្បិតពលរដ្ឋប្រាជ្ញ ។

CHANBOKEO.COM

# ក្រាំងពិសិដ្ឋមួយ

អ្នកមួយរៀនចេះត្រិះគ្នាន់គ្មេរ    ប្រមូលសរសេរសព្វគំនិត
ចារតម្រិះទុកក្រាំងពិសិដ្ឋ    ចែកចាយញាតិមិត្តអានវិភាគ ។
អ្នកពីរបានក្រាំងដើរចែកចាយ    ពីនាយដល់អាយហុចគ្នាក្បៀក
ចៃដន្យភ្លេចបើកអានវិភាគ    ពិចារណ៍ខ្លឹមពាក្យពេចន៍ខាងក្នុង ។
អ្នកបីចាប់ក្រាំងពួនពិចារណ៍    ជំរះន័យអាថិយ៉ាងផ្ចិតផ្ចង់
រៀនត្រងគំនិតពិតជ្រៅលង់    អោយយល់ក្រៅក្នុងចេះចាំស្ទាត់ ។
អ្នកបួនរៀនចេះជ្រាលជ្រៅហើយ    បិទក្រាំងព្រងើយភ្លេចអនុវត្តន៍
ចាំអស់ទ្រឹស្តីមិនភ្លាំងភ្លាត់    ឯរឿងអនុវត្តន៍បែរកម្រ ។
កវីគន់គិតចិត្តបារម្ភ    តុមួយបួនមុំឈរជាប់ល្អ
ពឹងលើជើងបួនជាជំហរ    បាត់ជើងមួយឈរអស់លំនឹង ។
ច្នេះឱមិត្តអើយគិតជាថ្មី    ជាន់បានកាំបីសូមសញ្ជឹង
កុំភ្លេចកាំបួនប្រព្រឹត្តប្រឹង    អនុវត្តន៍ពង្រឹងអត្ថន័យក្បួន ។

CHANBOKEO.COM

# វាស់តម្លៃតាមទឹក

ទឹកលុយទឹកមាសទឹកប្រាក់ទឹកពេជ្រ    ទឹកភ្លឺរំលេចតម្លៃរបស់
ថ្លៃថោកលើទឹកវាយបានទាំងអស់    ទឹកកាត់ថ្លៃយសភស្តុភារសព្វយ៉ាង ។
រីតម្លៃមនុស្សក៏វាស់នឹងទឹក    ថ្លៃថោកពន្លឺកទឹកឆ្លុះបញ្ចាំង
តម្លៃទឹកចិត្តពិតជាក្លាខ្លាំង    ទឹកវាស់សំរាំងកិត្តិយសបុគ្គល ។
មិនថាបញ្ញវន្ត័ សេដ្ឋីឧកញ៉ា    កិត្តិយសសក្តាខ្ពស់ល្អនិមល
បើខ្វះទឹកចិត្តញោតិសើចរចល់    យសធំអស់កលល្អត្រឹមសំបក ។
ទឹកចិត្តអាចវាស់តម្លៃមនុស្ស    ពិតជាមិនខុសទឹកវាស់គ្រប់ច្រក
ពេជ្រត្បូងលុយកាក់ចាយទាំងកន្ត្រក    ទឹកវាស់មិនខកតម្លៃទាំងឡាយ ។

CHANBOKEO . COM

# កណ្ដៀវ

កណ្ដៀវល្អិតៗប្រមូលផ្ដុំ    ក ទព័ប្រជុំពូនដំបូក
តិចតួចតក់ៗជញ្ជូនយក    សង់បានជំរកលំនៅក្សាន្ត ។
ថ្វីបើកណ្ដៀវជាតិជាសត្វ    ល្អិតតូចពេកក្ដាត់ឥតលំអាន
អាចពូនដំបូកខ្ពស់ថ្កើងថ្កាន    ជ្រកនៅសុខសាន្តមិនព្រួយភ័យ ។
ជាតិជាមនុស្សវិញគួរខ្មាស់អៀន    រៀនមើលគំរូសត្វតូចក្រៃ
ធ្វើការសាមគ្គីគ្រប់ៗដៃ    មិនពៃរ៍ពេបជ្រាយមើលបំណាំ ។
ជាតិមនុស្សគួរណាស់ចេះជាងសត្វ    មិនភ្លាត់បែកបាក់ធ្លាក់ផ្លូវកម្ម
 កសាងប្រទេសថ្កើងរឹងមាំ    ដូចកណ្ដៀវស្ដាំសាមគ្គីព្រម ។

CHANBOKEO . COM

# សាង...

ស្រុកផុតសង្គ្រាមនាំគ្នាសាង ភូមិគ្រឹះស្អិតស្អាងសាងផ្លូវជាតិ
សាងសណ្ឋាគារស្រស់វរនាថ វត្តអារាមទៀតល្អរមណីយ៍ ។
គ្រឹស្ថានតូចធំដុះស្អេកស្កុះ លូតលាស់ត្រចះវាតដីធ្លី
ទេសចរណ៍ចេញចូលយ៉ាងមូលមីរ សំភីចង់ស្គាល់ខ្មែរលូតលាស់ ។
ថៃដន្យយើងសាងអាគារល្អ ភ្លេចសាងសីលធម៌ខ្ពស់ត្រចះ
ចាកនូវវិន័យតាមធម៌ព្រះ ខេមរានិរាសចាកគុណធម៌ ។
សម័យជឿនលឿនអភិវឌ្ឍន៏ ខ្មែររៀនចេះស្ទាត់កំព្យូទ័រ
ប៉ុន្តែភ្លេចសាងអំពើល្អ ដល់ញាតិក្រីក្ររស់វិនាថ ។
សាងសង់ប្រទេសមានគ្រប់ជ្រោយ សាងអាគារហើយសាងមនុស្សទៀត
សាងទាំងសីលធម៌វប្បធម៌ជាតិ ទើបខ្មែរចាកឃ្លាតហាយនភព ។

CHANBOKEO.COM

# ទឹកសមុទ្ទនិងទឹកត្រពាំង

សមុទ្ទធំធេងទឹកថ្លាក្រៃ ស្រណោះវិស័យពឹងមិនបាន
ពេលឃ្លានពេលស្រេកបែរអាក់ខាន សមុទ្ទប្រែខានផឹកសម្រន់ ។
ត្រពាំងតូចក្តាត់ទឹកល្អក់ខ្វល់ បែរជានិមលគួរអោយភន្ត័
អ្នកស្រុកដងប្រើពេញភូមិលាន់ រស់រានឃ្លានស្រន់ត្បិតទឹកជា ។
សមុទ្ទដូចមនុស្សអស្សុរស មានបុណ្យសក្តិយសមានទ្រព្យា
ចិត្តវិញជាកំណាញ់មិនធូរធារ នឹងមនុស្សដូចគ្នាសូម្បីមិត្ត ។
រីទឹកត្រពាំងដូចអ្នកបុណ្យ តិចតួចចែកគ្រាន់ល្មៀងជីវិត
មិនមើលបំណាំស្អាំវិបរិត ញាតិផៅឆ្ងាយជិតពឹងពាក់បាន ។
ថ្មេះធ្វើសមុទ្ទប្រយោជន៏អ្វី ធំធេងពេកក្រៃតែសាមាន្យ
សូវធ្វើត្រពាំងទឹកកល្យាណ សន្តានរំភើបត្បិតសប្បុរស ។

CHANBOKEO.COM

# អរិជ្ជានិងកម្លៅ

អរិជ្ជាមានន័យថាល្ងិតល្ងង់ ចង់ភ្លឺរៀនឡើងអោយជ្រះស្វាង
សាងខ្លួនខ្ពង់ខ្ពស់មានសំណាង ធ្វើមេចាងហ្វាងគ្រប់គ្រងការ ។
អរិជ្ជាមានន័យថាមិនចេះ ស្រវាតម្រេះត្រង់សិក្សា
បណ្តុះខ្លួនឡើងយសភ្លឺថ្លា ក្លាយជាបញ្ញាជនគំរូ ។
រីឯកម្លៅមានន័យផ្សេង ជាអ្នកចេះដឹងប្រឹងគយ្ហូរ
វាយឫកអញចេះគ្មានអ្នកប្តូរ កុំជោរកែកុនអោយយោបល់ ។
កម្លៅសំដៅអ្នកដឹងចេះ មានចិត្តមានះមិនរវល់
ពុំស្តាប់គតិយោងហេតុផល ច្រានចោលយោបល់រិះគន់ខ្លួន ។
ជំងឺពីរនេះឈឺខុសគ្នា ឈឺអរិជ្ជាពេទ្យអាចស្ងួន
តែឈឺកម្លៅគ្មានទេក្បួន ពេទ្យអាចថែធ្ងួនជាងាយឡើយ ។

CHANBOKEO.COM

# ជាតិជានរណា

យើងតែងតែសួរជាតិជានរណា ឱអស់ខេមរាជាតិគឺខ្លួនយើង
សាងខ្លួនបានល្អជាតិនឹងថ្កុំថ្កើង វិវត្តន៍លូតឡើងយើងជាសសរ ។
ជាតិមានអត្ថន័យវង្ស់គ្រួសារ មាតាបិតាញ្ញាតិផៅបវរ
មិត្តផងទាំងឡាយទៅមករាប់រក៏ មានសីលគុណធមិល្អពេញសណ្ដាប់ ។
ជាតិគឺជំរកលំនៅដីភូមិ ជីវិតជួបជុំសប្បាយសាយភ័ព្វ
ស្ពកមួយដែរយលូកបាយយ៉ាងញាប់ អាហារឆ្ងាញ់គាប់ត្បិតចិត្តយើងជា ។
ជាតិគឺដីវាលដីក្រុងដីស្រែ ព្រៃភ្នំផងដែរទន្លេសព្វសារ
បឹងបួរប្រឡាយប្រាសាទថ្មដា អារាមសាសនាពុទ្ធាព្រះគ្រូ ។
ជាតិគឺអក្សរអំបូរភាសា វិជ្ជាសាស្ត្រាថែងចារយន់យូរ
ភាសាលូតលាស់ជាតិយើងក៏ភ្លឺ នាមារន្ទីភ្លឺស្វាងភិមាន ។
ជាតិគឺវប្បធមិច្បាប់ប្រពៃណី នាំជោគសិរីខ្ពង់ខ្ពស់ថ្កើងថ្កាន
រក្សាថ្នមថៃខ្មែរគ្រប់សន្តាន យល់តែកេរ្យមក្សាន្តចេរកាលយូរលង់ ។
ជាតិជាឫសគល់បង្ហាញអត្ត សញ្ញាណយើងឆ្លាក់ជាប់ក្នុងកាយអង្គ
បេះដូងជាខ្មែរថ្នមថៃញាតិវង្ស ជាតិយើងសុរិយង្គត្បិតឫសគល់មាំ ។

CHANBOKEO.COM

# មុននឹងអស់សង្ខ័យ....

កើតចាស់ឈឺស្លាប់ច្បាប់ធម្មជាតិ　　　មនុស្សមិនអាចឃ្លាតអាចបំពាន
តែនៅអាចជ្រើសជីវិតបាន　　　ពេលរស់គ្រប់ប្រាណសាងក្តីល្អ ។
ទាន់មានជីវិតគិតរៀងរៃ　　　សាងខ្លួនប្រពៃក្នុងសីលធម៌
ប្រព្រឹត្តសុចរិតក្រិត្យបវរ　　　ធ្វើអំពើល្អចំពោះញាតិ ។
នៅក្មេងបណ្តុះសព្វវិជ្ជា　　　ជំនាញសាស្ត្រាមិនរវាត
ធំឡើងធ្វើការស្វែងអស់ស្មៀត　　　ចិញ្ចឹមផៅញាតិចាកអត្តខាត់ ។
មិនខ្ជិលទំរន់ទន់រាងកាយ　　　ងើបឡើងធ្វើហើយយ៉ាងប្រយ័ត្ន
ពាក្យម៉ែឪផ្តាំចាំគ្រប់ម៉ាត់　　　ប្រព្រឹត្តមធ្យ័តជាគំរូ ។
ដល់ចាស់ពេញវ័យស្តីពិរោះ　　　ស្រឡាញ់ស្មគ្រ័ស្មោះថែធ្នូនគ្រូ
អប់រំកូនចៅដោយគុណធម៌　　　មិនជោរប្លូកជួរឆ្នើងកន្ទ្រើង ។
ធ្វើខ្លួនជាទីហៅស្រឡាញ់　　　ញាតិផងត្របាញ់ស្កាត់រកយើង
ផ្តល់គំនិតខ្ពស់រស់ថ្កុំថ្កើង　　　ថែធ្នូនស្រុកយើងរស់សប្បាយ ។
នោះដល់យើងស្លាប់បិទភ្នែកជិត　　　ត្បិតព្រោះជីវិតសុក្រិតក្រៃ
សាងនូវក្តីល្អសព្វវិស័យ　　　គំរូប្រពៃនៃកូនចៅ...

CHANBOKEO.COM

# ទុក្ខព្រាត់...

ទុក្ខអ្វីមិនស្មើនឹងទុក្ខព្រាត់ គ្រួសារខ្ចាយខ្ចាត់លែងឃើញមុខ
ដូចប្រទេសជាតិត្រូវរងទុក្ខ ពលរដ្ឋប្រាសស្រុកលែងវិលវិញ ។
ពីដើមព្រាត់ញាតិឃ្លាតគង់វិល យូរឆ្នាំមមិលអស់ទោម្ទេញ
ស្រុកប្រែសាន្តត្រាណក្សាន្តពោរពេញ គ្រួយើងវិលវិញជួបជាថ្មី ។
ថ្ងៃដន្យយើងផ្លាស់ប្តូរមារយាទ តាំងពីបែកឃ្លាតផងទីទៃ
ត្រងយកទំនៀមសាសន៍ដទៃ ឃ្លាតប្រពៃណីស្តីគិតប្លែក ។
បងប្អូនជួបវិញលែងស្គាល់ស្និទ្ធ រីការប្រព្រឹត្តហាក់អល់ឯក
គិតអ្វីធ្វើអ្វីប្រែចម្លែក ខ្មែរជួបសង្វេគសាជាថ្មី ។
អ្នកឃ្លាតស្រុកទៅប្រឹងរក្សា ទំនៀមខេមរាទាំងសំដី
លុះវិលចូលស្រុកភ្ញាក់ផ្អើលភ័យ ត្បិតញាតិប្រុសស្រីលែងខ្មែរហើយ ។
គេស្លៀកមិនីសក់ទង់ដែង សាក់ស្បែកតុបតែងយ៉ាងឆើតឆាយ
ចំរៀងធុងបាសសើចក្អាកក្អាយ ផឹកស្រាសប្បាយក្រោមអាយុ ។
ឬកពាក្មេងក្អាងចាងសំដី ទាស់ចិត្តធាក់ប្រាយកៅអីតុ
ឡូឡាព្រហើនអស់ពិន្ទុ កាំភ្លើងគ្រាប់ផ្ទុះជាកំណល់ ។
គេឈប់និយាយភាសាខ្មែរ វិលបែរឈោងចាប់អោយរចល់
ភាសាជាតិគេស្តីសោតសល់ ខ្មែរឯងលែងយល់ថែរក្សា ។
ពីដើមព្រាត់ញាតិចិត្តគិតព្រួយ អីលូវជួបហើយនៅសោកា
ញាតិខ្មែរពីមុនបាត់កាយា ឃើញតែខេមរាត្រឹមសំបក ។
ព្រាត់ហើយវប្បធម៌ប្រពៃណី បវររមណីយ៍ដែនគោកធ្លក
វិលវិញឃើញខ្មែរត្រឹមសំបក សម្បត្តិជាតិខកព្រាត់ដដែល...!!!

CHANBOKEO.COM

# វគ្គទីមួយ
# ទូកជីវិត

ក្រុងបាត់ដំបង...

ថ្ងៃ ៣១ ខែមករា ១៩៧៩...

ស្ត្រីមួយរូបចំណាស់សែបប្លយ រូបរាងស្គាំងស្គមទទូរក្រមា ដឹក ដៃកុមារីអាយុជាងបីឆ្នាំ ដើរទៅជិតពួកពលទាហានយាមល្បាត ជាតិវៀតណាម នៅមុំខាងលិចក្បាលស្ពានថ្មថ្មី ក្រុងបាត់ដំបង ដើម្បីសុំអនុញ្ញាតិដើរឆ្លងស្ពានទៅត្រើយខាងកើត ស្រាប់តែពួកទាហានកងល្បាតម្នាក់ និយាយប៉ែឡាំតបទៅគាត់វិញថា ៖

- ឆ្លងមិនបាន...! ចេញទៅ កុំចចេសពេក!

គាត់បានទទូចពីរបីដងហើយ តែកងល្បាតមិនព្រមអនុញ្ញាត្តទេ ថែមទាំងច្រានគាត់អោយថយក្រោយ រហូតដល់គាត់ដួលផ្ងោលលើ អុកគូថលើស្មៅលើឆ្នេរស្ទឹង ។ ដោយក្តីភិតភ័យផង ដោយក្តីអស់ សង្ឃឹមផង ស្ត្រីនោះក៏ងើបឡើង ដឹកដៃចៅដើរថយក្រោយទាំងទឹក ភ្នែករលីងរលោង ។ គាត់គ្មានអ្វីជាប់ខ្លួនទេ មានតែកូនផ្តាំងសមួយ និងបង្វិចខោអាវកញ្ចាស់ពីរបីបន្លាស់ មើលទៅជីវភាពដូចជាទ្រុឌ ទ្រោម ឃើញហើយគួរអណោចអធម្មក្នុងចិត្តពន់ពេកណាស់ ។

មែនហើយ សម័យនោះកងទ័ពវៀតណាមបានចូលមកក្នុងទឹកដីកម្ពុជាហើយបានបង្ក្រាបអង្គការខ្មែរក្រហមចេញពីប្រទេសខ្មែរ ។ ពលរដ្ឋខ្មែរវាល់សែនលាននាក់បានត្រូវស្លាប់យ៉ាងរង្គាលដោយសារ ទារុណកម្មរបស់ខ្មែរក្រហមផង និងដោយសារសង្គ្រាមរវាងកងទ័ព វៀតណាមនិងខ្មែរក្រហមផងដែរ ។ ពេលនេះកងទ័ពវៀតណាម ទើបចូលមកកាន់កាប់ក្រុងបាត់ដំបងពេញសន្ទឹង ។ ក្នុងពេលដែល

CHANBOKEO.COM

ភូមិស្រុករងភាពរីករវចលាចល ពលរដ្ឋទាំងឡាយក៏រត់ត្រងររករស់ តែរៀងៗខ្លួន ដោយគ្មាននរណាគិតនរណាឡើយ ។

ស្ត្រីមួយរូបនោះ ដើរត្រឡប់ទៅជើងតាមដងស្ទឹងសង្កែ រហូត មកដល់វត្តស្លាកែត ទើបសុំទូកគេឆ្លងទៅត្រើយម្ខាង ។ ចៃដន្យ បុរសម្ចាស់ទូកមានទឹកចិត្តល្អ ក៏ជួយចែវចម្លងគាត់និងកុមារីតូច ។ នៅលើទូក មាណពនោះសួរស្ត្រីចំណាស់ថា ៖

- អត់ទោស! មីងជាអ្នកបាត់ដំបងដែរ ? ខ្ញុំហាក់ដូចជាធ្លាប់ស្គាល់ ធ្លាប់ឃើញមុខរបស់មីងពីមុនមក ។

ស្ត្រីចាស់អង្គុយអោបចៅស្រីលើទូក នៅស្ងៀមស្ងាត់យូរហើយ កាលបើឮម្ចាស់ទូកស្រដីសួរដូច្នោះ ក៏ឆ្លើយថា ៖

- មីងមានកំណើតនៅព្រះនេត្រព្រះ តែធ្លាប់មករស់នៅបាត់ដំបង នេះមែន កាលពីមុនឆ្នាំ១៩៧៥ ។
- អញ្ចឹង មីងធ្លាប់ធ្វើការនៅវិទ្យាល័យនេតយ៉ង់ទេ ? ខ្ញុំដូចជាធ្លាប់ ឃើញមីងនៅធ្វើការទីនោះ ជាគ្រូបង្រៀន ។

ពេលនោះ ស្ត្រីចាស់មិនហ៊ានមាត់តទៅទៀតទេ ត្បិតមិនទុកចិត្តថានរៈម្ចាស់ទូកមានបំណងយ៉ាងណា ។ ម្យ៉ាងទៀត ជិតបួនឆ្នាំ កន្លងមក របបផ្តាច់ការរបស់ខ្មែរក្រហមបានធ្វើឃាតពលរដ្ឋខ្មែរ យ៉ាងរង្គាល អោយតែគេដឹងប្រវត្តិចាស់ថាជាបញ្ញវ័ន្ត ជាអ្នក មានបុណ្យសក្តិ មានទ្រព្យ ឬ មានការងារជាបុគ្គលិករបស់អតិតរដ្ឋា ភិបាលជាដើម ។ ស្ត្រីចំណាស់បែរជាសួរតបទៅវិញថា ៖

- ហើយចុះក្មួយធ្លាប់ជាសិស្សនៅទីនោះ មែនទេ ?
- បាទ! (មាណពម្ចាស់ទូកឆ្លើយយ៉ាងត្រង់) កាលនោះ ខ្ញុំទើបតែ ជាប់ឌីប្លូម ស្រុកទេសក៏ប្រែប្រួលទៅ ។ ខ្ញុំបានត្រូវពួកអាខ្មៅវា ចងវាយយកទៅសម្លាប់រិះអស់ជីវិត តែបានវាយតដៃរត់រួចខ្លួនមក វិញ ។ សំណាងល្អហើយដែល ពេលនេះពួកវារត់ចោលស្រុកអស់ កុំអីវាតាមរកខ្ញុំសម្លេះមិនសល់ឆ្អឹងទេ ។

បើគន់មើលទៅនរៈនោះយូរទៅ គេមានវ័យមិនលើសពី២០ ឆ្នាំឡើយ ។ ពេលនោះ ទូកក៏មកដល់ច្រាំងល្មម ។ ស្រីចាស់ក៏ស្រដី ទៅកាន់នរៈយើងថា ៖

- មីងអរគុណណាស់ចំពោះសន្តានចិត្តដ៏ល្អរបស់ក្មួយ ។ សូមអោយ ក្មួយបានសុខសប្បាយរហូតទៅ ។

CHANBOKEO.COM

- បា៎ទ! មីងក៏ដូចគ្នាដែរ ។ សូមអោយមីងនិងចៅបានជួបតែសុខ សប្បាយរហូត ។
- អរគុណណាស់ក្មួយ! អូហ៍ នែ៎ក! ហើយចុះក្មួយឈ្មោះអីដែរ ?
- បាទ! ឈ្មោះ សល់!
- ហើយចុះក្មួយមានសាច់ញាតិដែរទេ ?
- បាទគ្មានទេ គឺរស់នៅតែម្នាក់ឯងនៅលើទូកនេះ មិនមានញាតិ សន្តានអីទេមីងអើយ... ព្រោះវង្វេងគ្នាបាត់យូរហើយ មិនដឹងថា នរណាស្លាប់ នរណារស់ ខ្លះទេ ។ រីឯផ្ទះសម្បែងវិញក៏គ្មានដែរ ។

ស្ត្រីចាស់សម្លឹងមុខនរៈដោយក្តីអាណិតអាសូរ បន្តិចមកក៏មាន ប្រសាសន៍បន្តទាំងទឹកភ្នែករលីងរលោង ៖

- មីងក៏វង្វេងសាច់ញាតិអស់ដូចគ្នាដែរ...យើងមិនខុសគ្នាទេ ប៉ុន្តែមីងសូមជូនពរ អោយក្មួយឆាប់បានជួបក្រុមគ្រួសារសាច់ញាតិវិញ ឆាប់ៗនេះ កុំបីខាន ។
- បាទ អរគុណមីងណាស់! ហើយចុះមីងឈ្មោះអ្វីដែរទៅ ?
- មីងឈ្មោះណៃ ឯចៅស្រីតូចនេះ ឈ្មោះអាមុំ ។
- ចុះផ្ទះមីងវិញនោះ ?
- មីងក៏អត់ផ្ទះដូចក្មួយអញ្ចឹងដែរ...កំពុងតាមរកក្រុមគ្រួសារមីង...
- អញ្ចឹង មីងអញ្ជើញទៅរកនៅខាងណាដែរ ?
- មីងធ្លាប់មានមិត្តភក្តិរស់នៅជិតវត្តបាឡាត់ គិតថាទៅរកគេក្រែង មានពំនាក់សិន បើមិនដូច្នេះទេ... មីងច្បាស់ជារសាត់តាមតែ ដំណើរហើយ ។

ថាហើយ មីងណៃក៏លើកចៅព ចុះពីទូកដើរឡើងដីគោកចេញ ទៅ ទុកអោយនាយសល់សម្លឹងមើលតាមពីក្រោយដោយដួងចិត្ត ញាប់ញ័រ គិតក្តុកក្តួលនៅក្នុងចិត្តថា ៖

- គួរអោយអាណិតណាស់... មិនដឹងជាមានខ្មែរប៉ុន្មានលាននាក់ទេ ដែលត្រូវរងទុក្ខដោយការព្រាត់ប្រាសសាច់ញាត់សន្តាន និងការបាត់ បង់ផ្ទះសម្បែង ក្រោមរបបផ្តាច់ការខ្មែរក្រហម... ចំណែកឯខ្ញុំវិញ តើថ្ងៃណា ខ្ញុំមានវាសនាបានជួបក្រុមគ្រួសាររបស់ខ្ញុំវិញដែរ ?

បន្តិចមក គេក៏ដើបទាញច្រវាចែវមួយៗចេញទៅ...

ចំណែកមីងណៃវិញក៏នឹកមានអំណរក្នុងចិត្តហើយគិតថា ៖

CHANBOKEO.COM

- ថ្ងៃបើរបបខ្មែរក្រហម ខំប្រឹងបំផ្លាញខ្មែរទាំងជីវិតពលរដ្ឋ ទាំង វប្បធម៌ អក្សរសាស្ត្រ សង្គមធម៌ គុណធម៌ សីលធម៌ និងសេចក្ដី ស្រឡាញ់រវាងគ្នានឹងគ្នាយ៉ាងណាក៏ដោយ ក៏ខ្មែរនៅតែមានកម្លាំង ចិត្តខ្លាំងក្លារក្សាព្រលឹងរបស់ខ្លួនអោយនៅរស់ជានិច្ច ជាពិសេសគឺ ការមានទឹកចិត្តនិងការសម្ដែងនូវសន្ដានចិត្តល្អចំពោះញាតិ ។ មើលទៅ យុវជននេះចុះ គេមិនដែលស្គាល់យើងទេ តែគេក៏នៅមាន ទឹកចិត្តចំពោះយើងនឹងចៅស្រី... ហោចណាស់ ជាតិជាខ្មែរសាមញ្ញ ដូចគ្នា ទុកណាក៏គេនៅបង្ហាញសន្ដានចិត្តចំពោះខ្មែរដូចគ្នាដែរ ខុស អីតែខ្មែរក្រហមមួយ... តើបេះដូងរបស់គេធ្វើពីអ្វីបានជាគេសាហាវ យោរយៅម្ល៉េះ សម្លាប់មនុស្ស ធ្វើបាបមនុស្សស្លូតត្រង់ដោយឥត មេត្តាយ៉ាងនេះ ? ឬក៏គេជាមនុស្សដែលទទួលរងវិបត្តិធ្ងន់ធ្ងរក្នុង ជីវិតពេកទេដឹង បានជាគេក្លាយជាជនសាហាវឧក្រិដ្ឋបែបហ្នឹង ?

មីងណៃក៏ដឹកដៃចៅស្រីដើរមកដល់មុំវត្តបាឡាត់ សួររកមិត្តភក្តិ ដែលធ្លាប់ស្គាល់គ្នា ស្រាប់តែមានគេប្រាប់ថា ក្រុមគ្រួសារនោះត្រូវ អង្គការខ្មែរក្រហមប្រមូលយកទាំងពូជតាំងពីឆ្នាំ១៩៧៥ម្ល៉េះ ។ មីងយើងក៏រសេះរសោះដៃជើងមួយរំពេច កាលបើបានឮដូច្នោះ ។ លុះនៅវេរាមួយស្របក់មិនដឹងទៅណា មីងក៏សំរេចចិត្តដើរចូលទៅក្នុង វត្តបាឡាត់ដើម្បីរកសុំទីសំណាក់ ។ ចៃដន្យ នៅទីនោះមិនទាន់មាន ព្រះសង្ឃគ្រងផ្នួសទេ មានតែអ្នកដំណើរជាច្រើននាក់រត់ចូលទីនោះ រកដំបូលជ្រកដែរ ។ ដោយមីងណៃមកដល់ក្រោយគេ រកកន្លែង ជ្រកមិនបាន គាត់ក៏នាំចៅចូលជ្រក នៅសំយាបកុដិចាស់មួយ ហើយក៏ដើររើសធាងដូងអាប់ពីរបីធាង មកបាំងជាដំបូល បណ្ដោះអាសន្នសិន ។ បន្តិចមក គាត់ក៏ដណ្ដាំបបរបញ្ចុកចៅស្រី ។ មីង ណៃធ្វើបណ្ដើរ លួចសម្រក់ទឹកភ្នែកបណ្ដើរ នឹកអាណិតខ្លួនដែលត្រូវ មករងកំសត់វេទនាយ៉ាងត្រមង់ត្រមោចពីរនាក់នឹងចៅស្រី ។

កំពុងតែនាំចៅបរិភោគ ស្រាប់តែមានភ្លៀងមកយ៉ាងខ្លាំង ជាភ្លៀងកក់ផ្កាស្វាយយ៉ាងធំមួយ ។ រន្ទះផ្ទៃងឆ្វាត់ហោះកាត់ស្បៃមេឃ បង្កបានជាផ្គរលាន់យ៉ាងគ្រាំគ្រេងគ្រួរន្ធត់ ហាក់ដូចជាកំពុងសម្លុត អារម្មណ៍មីងណៃនិងចៅអោយរិតតែតក់ស្លុតឡើង ។

- យាយ ! (នាងតូចស្រវាអោបកជីដូនដោយក្ដីភ័យខ្លាច)

CHANBOKEO.COM

មីងណៃស្រវាអោយចៅស្រីផ្ទាប់នឹងដើមទ្រូង :

- កុំភ័យអីចៅ! បន្តិចទៀត ភ្លៀងរាំងហើយ...

គ្រាប់ភ្លៀងសាចគ្រាប់ព្រោងព្រាត តាមចន្លោះស្លឹកដូងមកលើ មីងណៃនិងចៅស្រី ហាក់ដូចជាគ្មាននឹកប្រណី ដល់ជនដែលគ្មាន ជំរកទាំងពីរនាក់នេះបន្តិចណាឡើយ ។ មីងណៃបែរខ្លួន យកខ្នង របស់គាត់ទទួលសំណាចគ្រាប់ភ្លៀង ហើយដាក់ចៅផ្ទែកជញ្ជាំងកុដិ កុំអោយនាងទទឹករងា ។ នេះហើយចិត្តជីដូន... ស៊ូលំបាកខ្លួនដើម្បី ថ្នមរក្សាចៅអោយផុតក្តៅរងា ។ ប៉ុន្តែ... ពេលចៅធំឡើង តើគេ នឹងនឹកឃើញភាពកម្សត់កម្រ និងការតស៊ូពលីរបស់ជីដូនចំពោះរូប គេដែរឬទេ ?

រំពេចនោះ បុរសម្នាក់ក្នុងវ័យប្រមាណប្រហែល៤០ឆ្នាំ បានដើរ មកជិតមីងណៃហើយស្រដីថា ៖

- បងស្រី! ចូលមកខាងក្នុងវិញមក កុំអោយទទឹកភ្លៀង ។ នុ៎ះ! នៅជ្រុងកុដិខាងក្នុងមានសល់កន្លែងអង្គុយខ្លះដែរ បងនាំនាងតូច ចូលជ្រកសិនទៅ ។

មីងណៃងើបមើលមុខបុរសនោះ ដោយសេចក្តីត្រេកអរក្នុងចិត្ត រួចហើយក៏តបវិញថា ៖

- អរគុណណាស់ ចំពោះទឹកចិត្តដ៏ល្អនេះ ។

មីងណៃញញឹមហើយក៏លើកចៅពសំដៅរកទីអង្គុយ ។ ការពិត មនុស្សអង្គុយប្រជ្រៀតគ្នាពេញកុដិ មិនដឹងជាគេមានដំណើរពីណា ទៅណាទេ ទើបមកដល់ទីនោះដែរ ។ នៅកន្លែងដែលមីងណៃចូល អង្គុយនោះ គឺគ្រាន់តែប្រឡោះតូចក្រាលដោយបាវកញ្ជាស់មួយតែ ប៉ុណ្ណោះ ។ កាលបើគាត់ដាក់ខ្លួនអង្គុយចុះពីរនាក់ចៅក៏ពេញកន្លែង បាត់ទៅហើយ មិនអាចអោយបុរសនោះត្រឡប់ចូលមកអង្គុយថែម ម្នាក់ទៀតបានទេ វៀរលែងតែគាត់លើកចៅអោយអង្គុយលើភ្លៅ របស់គាត់ ។ ភ្លាមនោះ មីងណៃហាក់ដូចជាមានការទើសទាល់ក្នុង ចិត្តដែលគាត់មិនដឹងថាត្រូវធ្វើយ៉ាងណាអោយសមរម្យ នឹងអោយ បុរសនោះចូលមកអង្គុយជិតនិត្យសាច់ក៏មិនកើត នឹងអោយគេឈរ ហាលភ្លៀងឯខាងក្រៅក៏មិនសម ។ លុះឃើញមីងណៃអង្គុយទំនង អេះអុញហាក់មិនស្រួលក្នុងចិត្ត បុរសនោះក៏ពេលប្រាប់មីងណៃថា៖

- មិនអីទេ បងស្រី! ខ្ញុំឈរនៅខាងក្រៅនេះមួយស្របក់ចុះ បន្តិចទៀត ភ្លៀងរាំងហើយ ។

CHANBOKEO.COM

ប្រុសញញឹមដាក់មីងណៃដោយទឹកមុខទន់ភ្លន់ ហើយក៏បែរទៅ
ឈរផ្ទៃកជញ្ជាំងបែរមើលមេឃវិញតែម្នាក់ឯងស្ងៀមស្ងាត់ ។ មីង
ណៃសម្លឹងទៅប្រុសដោយដួងចិត្តញាប់ញ័រ នឹកទៅដល់ប្ដីរបស់គាត់ ដែលពេលនេះ
មិនដឹងថាស្លាប់ឬរស់ ឬក៏យ៉ាងណា... កូនរបស់ គាត់ក៏បែកពីគាត់ទៅគ្រប់គ្នា
ហើយក៏មិនដែលបានទទួលដំណឹងថា គេទាំងនោះសុខទុក្ខយ៉ាងណាដែរទេ ។

មើលទៅប្រុសម្នាក់នោះ ក៏ហាក់ដូចជាមានទុក្ខកង្វល់ ក្នុងជីវិត
មិនខុសពីមីងណៃយើងប៉ុន្មានដែរ ។ ថ្វីបើគេខំញញឹម បង្ហាញ សន្តានចិត្តចំពោះមីងណៃ
ប៉ុន្តែទឹកមុខរបស់គេបានបង្ហាញទុក្ខព្រួយ និងភាពហ្មូហួងយ៉ាងធំធេង ។
ភាពស្គាំងស្គមរបស់គេក៏បង្ហាញផង ដែរ នូវសេចក្ដីរងទុក្ខវេទនាកន្លងមក
ក្នុងរបបកុម្មុយនិស្តផ្ដាច់ការ របស់ខ្មែរក្រហម ។ ប៉ុន្តែ គួឲ្យកោតសរសើរទឹកចិត្តគេណាស់ ។
ថ្វីបើគេមិនដែលស្គាល់មីងណៃនិងចៅក៏ដោយ ក៏គេមានសន្តានចិត្ត
លះបង់កន្លែងខ្លួនអោយមីងណៃនិងចៅជ្រកភ្លៀងដែរ ។ ចំណែក
ខ្លួនគេបែរជាទៅឈរទទួលសំណាចភ្លៀងឯខាងក្រៅ ជាជំនួសទៅ វិញ ។
មីងណៃសម្លឹងប្រុសមិនដាក់ភ្នែកទេ ក្នុងចិត្តនឹកទៅដល់ ស្វាមី
ដែលធ្លាប់ផ្ដល់នូវសេចក្ដីកក់ក្ដៅយ៉ាងធំធេងដល់គាត់... នឹក
ទៅដល់កូនប្រុសកូនស្រីដែលកំពុងពេញវ័យសិក្សា ស្រាប់តែត្រូវ
អង្គការជន្លៀសយកធ្វើកងចល័ត បែកពីក្រុមគ្រួសារទាំងឈឺចាប់ ។
មីងណៃឈ្ងោកសម្លឹងនាងតូចមុំដែល កំពុងសម្ងំគេងក្នុងដៃជីដូន ស្វែងរកភាពសុខសាន្ត
ក៏នឹកទៅដល់ម្ដាយឪពុករបស់នាងតូចដែល ព្រាត់ទៅ... ពេលនេះ
ក៏មិនដឹងថាស្លាប់ឬរស់យ៉ាងណា... ហ៊ឺ!
ហេតុអ្វីក៏ជីវិតដាក់ទណ្ឌកម្មមីងណៃនិងចៅស្រីដល់ថ្នាក់នេះផង ?

ច្រើនម៉ោងកន្លងទៅ...

ភ្លៀងបង្អន់អនុភាពហើយ ។ អ្នកដំណើរក៏ចាប់ផ្ដើមដើរចេញ ពីកុដិ
បន្តដំណើរទៅមុខទៀត ។ មីងណៃក៏ងើបឡើង ចាប់បាវបត់
ហើយហុចទៅអោយម្ចាស់របស់គេវិញ ព្រមទាំងស្រដីថា ៖

- បងអរគុណប្អូនប្រុសណាស់ ដែលផ្ដល់កន្លែងអោយបងនិងចៅ ចូលជ្រក ។
បងពិតជាមិនភ្លេចនូវទឹកចិត្តដ៏ល្អនេះទេ ។ ថ្ងៃក្រោយ មានវាសនា យើងជួបគ្នាទៀតណា៎!

CHANBOKEO.COM

- ហើយចុះបងស្រីមានបំណងទៅណាដែរ ?

- បងចង់រកផ្លូវទៅផ្ទះចាស់របស់បង នៅជិតវត្តពោធិក្នុង ក្រែង លោកឯទ័ពវៀតណាមគេអនុញ្ញាត្តិអោយចូលទៅរស់នៅវិញបាន ។

- អូហ៍ ផ្ទះរបស់ខ្ញុំនៅជិតវត្តកណ្តាល មិនឆ្ងាយពីគ្នាប៉ុន្មានទេ ។ បើដូច្នេះ យើងរួមដំណើរគ្នាបានព្រោះនៅបណ្តោយផ្លូវជាមួយគ្នា ។

មីងណៃឮហើយញញឹម ត្បិតមានគ្នាដើរទៅជាមួយ ហាក់ដូចជា មិនកណ្តោចកណ្តែងពេក ។ មើលទៅបុរសនោះក៏ហាក់ដូចជាមាន ទឹកចិត្ត មានសំដីស្រួលយល់ស្រួលស្តាប់ អាចរាប់ជាញាតិបាន ។ មីងក៏ដឹកដៃចៅដើរពីក្រោយបុរសធ្វើដំណើរចេញទៅ ។

មិនយូរប៉ុន្មាន អ្នកទាំងបីក៏បានមកដល់ផ្ទះថ្ម ចុងស្ពានថ្មថ្មី ត្រើយខាងកើតស្ទឹងសង្កែ ។ ថៃដន្យ កងទ័ពវៀតណាមដាក់ដង រនាំងឃាត់មិនឲ្យអ្នកស្រុកធ្វើដំណើរ ឆ្លងផ្លូវទៅខាងត្បូងស្ពានទេ ហើយក៏ហាមមិនឲ្យឆ្លងស្ពានទៀតផង ទោះបីជាអ្នកស្រុកទទូចសុំ ទៅមើលតែសំបកផ្ទះរបស់ខ្លួនគេក៏មិនអោយដែរ ។ លុះឈរចាំយូរ ទៅ នៅតែមិនបានទទួលសេចក្តីអនុញ្ញាតដដែល មីងណៃក៏ដឹកដៃ ចៅបែរក្រោយ ថែមទាំងស្រដីទៅបុរសនោះថា ៖

- ពេលនេះ ព្រលប់ហើយ ។ បងគិតសុំលាត្រឡប់ក្រោយរក កន្លែងជ្រកសិន ខ្លាចយប់នេះភ្លៀងធ្លាក់ទៀត ។

- អញ្ចឹង បងស្រីគិតទៅណាវិញ ?

- គិតទៅជ្រកនៅកុដិចាស់ឯវត្តបាឡាត់នោះបណ្តោះអាសន្នសិន ។ ចាំស្អែក ចាំគិតទៀត ។

ថាហើយ មីងណៃក៏ដឹកដៃចៅស្រីដើរត្រលប់ក្រោយ ទុកអោយ បុរសឈរមើលគាត់ពីក្រោយដោយមិនអស់ចិត្ត ។

យប់នោះ មីងណៃនសំរាន្តផ្ទាល់លើកំរាលឥដ្ឋចាស់ សុទ្ធតែដី ព្រោះគាត់គ្មានអ្វីក្រាលសំរាន្តទេ ក្រៅពីក្រមាកញ្ចាស់ដែលក្រាលឲ្យ នាងមុំគេង ។ នៅទីនោះ មានមនុស្សបីបួននាក់ទៀតជាអ្នកដំណើរ មកចូលស្នាក់ដែរ ប៉ុន្តែម្នាក់ៗសុទ្ធតែទើបដើបពីទុរ្ភិក្សអត់អាហារ និងធ្វើការហួសកម្លាំង មើលទៅស្គាំងស្គមហើយស្លេកស្លាំងគួរឲ្យ អាណិត ម្ល៉ោះហើយ គ្មាននរណាគួរសមនរណា ស្រដីរកនរណាទេ

CHANBOKEO.COM

ក្រៅតែពីសម្ងំគេងយកកម្លាំងតែរៀងៗខ្លួន ។

ភ្លឺឡើងថ្ងៃរះស្វាង មីងណៃដើបឡើងនាំបបរបញ្ចុកចៅស្រី ។ លុះដាក់ភ្នែកទៅជ្រុងកុដិម្ខាង ស្រាប់តែគាត់ប្រទះឃើញបុរស ដែលគាត់ជួបកាលពីម្សិលមិញនោះ កំពុងនិទ្រាយ៉ាងស្ងៀមស្ងាត់ ។ គាត់ក៏បែរមកបញ្ចុកចៅវិញតាមធម្មតា ។ បន្តិចមក បុរសក៏ភ្ញាក់ដឹងខ្លួនឡើង ដើបបើកភ្នែក ក៏ប្រទះនឹងមីងណៃនឹងចៅ ។ គេក៏ញញឹមឡើងហើយស្រដីមករកគាត់ថា ៖

- យើងជួបគ្នាទៀតហើយ បងស្រី!

មីងណៃញញឹមហើយដួសបបរមួយចានហុចអោយបុរស ៖

- នែ៎ះ! បរិភោគបបរសម្រន់ពោះសិនទៅ នឹងអាលចេញរកផ្លូវ ទៅរកផ្ទះយើងបន្តទៀត ។

បុរសនោះមិនប្រកែកទេ ។ គេទទួលយកចានបបរពីមីងណៃ ដោយអំណររួចហើយក៏សួរគាត់វិញថា ៖

- ហើយចុះបងស្រីមានគំរោងការណ៍យ៉ាងណាទៀតថ្ងៃនេះ ?

- មិនដឹងទេ ប្អូនអើយ! បងដូចជាងងឹតងងល់អស់ហើយ ។ ផ្ទះ ក៏ទៅមិនបាន ប្ដីនិងកូនក៏បាត់ខ្លួនអស់ នៅសល់តែចៅស្រីមួយនេះ មិនដឹងថាបងត្រូវដោះស្រាយជីវិតយ៉ាងណាឡើយ...

មីងណៃស្រដីទាំងរលីងរលោងទឹកភ្នែកអួលដើមក ធ្វើអោយបុរសមួយរូបនោះរលីងរលោងទឹកភ្នែកដូចគ្នា ៖

- រឿងខ្ញុំមិនខុសពីបងស្រីទេ ។ ប្រពន្ធនិងកូនបែកទៅនៅឆ្នាំ៧៥ មិនដឹងជាស្លាប់រស់យ៉ាងណា... ហើយក៏មិនដឹងតាមរកគេនៅឯណា ផងទើបឃើញ មានតែត្រឡប់ទៅលំនៅចាស់វិញប៉ុណ្ណោះក្រែង លោគេត្រឡប់មករកខ្ញុំនៅទីនោះដូចគ្នាដែរ នោះយើងនឹងបានជួប គ្នាវិញ ។ ថៃដន្យទាហានវៀតណាមដាក់បំរាម មិនអោយយើងចូលទៅទីសោះ ។ ឥឡូវនេះ ខ្ញុំក៏ទាល់ច្រកដូចបងអញ្ចឹងដែរ...

បន្តិចមក មីងណៃក៏នឹកឃើញមធ្យោបាយមួយ ៖

- មែនហើយ បងបានជួបយុវជនម្នាក់កាលពីម្សិល ។ គេរស់នៅ លើទូក មិនមានផ្ទះសម្បែងបងប្អូនទេ តែរកស៊ីចម្លងទូកនៅវត្ត ស្លាកែតនិងវត្តនរា ។ បើសិនជាយើងចូលហ៊ុនកម្លាំងដៃគ្នារកត្រីដូរ

CHANBOKEO.COM

អង្ករឬរបស់ប្រើប្រាស់ប្រហែលជាយើងអាចដោះស្រាយជីវភាពខ្វះ ខាតរបស់យើងបានខ្លះ ហើយឆ្លៀតឱកាសនេះ តាមរកសាច់ញាតិ របស់យើងផង ។

ដោយយល់ថាមីងណៃមានយោបល់ល្អ បុរសនោះក៏ដើរទៅជាមួយមីងមកដល់មាត់កំពង់ភូមិនរា ។ អ្នកទាំងពីរបានជួបយុវជនដដែលនោះកំពុងចម្លងទូកជាថ្នូរអង្ករកំប៉ុង ។

- យើងជួបគ្នាទៀតហើយមីង! (នាយសល់ស្រដីទាំងញញឹម)
- អោយមីងសុំពឹងពាក់បន្តិចបានទេ ក្មួយ ? (មីងណៃសួរ)
- អូហ៍ ? រឿងអ្វីទៅបាទ ?
- គឺ ប្អូនប្រុសខាងនេះក៏ជាមនុស្សដាច់សង្វែងដូចមីងនឹងក្មួយដែរ បើសិនយើងចូលកម្លាំងគ្នារកស៊ី ប្រហែលជាអាចដោះស្រាយជីវិតរបស់យើងបានគ្រាន់បើជាងនេះ ។

បុរសនោះក៏ណែនាំខ្លួនឡើងថា ៖

- ពូឈ្មោះសំបូរ ហៅខ្លីៗថា ពូបូរ (បុរសឆ្លើយតបវិញ)
- ឯខ្ញុំឈ្មោះកោសល្យ ហៅនាយសល់ ហើយចុះពូបូរវិញនោះ មានយោបល់យ៉ាងណាដែរបាទ ?

ស្រាប់តែមីងណៃមានប្រសាសន៍កាត់មុនពូបូរថា ៖

- ស្ទឹងសង្កែនោះជាប្រភពត្រីស្រាប់ទៅហើយ ចំខែនេះជាខែ ទឹកស្រកទៀត ពិតជាសំបូរត្រីណាស់ ។ បើសិនជាយើងរកឫស្សី ត្បាញធ្វើឈ្នាងធំដាក់សម្រាស់មែកឈើអូសឈ្នាងមួយថ្ងៃពីរដង ប្រហែលជាអាចបានត្រី យកមកបរិភោគផង ហើយយើងអាចយកទៅដូរតវាន់ផ្សេងៗសំរាប់ប្រើប្រាស់ផង ។

ទាំងពូបូរ ទាំងនាយសល់ សុទ្ធតែមានការភ្ញាក់ផ្អើលចំពោះមីងណៃដែលមានគំនិតគិតឃើញមធ្យោបាយល្អ ។ បើគន់មើលទៅមីង ពីក្រៅគាត់មានវ័យចំណាស់ប្រហែល៤៥ឆ្នាំហើយ ស្គាំងស្គម កោរ សក់ ទទូរក្រមា មុខមាត់ប្រកបដោយភាពទុរគត និងសេចក្តីទុក្ខ សោក តែមិនគួរណាគាត់មានប្រាជ្ញាឈ្លាសវៃ គិតឃើញមធ្យោបាយ មុនបុរសទាំងពីរ ដែលមានវ័យក្មេងជាងមានកម្លាំងជាងនោះទេ ។ ពូបូរក៏ញញឹមឡើង ៖

- មែនហើយ! ចំពោះក្មួយសល់ដែលមានទូកស្រាប់នោះ យើងអាចដឹកត្រីដូរអង្ករឬអ្វីៗតាមភូមិតាមដងស្ទឹងនោះបានងាយផង ។

CHANBOKEO.COM

មិនយូរប៉ុន្មាន អ្នកទាំងបីក៏ស្រុះស្រួលគ្នា ឡើងទៅរកកាប់ ឬស្សីធ្វើឈ្នាង ។ ថៃដន្យ
គេគ្មានអ្វីទៅដោះដូរជាថ្នូរឬស្សីរបស់ អ្នកស្រុកសោះ ម្ល៉ោះហើយ
មីងណៃក៏សុំដាក់កិច្ចសន្យាជាមួយអ្នក ភូមិ ដូរឬស្សីជាមួយនឹងត្រីស្រស់ មានន័យថា
នៅពេលដែលគេ អូសឈ្នាងស្ទឹងបានត្រីកាលណា គេត្រូវបែងចែកមួយគីឡូឲ្យម្ចាស់ ឬស្សី
ក្នុងចំនួនពេលមួយខែ ។

បន្ទាប់មក អ្នកទាំងបីក៏ចាប់ផ្ដើមធ្វើឈ្នាង ត្រាំទឹកស្ទឹង អូស
ឡើងរាល់ព្រលឹមនិងរាល់រសៀល មួយថ្ងៃពីរដង យកត្រីធ្វើអាហារ
ផង សងគេផង ហើយរែកលក់ដូរអង្ករនិងរបស់ប្រើប្រាស់ផង ។

នៅសម័យឆ្នាំ១៩៧៩នោះ ស្រុកខ្មែរមិនទាន់ចាយលុយនៅ ឡើយទេ ។
របស់អ្វីៗត្រូវជួញដូរជាចំនួនអង្ករ ជាស្រូវ ជាមាស ឬប្រាក់សុទ្ធ
មិនខុសពីជំនាន់បុរាណសម័យលង្វែកឡើយ ។ ដូច្នេះ ហើយ
ទើបគេសង្កេតឃើញអ្នកស្រុកទាំងឡាយ ដោះដូរគ្នាតាម បែបបុរាណសាជាថ្មី
រស់នៅតាមបែបព្រឹទ្ធសម័យគួរអោយសង្វេគ ថ្វីបើប្រទេសជាតិដទៃ
មានការវិវត្តន៍ខាងវិទ្យាសាស្ត្របង្ហោះយាន
អវកាសលើពពកឬទំលើដីព្រះចន្ទ័បានទៅហើយក៏ដោយ ។

អ្នកទាំងបីរស់នៅលើទូកយ៉ាងកំសត់ក៏ពិតមែន តែគេហាក់ដូច
ជាមាននិស្ស័យនឹងគ្នាជាញាតិសន្ដាន រស់នៅសុខដុមរមនាដូចជា
ក្រុមគ្រួសារមួយយ៉ាងកក់ក្ដៅបំផុត ។ រៀងរាល់ថ្ងៃ មីងណៃតែងតែ
បង្ខំអោយនាយសល់ចែវទូកពីនរាទៅបាត់ដំបង រំពឹងរកឱកាសវិល ត្រឡប់ចូលផ្ទះរបស់គាត់វិញ
ក្រែងលោអាចបានជួបឬបានដំណឹង អ្វីពីកូនចៅនិងប្ដីរបស់គាត់ ។ ប៉ុន្តែ
រៀងរាល់ពេលដែលទូកនាយ សល់មកជិតដល់ជិតស្ពានថ្មថ្មីផ្សារក្រោម កងទ័ពវៀតណាមតែងតែ
បាញ់កាំភ្លើងរះគម្រាមឃាត់ដំណើរទូកជានិច្ច ធ្វើអោយមីងខកចិត្ត ខកបំណង
អោយរាល់តែលើក ។

ព្រលប់នេះ ពូបូរត្រលប់មកពីដោះដូរត្រីក៏ជួបនាយសល់ទើប ត្រឡប់មកដល់ដែរ
ស្រាប់តែបាត់មីងណៃ ឃើញតែនាងតូចមុំគេង លក់ម្នាក់ឯងលើកក្ដារទូក ។ ដោយបារម្ភពីមីងណៃ
ពូបូរស្រដីថា ៖
- សល់ ! ញ៉ាំបាយមុនពូទៅ ហើយមើលស្រីមុំផង ។ ពូឡើងទៅ រកបងស្រីនៅខាងលើបន្តិច ។

CHANBOKEO.COM

ថាហើយ ពូបូរឡើងចេញទៅយ៉ាងរហ័សតាមរកមីងណៃ ទាំងដួងចិត្តខ្វាយខ្វល់ ។ គាត់បានដើររកមើល តាមឆ្នេរស្ទឹងម្តុំៗនោះ ក៏ មិនឃើញ ដើរសួរអ្នកស្រុកម្តុំៗនោះ ក៏គ្មាននរណាគេចាប់ភ្លឹកថា មីងបានទៅណាមកណាទេ ។ ពេលនោះ ពូបូរហាក់ដូចជាមាន អារម្មណ៍ធុញថប់ក្នុងចិត្តខុសធម្មតា ត្បិតមិនដឹងថា មីងណៃបាត់ខ្លួនទៅណា ។ លុះដើររកអស់ចិត្តអស់ចង់ហើយ គាត់ក៏ដើរត្រលប់មកទូកវិញទាំងរសេះរសោះដៃជើង ។ ព្រលប់នោះ ពូបូរមិនពិសារ បាយទេ សុខចិត្តនៅអង្គុយចាំផ្លូវមីងណៃទាំងអារម្មណ៍កន្ទុះរា ។

- ពូ! ពិសារបាយសិនទៅ (នាយសល់ស្រដីហៅពូដោយវាចាដ៏ស្រទន់ទំនងដូចជាចង់លោមចិត្តគាត់មិនអោយខ្វាយខ្វល់ពេក) កុំបារម្ភពីមីងណៃរហូតដល់អត់បាយដូច្នេះប្រយត្ន័ឈឺណាពូ!
- តែ..ពូនឹកមិនអស់ចិត្តសោះថា ហេតុអ្វីបងណៃគាត់ដើរចោលចៅស្រីអោយនៅម្នាក់ឯងដោយឥតដំណឹងដូច្នេះ ?
- សល់ក៏មិនយល់ដូចគ្នាដែរពូ... មិនដឹងថាមានរឿងអ្វីទេ ខ្ញុំបារម្ភ ពីគាត់ណាស់ ។ ទោះបីជាយ៉ាងណា សូមអោយតែគាត់ត្រឡប់មក វិញដោយសុខសប្បាយផងចុះ ។

អស់កម្លាំងពេក នាយសល់ក៏លូនចូលទៅប្រាសខ្លួនក្បែរនាង តូចមុំ ហើយក៏សំងំនិន្ទ្រាទៅ ។ ពូបូរក៏ចេញមកក្រៅ ដើរឡើងដី ច្រាំងទៅអង្គុយនៅគល់ដូងមួយដែលដុះទេរទៅស្ទឹង ក្នុងចិត្តរវេង រសាប់រសល់យ៉ាងណាមិនដឹង... រំពេចនោះស្រាប់តែគាត់ប្រទះនឹងស្រមោលមួយដើរតតេះតតះលើឆ្នេរស្ទឹងត្រឡប់មករកទូកវិញ ៖

- បងណៃ!

ពូបូរស្រែកហៅហើយក៏ស្ទុះរត់ទៅទទួល ។ មែនហើយ!នោះ គឺជាមីងណៃពិតមែន តែមើលទៅអាការៈរបស់គាត់ហាក់ដូចជាទ្រុឌ ទ្រោមដល់ក៏រិតហើយ ។

- បងស្រីមានរឿងអ្វីហ្នឹង ? ហេតុអ្វីក៏បងទុរន់ទុរាយ៉ាងនេះ ?

ពូបូរគ្រាហ៍មីងណៃចូលទៅក្នុងឃ្លប់ទូកយ៉ាងលឿន ។ មីងដាក់ខ្លួនផ្អែកនឹងជញ្ជាំងទូកដោយអាការៈល្ហិតល្ហៃ ។ រីឯរង្វង់មុខរបស់គាត់វិញក៏ដក់ដោយទឹកភ្នែកយ៉ាងជិតដាម ។ ពេលនោះ ពូបូរបានឃើញជើងទាំងគូរបស់មីងណៃមានហូរឈាមតាមចង្វេកម្រាមយ៉ាង ក្រហមទែង ទំនងដូចជាបានរត់កាត់បន្លាឬថ្មគ្រួសរបួសជើងយ៉ាង ដំណំ ។ ពូបូរក៏ស្ទុះទៅបោចស្លឹកអំពិល

CHANBOKEO.COM

ដាក់ស្ទោរលាយអំបិល យកមកលាងរបួសអោយមីងយ៉ាងរហ័ស តែពូក៏មិនហ៊ានសួរមីង ណៃដែរ កាលបើឃើញមីងដូចជាទុរន់ទុរាពេក ។

ពេលនោះ ថ្វីបើជាតិអំបិលនិងជាតិម្ទេសអំពិលបានធ្វើអោយមុខ
របួសគាត់ឈឺផ្សាយ៉ាងណាក៏ដោយ ក៏មីងយើងមិនខ្វល់នឹងធ្វើដឹង ឡើយ ។
គាត់នៅតែអង្គុយសំកុកវិយោគក្នុងចិត្តស្ងៀមស្ងាត់ ទំនង
ដូចជាកំពុងតែប្រទះនូវវិបត្តិផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរឥតឧបមា ។ រីពូបូរ វិញ ក៏មិនអស់ចិត្ត
ដែលសុខៗ មីងណៃផ្លាស់ប្តូរខ្លួនពីស្ត្រីដ៏មាន សតិស្មារតីរឹងប៉ឹងឈ្លាសវៃរហ័សរហួនម្នាក់
មកជាមនុស្សដែលលង់ ចិត្តវិបត្តិគួរសង្រេងយ៉ាងនេះទៅវិញ ។

ពេលវេលាកន្លងទៅយ៉ាងយឺតបំផុត ។ ពូបូរដាក់ខ្លួនផ្អែកជង ច្រវាទូក
សម្លឹងមីងណៃមិនដាក់ភ្នែក... សំដែងទឹកមុខបារម្ភផង កន្ទះរាផង
ទំនងហាក់ចង់ដឹងអំពីហេតុការណ៍ដែលកើតឡើងចំពោះ មីងណៃថ្ងៃនេះ ។ រំពេចនោះ
នាងតូចមុំក៏ភ្ញាក់ឡើង ស្រែកហៅ ៖

- យាយ !

ឮសំលេងចៅស្រី មីងណៃភ្ញាក់ព្រើតពីអារម្មណ៍រាយមាយ រួច ងាកបែររកចៅភ្លាម ។
បន្ទាប់មក គាត់ក៏ស្ទុះទៅលើកចៅឡើង យកមកអោប ស្រោប់តែគាត់យំសសឹកតែម្តង ។
ឃើញដូច្នោះនាង តូចបើកភ្នែកធ្វើមុខឡឹងឡង់ហាក់ភិតភ័យ ត្បិតនាងមិនយល់ហេតុ ការណ៍ ។
កាលបើឃើញទឹកមុខចៅស្រីទំនងមិនស្រួលក្នុងចិត្ត មីង ណៃក៏ជូតទឹកភ្នែកយ៉ាងរហ័ស
រួចហើយក៏យកដៃបបោសក្បាលចៅ កុំអោយនាងភិតភ័យ ៖

- ឃ្លានបាយទេ ចៅ ? ចាំយាយដួសអោយញុំា ។
- អត់ទេ មុំចង់គេងវិញហើយយាយ (នាងតូចគ្រវីក្បាល)
- អឺ! បើអញ្ចឹង ចៅគេងវិញទៅណ៎!

មីងណៃដាក់នាងមុំអោយគេងទៅវិញ ។ មួយភ្លែតក្រោយមក នាងតូចក៏លង់លក់វិញទៅ ។
ភ្លាមនោះ ពូបូរមានប្រសាសន៍សួរ៖

- បងណៃ ពិសារបាយហើយឬនៅ ?

មីងណៃភ្ញាក់ព្រើត បែរក្រោយសួរត្រឡប់ទៅវិញថា ៖

- បូរមិនទាន់ទទួលទានទេហ៏ ?
- បាទ! នៅទេ... គឺនៅចាំបង បរិភោគជុំគ្នា...

CHANBOKEO.COM

- ពុទ្ធោ! នៅចាំបងធ្វើអ្វី ? ពេលនេះ ប្អូនឡាស់ជាឃ្លានល្មោច ពោះស្លាប់ហើយ ។
សូមទោសដែលបងភ្លេចខ្លួន មិនបានគិតដល់ សុខទុក្ខរបស់ប្អូន ។ ម៉ោះ!
បងទៅដួសបាយសម្លមកអោយ ។
- មិនអីទេបង! ការពិត គួរតែប្អូនទេដែលត្រូវបារម្ភពីបង... មើល បងចុះ
ថ្ងៃនេះមានរឿងអ្វីប្លែកឬបង បានជា... ?
  មីងណៃយកវែកដួសបាយដាក់ចានហើយនិយាយបន្តថា :
- ណេះ! បរិភោគទៅ! កុំគិតពីបងអី... បងមិនអីទេ ។
- ប៉ុន្តែ... បើបងមិនពិសារ ប្អូនក៏មិនទទួលអាហារដែរ ។
  មីងណៃឮដូច្នេះ ក៏ដើបសម្លឹងមុខពូប្អូន រួចឆ្លើយថា ៖
- រឿងរ៉ាវរបស់មនុស្ស ដែលទទួលទារុណកម្មពីរបបខ្មែរក្រហម
វាឈឺចាប់ណាស់ ប្អូនយល់ហើយតើហ៎ ? គឺវាធ្វើអោយយើងឆ្កួត លេបបាយលែងរួចណា៎ប្អូន!
- បាទ យល់ណាស់ ព្រោះខ្ញុំក៏ជាជនរងគ្រោះម្នាក់ដូចបងណៃដែរ! ប៉ុន្តែ ថ្ងៃនេះ
បងណៃមានរឿងអ្វីដែរទៅ ទើបបង... ?
  ឮដូច្នោះ មីងណៃឈ្ងោកមុខធ្វើទឹកភ្នែករលីងរលោង ទំនង
ញាប់ញ័រក្នុងចិត្តចំពោះរឿងរ៉ាវដ៏អាថ៌កំបាំងរបស់គាត់ ។ ទីបំផុត
គាត់ក៏ដាច់ចិត្តទំលាយប្រាប់ត្រួសៗ កុំអោយពូប្អូនបារម្ភ ៖
- ការពិត... កាលពីថ្ងៃមិញនេះ បងបានប្រទះមនុស្សម្នាក់មុំៗឆ្មេរ ស៊ឹងវត្តស្លាកែតនេះ ។
គេមានរូបរាងប្រហាក់ប្រហែលនឹងប្ដីរបស់ បងណាស់... ថែដន្យ ពេលបងរត់តាមទៅរកសួរគាត់
គាត់បែរជា រត់គេចរូបបង មិនព្រមអោយជួបទេ ។ បងក៏រត់តាមគាត់រហូតដល់ ដូនទាវ
ស្រាប់តែវង្វេងបាត់គាត់ទៅ... ទើបបងមិនអស់ចិត្ត...ប៉ុន្តែ បងទាល់ច្រក
មិនដឹងថាត្រូវតាមរកគាត់របៀបណាទៀត ទើបបង ត្រឡប់ក្រោយវិញមកទូកវិញ
ណាមួយៈបារម្ភពីចៅមុំដែលបងបាន ទុកឲ្យនៅគេងក្នុងទូកតែម្នាក់ឯងផង ។
  ពូប្អូនធ្វើទឹកមុខភ្ញាក់ផ្អើល ថែមទាំងឧទានថា ៖
- ហ៊ឺ! បើគាត់ជាប្ដីរបស់បងមែន ហេតុអ្វី បានជាគាត់បែរជារត់ គេចមុខពីបងទៅបាត់អញ្ចឹង ?
ហើយបើគាត់ជាមនុស្សមិនស្គាល់ គ្នាវិញ ហេតុអ្វីក៏កំណាញ់ម្ល៉េះ ត្រឹមតែឆ្លើយថាមិនមែន ?
- ព្រោះតែដូច្នេះហើយ ទើបបងមិនអស់ចិត្ត... រត់តាមរកជួបគាត់ រហូតទៅដល់ភូមិដូនទាវ...
តែក៏វង្វេងគ្នាបាត់ទៅ...

CHANBOKEO.COM

មីងណៃឈ្ងោកមុខយំខ្សឹកខ្សួលសាជាថ្មី ។ ពេលនោះពូបូរក៏ នៅអង្គុយស្ងៀមស្ងាត់
មិនហ៊ានស្រដីសួរអ្វីទៀតដែរ ។ ការពិត ពូ បូរយល់ណាស់ថា
ការបែកព្រាត់ប្រាស់គូស្វាមីភរិយាជាទីស្រឡាញ់ នោះ ធ្វើឲ្យបេះដូងខ្លួនឈឺចាប់ប៉ុនណា
ត្បិតគាត់ក៏ព្រាត់ប្រពន្ធកូន ដូចគ្នា មិនខុសមីងណៃដែលព្រាត់កូននិងប្តីរបស់គាត់ដូច្នោះដែរ ។
- រំសាយចិត្តខ្លះទៅណា៎បង! បើថ្ងៃស្អែកនៅមាន យើងមិនគួរលះ
បង់សេចក្តីសង្ឃឹមរបស់យើងទេ...

មែនហើយ! បើសិននៅតែមានថ្ងៃស្អែក មីងណៃមិនគួរនឹង
លះបង់សេចក្តីសង្ឃឹមរបស់គាត់ទេ ព្រោះគាត់នៅមានឱកាសដើរ
រកបុគ្គលជាទីស្រឡាញ់របស់គាត់ ក្រែងលោបានជួបគ្នាវិញដូចក្តី បំណង ។
ឮប្រយោគនេះកាលណា មីងណៃងើបមុខឡើង យក ដៃជូតទឹកភ្នែកភ្លាមតែម្តង ៖
- អរគុណណាស់ ដែលបូរជួយរំលឹកបង! ប្តីរបស់បងក៏ធ្លាប់ប្រើ
ប្រយោគនេះជាមួយបងដែរ... ហើយបងក៏ធ្លាប់បានសាងក្តីសង្ឃឹម
រង់ចាំថ្ងៃស្អែកដែលមានរស្មីនោះ តាមដែលគាត់ធ្លាប់មានប្រសាសន៍ ប្រាប់បងជាយូរឆ្នាំហើយ
ប៉ុន្តែថ្ងៃស្អែកដែលបងរស់ចាំនេះ មិនចេះ មកដល់ទាល់តែសោះ
រហូតដល់បងអស់កម្លាំងចិត្តនឹងពុះពារ បន្តទៅទៀត...

មីងណៃដកដង្ហើមធំ ធ្វើទឹកមុខស្រងូត ។ ពូបូរឃើញដូច្នោះក៏ មានប្រសាសន៍តបវិញថា ៖
- ជួនកាល ការដែលយើងទន្ទឹងខ្លាំងពេក អាចបណ្តាលអោយ
ពេលវេលានឹងរិតតែបង្អូសយូរទៅៗ ប៉ុន្តែបើយើងរំសាយការ ទន្ទឹងខ្លះ
ប្រហែលជាពេលវេលាដែលយើងរង់ចាំនោះមិនធ្វើអោយ
ចិត្តយើងកន្ទះរាពេកទេ ។ បូរសង្ឃឹមថា ថ្ងៃស្អែកនៅមានជានិច្ច សំរាប់ជីវិតយើងគ្រប់ៗគ្នា...

បូរស្រដីប្រកបដោយជំនឿក្នុងចិត្តយ៉ាងមាំ ។ មើលទៅគេ ពិត
ជាមិនលះបង់សេចក្តីសង្ឃឹមរបស់គេទេ ក្នុងការតាមរកមនុស្សជាទី ស្រឡាញ់ក្នុងជីវិតរបស់គេ ។
ចុះមីងណៃវិញ តើគាត់គិតយ៉ាងណា ដែរទៅ ? ភ្លាមនោះ មីងណៃញញឹមឡើង ៖
- មានប្អូនជាកម្លាំងចិត្តដូច្នេះ រឿងអ្វីដែលបងត្រូវលះបង់សេចក្តី សង្ឃឹមផង ? ពេលនេះ
បងសំរេចចិត្តហើយ ថាបងនឹងប្រឈម មុខចំពោះជីវិតរបស់បងយ៉ាងក្លាហាន
យកជ័យជំនះលើជំងឺចិត្ត វិបត្តិនិងឧបសគ្គដទៃសព្វយ៉ាងអោយខាងតែបាន លុះត្រាតែបង

CHANBOKEO.COM

បានជួបមនុស្សដែលបងស្រឡាញ់នោះជាថ្មីម្តងទៀត ជាពិសេសគឺប្តីនិងកូនប្រុសស្រីទាំងអស់របស់បង ។

ពេលនោះ ពូបូរបានឃើញមីងណៃញញឹមឡើងយ៉ាងស្រស់ បំព្រងជាលើកដំបូងបំផុត ។ តាំងពីគាត់បានស្គាល់មីងណៃថ្ងៃណា មក ពូបូរមិនដែលឃើញគាត់ញញឹមស្រស់អញ្ចឹងទេ ។ ការពិត ពិតមែនតែមីងណៃមានវ័យ៤៥ឆ្នាំទៅហើយ តែមីងនៅមានលាក់គំនួចសោភ័ណធម្មជាតិមួយយ៉ាងត្រកាលក្រៃលែង ។ បើនរណា បាននៅក្បែរមីងណៃមិនលែងអីគេនឹងបានទទួលនូវភាពកក់ក្តៅ ក្នុងចិត្តខ្លះមិនខានឡើយ ត្បិតគាត់ជាមនុស្សមានសទ្ធាមានទឹក ចិត្តល្អ ប្រកបដោយការប្រឹងព្យាយាមជួយខ្លួន ដោយសតិបញ្ញា ស្មារតី និងកម្លាំងតស៊ូមិនរាថយចំពោះជីវិត ។ ថ្វីបើពេលខ្លះ គាត់បាក់កម្លាំងចិត្ត ម្តងមួយយាមក៏ដោយ ក៏គាត់នៅប្រឹងងើបឈរ កែសម្រួលស្ថានការណ៍ ឲ្យធូរស្រាលចិត្តមកវិញយ៉ាងរហ័ស ភ្លាមៗ ដើម្បីជួយជីវិតខ្លួនឯងឲ្យភ្លឺស្វាង ។ ជាពិសេសបំផុតនោះ គាត់មិនព្រមលះបង់សេចក្តីសង្ឃឹមរបស់គាត់ក្នុងការស្វែងរកប្តីនិងកូនរបស់ គាត់ឡើយ ។ រីឯជីវភាពប្រចាំថ្ងៃរបស់ទាំងអស់គ្នាសុទ្ធសឹងតែពឹង ប្រាជ្ញរបស់មីងណៃគ្រប់យ៉ាង ព្រោះគាត់តែងតែមានគំនិតប្លែកៗ ដោះស្រាយជីវភាពរបស់គេឲ្យធូរស្រាលជានិច្ច ។

ពូបូរលួចសម្លឹងមុខមីងណៃភ្លៀកៗ ទំនងហាក់ដូចជាកំពុងតែចាប់អារម្មណ៍នឹងស្នាមញញឹមលើផ្ទៃមុខរបស់មីងណាស់ រហូតដល់ មីងចាប់ភ្លឹកបានថាពូបូរសម្លឹងមុខគាត់ យ៉ាងចម្លែកហួសធម្មតា ។ ភ្លាមនោះ មីងរបស់យើងក៏មានប្រសាសន៍ឡើងថា ៖

- បូរអើយ ! កុំស្រម័យវែងឆ្ងាយអ្វី ! នេះពិភពជីវិតពិតៗណា៎ ! យើងនៅមានភារៈតាមរកសាច់ញាតិក្រុមគ្រួសាររបស់យើង អោយ ឃើញមកវិញ ។ បូរភ្លេចហើយឬអ្វី ? សុំកុំបែកអារម្មណ៍ទៅណា មកណាអោយសោះ ។

មីងណៃនិយាយ ហាក់ដូចជាយល់នូវអត្ថន័យរបស់ក្រសៃភ្នែកពូបូរដែលសម្លឹងមកគាត់នោះដល់ហើយ ។ ឮសំដីមីងណៃដូច្នោះ ពូបូរនឹករអៀសខ្លួនក៏ដាក់ភ្នែកចុះ នៅស្ងៀមមួយស្របក់ ។ បន្តិច មក គាត់ក៏ងើបមុខមកវិញសួរទៅមីងណៃថា ៖

- យើងរស់នៅជាញាតិនឹងគ្នាច្រើនអាទិត្យហើយ បងមិនដែល សាកសួរពីប្រវត្តិរបស់ខ្ញុំសោះ ។ បងមិនចង់ស្គាល់ខ្ញុំទេ ?

មីងណៃអង្គុយផ្អែកនឹងជញ្ជាំងឃ្លប់ទូក ដកដង្ហើមបន្ធូរទ្រូង មួយឃ្មូ ទើបស្រដីតបវិញថា ៖

CHANBOKEO.COM

- សូមទោសដែលខួរក្បាលបងពេញណែនដោយកង្វល់ ទើបមិន បានជាចាប់ភ្លឹកសួរ ។ ពេលនេះ បងទំនេរហើយ ប្អូនចង់និយាយ អ្វី និយាយមក បងរង់ចាំស្តាប់ ។

- ហើយចុះពេលបូរប្រាប់បងហើយ បងនិយាយរឿងបងអោយខ្ញុំ ដឹងវិញទេ ?

- ហ៊ឺ រឿងបងកំសត់ណាស់ បូរ! មិនដឹងថាបងត្រូវនិយាយប្រាប់ ប្អូន ដោយចាប់ផ្តើមពីត្រង់ណាទៅទេ...

- ណ្ហើយចុះ! បើឈឺចាប់ពេក បងមិនបាច់និយាយក៏បានដែរ ប៉ុន្តែ បូរចង់អោយបងស្គាល់បូរច្បាស់ ព្រោះបើយើងរស់នៅជា មួយគ្នាជាសមាជិកគ្រួសារតែមួយ នោះគួរយើងស្គាល់គ្នាអោយបាន ច្បាស់បន្តិច មែនទេបង ?

ការពិត ពូបូរធ្លាប់ធ្វើការនៅស្ថានីយ៍រថភ្លើងបាត់ដំបង មាន ប្រពន្ធនិងកូនប្រុសម្នាក់ តែត្រូវបែកគ្នានៅថ្ងៃខ្មែរក្រហមចូលក្រុង នៅខែមេសា១៩៧៥ ចាប់ដេញអ្នកស្រុកជន្លៀសចេញទៅក្រៅក្រុង ដោយមិនអនុញ្ញាត្តិឲ្យនរណាវិលត្រលប់មកផ្ទះប្រមូលយកសម្បត្តិអ្វី តាមខ្លួនឡើយ សូម្បីតែប្រពន្ធកូន ។ កាលនោះ ប្រពន្ធពូបូរនៅផ្ទះ ជាមួយកូនឯវត្តកណ្តាល ហើយត្រូវគេជន្លៀសចេញទៅខាងណាមិន ដឹង ។ ចំណែកពូបូរវិញនៅកន្លែងធ្វើការ ត្រូវគេបណ្តេញចេញទៅ ទិសខាងលិចតាមគេតាមឯង ធ្លាក់រហូតទៅដល់ម្តុំភ្នំក្រពើ ។ ដោយសារគាត់មានសម្បុរស្រអែមបន្តិច ពូបូរក៏ភូតគេបានថា គាត់គ្រាន់ តែជាកម្មករកំប៉ិកកំប៉ុកម្នាក់ ហើយលាក់ខ្លួនពួនធ្វើការទាំងត្រដាប ត្រដួសរហូតដល់ទ័ពវៀតណាមចូលក្រុងបាត់ដំបងនៅឆ្នាំ១៩៧៩ ។

ពូបូរយើងរៀបរាប់រឿងចាស់របស់គាត់ មួយៗ ដោយទឹកមុខ ស្រពោនក្រៀមក្រំ ។ បន្តិចមក គាត់ក៏ស្រដីបន្ថែមថា ៖

- បើសិនជាកូនប្រុសរបស់ខ្ញុំនៅមានជីវិតនៅឡើយ ឆ្នាំនេះគេមាន វ័យ១៥ឆ្នាំហើយ ។

ឮដូច្នោះ មីងណៃក៏លាន់មាត់ឡើងថា ៖

- គឺដំណាលគ្នានឹងវិសាលកូនពៅរបស់ខ្ញុំដែរ... បើគេមានសំណាង ល្អមិនទទួលគ្រោះថ្នាក់អ្វីទេ ឆ្នាំនេះគេក៏មានអាយុ១៥ឆ្នាំដែរ ។

- ចុះបងមានកូនប៉ុន្មាននាក់ដែរទៅ ? (ពូបូរសួរ)

CHANBOKEO.COM

- ប្អូននាក់ ប្រុសពីរស្រីពីរ ហើយស្រីបងជាម្តាយរបស់ចៅមុំនេះ ឯង ។
ឯបីនាក់ទៀតនៅក្មេងៗមិនទាន់មានគូស្រករទេ កាលពីនៅ ឆ្នាំ១៩៧៥
មុនពេលដែលគេបែកពីបងទៅ ។

- ចុះបងប្រុសវិញនោះ គាត់ធ្វើការអ្វីដែរ បង ?

ពូឆ្លូច្នោះ មីងណៃទំលាក់ទឹកមុខជប់លែងស្រដីតែម្តង ។ លុះ
ឃើញឥរិយាបថរបស់មីងណៃដូច្នោះ ពូបូរជ្រួញចិញ្ចើម ហាក់នឹក ឆ្ងល់ ។ បន្តិចមក
មីងណៃក៏ស្រដីថា :

- បងងងុយហើយ! ចាំស្អែកយើងនិយាយគ្នាទៀតណា៎! បងសុំ សំរាកយកកម្លាំងបន្តិចសិន ។

ថាហើយ មីងណៃក៏លូនចូលទៅជិតចៅស្រីដែលនៅគេងចំ
កណ្តាលទូកក្បែរនាយសល់ ប្រាសខ្លួនបិទភ្នែកចូលដំណេកទៅ ទុក
អោយពូបូរអង្គុយត្របោមជង្គង់ លួចមើលមីងណៃពីកន្សៃទូកមក ភ្លៀកៗមិនអស់ចិត្ត ។
មែនហើយ! ថ្ងៃនេះគាត់មានអារម្មណ៍ប្លែក ណាស់ចំពោះមីងណៃ
ជាដួងចិត្តអាណិតអាសូរជាទីបំផុត ចំពោះស្ត្រី មួយរូបនោះ ។ តើអ្វីទៅហ្ន៎
ដែលចេះតែបណ្តាលអោយចិត្តគាត់ បារម្ភពីមីងណៃដល់ម្លឹង ?

រីឯមីងណៃវិញ ថ្វីបើគាត់ប្រឹងបិទភ្នែកនិន្ទ្រាក៏ពិតមែន ប៉ុន្តែ
អារម្មណ៍របស់គាត់ពុះកញ្ជ្រោលណាស់ នឹកដល់រឿងរ៉ាវពីថ្ងៃមិញ ផង
នឹកទៅដល់អតិតកាលមួយដែលគាត់រស់នៅជួបជុំគ្រួសារ ប្តី និងកូនប្រកបដោយសុភមង្គលផង ។
ថ្ងៃនេះ គាត់ក្លាយជាជនខ្វាត់ ព្រាត់ឥតជំរក ស្នាក់អាស្រ័យជាមួយចៅស្រីលើទូករបស់យុវជន
ម្នាក់ដែលគាត់មិនស្គាល់ប្រវត្តិពីមុនមក ដឹងត្រឹមតែថា គេជាក្មេង ល្អម្នាក់តែប៉ុណ្ណោះ ។ យូរៗម្តង
ទឹកភ្នែកថ្លាឆ្វង់លួចហូរចុះពីរង្វង់ ភ្នែករបស់គាត់យ៉ាងស្ងៀមស្ងាត់...

នៅខាងក្រៅ ជំនោររាត្រីបក់នាំទឹករលក់បោកទង្គិចបាតទូកឮ សូរឆ្លិកឆ្លក់ៗ
ធ្វើអោយទូកផ្អៀងផ្អងឃ្លោងឃ្លោងៗ មិនខុសឡើយ ពីជីវិតរបស់មីងណៃ
ដែលកំពុងអណ្តែតឃ្លេងឃ្លោងគ្មានលំនឹងនៅ ពេលនេះដូច្នោះឯង...

oooooooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី២
# ប្រផ្នូល

វត្តកណ្ដាល ក្រុងបាត់ដំបង
ថ្ងៃ១៣មេសា ១៩៧៥...

លោកដុកទ័រវិចិត្រចុះពីរថយន្តកាន់ដៃភរិយា នាំមុខកូនប្រុស កូនស្រីនិងកូនប្រសារដើរសំដៅទៅព្រះវិហារដែលកំពុងមាន ប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរតាមប្រពៃណី ។ នៅជំនាន់នោះប្រទេស ខ្មែរកំពុងរងវិបត្តិសង្គ្រាម រវាងសាធារណរដ្ឋខ្មែរនិងខ្មែរក្រហម ។ ថ្វីបើពេលនោះជាពេលបុណ្យចូលឆ្នាំក៏ដោយ ក៏ស្នូរកាំភ្លើងនៅតែលាន់ឮក្ទួងៗសង្វើញជីវិតមនុស្សមិនឈប់ឈរសោះឡើយ ។

លុះចូលមកដល់ក្នុងព្រះវិហារ អ្នកទាំងអស់គ្នាក៏ចូលអុជធូប ថ្វាយព្រះភ្លាម ។ ថ្ងៃនោះ សមាជិតក្រុមគ្រួសាររបស់លោកដុកទ័រ វិចិត្របានមកដល់វត្តគ្រប់គ្នាទាំងអស់ មិនខ្វះម្នាក់ណាទេ រួមទាំង អ្នកគ្រូចរណៃដែលជាភរិយា នាងម៉ៅជាកូនស្រីច្បងកំពុងបីកូនខ្ចី នៅក្នុងដៃបុរីជាកូនប្រសារ ចិត្រាប្អូនប្រុសបន្ទាប់របស់ស្រីម៉ៅ បារមីជាប្អូនស្រីទីបីនិងវិសាលជាកូនប្រុសពៅផងដែរ ។

លុះថ្វាយបង្គំព្រះបដិមារបីដងហើយ លោកដុកទ័រវិចិត្រក៏ងាកមកមានប្រសាសន៍ប្រាប់កូនទាំងអស់គ្នាថា ៖

- កូនៗរបស់ប៉ាទាំងអស់ស្ដាប់ប៉ាណាំកូន..! ពេលនេះស្រុកយើង មានអាសន្នវឹកវរណាស់.. មិនដឹងថាជីវិតប្រទេសជាតិយើងនឹងត្រូវ បែរទៅទិសណាទេ ហើយពួកយើងគ្រប់គ្នាទៀតសោតក៏រស់នៅ ក្នុងសំណាចគ្រាប់ភ្លៀងនៃកាំភ្លើងធំតូចរបស់បច្ចាមិត្រ ជារៀងរាល់ ថ្ងៃដែរ ។ យើងមើលអនាគតមិនឃើញទេ ថាស្រុកយើងនឹងសុខ សាន្តត្រាណមកវិញឬក៏យ៉ាងណា... ប៉ុន្តែថ្វីបើយើងមិនដឹងថានឹង ត្រូវរស់រងគ្រាប់កាំភ្លើងយូរតទៅទៀតប៉ុនណាក៏ដោយ ក៏ប៉ាចង់អោយកូនទាំងអស់គ្នាចងចាំផងថា មិនថាប៉ានៅមានជីវិតឬក៏ប៉ាត្រូវ ស្លាប់ទេ ប៉ាស្រឡាញ់កូនគ្រប់គ្នាទាំងអស់ ហើយមិនចង់អោយ កូនៗបែកឃ្លាតពីប៉ាម៉ាក់ទៅណាដែរ ។

CHANBOKEO.COM

ថៃដន្យ... បើសិនជាប៉ាឬ ម៉ាក់ត្រូវឃ្លាតរូបកូនទៅដោយសារវិបត្តិសង្គ្រាម ប៉ាសូមផ្តាំអោយ
កូនចេះស្រឡាញ់គ្នាហើយ ថែរក្សាគ្នាទៅវិញទៅមកជានិច្ចណា៎កូន ណា៎ ។
សេចក្តីស្រឡាញ់នេះហើយ នឹងធ្វើអោយកូនមានកម្លាំងចិត្ត ហ៊ានពុះពារនូវឧបសគ្គអ្វីៗ
សព្វបែបយ៉ាង ក្នុងជីវិតបានយ៉ាង ក្លាហានរួចជោគជ័យជាទីបំផុត ។
ចូរកុំភ្លេចមើលរក្សាគ្នាណា៎កូន!
- ចា៎ស! បាទ! លោកប៉ា!

កូនទាំងប្រាំនាក់អោនក្បាលសំពះទទួលពាក្យរបស់ឪពុក ព្រម គ្នា ។ បន្ទាប់មក
លោកឧកញ៉ាក៏បែរទៅអ្នកគ្រូចរណៃដែលជា ភរិយារបស់លោក រួចហើយក៏ស្រដីបន្តថា ៖
- ណៃ! អូនជាដួងជីវិតរបស់បង ហើយក៏ជាម្លប់ត្រជាក់របស់កូន យើង គ្រប់ៗគ្នា ។
បងសូមបន់ស្រន់អោយគ្រួសាររបស់យើងបាន ចៀសផុតនូវមហន្តរាយទាំងឡាយ
ដែលសង្គ្រាមបានបង្កឡើង ។ ថ្ងៃនេះ បងមានប្រផ្នូលក្នុងចិត្តយ៉ាងចម្លែកក្នុងចិត្តណាស់... ប៉ុន្តែ...
បងមិនបណ្តោយឲ្យប្រផ្នូលនោះ នាំចិត្តរបស់បងរសាយសេចក្តី សង្ឃឹមបានឡើយ ។
បងសូមបន់ស្រន់អោយបងនិងអូនព្រមទាំង
កូនមានសុវត្ថិភាពហើយបានរស់នៅជួបជុំគ្នាជារៀងហូត មិនឲ្យ បែកព្រាត់ទៅណា ។ ប៉ុន្តែ
បើស្ថានការណ៍ជំរុញអោយយើងខក បំណងវិញនោះ សូមណៃចងចាំផង ថាបងស្រឡាញ់អូន
ស្រឡាញ់ ជានិច្ចរៀងរហូតទៅ លុះថ្ងៃអវសាននៃជីវិតរបស់បង មិនផ្លាស់ប្តូរ ឡើយ ។
- បងចិត្រ! មានប្រសាសន៍អ្វីចម្លែកម្ល៉េះថ្ងៃនេះ ? (អ្នកគ្រូចរណៃ ឧទានតបទៅស្វាមីវិញ)
នេះជាថ្ងៃចូលឆ្នាំណា៎បង! ម៉េចក៏បង និយាយរឿងព្រាត់ប្រាសគ្នាទៅវិញ ?

មែនហើយ! ថ្ងៃនេះ លោកឧកញ៉ារបស់យើងមានប្រផ្នូល
ចម្លែកក្នុងចិត្តតាំងពីលោកភ្ញាក់ពីដំណេកមកថា លោកហាក់ដូចជា
កំពុងតែមានដំណើរត្រូវព្រាត់ប្រាស ចេញពីក្រុមគ្រួសាររបស់លោក ដូច្នោះឯង ។ ភ្លាមនោះ
លោកក៏លូកស្រវាចាប់ដៃភរិយាយកមក កាន់ ហើយមានប្រសាសន៍ថា ៖
- មែនហើយ! ថ្ងៃនេះជាថ្ងៃចូលឆ្នាំ ព្រះលោកយាងចុះមកប្រទាន ពរជ័យដល់យើងហើយ ។
ដូច្នេះយើងប្រញាប់ថ្វាយបង្គំសូមពរពី ព្រះអង្គអោយយើងស្រឡាញ់គ្នារហូតរៀងទៅ
ហើយសូមឲ្យយើង បានរស់នៅជួបជុំគ្នារហូតលុះដង្ហើមចុងក្រោយរបស់យើង ។

CHANBOKEO.COM

- ចា៎សបង! ណៃចង់សូមពរពីព្រះអង្គអោយបងនិងអូនរស់នៅ
អាយុវែងៗមិនទៅណាចោលគ្នាងាយៗទេ លុះណាយើងមិនទាន់ មានអាយុគ្រប់មួយរយឆ្នាំ
ហើយយើងក៏នៅតែជាគូស្រករដែល ស្រឡាញ់គ្នាបំផុត មានសុភមង្គលបំផុត នៅលើលោកនេះ ។
    កូនៗទាំងប្រាំនាក់លួចសម្លឹងមុខគ្នា ញញឹមក្រប្លូចមាត់ កាល
បើគេបានឮប្រយោគដែលប៉ាម៉ាក់របស់គេ សម្តែងនូវអារម្មណ៍មនោ
សញ្ចេតនារបស់លោកនៅចំពោះមុខកូនៗយ៉ាងដូច្នេះ ។
    លោកដុកទ័រវិចិត្រញញឹមយ៉ាងស្រស់បំព្រងដាក់ភរិយា ហើយ ក៏ឆ្លើយឡើងថា ៖
- រូបអូនជាប្រភពនៃកម្លាំងចិត្តរបស់បងជានិច្ច ។ វាចារបស់អូន មានន័យទូលំទូលាយណាស់ ។
សូមអោយបំណាន់របស់អូនបាន សំរេច នោះបងនិងមានជីវិតរស់នៅក្បែរអូនរៀងរហូតទៅ...!
    អ្នកគ្រូចរណៃញញឹមតបទៅស្វាមីវិញយ៉ាងផ្អែមល្ហែម ៖
- បើបំណាន់ណៃសក្តិសិទ្ធិដល់ម្លឹង ណៃសូមបន់អោយយើងនិងកូន
បានចាកផុតនូវទុក្ខទោសមហន្តរាយទាំងឡាយនៃសង្គ្រាម ។ ម៉ោះ!
អុជធូបបន់ជាមួយអូនម្តងទៀតណា៎!
    ទាំងលោកវិចិត្រ ទាំងអ្នកគ្រូចរណៃ និងកូនគ្រប់គ្នាក៏អោន វន្ទាសិរសាដល់កំរាល
ថ្វាយបង្គំព្រះពុទ្ធអង្គសាជាថ្មី ។ ថ្ងៃនោះ ពិត មែនតែកូនចៅទាំងអស់មានសេចក្តីរីករាយសប្បាយ
ដោយបានមក ធ្វើបុណ្យចូលឆ្នាំនៅវត្ត តែលោកគ្រូពេទ្យមិនមានអារម្មណ៍ជ្រះ ស្រឡះក្នុងចិត្តសោះ
គឺហាក់ដូចជាក្តុកក្តួលយ៉ាងណាមិនដឹង រកថា មិនត្រូវសោះ ។
- បង! ម្តេចធ្វើមុខស្ងួតម៉្លេះ ?
    អ្នកគ្រូចរណៃលួចខ្សិបសួរស្វាមី ។ លោកគ្រូពេទ្យញញឹមធ្វើ មុខស្មើៗ
ហើយឆ្លើយវិញដោយដួងចិត្តញាប់ញ័រចម្លែក ៖
- មិនដឹងទេអូន! បងចេះតែញាប់ញ័រក្នុងចិត្តទប់អារម្មណ៍មិន បាន ចេះតែមានប្រផ្នូលថា
ក្រុមគ្រួសារយើងកំពុងមានដំណើរ ឈានចូលទៅក្នុងភាពងងឹតមួយយ៉ាងចម្លែក...
    អ្នកគ្រូចរណៃញញឹមដាក់ស្វាមី ហើយលូកដៃអង្អែលខ្នងដៃ លោកបន្តើរៗ រួចលួងលោមថា ៖
- កុំសូវជឿប្រផ្នូលពេកអីណា៎បង! ជួនកាល ប្រផ្នូលឆ្លងកាត់ជីវិត
យើងដូចជាយល់សប្តិមួយអញ្ចឹង គឺមិនដាក់ថា ប្រផ្នូលនោះអាច ក្លាយជាការពិតបានទេ ។
បងកុំទៅគិតច្រើនធ្វើអ្វី ។

CHANBOKEO.COM

ថ្ងៃនោះ មិនថាអ្នកគ្រូចរណៃនិយាយបន្លប់លួងលោមចិត្តលោក គ្រូពេទ្យយ៉ាងណាក៏ដោយ ក៏លោកនៅតែប្រឹងញញឹមមិនចេញ ដដែល ។ ផ្ទុយទៅវិញ កូនប្រុសស្រីរបស់លោក បែរជាមានអារម្មណ៍សប្បាយរីករាយពន់ពេកណាស់ ដែលពួកគេបាននៅជួប បងប្អូនធ្វើបុណ្យជុំគ្នា ដោយមិនមានបែកនរណាម្នាក់ ។

ថ្ងៃបន្ទាប់មក...

លោកគ្រូពេទ្យហៅកូនទាំងអស់ មកបរិភោគបាយជុំគ្នានៅផ្ទះ របស់លោក រួមទាំងប៉ុរីនិងស្រីម៉ៅដែលរស់នៅឯផ្ទះមួយមិនឆ្ងាយ ពីលោកប៉ុន្មានទេ ។ លោកគ្រូពេទ្យបរិភោគបណ្ដើរ មានប្រសាសន៍ បណ្ដើរ ទៅកាន់កូនៗគ្រប់គ្នាថា ៖

- ប៉ាបានតាមដានពត៌មានស្រុកទេសរាល់ថ្ងៃ ឃើញថាស្ថានការណ៍ កាន់តែធ្ងន់ធ្ងរឡើងៗជានិច្ច ។ មិននឹងថាពួកយើងមានឱកាសបាន បរិភោគបាយរួមគ្នាបែបនេះ ប៉ុន្មានដងទៀតទេ ។ ប៉ុន្តែ កាលបើ យើងនៅសល់ឱកាសខ្លះៗនោះ ប៉ាសូមអោយកូនមកទីនេះបរិភោគ បាយជុំគ្នាចាប់ពីពេលនោះតទៅ ។ ហោចណាស់យើងបានទទួលនូវ ការកក់ក្ដៅរបស់គ្រួសារយើង រហូតដល់ពេលមួយដែលយើងមិន អាចធ្វើអ្វីបានតទៅទៀត...

អ្នកគ្រូចរណៃលួចសម្លឹងមុខស្វាមី ។ ឯកូនៗរបស់លោកវិញក៏ លួចមើលមុខគ្នា ធ្វើឡឹងឡង់ៗ ត្បិតលោកគ្រូពេទ្យជាមនុស្សចូល ចិត្តគិតអ្វីនិយាយអ្វីមានសុទិដ្ឋិជានិច្ច ។ ចម្លែកអី ពីរថ្ងៃមកនោះ លោកបែរជានិយាយប្លែកៗក្នុងលក្ខណៈពិភាល់ជាអវិជ្ជមាន មិន ឈប់ឈរសោះ មើលទៅហាក់ដូចជាលោកកំពុងត្រៀមខ្លួនសំរាប់ ស្ថានការណ៍ផ្លាស់ប្តូរអ្វីមួយយ៉ាងចម្លែកអញ្ចឹង ។ ប៉ុន្តែ ពេលនោះ គ្មាននរណាម្នាក់ហើបមាត់និយាយអ្វី សួរអ្វីទេ ព្រោះខ្លាចរំខានចិត្ត លោក ម្ល៉េះហើយ គេគិតតែពីនាំគ្នាបរិភោគបាយយ៉ាងស្ងៀមស្ងាត់ តែប៉ុណ្ណោះ ។

ក្រោយពីពេលបាយហើយ លោកគ្រូពេទ្យទាញខ្សែកប្លាទីន បន្តោងព្រះ ចំនួនប្រាំខ្សែយកចេញមក ហើយក៏ប្រគល់ទៅកូន របស់លោកម្នាក់មួយ រួមទាំងប៉ុរីដែលជាកូនប្រសារផង ៖

- នេះ! យកពាក់ម្នាក់មួយទៅកូន ដើម្បីអោយព្រះលោកតាមថែ រក្សាកូន គ្រប់ពេលវេលាទាំងអស់ក្នុងជីវិត ។ ទោះបីជាប្រទេស យើងបានទទួលរងគ្រោះដោយសង្គ្រាមយ៉ាងណាក៏ដោយ ប៉ាសូមបែ បន់អោយកូនទាំងអស់របស់ប៉ា បានចៀសផុតនូវគ្រោះថ្នាក់ទាំងពួង នឹសាហាវនោះជានិច្ច ។

CHANBOKEO.COM

ទាំងអស់គ្នាក៏លូនទៅជិតឪពុក លូកដៃត្រងទទួលយកខ្សែក ម្នាក់មួយខ្សែយកមកពាក់ ទាំងទឹកចិត្តរំជើបរំជួលហើយពិភាល់ យ៉ាងចម្លែក ។ នៅក្បែរលោកគ្រូពេទ្យ អ្នកគ្រូចរណៃអង្គុយសម្លឹង សង្កេតកិរិយារបស់ស្វាមីមិនហ៊ានព្រិចទេ តែក៏មិនមានស្រដីអ្វីម អោយអាក់ទឹកចិត្តរបស់លោកដែរ ។

បន្តិចមក កូនៗក៏ដើបចេញអស់ទៅ ។ លោកគ្រូពេទ្យក៏ដើប ទៅឈរនៅរានហាលមុខផ្ទះធ្វើទឹកមុខស្រងូត ។ ឃើញដូច្នោះ អ្នក គ្រូចរណៃក៏ដើរទៅជិត យកដៃអង្អែលខ្នងលោកបន្ថើរៗ ៖

- បងកុំគិតច្រើនពេកអី! មិនយូរមិនឆាប់ ប្រទេសយើងនឹងបាន សុខសាន្តត្រាណមកវិញមិនខានឡើយ ។

លោកគ្រូលូកដៃត្រកងស្នាភរិយា ហើយញញឹមដាក់យ៉ាងផ្អែម ល្ហែម ព្រមទាំងមានវាចាយ៉ាងស្រទន់ ថា ៖

- បងក៏បែបនអញ្ចឹងដូចគ្នាដែរ ។ បើសិនជាប្រទេសយើងបាន ទទួលសុខសន្តិភាពវិញពិតមែន នោះយើងនឹងបានរស់នៅមាន សេចក្តីសុខជាក្រុមគ្រួសារដ៏កក់ក្តៅរៀងរហូតទៅ មែនទេអូន ?

រួចហើយ លោកក៏ផ្ទាប់នាសាផ្ដិតលើសៀតផ្កាភរិយាសម្តែងនូវ ទឹកចិត្តស្នេហាយ៉ាងធំធេងរបស់លោកចំពោះអ្នកគ្រូចរណៃ ។ អ្នក គ្រូក៏ញញឹមទទួលវិញទាំងឱរារំភើបបំផុត ៖

- មិនថាពិភពលោកប្រែប្រួលយ៉ាងណាទេ ណៃក៏នៅតែស្រឡាញ់ បងនិងកូនគ្មានថ្ងៃកែប្រែបានឡើយ ។ ជីវិតអូនមួយសូមពលីជូន បងនិងកូនៗរបស់យើង... អ្វីក៏ដោយអោយតែអូនអាចធ្វើបាន អូន នឹងធ្វើទាំងអស់គ្រប់យ៉ាង អោយតែបងនិងកូនមានសេចក្តីសុខនិង មានសុវត្ថិភាព!

ឮដូច្នោះ លោកគ្រូពេទ្យបែរឈ្ងោកសម្លឹងមុខភរិយា ៖

- ម៉េចក៏ស្រដីដូច្នេះអូនណៃ! យើងស្រឡាញ់គ្នាទៅវិញទៅមក ។ យើងនឹងពលីដើម្បីគ្នាទៅវិញទៅមក និងដើម្បីកូនចៅរបស់យើង.. បងពិតជាមិនបណ្តោយអោយអូនពលីតែម្នាក់ឯងទេ...

បន្តិចមក លោកគ្រូពេទ្យទាញដៃភរិយាអោយដាក់ខ្លួនអង្គុយចុះ នៅក្នុងអង្រឹងដែក លើរានហាលមុខផ្ទះទន្ទឹមនឹងលោក រួចក៏យោល អង្រឹងឡើងយឺតៗ ។ អ្នកគ្រូពេទ្យក៏កេសាកើយស្មាស្វាមីដោយដួង ចិត្តស្នេហាយ៉ាងជ្រាលជ្រៅ

CHANBOKEO.COM

មិនខុសពីទឹកចិត្តរបស់លោកគ្រូពេទ្យ ដែលស្រឡាញ់អ្នកគ្រូជាភរិយានោះឡើយ ។ ភ្លាមនោះ លោកគ្រូ ពេទ្យយើងមានប្រសាសន៍ឡើងថា ៖

- ណៃ! បងស្រឡាញ់អូនណាស់...បងស្រឡាញ់អូនថែមឡើងរៀង រាល់ថ្ងៃ មិនមានថមថយឥទ្ធិពលទេ ។ បើសិនជាជាតិក្រោយមាន មែននោះ សូមអោយបងបានជួបអូនជាគូជាថ្មីទៀតកុំខាន!!

កាលបើឮវាចាដូច្នោះ អ្នកគ្រូក៏តបវិញថា ៖

- ណៃមិនដឹងថាជាតិក្រោយយ៉ាងណាទេ ប៉ុន្តែចំពោះជាតិនេះ ណៃ សូមសច្ចាថានឹងស្រឡាញ់បង លុះលង់រហូតដល់ថ្ងៃអូនលាលោក នេះទៅវិញ ។ នៅជាមួយបង ជីវិតរបស់អូននិងកូនមានសេចក្តី សុខរមនាបំផុត ។

រំពេចនោះ ស្នូរគ្រាប់ផ្លោងហោះវីវៗពីលើក្បាល ធ្លាក់ចូលក្រុង បាត់ដំបង ផ្ទុះក្ផងក្ផាំង បង្កជាសន្ធឹកខ្ទ័រដីក្រុងទាំងមូល ។ លោក គ្រូពេទ្យស្ទុះងើបឡើងយ៉ាងរហ័ស ទាញដៃភរិយារត់ចុះតាមជណ្តើរ មកជាន់ក្រោម ហើយកូកហៅកូនប្រុសស្រីរបស់លោក ៖

- កូនត្រា ម៉ី និងសាល ឆាប់រត់ចូលត្រង់សេណ៉ាកូន ។

ភ្លាមនោះ លោកឃើញកូនៗរបស់លោក ស្រវាកាន់ដៃគ្នារត់ ត្រសងរកទីពួន ។

- ហើយចុះឯណាស្រីម៉ៅនិងបុរីព្រមទាំងកូនតូចរបស់គេ?

អ្នកគ្រូចរណៃស្រែកសួរកូនទាំងបី ។ បារមីបែរក្រោយឆ្លើយ យ៉ាងរហ័សមកវិញថា ៖

- ខ្ញុំឃើញបងរៃនាំបងម៉ៅនិងកូនត្រឡប់ទៅផ្ទះ ។ គាត់ថាល្ងាច នេះ គាត់ត្រឡប់មកវិញម្តងទៀត ។

មួយស្របក់ក្រោយមក គ្រាប់ផ្លោងក៏ស្ងាត់ទៅវិញ ។ លោកគ្រូ ពេទ្យក៏លើកអាវផាយមកពាក់ ហើយចាប់កូនសោរឡានបំរុងនឹងបរ ចេញទៅ ។

- បងបំរុងទៅណ៉ាហ្នឹង? (អ្នកគ្រូចរណៃសួរ)

- បងគិតទៅពេទ្យធំបន្តិច (លោកគ្រូពេទ្យឆ្លើយ) ថ្ងៃនេះ ច្បាស់ ជាមានអ្នកស្រុករងរបួសទៀតហើយ ។

មែនហើយ! ភារកិច្ចជាគ្រូពេទ្យពិតជាធ្វើអោយលោកដុកទ័រ វិចិត្រទ្រាំបញ្ឈរភ្នែកមើលមិនបានទេ ។ បន្តិចមក លោកក៏បញ្ឆេះ ម៉ាស៊ីនចេញទៅ ។

- កុំធ្វើការអោយហួសកម្លាំងណ៉ាបង! ល្ងាចនេះ ពួកយើងនៅចាំ បងមកបរិភោគបាយជុំគ្នា (អ្នកគ្រូចរណៃពោលផ្តាំស្វាមី)

CHANBOKEO.COM

លោកគ្រូពេទ្យមួលទម្លាក់កញ្ចក់ឡានចុះ រួចញញឹមដាក់ភរិយា របស់លោកវិញ ៖

- បាទ៎! បងពិតជាមកវិញអោយទាន់ពេលមិនខាន ។

អ្នកគ្រូចរណៃក៏ញញឹមតបលោកវិញយ៉ាងត្រកាល ហើយឈរ សម្លឹងមើលតាមពីក្រោយ រហូតដល់រថយន្តចេញផុតពីរបងផ្ទះ ។ ថៃដន្យ យប់នោះ អ្នកគ្រូត្រូវនៅអង្គុយបរិភោគជាមួយកូនយ៉ាង ស្ងៀមស្ងាត់ ព្រោះលោកគ្រូពេទ្យមិនបានវិលត្រឡប់មកទាន់ពេល វេលាដូចដែលលោកសន្យាទេ ដោយសារតែមានអ្នករបួសដឹកចូល ពេញមន្ទីរពេទ្យរកកន្លែងដាក់គ្មាន ។ ដូច្នេះ លោកគ្រូពេទ្យនិង សមាជិកពេទ្យជាច្រើនក៏ត្រូវជាប់ដៃធ្វើការ ស្ទើរមិនបានសំរាកទាំង អស់គ្នា ។

យប់នោះ ស្រីម៉ៅដែលជាកូនច្បងរបស់អ្នកគ្រូបាននាំប្ដីនិងកូន តូចមកស្នាក់លេងដែរ ។ កាលបើឃើញម្ដាយនៅអង្គុយចាំផ្លូវឪពុក យ៉ាងផ្សាភ្នែក ស្រីម៉ៅក៏បីកូនមកជិតដើម្បីអង្គុយកំដរម្ដាយ ៖

- បន្តិចទៀត ប៉ានឹងមកដល់ហើយណា៎ម៉ាក់! បើអស់កម្លាំង ម៉ាក់ ចូលសម្រាន្តសិនទៅ ចាំខ្ញុំទៅជំរាបបងប៊ុរីអោយគាត់នៅចាំមើល ផ្លូវប៉ាជំនួសវិញ ។

ឃើញកូនសម្ដែងទឹកចិត្តខ្វាយខ្វល់ចំពោះលោកដូច្នេះ អ្នកគ្រូ ក៏មានប្រសាសន៍តបទាំងញញឹមវិញថា ៖

- មិនអីទេកូន! កូនវិញតើហ៎ដែលត្រូវចូលដំណេកអោយបានឆាប់ នោះ ។ មើលចុះ! សរសៃខ្ចីផង កុំស្ងូវអត់ងងុយពេកណា៎កូន! ម៉ាក់មិនទាន់ងងុយគេងទេ អាចនៅចាំប៉ាមួយសន្ទុះទៀតបាន ។ កូនចូលទៅគេងទៅ មិនបាច់នៅកំដរម៉ាក់ទេ ។ បើសិនត្រូវការ ចាំម៉ាក់ទៅដាស់កូនប៊ុរីអោយមកជួយ ។

ថាហើយ អ្នកគ្រូក៏ខិនឈ្ងោកថើបថ្ពាលចៅស្រីដែលកំពុងគេង លក់នៅក្នុងរង្វង់ដៃម្ដាយ ៖

- យប់ត្រជាក់ធ្លាក់ខ្យល់ហើយ ប្រយត្ន័កូនត្រូវខ្យល់ផ្ដាសាយ ឆាប់ ចូលទៅក្នុងផ្ទះវិញទៅកូន ។

- ចា៎សម៉ាក់!

នាងម៉ៅក៏លើកកូនបី ដើរត្រឡប់ចូលក្នុងផ្ទះវិញទៅ ។

នៅវាងប្រហែលម៉ោងមួយអាធ្រាត លោកគ្រូពេទ្យក៏ត្រឡប់ មកវិញដោយទឹកមុខអស់កម្លាំងល្ហិតល្ហៃ ។ អ្នកគ្រូចរណៃប្រញិប ប្រញាប់ស្ទុះរត់ទៅទទួលប្រណិបតន៍ស្វាមីភ្លាម ។ ថ្វីបើលោកត្រូវ អង្គុយពិសារបាយនៅម៉ោងមួយជិតភ្លឺក៏ដោយ ក៏លោកគ្រូពេទ្យមិន

CHANBOKEO.COM

មានស្រដីត្អូញមួយម៉ាត់ដាក់ភរិយាមួយម៉ាត់ឡើយ តែបែរជាញញឹម
ដាក់អ្នកគ្រូវិញយ៉ាងស្រស់ទៅវិញ ។ ឃើញលោកគ្រូពេទ្យញញឹម មិនដាច់
អ្នកគ្រូក៏មានប្រសាសន៍សួរ ៖

- បងមានអ្វីសប្បាយៗ ចង់ប្រាប់អូនមែនទេ បានជាញញឹមស្រស់ មិនព្រមឈប់ យ៉ាងនេះ ?

  លោកគ្រូពេទ្យញញឹមគ្រហាញ ហើយឆ្លើយថា ៖

- ពិតជាមានហើយ មិនអត់ទេ ។
- មែនហ្អែស ? តើជាអ្វីទៅ បងចិត្រ ?
- គឺញញឹមព្រោះបងសប្បាយចិត្ត ដែលបានឃើញមុខប្រពន្ធបង
ញញឹមដាក់ពេលមកដល់ផ្ទះភ្លាមនោះអី ។
- អូហ៎ អញ្ចឹងទេហ៎ ? ណែស្មានតែបងមានដំណឹងអ្វីប្លែកតើហ៎ !
- ហើយចុះនរណាគេទៅមិនញញឹមនោះ ពេលគេបានឃើញមុខ មនុស្សជាទីស្រឡាញ់របស់គេ ?
មើលហ្ន៎ ! សូម្បីតែណែក៏ញញឹម អត់ឈប់... មិនខុសពីបងឡើយ ។

  អ្នកគ្រូសើចកខឹកតែម្តង ៖

- បើដឹងអញ្ចឹងហើយ សូមបងប្រញាប់មកផ្ទះអោយលឿនជាងនេះ បន្តិចណា
នឹងអាលអោយណែឆាប់បានញញឹមពីក្បាលព្រលប់ផង ។

  លោកគ្រូពេទ្យយកដៃបូតច្រមុះភរិយាដោយឃ្នាន់ខ្នាញ់ ៖

- បា៎ទ ចៅហ្វាយស្រី ! ថ្ងៃនេះបងជ្រុលធ្វើការយប់ជ្រៅ ! ចាំថ្ងៃ ក្រោយ
បងនឹងមកផ្ទះវិញអោយបានឆាប់ជាងនេះណា៎ព្រលឹងមាស បង
ដើម្បីអោយអូនបានញញឹមដាក់ស្នេហ៍បងអោយបានច្រើនៗ ។

  ទាំងពីរនាក់សម្លឹងមុខគ្នាហើយសើចកខឹកយ៉ាងរីករាយ ។ ថ្វីបើ
លោកទាំងពីរមានចំណាស់ជាងសែទៅហើយ តែលោកនៅតែ
ស្រឡាញ់គ្នាល្អូកល្អឺនផ្អែមល្ហែមក្រៃលែង មិនចាញ់គូស្រករក្មេងៗ
ដែលទើបនឹងរៀបការថ្មីៗនោះឡើយ ។ ចាប់តាំងពីថ្ងៃរៀបមង្គល ការរហូតមកទល់ថ្ងៃនេះ
ទឹកចិត្តស្រឡាញ់រវាងលោកទាំងពីរហាក់ ដូចជាមិនមានថមថយឥទ្ធិពលបន្តិចឡើយ ។
ផ្ទុយទៅវិញ លោក ហាក់ដូចជាស្រឡាញ់គ្នាកាន់តែច្រើនថែមឡើងជានិច្ច រៀងរាល់ថ្ងៃ
រហូតដល់ហ៊ានសម្តែងទឹកចិត្តស្នេហារបស់លោក នៅចំពោះមុខកូន
ប្រុសស្រីយ៉ាងចំហទៅហើយ ។ ដោយសារតែហេតុនេះហើយទើប

CHANBOKEO.COM

ក្រុមគ្រួសាររបស់លោកបានទទួលនូវសេចក្តីសុខយ៉ាងរមនា ។ កូនចៅរបស់លោកគ្រប់គ្នាសុទ្ធតែជាក្មេង ដែលមានសម្បទាកិរិយាសម ប្រកបហើយមានចរិតថ្លៃថ្នូរគួរអោយស្រឡាញ់ ។ តាំងពីគេមាន កំណើតមកគេមិនដែលស្គាល់ថាអ្វីដែលថាជារឱស្ថានឡើយ គឺគេ ស្គាល់តែសេចក្តីរីករាយនិងភាពកក់ក្តៅមានលំនឹងក្នុងចិត្ត ហើយ ស្រឡាញ់បងស្រឡាញ់ប្អូនយ៉ាងជិតស្និទ្ធបំផុត ស្ទើរតែបែកគ្នាមិនបានទៅហើយ ។ នោះហើយគឺជាអំណោយផលនៃសេចក្តីស្រឡាញ់និងការឃុំគ្រងដ៏រមនាក្សេមក្សាន្ត ពីលោកគ្រូពេទ្យនិងភរិយារបស់ លោក ។ កាលបើសេចក្តីស្រឡាញ់របស់លោក មានទំហំធំធេង ដល់ម្លឹងលែងអីមិនមានអនុភាពខ្លាំងក្លាដល់ជីវិតរបស់កូនចៅ លោកនោះ ។ ព្រោះតែគេរស់នៅជិតដិតនឹងលោករាល់ថ្ងៃ ទើបកូនចៅគ្រប់ៗគ្នាបានទទួលនូវចំហាយឥទ្ធិពលនៃសុភមង្គលពីរូបលោក ដោយខានមិនបាន ។

ថ្ងៃ១៧មេសា១៩៧៥...

ទំព័រប្រវត្តិសាស្ត្រថ្មីមួយ បានលាតគ្របដណ្តប់លើប្រទេសខ្មែរ ទាំងមូល ។ លោកគ្រូពេទ្យធ្វើការយ៉ាងញាប់ដៃនៅក្នុងមន្ទីរពេទ្យ មិនបានចាប់ភ្លឹកនឹងស្ថានការណ៍ខាងក្រៅ ។ ស្រាប់តែចិត្រាជិះម៉ូតូ ទៅតាមលោកដល់ការិយាល័យតែម្តង ។

- មានការអ្វីកូនត្រា ? (លោកវិចិត្រសួរ)
- បាទ! លោកប៉ា! ម៉ាក់មានប្រសាសន៍អោយអញ្ជើញលោកប៉ា ទៅផ្ទះជាប្រញាប់ ។

លុះឃើញទឹកមុខកូនមិនស្រួល លោកដុកទ័រក៏ដោះអាវផាយ រឹងចេញត្រឡប់ទៅផ្ទះភ្លាមយ៉ាងរហ័ស ។ នៅទីនោះ អ្នកគ្រូនិងកូនឈររង់ចាំលោកទាំងទឹកមុខអន្ទះសា ៖

- បង! (អ្នកគ្រូឧទានពេលឃើញមុខស្វាមីមកដល់ភ្លាម) ខ្មែរក្រហមយកភ្នំពេញបានហើយ ។ ពេលនេះ តើបាត់ដំបងយើងមាន វាសនាយ៉ាងណាទៅ ? ហើយ...តើយើងគួរគិតយ៉ាងម៉េចទៀត ?

លោកគ្រូពេទ្យឃើញប្រពន្ធកូន ឈរសម្លឹងលោកទាំងទឹកមុខ ភ័យជ្រួលច្របល់ លោកក៏មានប្រសាសន៍ឡើងកម្លាចិត្តថា ៖

- អូនរៀបចំឥវ៉ាន់សំខាន់ៗភ្លាមទៅ ។ បងទៅសាលាខេត្តស៊ើប ដើងការបន្តិច ។ មួយស្របក់ទៀត បងនឹងត្រឡប់មកវិញហើយ ។

CHANBOKEO.COM

អ្នកគ្រូចរណៃក៏ម្ទីម្ទានាំកូនរត់ចូលក្នុងផ្ទះរៀបចំតវ៉ាន់ តាមសំដី របស់លោកភ្លាម ។ ចំណែកលោកគ្រូពេទ្យវិញក៏ហក់ចូលឡានវឹង បរសំដៅទៅសាលាខេត្តយ៉ាងលឿន ។ លុះមកដល់ធ្លាមុខសាលា ខេត្ត លោកគ្រូពេទ្យប្រទះមនុស្សសំខាន់ក្នុងជួររដ្ឋការជាច្រើននាក់ ដែលជាមិត្តភក្តិ កំពុងតម្រង់ជួរឡើងយន្តហោះកន្ទុំរុយមួយគ្រឿង ដែលកំពុងវិលកង្ហាររបំរុងចេញដំណើរ ។ ភ្លាមនោះ ឧត្តមសេនីយ មួយរូប រត់មកគោះស្មាលោកគ្រូពេទ្យ ៖

- វិចិត្រ! ឡើងកប៉ាល់ហោះទៅ! យើងគ្មានពេលគិតច្រើនទេ ។ ពេលនេះ ត្រូវតែភៀសខ្លួនបណ្តោះអាសន្នសិនហើយ ។

- ចុះកប៉ាល់ហោះនេះចេញទៅខាងណាដែរ ? (លោកវិចិត្រសួរ)

- ទៅស្រុកថៃ ។ យើងត្រូវចេញអោយបានឆាប់រហ័សបំផុតព្រោះ ខ្មែរក្រហមលូនមកជិតដល់ក្រវាត់ក្រុងបាត់ដំបងហើយណា៎ យើង គ្មានពេលច្រើននឹងគិតទេ ព្រោះមេកោយយើងនៅភ្នំពេញបានបែក បាក់ទ័ពអស់ហើយ... យើងត្រូវតែរក្សាសុវត្ថិភាពមួយពេលសិន ។

លោកវិចិត្របែរមើលជុំវិញខ្លួន ឃើញអ្នករដ្ឋការសំខាន់ៗប្អូន ដប់នាក់រត់ឡើងយន្តហោះបន្តកន្ទុយគ្នាយ៉ាងអាសន្ន ។ ភ្លាមនោះ លោកក៏នឹកទៅដល់ប្រពន្ធកូនដែលនៅឯផ្ទះភ្លាមមួយរំពេច... មែន ហើយ! លោកស្រឡាញ់ពួកគេណាស់ ។ លោកមិនដាច់រត់ចោល ពួកគេយកសុខតែម្នាក់ឯងបានទេ ។

- លោកគ្រូពេទ្យឆាប់ឡើងមក!

បុរសម្នាក់ស្រែកហៅ ។ លោកគ្រូពេទ្យក៏ងាកតបវិញថា :

- សូមអញ្ជើញទៅមុនអោយបានសុខសប្បាយ! ខ្ញុំរង់ចាំចេញដើង ក្រោយវិញ ។

ភ្លាមនោះ ឧត្តម្ភាគចក្រក៏ចេញដំណើរទៅ នាំលោកចៅហ្វាយ ខេត្តនិងសមាជិករដ្ឋការប្អូនដប់ទៀត ចៀសពីគ្រោះថ្នាក់ដែលកំពុង សន្ធប់លើផ្ទៃក្រុងបាត់ដំបងទាំងមូល ។ រីឯលោកគ្រូពេទ្យវិញបរ រថយន្តថយក្រោយត្រឡប់ទៅផ្ទះយ៉ាងលឿន ។

- ណែ! អូនជាដួងជីវិតរបស់បង! បងមិនរត់ចោលអូននិងកូន របស់យើងជាដាច់ខាត ។ ទោះបីជារស់ឬស្លាប់ សុំឲ្យតែបងបាន
នៅជាមួយអូននិងកូនរបស់យើងរហូតដង្ហើមចុងក្រោយរបស់បង!

លោកដុកទ័រគិតតែម្នាក់ឯងក្នុងចិត្ត ។ លុះមកដល់ផ្ទះកាលណា
លោកក៏ហៅភរិយានិងកូនរៀបឥវ៉ាន់ដាក់ចូលរថយន្ត ។

- បងមានគំរោងការយ៉ាងណាដែរ ? (អ្នកគ្រូចរណៃសួរស្វាមី)

- ទៅសាលាខេត្ត រង់ចាំក្រែងមានជើងយន្តហោះកន្ទុំរុយត្រឡប់មក យកយើងមួយសាទៀត
នោះយើងអាចឡើងយន្តហោះចេញទៅជា មួយគេបាន ។ មិនដូច្នោះទេ
យើងត្រូវតែប្រថុយបររថយន្តតាម ផ្លូវជាតិសំដៅទៅស្រុកថៃហើយ
ដើម្បីរក្សាជីវិតរបស់យើងមួយ ពេលសិន ។ ទំរាំស្ថានការណ៍ស្រុកទេសធូរស្រាល បងនឹងវិល
ទៅទទួលអូននឹងកូនអោយត្រឡប់មកស្រុកវិញ ។

- មានន័យថាបងនឹងវិលមកស្រុកខ្មែរវិញតែម្នាក់ឯង ?

- មែនហើយ! បងជាកូនប្រុសម្នាក់ អោយដើរចោលប្រទេសខ្លួន ឯងដូច្នោះវាអាក្រក់មើលណាស់
តែបើទុកអូននៅទីនេះ បងពិតជា
បារម្ភអំពីសុវត្ថិភាពរបស់អូននិងកូនណាស់... បងពិតជាធ្វើការមិន កើតទេ ។

មានប្រសាសន៍ហើយ លោកគ្រូពេទ្យថ្មីម្នាបរដឹកប្រពន្ធនិងកូន ចៅចេញទៅ ។
ចំណែកតាខេមយាយលឿមដែលនៅចាំផ្ទះអោយ
លោកនោះក៏ឡើងចេញទៅនៅជាមួយសាច់ញាតិឯអន្លង់វិល ។

ថ្ងៃដន្យ សំណាងមិនល្អ នៅមុខសាលាខេត្តមានមនុស្សកកកុញ
រង់ចាំការសង្គ្រោះពីសំណាក់យន្តហោះជើងក្រោយ ប៉ុន្តែ ចាំបាត់ៗ
មិនឃើញស្រមោលយន្តហោះវិលមកវិញសោះ ។ ដោយការធុញ ថប់អន្ទះសាខ្លាំងពេក
លោកគ្រូពេទ្យក៏បរនាំក្រុមគ្រួសារចេញពី
បាត់ដំបងចេញទៅផ្លូវជាតិលេខប្រាំសំដៅសេរីសោភ័ណ ។ គ្រប់គ្នា
នៅក្នុងរថយន្តមានទឹកមុខតក់ស្លុតណាស់ តែគ្មាននរណានិយាយអ្វី ឡើយ
គិតតែធ្វើតាមតែពាក្យលោកដុកទ័រ ស្តីប្រាប់តែប៉ុណ្ណោះ ។ រំពេចនោះ បារមីក៏ស្រក់ទឹកភ្នែក ។

CHANBOKEO.COM

– កុំយំអីកូន! យើងមិនមែនលាផ្ទះយើងទៅរហូតទេ ។ នេះគ្រាន់តែជាការគេចខ្លួនបណ្តោះអាសន្នប៉ុណ្ណោះ ដើម្បីរក្សាជីវិតរបស់យើង អោយសុខសប្បាយ ។ កូនអត់ទ្រាំបន្តិចទៅណា៎ ។

អ្នកគ្រូណៃលួងលោមកូនស្រីដែលកំពុងមានអារម្មណ៍រន្ធត់ញាប់ញ័រដោយការភិតភ័យចំពោះស្ថានការណ៍ប្រែប្រួលក្នុងស្រុក ។

បន្តិចមក រថយន្តបានមកដល់មុំភូមិវាលទ្រាព្រមជាមួយអ្នកដំណើរទៅមកលើថ្នល់រចល់មិនដឹងថាគេទៅណាមកណាទេ ។ ភ្លាម នោះ ស្រាប់តែគេឮសូរគ្រាប់កាំភ្លើងផ្ទុងផាំងឡើងយ៉ាងខ្ទ័រខ្ទារទំនងហាក់កំពុងបាញ់តម្រង់មកអ្នកស្រុកដែលកំពុងធ្វើដំណើរតាមផ្លូវជាតិទាំងនោះ.. ផាំង! គ្រាប់កាំភ្លើងរត់ចំកញ្ចក់ឡានខាងមុខបែក ប្រាវ ។ អ្នកទាំងអស់គ្នាស្រែកជ្រួលឡើង ។ រួចហើយ ផាំង! ម្តងទៀតចំកង់ក្រោយ ។ រថយន្តក៏គ្រវីឃ្លេងឃ្លោងឡើងលែងមាន លំនឹង ។ លោកគ្រូពេទ្យព្រងឹងស្មារតីបររថយន្តទម្លាក់ចុះទៅវាល ស្រែរួចបក់ដៃអោយកូនចុះចេញពីរថយន្តរត់គេចខ្លួនចូលព្រៃ ភ្លាម ។ អ្នកស្រុកទាំងឡាយក៏ភ្ញាក់ផ្អើលរត់ប្រសេចប្រសាចចុះពី ថ្នល់ជាតិគេចរកកន្លែងជ្រកតែរៀងៗខ្លួន មិនខុសពីក្រុមគ្រួសារ លោកគ្រូពេទ្យទេ ។ ខ្លះក៏ត្រូវរបួស ខ្លះក៏ដួលស្លាប់នៅលើថ្នល់ ជាតិយ៉ាងរប៉ាត់រប៉ាយ...

សំណាងល្អសមាជិកក្រុមគ្រួសាររបស់លោកគ្រូពេទ្យគ្មាននរណា ម្នាក់របួសទេ ។ សូរកាំភ្លើងនៅតែលាន់ឮបន្តសង្វើញជីវិតមនុស្ស ឥតឈប់ឈរជាយូរម៉ោងកន្លងមកហើយ នៅតែមិនព្រមថមថយ អនុភាពសោះ ។ យប់នោះ ក្រុមគ្រួសារលោកដុកទ័របានមកទើរនៅទួលមួយដែលមានដើមដង្កោនិងដើមដង្កៀបក្តាមពីរបីដើម ។ អ្នកទាំងអស់គ្នាអង្គុយត្រេបោមជង្គង់ធ្វើមុខស្រងូត ត្បិតមិនដឹងថាត្រូវ ធ្វើយ៉ាងណាតទៅទៀត ។

នៅក្បែរគល់ដង្កោមួយ លោកគ្រូពេទ្យយើងលើកកូនវិទ្យុតូច មួយមកអង្គុយមួលស្តាប់ពត៌មានតែម្នាក់ឯង ។ ឯកូនចៅក៏នាំគ្នាប្រាសខ្លួនលើស្មៅសំរាកខ្លួនពីការរត់ភិតភ័យប៉ុន្មានម៉ោងមុននេះ ។ គួរអោយអាណិតស្រីម៉ៅណាស់ ដែលកំពុងតែសរសៃខ្ចីទើបសំរាល កូនបានពីរខែ ហើយមកត្រូវរត់ដេកដួលហាលវាលហាលខ្យល់ ។ ប៊ុរីឃើញប្រពន្ធហាក់ដូចជាល្ហិតល្ហៃ ក៏រត់ទៅជិតបបោសខ្នងនាងឲ្យ

CHANBOKEO.COM

រំងាប់ដួងចិត្តភិតភ័យរន្ធត់ ។

ថ្វីបើកាលនោះ ស្រុកខ្មែរ បានរងគ្រោះដោយសង្គ្រាមក៏ដោយ ក៏ប្រជាពលរដ្ឋខ្មែរទាំងមូលនៅតែមានសន្តានចិត្តចំពោះគ្នាជានិច្ច ។ កាលបើឃើញស្ត្រីកូនខ្ចីមកស្នាក់ក្រោមដើមឈើយ៉ាងកំសត់ អ្នកស្រុកម្នាក់បានអោយឆ្នាំងខ្ចីដាំបាយដាំទឹក ថែមទាំងហៅអោយស្រីៗទៅស្នាក់នៅខ្ទមស្រែរបស់គេទៀតផង ទោះបីជាគេមិនស្គាល់ក្រុមគ្រួសាររបស់លោកគ្រូវិចិត្រក៏ដោយ ។

នៅកណ្តាលវាលស្រែនោះ មានផ្ទះអ្នកស្រុកបួនដប់ខ្នង សង់ នៅឆ្ងាយៗគ្នាល្មមអាចហៅឮ ។ ពូណាតនិងប្រពន្ធឯងឋិតភ្អែកជា ម្ចាស់ខ្ទមមួយក្បែរនោះមានសន្តានចិត្តល្អណាស់ ។ គាត់មានកូនពីរ នាក់ដែរ តែគេបានទៅស្នាក់នៅវត្តឯបាត់ដំបង ដើម្បីទៅរៀននៅ វិទ្យាល័យ តែចូលឆ្នាំនេះ ពូណាតមិនឃើញពួកកូនៗមកលេងផ្ទះ ដូចរាល់ដងទេ ។

យប់នោះ ពូណាតបានហៅលោកដុកទ័រនិងកូនប្រុសឲ្យស្នាក់នៅលើរានហាលក្បែរក្រោលគោ ។ រីឯស្រីៗវិញ គាត់ឲ្យឡើងទៅស្នាក់នៅខាងក្នុងខ្ទមជាមួយប្រពន្ធគាត់ ។ ភ្លាមនោះ ពូណាតនិងមីងថនបានយកខោអាវចាស់ៗមកហុចឲ្យព្រមទាំងស្រដីថា ៖

- ប្អូនឯងនាំកូនចៅផ្លាស់ខោអាវទៅ ។ ម្ដុំនេះ សំបូរចរាចរពួក ខ្មែរក្រហមណាស់ ដូច្នេះត្រូវលាក់ខ្លួនជាមនុស្សសាមញ្ញ ឲ្យដូចអ្នក ភូមិម្ដុំនេះ ដើម្បីចៀសវាងការស្មាក់ប្លន់និងការធ្វើបាបពីពួកខ្មែរ ក្រហម...

លោកគ្រូពេទ្យសម្លឹងមុខភរិយាហើយក៏ងក់ក្បាលធ្វើតាមមិនឲ្យ ខូចការណ៍ ។ បន្តិចក្រោយមក គេទាំងអស់ក៏ប្រែរូបទៅជាអ្នក ស្រុកធម្មតា ។ លុះក្មេងៗចូលដំណេកអស់ ពូណាតក៏សួរលោកគ្រូពេទ្យថា ៖

- ប្អូននិងគ្រួសារមានដំណើរទៅខាងណាដែរហ្នឹង ?
- ខ្ញុំចង់ទៅសេរីសោភ័ណ តែមើលទៅតាមផ្លូវដូចជាគ្រោះថ្នាក់ ពន់ពេកក្រៃ មិនដឹងថាអាចទៅដល់ឬក៏យ៉ាងណាទេ ។

ពូណាតនៅស្ងៀមមួយស្របក់ក៏និយាយថា ៖

CHANBOKEO . COM

- យកល្អ ប្អូននៅស្ងៀមៗម៉ាពេលសិនទៅ ។ ពេលនេះ ខ្ញុំឃើញ ខ្មែរក្រហមចេញដើរច្រវាត់ច្រវៃងម៉ុំភូមិយើងណាស់ ។ ពួកគេមិន សួរប្រណីអ្នកដំណើរប៉ុន្មានទេ អោយតែប្រទះគឺគេបាញ់រះសម្លាប់ ទាំងអស់ មិនរើសមុខទេ ។

លោកគ្រូពេទ្យនៅស្ងៀមទំនងគិត ។ បន្តិចមក គាត់ក៏យកកូន វិទ្យុមកបើកស្តាប់សាថ្មី ៖

- ល្បងចង់ស្តាប់ពត៌មានពីភ្នំពេញទេ ? (លោកគ្រូពេទ្យបបួលពូ ណាត) មានផ្សាយពត៌មានពីស្រុកទេសយើងអំពីស្ថានការណ៍ថ្មីៗ...

ដោយចង់ដឹង ពូណាតក៏ខិនដាក់ត្រចៀកស្តាប់ពីរនាក់លោកគ្រូ ពេទ្យភ្លាម ។ ពេលនោះ វិទ្យុបានផ្សាយនូវការបញ្ជា អោយអ្នកទី ក្រុងចាកចេញពីភ្នំពេញយ៉ាងអាសន្ន ដោយយកលេសថាយន្តហោះ អាមេរិកាំងនឹងមកទំលាក់គ្រាប់បែកសម្លាប់រង្គាលពេញក្រុងភ្នំពេញ ថ្ងៃនោះហើយ ។ បន្តិចមក ពូណាតក៏សុំអោយលោកគ្រូពេទ្យរាវរក ប៉ុស្តិ៍បាត់ដំបង ស្រាប់តែឮគេផ្សាយប្រាប់អ្នកស្រុកអោយនៅស្ងៀម ស្ងាត់កុំចលាចល ទំនងដូចជាខ្មែរក្រហមយកបាត់ដំបង មិនទាន់ បាននៅឡើយ ។

យប់នោះ លោកគ្រូពេទ្យសំរាន្តមិនលក់សោះ ចេះតែរសាប់ រសល់ មិនដឹងថាត្រូវធ្វើយ៉ាងណាទៀតនៅថ្ងៃស្អែក ។ នៅរវាង ប្រហែលពាក់កណ្តាលអាធ្រាត ស្រាប់តែលាន់សន្ធឹកស្គរជើងមនុស្ស ធ្វើដំណើរគគ្រឹកគគ្រេង និងសន្ធឹកឡានបរលើផ្លូវជាតិយ៉ាងច្រើន មហិមា ។ លោកគ្រូពេទ្យស្ទុះងើបយ៉ាងរហ័ស ស្រាប់តែប្រទះនឹង ពូណាតដែលក្រោកឡើងមកដែរ ។ ភ្លាមនោះ គាត់ក៏ដើបទៅប្រាប់ ស្រីៗខាងលើផ្ទះមិនអោយឆោឡោក្រែងលោមានគ្រោះថ្នាក់ ។

ខណៈនោះ លោកគ្រូពេទ្យសង្កេតឃើញហ្វូងមនុស្សទាំងនោះ សុទ្ធតែជាមនុស្សប្រុសស្លៀកខ្មៅពាក់ខ្មៅប្រដាប់អាវុធពេញខ្លួន ធ្វើ ដំណើរតម្រង់ទៅបាត់ដំបង ។ បន្តិចមក លោកក៏ឮសូរសម្លេង កាំភ្លើងធំលាន់ឡើងឈូឆរ ។ សំណាងល្អដែរដែលពួកគេមិនរវល់ នឹងអ្នកស្រុកដែលរស់នៅរាយប៉ាយតាមវាលស្រែនោះ ។ មើលទៅ ពួកគេហាក់ដូចជាមានមុខសញ្ញាសំដៅទៅបាត់ដំបងអោយបានឆាប់ បំផុត ទើបហាក់ដូចជាមិនរវល់នឹងធ្វើអីអ្នកស្រុកតាមផ្លូវនោះទេ ។ លោកគ្រូពេទ្យទាញក្រមាយកមករុំក្បាល ហើយកេះកូនប្រុសទាំងបី អោយសញ្ញាកុំអោយពួកគេភ្លេចខ្លួន ។ ពួកគាត់នៅសម្ងំស្ងៀមឡើង បែកញើសសស្រាក់ នឹកភិតភ័យក្រែងពួកនោះមកឆែកឆេរខ្ទមពូ ណាត ។ ចៃដន្យ

CHANBOKEO.COM

កងទ័ពអាវខ្មៅគិតតែធ្វើដំណើរទៅមុខគគ្រឹក គគ្រេងតែម្យ៉ាង គ្មាននរណាគេរវីរវល់ខ្វមពួណាតនោះឡើយ ។

ព្រហាមឡើង គេសង្កេតឃើញកងទ័ពខ្មែរក្រហមដើរច្រវាត់ ច្រវ៉ែងតាមដងផ្លូវជាតិផង តាមវាលស្រែអមសងខាងផ្លូវជាតិផង ទំនងដូចជាកំពុងល្បាត មិនអោយនរណាម្នាក់ធ្វើដំណើរតាមផ្លូវជាតិ ឡើយ ។

បីបួនថ្ងៃកន្លងទៅ...

អ្នកគ្រូចរណៃលួចកេះលោកគ្រូពេទ្យខិបសួរ ៖

- បង! មើលទៅស្ថានការណ៍កាន់តែតានតឹងហើយ ។ ពួកខ្មែរ ក្រហមយាមផ្លូវយ៉ាងស្អេកស្កះ តើយើងត្រូវគិតយ៉ាងណាទៅវិញ ? ឯម្ចាស់ផ្ទះនេះក៏ក្រីក្រ... តើគាត់អាចជួយយើងបានប៉ុនណាកាលបើ គ្នាយើងមានគ្នាច្រើននាក់ ហើយសុទ្ធតែជាមនុស្សពេញវ័យ ពេញ បរិភោគយ៉ាងនេះ ? យើងប្រាកដជានឹងដាច់ស្បៀង ឆាប់ៗនេះ មិនខានឡើយ ។

- បងក៏ទាល់គំនិតដែរណាំអូន! ព្រឹកមិញ បងស្តាប់វិទ្យុបាត់ដំបង ឃើញគេផ្សាយថាខ្មែរក្រហមរំដោះយកបាត់ដំបងហើយ... មិនដឹង ថាគេជន្លៀសអ្នកស្រុកដូចដែលគេប្រកាសដេញមនុស្សនៅភ្នំពេញ ដែរឬក៏យ៉ាងណា ? មើលទៅស្ថានការណ៍ដូចជារំជើបរំជួលណាស់! បងគិតថាកងទ័ពខ្មែរក្រហមរៀបជើងព្រួល មិនអោយជនបាក់ទ័ព រត់គេចចូលដីថៃរួចទេ ។ ពេលនេះ ប្រហែលគេពង្រឹងស្ទែងក្របី យាមច្រកឆ្លងដែនអស់ហើយ ។ បើសិនជាយើងនាំគ្នាគេចទៅរកច្រកព្រំដែនគឺមិនខុសពីដើរចូលមាត់ខ្លាទេ ។ យកល្អយើងនៅលាក់ ខ្លួនមួយពេលសិនទៅ ទំរាំយើងរកឃើញមធ្យោបាយថ្មីទៀត ។

ថ្ងៃដដែលនោះ លោកគ្រូពេទ្យបានឃើញមនុស្សម្នាពពាក់ពពូនដើរចុះពីថ្នល់ជាតិសំដៅភូមិអ្នកស្រុក ។ ម្នាក់ៗសុទ្ធតែរែកពុនស្ពាយអូសកូនអូសចៅរញេចរញ៉ៃ ទាំងចាស់ទាំងក្មេង ទាំងពិការជរាឃើញហើយវេទនាភ្នែកណាស់ ។ មានពេលខ្លះ គេឮសូរសម្លេងសង្វើញគម្រាមសម្លុតអ្នកស្រុក លាយជាមួយនឹងស្នូរគ្រាប់កាំភ្លើងដ៏សែនរន្ធត់គួរស្ញើបពោះវៀន ។ លោកគ្រូពេទ្យស្ទុះទៅសួរ ដំណឹងពីអ្នកដំណើរ ទើបដឹងថាមនុស្សម្នានៅក្នុងទីក្រុងបាត់ដំបង ទាំងមូលកំពុងតែរងការជន្លៀសចេញពីក្រុង ដោយការបណ្តេញ របស់ពួកខ្មែរក្រហម ដែលបានវាតអំណាចលើទីក្រុងទាំងមូល ។

CHANBOKEO.COM

កាលដើមឡើយ ភូមិវាលទ្រាជាតំបន់វាលស្រែលាតសន្ធឹងផ្ទៃដី ឆ្ងាយដាច់កន្ទុយភ្នែក ។ រីឯអ្នកស្រុករស់នៅរាយប៉ាយ ឆ្ងាយៗគ្នា តាមស្រែរៀងៗខ្លួន ។ ពេលនេះ វាលស្រែខែប្រាំងដែលនៅសល់ តែដើងជញ្រ្ជាំងស្រូវក្រៀមក្រោះ បានក្លាយជាទីវាលប្រកបដោយហ្វូងអ្នកស្រុកដេករកេតរកូត ។ ខ្លះដួលដេកស្លាប់ដោយអត់ទឹកអត់ អាហារ ។ ខ្លះជាអ្នកជំងឺមិនអាចទ្រាំទ្រនឹងការធ្វើដំណើរជន្លៀសពី ក្រុងបានក៏ដាច់ដង្ហើមតាមផ្លូវ ។ ខ្លះទៀតក៏មានដង្ហើមម្ហូបៗដូចត្រី ក្រាញ់ឡើងគោក... មិនមាននរណាជួយនរណាកើតឡើយ ព្រោះគេ ម្នាក់ៗរត់រកកន្លែងរស់រៀងៗខ្លួន ។ ជួនកាលគេឃើញ ពួកខ្មែរក្រហមលើកកាំភ្លើងបាញ់ផ្តាច់ជីវិតអ្នកស្រុក ដែលមិនព្រមដើរចុះពី ថ្ពល់ជាតិទៅក្នុងដីស្រែ ។ ជួនកាល ទ័ពអាវខ្មៅចាប់អ្នកស្រុកឆែក ឆេរ ហើយក៏សម្លេះជីវិតផ្ទងផាំងកណ្តាលថ្នល់ដោយឥតមេត្តា មិនដឹងថាគេសម្លាប់មនុស្សឥតអាវុធទាំងនោះ ដោយហេតុអ្វីឡើយ ។

សំណាងល្អក្រុមគ្រួសារលោកគ្រូពេទ្យបានគេចខ្លួនបានមុនពីរបី ថ្ងៃ កុំអីមិនដឹងជាត្រូវរងទុក្ខប៉ុនណាទេ ។ ដោយទឹកចិត្តមេត្តាធម៌ របស់ពូណាតនិងមីងថន ក្រុមគ្រួសារលោកគ្រូពេទ្យក៏ស្នាក់នៅ ស្ងៀមស្ងាត់ ឯដីទួលក្នុងខ្ទមតូចនោះបានសុខមួយកំឡុងពេល ។ ប៉ុន្តែ... ពេលវេលាដែលគេមានសេចក្តីសុខជុំគ្នានោះ កាន់តែខើច បន្តិចម្តងៗទៅហើយ មិនខុសអ្វីពីចង្កៀងដែលកំពុងតែអ៊ីវ ជិត អស់ខ្លាញ់ដូច្នោះឯង...

ooooooooooooooooooooooo

ooooooooooooo

o

CHIANBOKEO.COM

# វគ្គទី៣
# បណ្ដាសា

ក្រុងបាត់ដំបង

ខែមិនា ១៩៧៩...

- សល់! ថ្ងៃនេះ យ៉ាងម៉េចហ្នឹង បានជាទទូរភួយមិនព្រមងើប ? នែ៎ ថ្ងៃរះខ្ពស់ណាស់ហើយ ឆាប់ងើបឡើងមកញុំាបបរ ។

មីងណៃយកដៃអង្រួននាយសល់ ស្រាប់តែទទួលអារម្មណ៍ថា សាច់នាយក្ដៅគគុក ។

- យី! ឯងគ្រុនទេតើហ៎ សល់!

មីងណៃលាន់មាត់ផងជ្រួញចិញ្ចើមផង ។ បន្តិចមក គាត់ក៏ដាំទឹកក្ដៅយកជូតខ្លួនអោយនាយសល់ ហើយក៏បែរមកពឹងពូបូរ ៖

- បូរអើយ! នៅមើលនាយសល់និងចៅម៉ុំផង បងឡើងទៅភូមិ អ្នកស្រុកបន្តិច ។

ថាហើយ មីងណៃក៏ស្រវាត្រីប្រឡាក់មួយកូនកញ្ជ្រែង កំពៀក ដើរចេញទៅ ។

- បងណៃទៅណាហ្នឹង ? (ពូបូរសួរ)

- ទៅរកដូរថ្នាំបុរាណមកដាំអោយក្មួយសល់ញុំា ។

មីងណៃឆ្លើយបណ្ដើរដើរឡើងច្រាំងបណ្ដើរ ។ ប្រហែលជាង មួយម៉ោងក្រោយមក មីងក៏ដើរត្រឡប់មករកទូករបស់គាត់វិញ ស្រាប់តែគាត់ប្រទះស្រីក្មេងមួយរូប ទទូរក្រមាដើរចុះពីទូកចម្លង មួយ នៅមិនឆ្ងាយពីទូកលំនៅរបស់គាត់ប៉ុន្មានទេ ។ មីងយើងភ្ញាក់ព្រើតបើកភ្នែកធំៗ ទំលាក់កញ្ចប់ថ្នាំឫសឈើចោល ហើយរត់ផង ស្រែកហៅនាងផង ៖

- កូនម៉ុំ! កូនម៉ុំ!

នារីនោះក៏ងាកបែរមករកមីងណៃ ៖

- ម៉ាក់!

ធិតាឧទានឡើងហើយក៏ស្ទុះរត់មករកមីងណៃ រួចហើយស្រវា អោបគាត់យ៉ាងណែន ។

- ម៉ាក់! កូននឹកម៉ាក់ណាស់ ។

- ម៉ាក់ក៏នឹកកូនដែរណ៎ាកូន ហើយនឹកខ្លាំងណាស់ទៀតផង!

CHANBOKEO.COM

ទាំងពីរនាក់ម្តាយនឹងកូនក៏ស្រវាឱបគ្នាយំសសឹកតែម្តង ដោយសារតែក្តីរលឹកនិងក្តីត្រេកអរដែលគេបានប្រទះឃើញគ្នាវិញសាជាថ្មី បន្ទាប់ពីគេបែកឃ្លាតគ្នាមកជាយូរ... មែនហើយ! ថ្វីបើមីងណៃបានបែកពីកូនស្រីអស់រវាងជាងបីឆ្នាំ ហើយនាងក៏បានធំលូតលាស់ទៅជានារីពេញវ័យមួយរូបក៏ដោយ ក៏មីងនៅចាំមុខកូនស្រីរបស់ គាត់ច្បាស់ណាស់ មិនច្រឡំឡើយ ។

- ម៉ី! សុខសប្បាយទេកូន ?
- មិនសុខ ហើយមិនសប្បាយទេម៉ាក់ ប៉ុន្តែពេលនេះ កូនសប្បាយចិត្តវិញហើយដែលកូនបានជួបម៉ាក់វិញ ។

មីងណៃងើបមុខសម្លឹងមើលកូនសាជាថ្មីទាំងទឹកចិត្តរំជើបរំជួល ក្រៃលែង ។ មែនហើយ! នោះពិតជាបារមីកូនស្រីរបស់គាត់ពិត មែន ។ ឆវីមានវ័យប្រហែល១៨ឆ្នាំប៉ុណ្ណោះ តែមានរូបកាយស្គាំង ស្គមស្លេកស្លាំងហើយតូចស្តើង មិនសមនឹងវ័យរបស់នាងសោះ ឡើយ ។ នោះប្រហែលមកពីនាងមិនបានទទួលជីវជាតិអាហារគ្រប់ គ្រាន់ រួចហើយធ្វើការហួសកម្លាំងរបស់នាងកាលសម័យខ្មែរក្រហម ហើយ ។ មីងណៃថើបកូនដោយក្តីនឹករលឹកនិងស្រឡាញ់ រួចហើយ ក៏ស្រវាកាន់ដៃកូន នាំដើរសំដៅទៅរើសកញ្ចប់ថ្នាំ ដែលគាត់បាន ទម្លាក់ចោលអំបាញ់មិញនោះ ទើបទើបដើរតម្រង់ទៅទូករបស់ គាត់វិញ ។

- សព្វថ្ងៃនេះ ម៉ាក់ស្នាក់នៅឯណាដែរ ? (បារមីសួរ)
- គឺ...ស្នាក់នៅក្នុងទូករបស់ក្មេងប្រុសម្នាក់ ។
- តែម្នាក់ឯងទេ ?
- អត់ទេ! មានចៅមុំនិងពូម្នាក់ទៀត ។

ចាផុតពីមាត់ ពូបូរដើរដឹកដៃនាងមុំចេញពីទូកមក ក៏ប្រទះនឹងមីងណៃកំពុងដឹកដៃកូនស្រីរបស់គាត់ ដើរមកដល់ចំណតទូកដែរ ។ គ្រាន់តែក្រឡេកឃើញពូបូរភ្លាម បារមីក៏បែរមើលមុខម្តាយហើយ សម្តែងទឹកមុខភ្ញាក់ផ្អើល រួចនឹកតែក្នុងចិត្តម្នាក់ឯងថា ៖

- តើពូម្នាក់នេះជានរណា ? ហេតុអ្វីបានជាគាត់មករស់នៅជាមួយ ម្តាយរបស់យើង ? ឬក៏គាត់ជាប្តីថ្មីរបស់ម៉ាក់ ?

CHANBOKEO.COM

ពេលនោះ ស្រាប់តែភាពរីករាយនៅក្នុងចិត្តបានរលាយរូបអស់ ពីបេះដូងបារមីភ្លាម ។ ស្នាមញញឹមនៅលើផ្ទៃមុខរបស់មាណវី ក៏ រសាត់បាត់ទៅព្រមជាមួយគ្នាដែរ ។ ប៉ុន្តែមីងណៃមិនបានចាប់ភ្លឹក ទេ បែរជារត់ទៅលើកពានាងតូចមុំឡើង យកមកហុចឲ្យបារមី ៖

- កូនមុី! នេះចៅមុំ ក្មួយរបស់កូន ។ នាងជាកូនស្រីរបស់បងម៉ៅ ឯងនោះអី ។ មុំ! នេះមីងមុី! សាធុមីងទៅកូន!

នាងតូចមុំលើកដៃសាធុភ្លាម តែបារមីបែរជារលីងរលោងទឹក ភ្នែកហើយឈរទ្រឹងមិនចេញស្តី ថែមទាំងមិនព្រមលើកដៃទទួល យកនាងមុំពីដៃមីងណៃ ម្តាយរបស់នាងទៀតផង ។ ផ្ទុយទៅវិញ បារមីបែរជាស្រដីតបទៅម្តាយរបស់ខ្លួនថា ៖

- មកពីម៉ាក់រស់នៅមានសុភមង្គលសុខដុមរមនាយ៉ាងនេះទេតើហ៎ ទើបបានជា មិនតាមរកកូនៗរបស់ម៉ាក់អ្វីបន្តិចសោះ យ៉ាងនេះ ? ដឹងទេ ថាខ្ញុំតាមរកម៉ាក់លំបាកយ៉ាងណា ប៉ុន្មានខែកន្លងមកនេះ ? ហេតុអ្វីក៏ម៉ាក់មិននឹកនាតាមរកកូនៗសោះអញ្ចឹង ?

ឮសំដីរបស់កូនដូច្នេះ មីងណៃភ្ញាក់ដូចគេចាប់គ្រវែង ៖

- មុី ? ម៉េចបានជាកូននិយាយអ្វីបែបនេះ ? ម៉ាក់ស្រឡាញ់កូន ស្រឡាញ់គ្រប់ៗគ្នាក្នុងគ្រួសារយើង... ហើយម៉ាក់ក៏បានព្យាយាម វិលត្រឡប់ទៅផ្ទះចាស់របស់យើង ក្រែងលោបានដំណឹងពីគ្នា តែ ម៉ាក់ធ្វើ មិនបានសំរេច... ព្រោះកងទ័ព...

មីងណៃស្រដីមិនទាន់ចប់ផង ស្រាប់តែនាយសល់លូនចេញពី យ្លប់ទូកអើតមុខចេញមក ដោយចៃដន្យ ។ គ្រាន់តែក្រឡេកឃើញ មុខរបស់នាយសល់ភ្លាម បារមីភ្ញាក់ស្រឡាំងកាំង បើកភ្នែកធំៗ រួចហើយក៏ឈានថយក្រោយក្រាកៗយ៉ាងលឿន ។ បន្ទាប់មក ឆវីក៏ បែរក្រោយរឹងរត់គេចចេញទៅ ដោយមិនស្រដីអ្វីមួយម៉ាត់សោះ ជាមួយម្តាយតទៅទៀតឡើយ ។

- មុី! ទៅណាហ្នឹងកូន ? មុី... ចាំម្តាយផង... មុី!

មីងណៃដាក់ចៅមុំចុះពីដៃ ហើយរត់តាមពីក្រោយកូនស្រីរបស់ គាត់យ៉ាងលឿន ថែមទាំងស្រែកដង្ហោយហៅនាងទាំងដួងចិត្តអួល អាក់ ។ គួរអនិច្ចាមីងណៃណាស់! បារមីមិនបានអត់ធ្មត់ទប់ចិត្តបែរ ក្រោយមកស្តាប់ពាក្យពន្យល់របស់ម្តាយទេ ។ នាងនៅតែប្រឹងរត់ យ៉ាងលឿនគេចខ្លួនបាត់ទៅ ធ្វើអោយមីងណៃវង្វេងរកលែងឃើញ តែម្តង ។ មីងរត់ចុះរត់ឡើងច្រើនសាតាមច្រកមាត់ស្ទឹង ឡើងរហូត ដល់ភូមិអ្នកស្រុក

CHANBOKEO.COM

តែមិនបានឃើញស្រមោលកូនឡើយ ។ ទឹក ភ្នែករាប់រយតំណក់
ក៏ប្រជៀតគ្នាចេញមកប្រលែងរង្វង់មុខដ៏ស្គម ស្គាំងរបស់មីងយើងភ្លាមមួយរំពេច ។
- កូនម៉ី! តើកូនមានរឿងអ្វីក្នុងជីវិតឬកូន បានជាកូនតក់ស្លុតរន្ធត់
ហើយបញ្ចេញកិរិយាប្លែកៗយ៉ាងនេះ ចំពោះម្ដាយ ? ម៉ី! ម៉ាក់នឹក កូន!
ម៉ាក់ស្រឡាញ់កូនណាស់... វិលវិញណ៎ាកូនណ៎ា ។

មីងណៃរត់ផងយំផង រត់ខ្វៃងជើងដើរសួរអ្នកស្រុកម្ដុំៗនោះតែ មិនបានសំរេចដូចបំណងទេ ។
ទីបំផុត គាត់ក៏ត្រូវសំរេចចិត្តដើរ ត្រឡប់ក្រោយទៅរកទូករបស់គាត់វិញ
ឃើញពូបូរកំពុងបង្កាត់ភ្លើង ដាំថ្នាំឬសឈើឲ្យនាយសល់ ។ ចំណែក នាងតូចម៉ុំអង្គុយយំសសឹក
យំហៅរកជីដូនដែលរត់ចេញ ចោលនាងទៅយ៉ាងអាសន្នក្នុងកិរិយា យ៉ាងចម្លែក
ធ្វើអោយនាងភិតភ័យតក្កមា ។ ថែដន្យ ពេលនោះ មីងណៃបានភ្លេចពីរឿងចៅម៉ុំទៅហើយ ។
គ្រាន់តែត្រឡប់មកដល់ ទូកវិញមិនទាន់ទេ មីងណៃលូកដៃស្រវាអង្រួនដាស់នាយសល់
ទាញដៃអោយនាយក្រោកមកភ្លាម ៖
- សល់ដើបឡើង!.... ឯងប្រាប់មីងមក៏ ថាឯងបានធ្វើអ្វីខ្លះចំពោះ បារមី កូនស្រីរបស់មីង ?...
ឯងធ្វើបាបអ្វីលើនាងខ្លះ ? ប្រាប់មក៏! បើមិនប្រាប់ទេ... មីងនឹងសម្លាប់ឯងហើយ!!

នាយសល់ភ្ញាក់ស្រឡាំងកាំងខំប្រឹងស្ទុះដើបមក ទាំងអារម្មណ៍
ធឹងឆោងនៅឡើយ :
- អត់ទេមីង! សល់សុំស្បថ! សល់មិនដែលបានធ្វើអ្វីនាងទេ
ថែមទាំងមិនដែលស្គាល់នាងទៀតផង!
- ឯងកុំប្រកែក! បើឯងនិងនាងមិនស្គាល់គ្នា ហេតុអ្វីក៏នាងតក់
ស្លុតភិតភ័យពេលនាងឃើញមុខឯងភ្លាម ? ពេលនេះ ឯងត្រូវតែ
ដើបទៅតាមនាងមកសងមីងវិញ... ព្រោះតែរូបឯងទើបកូនម៉ីរត់ ចេញពីមីងទៅ...

នាយសល់ជ្រួញចញ្ចើមដកដង្ហើមធំ ៖
- ខ្ញុំពិតជាមិននឹងមែនណ៎ាមីង! អោយសល់ស្បថដល់ណាក៏ហ៊ាន ដែរ ដើម្បីអោយមីងអស់ចិត្តថា
សល់ពិតជាមិនកុហកមីងទេ ។
- មីងមិនជឿសម្បថទេ ហើយក៏មិនជឿសំដីឯងបន្តិចណាឡើយ ។ ពេលនេះ មីងអោយឯងបីថ្ងៃ
ដើម្បីតាមរកកូនមីងអោយឃើញ ។ បើឯងរកមិនឃើញរូបនាងមកអោយមីងទេ
មីងនឹងលែងនៅទី នេះជាញាតិសន្ដានរបស់ឯងទៅទៀតហើយ ។

CHANBOKEO.COM

មីងណៃស្រដីផង ស្រក់ទឹកភ្នែកផង សំដែងនូវការឈឺចាប់ ពេញដើមទ្រូង ។ ម្យ៉ាងវិញ គាត់បានជួបបុរសម្នាក់ដែលមានភិន ភាគដូចប្ដីរបស់គាត់តែបុរសនោះក៏គេចខ្លួនបាត់ដោយឥតហេតុផល ពេលមីងណៃរត់តាមគាត់រកសួរដំណឹង ។ ថ្ងៃនេះ មីងបានជួបកូន ស្រីវិញហើយ ។ ចៃដន្យ មីងបែរជាធ្វើអោយនាងរបូតបាត់ទៅវិញ ដោយមិនដឹងរឿងថាហេតុអ្វីបានជានាងគេចខ្លួនទៅ ។ ភ្លាមនោះ នាងតូចមុំក៏យំកាន់តែខ្លាំងឡើង ។

- ចៅមុំ ? (មីងណៃលាន់មាត់)

មែនហើយ អាល័យតែខ្វល់រឿងកូន មីងណៃក៏ភ្លេចរឿងចៅ អស់រលីង ។ ឃើញចៅអង្គុយយំធ្វើមុខស្រងូត មីងក៏ស្រវាអោប ចៅបបោសលួងលោម ព្រមទាំងខំប្រឹងលេបទឹកភ្នែករំលត់ក្ដីជ្រួល ច្របល់នៅក្នុងដើមទ្រូងរបស់គាត់ ដើម្បីកុំអោយចៅស្រីភិតភ័យ ។ នៅថ្ងៃដដែលនោះ គ្មាននរណាម្នាក់ឡើយលេបបាយចូលទេ ហើយ ក៏គ្មាននរណាស្រដីសួរនរណាដែរ ។ លុះរសៀលបន្តិច មីងណៃក៏ ចៀនត្រីប្អូនដប់ខ្ទប់ស្លឹកចេកជាមួយបាយកកមួយដុំ រួចហើយដឹកដៃ ចៅមុំចុះពីទូក ។

- បងណៃបំរុងទៅណាហ្នឹង ? (ពូបូរសួរ)
- បងចង់ទៅចុងស្ពានថ្មបន្តិច សួរគេក្រែងលោអាចឆ្លងទៅរកផ្ទះ ចាស់របស់បងបាន ។
- ចុះម៉េចបងចាំបាច់វេចបាយទៅតាមធ្វើអ្វី ?
- វេចទៅក្រែងលោបងបានជួបកូន ជួបប្ដី នោះនឹងមានអ្វីធ្វើគេខ្លះ មិនដែលទទេពេកនោះអី ។

ពូបូរឮដូច្នោះ ក៏នៅស្ងៀម ហើយក៏មិនហ៊ានសុំទៅតាមផង ត្បិតមើលទៅឫកពាររបស់មីងណៃ ហាក់ដូចជាមានទឹកមុខមិនស្លូវ មានអំណោយទានដូចថ្ងៃធម្មតាឡើយ ។ ម្យ៉ាង គាត់ក៏ឃើញនាយ សល់ហាក់ដូចជាទ្រុឌទ្រោមយ៉ាងចម្លែកខុសធម្មតា ហាក់ដូចជា នាយកំពុងតែទទួលជម្ងឺយ៉ាងធ្ងន់មួយ គ្រាន់តែគ្មាននរណាដឹងថា នាយឈឺជំងឺអ្វីឡើយ ម្ល៉ោះហើយពូបូរមិនដាច់ចិត្តដើរចោលក្មេង ប្រុសនោះទេ ។ កាលនៅសម័យនោះ ប្រទេសខ្មែរបានត្រូវរលំ រលាយ ដោយសារការបំផ្លាញរបស់របបខ្មែរក្រហម ។ មន្ទីរពេទ្យ សាលារៀនអ្វីៗ បានត្រូវពួកវាបំផ្លាញខ្ទេចខ្ទីអស់រលីងគ្មានសល់ ឡើយ ។ កាលបើនាយសល់មានជំងឺដូច្នោះ មធ្យោបាយមានតែ ម្យ៉ាង

CHANBOKEO.COM

គឺស្ងោរថ្នាំឬសឈើបរិភោគតែប៉ុណ្ណោះ ។ បើមិនដូច្នោះទេ
គឺត្រូវដេករង់ចាំថ្ងៃចុងក្រោយរបស់ខ្លួន ។

មែនហើយ! ពិតមែនតែអ្នកទាំងបីទើបតែរស់នៅជាសន្តាន
ប្រហែលបានជាងមួយខែ តែម្នាក់ៗហាក់ដូចជាថៃទាំគ្នាទៅវិញទៅ មកដោយទឹកចិត្តសទ្ធា
ដោយមិនគិតថាគេជាសាច់ដទៃនឹងគ្នាឡើយ ប៉ុន្តែអកុសលមីងណៃ វាសីមិនសូវល្អ
ចេះតែជួបឧបសគ្គជីវិតអស់ ជាច្រើនសា ធ្វើអោយគាត់បាក់កម្លាំងចិត្តគួរអោយអាណិតបំផុត ។
ពូបូរសម្លឹងមើលតាមមីងណៃពីក្រោយ ដោយដួងចិត្តរំជើបរំជួល ។ ការពិត
ពូបូរហាក់ដូចជានឹកបារម្ភដល់សុខទុក្ខរបស់មីងណៃយើង ណាស់ ។
ថ្វីបើមីងមិនសូវរវីរវល់អើពើនឹងអារម្មណ៍របស់ពូបូរក៏ ដោយ
ក៏ពូនៅតែឆ្លៀតបង្ហាញទឹកចិត្តរបស់គាត់ចំពោះមីងដោយ ឥតលាក់លៀម ។
កាលបើមីងដើរចេញទៅដោយមិនបែរក្រោយ សោះ
ពូបូរហាក់ដូចជារសាប់រសល់ក្នុងចិត្តរកថាមិនត្រូវ ។

និយាយពីមីងណៃវិញ...

មកដល់ចុងស្ពានថ្មធំ មីងណៃដឹកដៃចៅដើរអែបៗដងស្ទឹង លួចមើលស្ថានការណ៍ ។
ពេលនោះ មីងបានឃើញឡានហ្ស៊ីបមួយ បរមកដល់
ដោយផ្ទុកនាយទាហានវៀតណាមពីរនាក់មកដល់ផង ។
បន្តិចមកគាត់ក៏ឃើញពួកកងទ័ពដែលឈរយាមនៅចុងស្ពានរត់ចុះ មកទទួលស្រូស្រតែម្តង
រួចហើយពួកគេក៏រៀបចំបាយទឹកទទួល ។ ពេលដែលនាយទាហានពីរនាក់នោះទទួលអាហារ
ស្រាប់តែគេដាក់ ភ្នែកមកចំមីងណៃដែលឈររេរាក្រោមដើមកខុបបារាំង ស្រាប់តែ
គេនិយាយមករកមីងភ្លាម ។ ចៃដន្យ មិងមិនចេះស្តាប់ភាសាគេទេ
ទើបឈរអេះអុញកាន់ដៃចៅនៅស្ងៀម ។ រំពេចនេះ មានកូន
ទាហានវៀតណាមម្នាក់ដើរមកជិតមីង ហើយសួរគាត់ជាភាសាខ្មែរ
ប៉ែឡាំថា ៖

- មីងមានការអីដែរ ? ពេលនេះ លោកនាយកំពុងពិសារអាហារ!
មីងមិនត្រូវមកឈរមើលមាត់គាត់ទេ ។

ឮដូច្នោះ មីងក៏ឆ្លើយវិញថា ៖

- មីងមិនបានមកឈរមើលមាត់ទេ តែមីងមានត្រីចៀនយកមកធ្វើ

តែមិនហ៊ានចូលយកទៅអោយ ។

ការពិត មីងមិនបានគ្រោងយកត្រីនោះមកផ្ញើនាយទាហាននោះទេ ។ ចៃដន្យ បើមិនឆ្លើយដូច្នោះ មីងព្រួយខ្លាចពួកទាហានទាំងនោះច្រឡំសង្ស័យថាគាត់មកលួចស៊ើបការណ៍ ។ កាលបើឮមីងណៃ ឆ្លើយដូច្នោះ ពលទោក្នុងម្នាក់នោះ ក៏បែរទៅនិយាយជាភាសាវៀតណាមដាក់នាយទាហានរបស់ខ្លួនដែលកំពុងបរិភោគ ។ ស្រាប់តែនាយទាហានទាំងពីរងក់ក្បាល ។ នាយទោមួយរូបនោះក៏បែរមក រកមីងវិញ ៖

- ឯណាត្រីចៀននោះ ? លោកនាយព្រមទទួលយកពិសារហើយ ។

មីងណៃដើរទៅជិត ស្រាយជាយក្រមាហុចកញ្ចប់បាយនិងត្រី ចៀនទៅអោយនាយទោ ។ ស្រាប់តែនាយទាហានមួយរូបក្នុង ចំណោមពីររូបនោះ និយាយបារាំងដាក់មីងភ្លាម ៖

- មីងចេះបារាំងទេ ?

មីងណៃភ្ញាក់ព្រើត ។ ស្រាប់តែ នាយទាហានសួរទៀតថា ៖

- យើងត្រូវការពេទ្យជំនួយខ្លះៗ មកជួយដៃជើងក្នុងពេទ្យ នៅ ក្នុងមន្ទីរពេទ្យធំ ឯត្រើយម្ខាង ព្រោះមានទាហានរបួសទទួលការ ព្យាបាលនៅទីនោះច្រើនណាស់ ។ យើងមិនមានគ្គីគ្នាគ្រប់គ្រាន់នឹង ជួយថែរក្សាពួកគេទេ ។

មីងណៃក៏ងាកទៅត្រើយម្ខាង នឹកទៅដល់ពេទ្យធំដែលប្ដីរបស់គាត់ធ្លាប់ធ្វើជាដុកទ័រនៅទីនោះ កាលពីមុនសម័យខ្មែរក្រហមកាន់ កាប់ស្រុក ។ គាត់នឹកភ្នកចង់ទៅទីនោះភ្លាមដើម្បីស៊ើបដំណឹងពី ប្ដី ។ ថ្វីបើមីងណៃមិនឆ្លើយអ្វីមួយម៉ាត់ក៏ដោយ ក៏កិរិយារបស់គាត់ បានបង្ហាញថា គាត់អាចស្ដាប់ភាសាបារាំងយល់ ធ្វើឲ្យនាយទាហាននោះចាប់ភ្លឹកតែម្ដង ។

- មើលទៅមីងដូចជាស្ដាប់យើងបាន ។

មីងណៃនៅស្ងៀម ធ្វើរារែកៗ ក្នុងចិត្តចង់សាកចូលខ្លួនទៅបំរើក្នុងពេទ្យ ក្រែងលោបានប្រទះប្ដីនាងវិញ ព្រោះបេះដូងជាគ្រូពេទ្យមិនលែងអីនឹងត្រឡប់មកធ្វើការទីនោះវិញទេ បើគាត់បានត្រឡប់មកស្រុកវិញដោយសុខសប្បាយ ។ ចិត្តមួយទៀត នៅរា រែក ព្រោះមិនទុកចិត្តកងទ័ពបរទេស ដែលកំពុងកាន់អំណាចលើដី ខ្មែរ ។

CHANBOKEO.COM

គាត់ឈរកាន់ដៃចៅនៅស្ងៀមមិនហ៊ានស្តី ។ នាយទាហាន
រូបនោះក៏និយាយបារាំងបន្តទៅទៀតថា ៖
- នែ៎ បើមីងអាច... ជួយរកមនុស្សថែមប្អូនដប់នាក់ទៀតក៏បាន ។
យើងត្រូវការជំនួយពិតមែនណា៎ ។
    មីងណៃនៅតែឈ្ងោកមុខមិនឆ្លើយដដែល ។ រំពេចនោះ មីង
បានឃើញឡានតូយ៉ូតារបស់ពួកទាហានវៀតណាមមួយ ដឹកឥវ៉ាន់ បរមកពីទិសខាងកើត
បំរុងនឹងឆ្លងស្ពានសំដៅទៅត្រើយម្ខាង ។ គ្រាន់តែមកដល់ប៉ុស្តិ៍យាមចុងស្ពាន
រថយន្តនោះក៏បន្ថយល្បឿន រួច ហើយក៏ស៊ីផ្លេទីនៗអោយសញ្ញា ។ ពលទោមួយរូបក៏ស្ទុះទៅលើក
រនាំងឡើង ដើម្បីអោយរថយន្តធ្វើដំណើរទៅមុខ តាមសំរួល ។ស្រាប់តែមីងណៃភ្ញាក់ព្រើត
ត្បិតគាត់បានឃើញបុរសម្នាក់មុខដូចប្តី របស់គាត់បេះដាក់
ស្លៀកពាក់ជាកម្មករនៅអង្គុយទំពីលើឥវ៉ាន់ ខាងក្រោយរថយន្ត ។ បុរសនោះ
ក៏ទំនងជាភ្ញាក់ផ្អើលដែរ ពេល ដែលគាត់ដាក់ភ្នែកមកឃើញមីងណៃឈរកាន់ដៃចៅស្រីនិយាយជា
មួយនាយទាហានវៀតណាម ។ ភ្លាមនោះ រថយន្តក៏បរចេញទៅ
ធ្វើអោយមីងណៃរន្ធត់តក់ស្លុតក្នុងចិត្តសាជាថ្មី ។ គាត់ខំលេបទឹក ភ្នែកចូលទៅក្នុងពោះ
ទ្រាំលាក់អារម្មណ៍មិនអោយពួកទាហានវៀត ណាមចាប់ភ្លឹកឡើយ ។ ពេលនោះ
មីងក៏ដាច់ចិត្តនិយាយបារាំងសួរ
ទៅនាយកោយមួយរូបនោះថា ៖
- តើរថយន្តអំបាញមិញបំរើភូមិភាគខាងណាដែរ ?
    នាយទាហាននោះ ញញឹមឡើង ៖
- មីងចេះបារាំងពិតមែនតើហ៎ ? ឡានអំបាញ់មិញនេះ ដឹកអាហារ
ចូលមន្ទីរពេទ្យធំសំរាប់ផ្គត់ផ្គង់ទាហានរបួស ។
    ឮដូច្នោះ មីងក៏ប្រញាប់ឆ្លើយភ្លាម ៖
- អញ្ចឹង អោយខ្ញុំសុំទៅបំរើនៅក្នុងមន្ទីរពេទ្យនោះបានទេ ?
- បាន! តែមីងមានគ្នាទៀតទេ ? យើងត្រូវការប្អូនដប់នាក់ទៀត
    មីងណៃគ្រវីក្បាល ៖
- មីងមានតែម្នាក់ឯងនិងចៅស្រីនេះប៉ុណ្ណោះ ។

CHANBOKEO.COM

តែនាយទាហាននោះមិនសូញសាញអ្វីដែរ ។ បន្តិចមក នាយទាហាននោះក៏បញ្ជាកូនទាហានម្នាក់ ឲ្យដឹកគាត់ទៅដាក់នៅពេទ្យធំ ភ្លាម ។ នៅទីនោះ មីងណៃត្រូវគេចាត់អោយនៅបោកកំរាលពូក និងខោអាវអ្នករបួស ជាមួយស្ត្រីចាស់ៗចំណាស់មីងណៃបីបួននាក់ ទៀតដែលបានមកធ្វើការទីនោះមុនគាត់ ។ មីងណៃធ្វើការបណ្តើរ លួចគយគន់តាមរកមើលស្រមោលប្តីរបស់គាត់បណ្តើរ ។ ប៉ុន្តែពេញមួយថ្ងៃហើយ គាត់មិនបានជួបមុខសោះ ។ ពេលខ្លះ មីងណៃបន្លំលួចដើរចេញពីបរិវេណបោកខោអាវ កងទាហានដែលអង្គុយ ល្បាតក្នុងពេទ្យនោះចេះតែបក់ដៃហៅគាត់អោយត្រឡប់មកវិញ មិនព្រមអនុញ្ញាត្តិអោយគាត់ដើររហូតរហូតក្នុងនឹមន្ទីរពេទ្យនោះ ឡើយ ។ ទោះជាយ៉ាងណា មីងណៃមិនបោះបង់សេចក្តីសង្ឃឹមរបស់គាត់ទេ ។ គាត់សច្ចាក្នុងចិត្តថាគាត់នឹងតាមរកប្តីរបស់គាត់ឲ្យឃើញ មិនថាគាត់ត្រូវរងក្តីលំបាកយ៉ាងណាឡើយ ។

ព្រលប់បន្តិច មីងណៃក៏ឃើញនាយទាហានម្នាក់ដែលហៅគាត់ មកធ្វើការកាលពីថ្ងៃមិញនោះបររថយន្តមកដល់ ។ មីងក៏រត់ទៅ រកសុំអនុញ្ញាតិទៅផ្ទះ ។ នាយក៏ស្រដីជាបារាំងដាក់គាត់វិញថា ៖

- នៅទីនេះ មានកន្លែងស្នាក់ដែរតើហ៎ ។ មីងមិនចាំបាច់ត្រឡប់ ទៅផ្ទះវិញទេ ។
- ប៉ុន្តែ ខ្ញុំចេញពីផ្ទះមកដោយមិនបានប្រាប់ម្ចាស់ផ្ទះដែលខ្ញុំស្នាក់ នៅសោះ ហើយម្យ៉ាងខ្ញុំក៏ចង់ទៅយកឥវ៉ាន់ផ្ទាល់ខ្លួនរបស់ខ្ញុំមក វិញផង ទើបត្រូវទៅផ្ទះមួយពេលសិន ។

គេក៏អនុញ្ញាតិអោយមីងទៅផ្ទះតាមសម្រួល ។

- អរគុណដែលលោកមានទឹកចិត្តចំពោះខ្ញុំ (មីងណៃពោល)
- មិនអីទេ មីង! ការពិត បានរៀននិយាយបារាំងខ្លះក៏ប្រសើរដែរ ព្រោះតាំងពីខ្ញុំឈប់រៀនមក ខ្ញុំត្រូវជាប់កំណោណ្ឌទាហានរហូត មិន ដែលបានទៅស្រុកជួយម៉ែឪនៅឡើយទេ ជាងពីរឆ្នាំមកហើយ ។ ពេលខ្ញុំឃើញមុខមីង ខ្ញុំក៏នឹកឃើញដល់ម្តាយនិងប្អូនរបស់ខ្ញុំដែលនៅឯវៀតណាម ។

រំពេចនោះ គេក៏ទុចងីក់ ដូរប្រយោគវិញ ៖

- មីងទៅផ្ទះចុះ ហើយស្អែកកុំភ្លេចមកជួយធ្វើការយើងកុំខាន ។

មីងណៃក៏លានាយទាហាននោះ ដើរត្រឡប់សំដៅទៅរកទូក របស់នាយសល់វិញ ។ ពេលគាត់ទៅដល់ ស្រាប់តែឃើញពូបូធ្វើ ទឹកមុខយ៉ាងចម្លែក ៖

CHANBOKEO.COM

- បងណៃ នាយសល់កាន់តែមិនស្រួលខ្លាំងហើយ ។

មីងស៊ុះទៅមើលនាយសល់ ឃើញនាយក្តៅខ្លួនរវើរវាយលែង មានស្មារតីទៅហើយ ។

- នេះយប់បន្តិចហើយ តើយើងធ្វើដូចម្តេចទៅ ?

បន្តិចមក មីងណៃក៏ចែវទូករកទីចតដើម្បីឡើងគោកវិញ ៖

- ប្អូរ! ឆាប់លីនាយសល់ឡើងមក!
- បងចង់នាំគេទៅណា ?
- ទៅពេទ្យធំបាត់ដំបង!
- ក្រែងទីនោះគេដាក់តែទាហានវៀតណាមដែលមានរបួសតើហ៍ ?
- បងទៅរកសុំគេសាកមើល... ក្រែងគេអាណិតជួយនាយសល់ ។

ពូប្អូរគ្មានសង្ឃឹមក្នុងចិត្តទេថា ពេទ្យនឹងចំហទ្វារទទួលនាយ សល់នោះ ។ តែលុះមីងណៃតឿនពេក គាត់ក៏ប្រថុយធ្វើតាមទាំង ទើសទាល់ ។ ចៃដន្យ ទាហានឆ្មាំទ្វារមិនអនុញ្ញាតិដូចពូប្អូរគិតទុក មែន ។

ភ្លាមនោះ ស្រាប់តែនាយឆ្មាំបើកទ្វាររបង អោយរថយន្តមួយ ចេញពីមកពីក្នុងពេទ្យសំដៅទៅក្រៅវិញ ។ មីងណៃក្រឡេកឃើញ ភ្លាម ក៏ស្គាល់ថា ជាឡានដែលប្តីរបស់គាត់ជិះលើនោះ កាលពីថ្ងៃ រសៀលមិញ ។ គាត់ព្រលែងស្រីមុំចោល ស្ទុះរត់តាមយ៉ាងលឿន៖

- បងចិត្រ! បងចិត្រ! ឈប់សិនបង! ចាំណៃផង! បងចិត្រ!

ចៃដន្យ រថយន្តមិនបានឈប់ទេ ។ មីងណៃនៅតែរត់តាម មិនព្រមឈប់ដដែល ។ មីងរត់ផងយំផងទាំងយប់ងងឹត ស្រាប់តែ មានទាហានវៀតណាមឈ្លបពិលចេញមកឃាត់ ៖

- នែ៎ ឆាប់ត្រឡប់ថយក្រោយភ្លាម ។ ទីនេះ គ្មានច្បាប់អនុញ្ញាត្ត អោយមានចរាចរទៅណាមកណាពេលយប់ទេ ដឹងហើយនៅ ?

មីងណៃទុកដឹក់ ។ ថ្វីបើគាត់ស្តាប់មិនយល់ថាទាហានវៀត ណាមនោះនិយាយស្អីក៏ដោយ ក៏គាត់អាចកាត់ស្មានបានថា គេឃាត់ គាត់មិនអោយធ្វើដំណើរទៅមុខទៀត ។ ទីបំផុត គាត់ក៏ត្រូវបង្ខំចិត្ត ត្រឡប់ថយក្រោយវិញ ទាំងដើមទ្រូងមហាសែនអួលណែនគ្មានអ្វី ប្រៀបស្មើបានឡើយ ។

CHANBOKEO.COM

- ឱ! ទេវតាអើយ! ហេតុអ្វីក៏លោកដាក់បណ្តាសាខ្ញុំខ្លាំងម្ល៉េះ ? ហេតុអ្វី...
មនុស្សជាទីស្រឡាញ់របស់ខ្ញុំត្រូវព្រាត់ពីជីវិតខ្ញុំអស់រលីង
គ្មានសល់យ៉ាំងនេះ ?

មីងណៃដើរយំខ្សឹកខ្សួល ត្រឡប់មករកចៅស្រីពូប្អូននិងនាយ សល់វិញ ។ មិនទាន់មកដល់កន្លែងចាស់វិញផង ស្រាប់តែមីង មានអារម្មណ៍ថា ងងិតមុខឈឹង ដកដង្ហើមផុតៗតែម្តង ។ មីង យើងក៏ដួលប្រូសទៅលើដី បាត់ស្មារតី សន្លប់ស្តូកស្តឹង តែម្នាក់ឯង កណ្តាលរាត្រីដ៏សែនងងិតនោះទៅ...

oooooooooooooooooooooo

oooooo

o

CHANBOKEO . COM

# វគ្គទីបួន
# បែកសំបុក

វាលទ្រា ដងផ្លូវជាតិលេខប្រាំ បាត់ដំបង...

ខែឧសភា ១៩៧៥...

ក្រុមគ្រួសាររបស់លោកគ្រូពេទ្យវិចិត្រ បានមករស់នៅលាក់ខ្លួនស្ងាត់ស្ងៀមជាមួយពូណាតនិងមីងថន ចំនួនជាងពីរអាទិត្យហើយ ។ ឯការរស់នៅក៏អត្តខាត់ក្រៃលែង ព្រោះនោះជាលើកទីមួយហើយដែលក្រុមគ្រួសារលោកត្រូវមករស់នៅកន្លែងខ្វះខាតយ៉ាងដូច្នោះ ។ ទោះបីជាពូណាតនិងមីងថនមានចិត្តសទ្ធាយ៉ាងណា ក៏មិនអាចទប់ទល់សេចក្ដីខ្វះខាតរបស់ក្រុមគ្រួសារលោកគ្រូពេទ្យដែរ ។ អង្ករនៅក្នុងធុងក៏កាន់តែស្រកស្រុតទៅ ។ អ្នកគ្រូចរណៃឃើញស្ថានភាពគ្រួសារកាន់តែពិបាកទៅរាល់ថ្ងៃដែរ ។ រីឯលុយកាក់ដែលដាក់មក តាមខ្លួនក៏ចាយលែងបាន អ្នកគ្រូក៏ដាច់ចិត្តដោះខ្សែដៃដែលពាក់ជាប់ខ្លួនយូរឆ្នាំហើយបំរុងយកដូរអង្ករពីអ្នកស្រុកម្ដុំៗនោះ ។ មិនទាន់បានដើរទៅដល់ភូមិអ្នកស្រុកដូរអង្ករបានផង ស្រាប់តែមានពួកទ័ពខ្មែរក្រហមដើរឆ្វាត់ឆ្វែងកោះហៅអ្នកស្រុកឲ្យទៅប្រជុំ ៖

- ពុក! ម៉ែ! មិត្តបង!មិត្តប្អូន! ឆាប់ចេញមកក្រៅទាំងអស់គ្នា ។ អង្គការមានការប្រជុំធំមួយជាមួយបងប្អូន... ត្រូវចាត់តាំងការងារ ធ្វើស្រែបង្កេបង្កើនផល ។ បើនរណាលួចលាក់ខ្លួននៅពួនក្នុងផ្ទះ មិនព្រមទៅប្រជុំ នឹងចាត់ទុកជាខ្មាំងប្រឆាំងនឹងអង្គការ...

លោកគ្រូពេទ្យនិងអ្នកគ្រូចរណៃសម្លឹងមុខគ្នា កាលបើពួកពួកកង ទាហានយោធារបស់ខ្មែរក្រហមដើរស្រែកខ្ញើយៗ យ៉ាងគួរខ្លាច ។ ភ្លាមនោះ អ្នកគ្រូមានប្រសាសន៍ឡើងថា ៖

- បងចិត្រ! ពេលនេះ មិនដឹងថា អង្គការថ្មីមានគម្រោងការយ៉ាង ណា បើគេបណ្តេញមនុស្សចេញពីទីក្រុងអោយមករស់នៅតាមស្រុក ស្រែជនបទ ដោយមិនអាចយកអ្វីមកតាមខ្លួនបាន... មនុស្សទាំង ឡាយរស់នៅតាមវាលស្រែ ក្រោមដើមឈើ អត់បាយក្រហាយទឹក ទាំងអ្នកឈឺ អ្នកពិការ ជនជរា ឬសូម្បីកុមារតូចក៏អង្គការមិនយោគ យល់ឡើយ... មិនដឹងថា ជីវិតរបស់អ្នកស្រុកនឹងរស់យ៉ាងណាទេ កាល បើពលរដ្ឋទាំងអស់គ្មានអ្វីជាប់ខ្លួនបន្តិចសោះនោះ ?

- មែនហើយ ពលរដ្ឋទាំងអស់បានក្លាយជាជនពនេចរឥតទីពំនាក់ គ្មានលទ្ធភាពនឹងធ្វើអ្វីបានទេ ក្រៅតែពីស្តាប់អង្គការតែម្យ៉ាងគត់ ។ នេះពួកយើងសំណាងហើយ ដែលចេះបានមកជួបល្បងណាតនិង ប្រពន្ធដែលជាមនុស្សមានទឹកចិត្ត កុំអីមិនដឹងជាយើងវេទនាយ៉ាង ណាទេ អូនណៃ ។

- តែ... យើងក៏មិនដឹងដែរ ថាយើងមានសំណាងគួរច្រេះរហូតទៅឬ យ៉ាងណា... ។ អូនដូចជាមានប្រផ្នូលចម្លែកណាស់ ពេលឃើញពួក យោធាខ្មែរក្រហមដើរកោះហៅអ្នកស្រុកមកប្រជុំគ្រប់គ្នា មិនអោយ សល់ម្នាក់ ហើយបើនរណាមិនចេញមក នឹងចាត់ទុកជាខ្មាំងរបស់ អង្គការ ។ មើលទៅ ស្ថានការណ៍កាន់តែចង្អៀត ហើយធ្ងន់ធ្ងរខ្លាំង ទៀតផង ។

ភ្លាមនោះ លោកគ្រូពេទ្យលូកចាប់ដៃភរិយា ប្រាប់ថា ៖

- មិនថាស្រុកទេសប្រែប្រួលយ៉ាងណាទេ សុំអោយតែគ្រួសារយើង បានរស់នៅជួបជុំគ្នា នោះជីវិតបងមានសេចក្តីសុខបំផុតហើយ ។

- អូនក៏បន់ស្រន់ដូច្នោះដែរបង ។

អ្នកទាំងពីរក៏ញញឹមបំព្រងឡើង ដើម្បីផ្តល់កម្លាំងចិត្តចំពោះគ្នា ទៅវិញទៅមក ។ កូនៗរបស់លោកបានដើរសំដៅទីប្រជុំមុនលោក អស់ហើយ នៅសល់តែលោកទាំងពីរទេដែលដើរតាមក្រោយ ។

កំពុងតែនិយាយគ្នាភ្លេចខ្លួន ស្រាប់តែ... ខ្ទាប់ៗ !

- អ៊ុំយ!

CHANBOKEO.COM

លោកគ្រូពេទ្យខទានឡើង ហើយក៏ងាកបែរមើលទៅមនុស្ស
ដែលយកខ្សែតីមកវាយលោកពីក្រោយខ្នង ដោយឥតហេតុផល ។ ពេលនោះ
លោកក៏ប្រទះឃើញក្មេងប្រុសអាយុប្រមាណ១៤-១៥ឆ្នាំ ស្លៀកពាក់ជាយោធាខ្មែរក្រហម
កំពុងឈរខមក្អែកក្រហម មករក លោក ដោយមានកាន់ទាំងរំពាត់ខ្សែតីនៅដៃម្ខាង ហើយកំពៀក
កាំភ្លើងមួយដើម នៅដៃម្ខាងទៀត ។

- មានរឿងអីហ្នឹង បានជាវាយពូយ៉ាងនេះ ?(លោកគ្រូពេទ្យសួរ)
- នែ៎ មិត្តពូ! នឹងខ្លួនថាកំពុងប្រព្រឹត្តខុសសីលធម៌ទេ ? ដើរ បណ្តើរ
ប៉ះដៃប៉ះជើងមនុស្សស្រីបណ្តើរ! ត្រូវពីររំពាត់ប៉ុននេះ តិចផង! (យុវជននោះឆ្លើយ)

លោកគ្រូពេទ្យភ្ញាក់ព្រើត ត្បិតមិននឹកស្មានថា ច្បាប់អង្គការ
ខ្មែរក្រហមអោយក្មេងមានសិទ្ធិត្រួតចាស់ ហើយអាចវាយធ្វើបាប ចាស់ដល់ម្លឹង ?
គ្រាន់តែកាន់ដៃប្រពន្ធក៏ខុសច្បាប់ រហូតដល់ត្រូវ រំពាត់ខ្សែតីផង ?
នឹកទៅគួរអោយខ្លាចរអារពួកគេដល់សូរហើយ ។
តើពួកគេមានវិបត្តិក្នុងជីវិតយ៉ាងណាខ្លះ រហូតដល់មិនមានទឹកចិត្ត
មនុស្សធម៌ចំពោះមនុស្សដូចគ្នា ? ឬសូម្បីតែការបង្ហាញភាពស្និទ្ធ
ស្នាលនិងសេចក្តីស្រឡាញ់ចំពោះប្រពន្ធកូន ក៏ខុសសីលធម៌ដែរ ?

លោកគ្រូពេទ្យមិនតមាត់អ្វីទៅពួកក្មេងយោធានោះទេ ព្រោះ
នឹកគិតដល់សុវត្ថិភាពរបស់លោកផ្ទាល់ ។ បន្ទាប់មក លោកក៏ដើរ
ឈ្ងោកមុខរហូតទៅដល់កន្លែងប្រជុំឯកណ្តាលវាលស្រែដ៏សែនល្វឹង ល្វើយមួយ ។ នៅទីនោះ
មានក្រុមយោធាខ្មែរក្រហមសន្ធឹកសន្ធាប់ រាប់មិនអស់ មកឈរចាត់ចែង
បង្គាប់អ្នកភូមិអ្នកស្រុកឲ្យអង្គុយ ដោយឡែកៗ ប្រុសតាមប្រុស ស្រីតាមស្រី ក្មេងតាមក្មេង ចាស់
តាមចាស់ ជរាតាមជរា ។ ជួនកាលពួកយោធាទាំងនោះបាញ់ កាំភ្លើងផ្ទួងផ្ទាំង
សម្លាប់មនុស្សចោលស្រស់ៗ នៅចំពោះមុខក្រុម គ្រួសារ ដោយឥតធម៌មេត្តា
ដើម្បីសម្លុតស្មារតីអ្នកស្រុកអ្នកភូមិទាំង
ឡាយនោះមិនឲ្យប្រកែកតវ៉ាអ្វីនឹងបញ្ជារបស់អង្គការឡើយ ។

ក្រុមគ្រួសារលោកគ្រូពេទ្យក៏ត្រូវអង្គការបំបែកអោយបែកខ្ញែក ទីទៃៗ គ្រប់គ្នា ។
លោកគ្រូពេទ្យនិងបុរីជាកូនប្រសារស្ថិតនៅក្នុង **កងចល័តបុរស** ។
ចិត្រាត្រូវអង្គការចាត់អោយទៅនៅក្នុង **កង ចល័តយុវជនដាច់ខាត** ។ ចំណែកបារមី

CHANBOKEO.COM

ចូល**កងចល័តនារីដាច់ ខាត** ។ រីឯវិសាលវិញត្រូវអង្គការដកហូតពីឪពុកម្តាយចូលទៅក្នុង **កងអង្គភាពកុមារឈានមុខ** ។ ស្រីម៉ៅមានកូនខ្ចី បានត្រូវទទួល **កិច្ចការ**ជាអ្នកស្រិតអង្ករប្រចាំសហករណ៍ ។ សូម្បីមីងថនងងិត ភ្នែកនោះ ក៏អង្គការចាត់អោយធ្វើការជាអ្នកជួយមើលកូនង៉ារបស់ ស្រីម៉ៅដែរ ។ ថ្ងៃនោះ អង្គការបានចាត់អោយអ្នកគ្រូណែជាអ្នក កាប់ដើមទន្រ្ទានខែត្រ ចិញ្ច្រាំលាយអាចមន៍គោធ្វើជីរ ដាក់ដំណាំក្នុង ចំការ ។ នៅរសៀលថ្ងៃដដែល អង្គការបានបញ្ជាអោយសមាជិក កងចល័ត ទាំងយុវជន ទាំងនារី ទាំងកងកុមារឈានមុខអោយ ត្រឡប់ ទៅរៀបចំឥវ៉ាន់ ដើម្បីចេញដំណើរទាំងប្រញាប់ប្រញាល់ ដោយមិនមានទុកពេលអោយពួកគេមានឱកាសបានលាក្រុមគ្រួសារ តាមសម្រួលឡើយ ។

ថ្ងៃនោះ គ្មាននរណាម្នាក់មានអារម្មណ៍ល្អឡើយ សូម្បីពូណាតក៏ ត្រូវទៅចាប់គោរបស់គាត់យកឲ្យអង្គការដែរ ត្បិតគាត់ត្រូវអង្គការ តម្រូវឲ្យធ្វើជាអ្នករែកទឹកដាក់ កាស៊ីនបាយ (ជាពាក្យខ្មែរក្រហម មានន័យថារោងបាយ) ប្រចាំកងមួយក្នុងភូមិ ដូច្នេះមិនអាចរក្សា គោពីរនឹមរបស់គាត់ជាកម្មសិទ្ធិផ្ទាល់បានទៀតឡើយ ។ ពូណាតមិន អាចទុកបាន សូម្បីតែរទេះនង្គ័លនិងរនាស់រាស់ដីសំរាប់ធ្វើចំការ របស់គាត់ ។ ពេលនោះ អ្វីដែលជាសម្បត្តិទ្រព្យរបស់អ្នកស្រុកបាន ត្រូវអង្គការរិបអូសយកគ្មានសល់ ។ គេអាចទុកបានត្រឹមតែខោអាវ ពីរបន្លាស់ម្នាក់និងសាក់កាដូមួយ (សំពៀតសំរាប់ដាក់ខោអាវ) ។ ក្រៅពីនោះ អ្វីៗក៏ក្លាយជាសម្បត្តិរបស់អង្គការទាំងអស់ រួមទាំង ដំណាំកំប៉ិកំប៉ុកកៀនផ្ទះ សំបុកមាន់ទា ឬស្រូវជង្រុកទាំងមូល...

នៅខាងក្នុងខ្ទមរបស់ពូណាត...

អ្នកគ្រូចរណៃស្រវាអោបកូនទាំងបី យំខ្សឹកខ្សួល ស្ទើរតែគាំង បេះដូងស្លាប់ទាំងកណ្តាលថ្ងៃ កាលបើកូនទាំងបីត្រូវអង្គការបំបែក យកចេញទៅយ៉ាងទាន់ហន់ដូច្នេះ ។ លោកដុកទ័រវិចិត្រអង្គុយ ក្បែរនោះ ធ្វើមុខខ្មៅប៉ែនិយាយមិនចេញ ។ បន្តិចមក លោកក៏ យកដៃអង្អែលខ្នងភរិយាបន្ថើរៗដើម្បីលួងលោមចិត្ត រួចហើយក៏ មានប្រសាសន៍ថា ៖

- ទប់ចិត្តខ្លះទៅអូន! យើងមានពេលតិចណាស់ គួរតែយើងយក ពេលនេះជូនពរកូនៗរបស់យើង មុនពេលគេចេញដំណើរវិញ!

ឮប្រសាសន៍របស់លោកគ្រូពេទ្យដូច្នោះ អ្នកគ្រូក៏លើកដៃផ្តិត

CHANBOKEO.COM

ទឹកភ្នែកចេញពីរង្វង់ភ្នែក ហើយក៏ស្រវារលាក់មាសពេជ្រពីកាបូប
មកបែងចែកឲ្យកូនៗរបស់គាត់មួយចំណែកម្នាក់ ៖
- ណេះ! យកដាក់តាមខ្លួនខ្លះទៅកូន សំរាប់ដោះទាល់ ពេលណា កូនមានការខ្វះខាត ។
យ៉ាងណាៗ សូមកូនផ្តល់ដំណឹងអោយម៉ាក់ ប៉ាបាននឹងផង ។ ពេលនេះ
ម៉ាក់ប៉ាមិនមានលទ្ធភាពអាចតាមថៃ រក្សាកូនបានទៀតទេ ។
កូនត្រូវតែពឹងលើសតិប្រាជ្ញស្មារតីរបស់ កូនផ្ទាល់ហើយ
ដើម្បីរក្សាខ្លួនឲ្យល្អ...ហើយសុខសប្បាយ ។ បើ មានឱកាស
សូមកូនត្រឡប់មកអោយម៉ាក់ប៉ាបានឃើញមុខកូនម្តង មួយយាមផងណា!
ម៉ាក់ប៉ារង់ចាំជួបកូនដោយក្តីស្រឡាញ់ហើយ ក្តីនឹកបារម្ភចំពោះកូនជានិច្ច ។

មានប្រសាសន៍ចប់ អ្នកគ្រូស្រវាអោបកូនទាំងបីថើបដោយដួង ចិត្តរន្ធត់ញាប់ញ័រឥតឧបមា ។
ថ្វីបើអ្នកគ្រូប្រឹងលេបទឹកភ្នែកមិន ឲ្យស្រក់មកលើផ្ទៃមុខយ៉ាងណា ក៏មិនអាចទប់បានឡើយ ។
សូរ សំនៀងខ្សឹកខ្សួលក៏ផ្លាយចេញមកយ៉ាងអណោចអធម្ម ធ្វើឲ្យគ្រប់ៗ គ្នាទប់ចិត្តលែងបាន
ក៏ស្រក់ទឹកភ្នែកតាមឡើងទាំងអស់គ្នា ។

តើនរណាម្នាក់ទៅ ដែលមិនតក់ស្លុត មិនរន្ធត់ មិនស្រក់ទឹក ភ្នែក
កាលបើកូនប្រុសកូនស្រីរបស់ខ្លួនត្រូវគេកាត់ផ្តាច់យកចេញពី
ក្រុមគ្រួសារទៅទាំងរស់ៗដោយទាន់ហន់ឆក់កញ្ឆៀតយ៉ាងនេះ ? ជាពិសេស
ពេលកូនរបស់គេជាក្មេងមិនទាន់ពេញវ័យផងនោះ
តើអ្នកជាឪពុកម្តាយមានអារម្មណ៍ក្តុកក្តួលយ៉ាងណា... រួចហើយ តើ
ឪពុកម្តាយណាមួយទៅហ៊ានប្រកែកនឹងបញ្ជាអង្គការទៅ បើអង្គការ បាញ់សម្លាប់មនុស្ស
យ៉ាងផុយៗ ដោយមិនញញើតដៃ នៅនឹង ភ្នែកស្រស់ៗដូចដែលគេបានឃើញរួចមកហើយ ?
មិនថាជននោះ មានវ័យប៉ុនណាឡើយ អោយតែហ៊ានជំទាស់នឹងបញ្ជារបស់អង្គការ
នោះគេនឹងទទួលលទ្ធផលយ៉ាងជាក់ស្តែង ភ្លាមៗតែម្តង ។
- បើសិននៅមានថ្ងៃស្អែក... ប៉ាសង្ឃឹមថា យើងនឹងបានជួបជុំគ្នា វិញជាមិនខាន ។
កុំលះបង់ក្តីសង្ឃឹម កុំលះបង់ការព្យាយាមតស៊ូ
កុំភ្លេចនូវសេចក្តីស្រឡាញ់ដែលយើងមានចំពោះគ្នា...!! កត្តាទាំង អស់នេះ
នឹងជាកម្លាំងជួយអោយកូនហែលឆ្លងឧបសគ្គបានដោយ ជោគជ័យមិនខាន ។

CHANBOKEO.COM

លោកគ្រូពេទ្យមានប្រសាសន៍ប្រាប់កូន ទាំងទឹកភ្នែករលីង រលោង ។ អ្នកគ្រូចរណៃក៏ពោលបន្តថា ៖

- ចាំអោយច្បាស់ណាកូន! ពេលនេះ គ្មាននរណាស្រឡាញ់កូន ថែរក្សារូបកូនអោយមានសេចក្តីសុខ ជាជាងរូបកូនផ្ទាល់នោះឡើយ ។ ដូច្នេះ សូមកូនប្រើសតិនិងប្រាជ្ញាអោយបានដល់ទីបំផុត ដើម្បីរក្សា ជីវិតកូនអោយស្ថិតនៅក្នុងសុវត្ថិភាព ប្រាសចាកនូវភយន្តរាយទាំង ពួងណាកូន ។ បើសិននៅតែមានថ្ងៃស្អែក... ម៉ាក់សង្ឃឹមថា ម៉ាក់នឹងបានជួបកូនម៉ាក់គ្រប់ៗគ្នាវិញមិនខាន ហើយយើងនឹងបានរស់នៅជួបជុំគ្នាយ៉ាងសុខដុមរមនាសាជាថ្មីម្តងទៀត ។

ពេលនោះ កូនរបស់អ្នកគ្រូម្នាក់ៗ មានអារម្មណ៍ក្តុកក្តួលរន្ធត់ និយាយមិនចេញសោះ ត្បិតគេមិនទាន់ដឹងថា អង្គការនឹងនាំពួកគេ ចេញពីភូមិទៅទិសខាងណាឡើយ ។ គ្រប់គ្នាបានត្រឹមតែឈ្ងោកមុខ ស្រវាអោបម្តាយ សំពះឪពុកជាចុងក្រោយ ហើយសម្រក់ទឹកភ្នែកតែម្យ៉ាងប៉ុណ្ណោះ ។

មួយសន្ទុះធំក្រោយមក អ្នកគ្រូចរណៃនិងលោកគ្រូពេទ្យ ក៏ដើរ ជូនកូនទាំងបីសំដៅទៅកន្លែងដែលអង្គការណាត់អោយពួកគេទៅ បង្ហាញខ្លួន ។ ការពិត ចិត្រា បារមី និងវិសាលទើបតែមានដំណើរ ចាកចេញពីក្រុមគ្រួសារ ជាលើកដំបូងបង្អស់ក្នុងជីវិតរបស់គេ ។ តាំងពីតូចក្រូចឆ្មារមក គេស្គាល់តែសេចក្តីសុខនិងភាពកក់ក្តៅក្នុង គ្រួសារយ៉ាងរមនា ។ ពេលនេះ បេះដូងរបស់គេទទួលនូវភាពឈឺ ចាប់ឥតឧបមា ដែលសុខៗ គេក៏ត្រូវឃ្លៀបអង្គការបង្ខំអោយគេ ដើរចេញពីក្រុមគ្រួសារជាទីស្រឡាញ់យ៉ាងទន់ហាន់រហូតដល់ពួកគេ គ្មានឱកាសត្រៀមចិត្តទទួលការផ្លាស់ប្តូរនោះបានឡើយ ។

ម្នាក់ៗដើរឈ្ងោកមុខស្ងៀមស្ងាត់ ។ លុះគេដើរជិតដល់វាល ស្រែទីណាត់អោយយុវជននិងកុមារមកជួបយោធាតំណាងអង្គការ ស្រាប់តែវិសាលហើយបែររត់ទៅអោបម្តាយឪពុកឧទានថា ៖

- ប៉ាម៉ាក់! កូនមិនចង់ទៅទេ... កូនចង់នៅជាមួយប៉ាម៉ាក់វិញ!

អ្នកគ្រូស្រវាអោបកូនទាំងបេះដូងរន្ធត់ ។ សម្លេងខ្សឹកខ្សួលរបស់កូនមានអនុភាពមិនខុសពីកាំបិតដ៏ស្រួចមកចាក់ឆ្កៀលបេះដូងរបស់អ្នកគ្រូអោយចុកចាប់ខ្ទេចខ្ទាំ... ស្រាប់តែ ៖

- នែ៎ មិត្តនេះ! យំស្អីហ្នឹង ?

CHANBOKEO.COM

យោធាខ្មែរក្រហមជំទង់មួយរូបឃើញវិសាលយំ ក៏ដើរមកក្បែរ ហើយស្រវាចាប់កអាវវិសាលអូសចេញពីម្តាយ ហើយចាប់នាយ ច្រានទៅដីព្រួស រួចគំហកថា ៖

- ម៉េចចង់ជំទាស់នឹងបញ្ជាអង្គការផងហ្អែស ? បើចង់ងាប់ យំ អោយឮជាងនេះបន្តិចទៅ នឹងអាលយើងបញ្ជូនមិត្តឯងអោយឆាប់ ទៅរកកន្លែងសំរាក ដោយមិនបាច់ពិបាកចេញដើរទៅណាមកណា បំរើអង្គការទៀតផង ! !

ថាហើយ យោធានោះក៏យកគ្រាកាំភ្លើងវាយក្បាលវិសាលផស បែកថ្ងាសជាំមួយរំពេច ។

- វិសាល !

អ្នកគ្រូចរណៃស្រែកភ្ញាត់សម្លេង កាលបើឃើញពួកគេធ្វើបាប វិសាល ។ ស្រាប់តែយោធាជំទង់លើកកាំភ្លើងភ្ជង់ដើមទ្រូងអ្នកគ្រូ យ៉ាងរហ័ស ៖

- យ៉ាងម៉េច ? ឈឺតែម្នាក់មិនចង់... ចង់ឈឺពីរនាក់មែនទេ ? បើ ចង់អញ្ចឹងមែន ស្រែកយំអោយឮបន្តិច !

ថាហើយ នាយក៏យកចុងកាំភ្លើង ចុចដើមទ្រូងរបស់អ្នកគ្រូ ទំនងចង់បាញ់អ្នកគ្រូចោល ជាមួយកូនប្រុសនៅទីនោះតែម្តង ។ ឃើញស្ថានការណ៍ធ្ងន់ធ្ងរ លោកដុកទ័រវិចិត្រស្ទុះឃាត់ ៖

- ណៃ... នៅស្ងៀមសិនទៅ...

លោកគ្រូពេទ្យទាញដៃភរិយាអោយថយចេញ រួចហើយក៏មាន ប្រសាសន៍បន្តថា ៖

- ឲ្យពូសូមទោសជំនួសមីងខាងនេះផងក្មួយ ! មីងនេះមានជំងឺ សតិ និយាយអ្វីគិតអ្វីមិនឆ្លាតឆ្លុំទេ ទើបស្តាប់បញ្ជារបស់ក្មួយមិន បាន ។ ចាំពូនាំគាត់ត្រឡប់ទៅវិញ ដើម្បីកុំអោយរំខានកិច្ចការរបស់ក្មួយ ។ ចូរក្មួយនាំពួកគេទាំងនេះចេញទៅចុះ ។

ថាហើយ គាត់ក៏អូសដៃអ្នកគ្រូថយក្រោយយ៉ាងលឿន ទាំងដួង ចិត្តរន្ធត់ញាប់ញ័រ ដោយមិនបាននៅឃើញមុខកូនជាចុងក្រោយ មុនពេលគេបែកពីលោកទៅ ត្បិតលោកបារម្ភក្រែងលោយោធា ជំទង់នោះទប់ចិត្តមិនបាន នឹងបាញ់សម្លាប់ទាំងអស់គ្នា ។ វិសាល យកដៃខ្ទប់របួសនៅលើថ្ងាសរបស់ខ្លួន ឯភ្នែកសម្លឹងតាមឪពុក ដែលអូសដៃម្តាយរបស់ខ្លួនចេញទៅ... ក្នុងបេះដូងរបស់គេ ពោរ ពេញទៅដោយការឈឺចាប់ ភិតភ័យ ហើយក៏ខឹងក្រេវក្រោធនឹង ពួកយោធា ដែលដាច់ធម៌មេត្តាចំពោះរូបគេ ។ គេអាលោះអាល័យ ម្តាយឪពុករបស់គេណាស់ ប៉ុន្តែគេមិនអាចសម្តែងមនោសញ្ចេតនា អ្វីចេញមកក្រៅបានឡើយ... ពុំនោះសោត ចុងកាំភ្លើងវាមិនយោគ យល់មុខនាយឡើយ ។

CHANBOKEO.COM

កុមារយើងប្រឹងលេបទឹកភ្នែក និងក្តីសោកា ចូលទៅក្នុងពោះវិញយ៉ាងលំបាកបំផុត ។ ភ្លាមនោះ យោធាម្នាក់ នោះយកជើងទាត់វិសាល ផ្កាប់មុខភីងហើយស្រែកថា ៖

- នែ៎ងើបឡើង! កុំទំរន់មើលតែកូនង៉ាអញ្ចឹងវ៉ើយ!

យើញវិសាលប្រឹងត្រដរក្រោកមកវិញ បារមីនិងចិត្រាដែល ឈរស្ងៀមម្តុំៗនោះយូរហើយ ក៏ស្ទុះមកជួយលើកប្អូនឡើង ។ ស្រាប់តែនាយយោធាក្មេងនោះគំហកឡើងថា ៖

- វ៉ើយ! អាណាគេ ប្រើពួកឯងឲ្យជួយវាខាងនេះ ? តិច...!

យោធានោះទាញកាំភ្លើងគាស់កែក្រាកៗ ។ បារមីនិងចិត្រាទុច ង៉ក់ ដកដៃភ្លាម ទុកអោយវិសាលងើបឡើងដោយខ្លួនឯងទាំងយ៉ាប់ ត្រដេរត្រដរ ។ មែនហើយ! កាលបើត្រូវមួយគ្រាកាំភ្លើងយ៉ាងធ្ងន់ វិសាលបែកអំពិលអំពែក ធឹងធោងនិយាយមិនត្រូវ ។ ពេលនោះ គេនឹកទៅដល់ការថ្នាក់ថ្នមដែលគេធ្លាប់បានទទួលពីម៉ាក់ប៉ា...បើសិន ជាស្រុកទេសមិនក្រឡាប់ផ្កាប់ផ្ងារ ម្ល៉េះគេប្រហែលជាមិនបានមក ជួបសេចក្តីវេទនាយ៉ាងនូច្នេះឡើយ ។ បន្តិចមក វិសាលក៏ងើបដើរ បានដោយខ្លួនឯង ហើយប្រឹងជំហរដើរទ្រេតទ្រោតរហូតដល់វាល ស្រែដែលអង្គការបានណាត់អោយកុមារមកជួបជុំ ។ មួយស្របក់ ក្រោយមកទៀត វិសាល បារមី និងចិត្រាក៏ត្រូវបំបែកជួរ ដើរ ចេញតាមក្បួនរបស់ពួកយោធា ដែលនាំពួកគេទៅតាមទិសទីទៃៗ រៀងៗខ្លួន បាត់រូបពីវាលស្រែម្តុំនោះអស់រលីងទៅ...

នៅក្រោយគុម្ពោតអំពិលទឹកមួយគុម្ព លោកគ្រូពេទ្យអង្គុយ លាក់ខ្លួន ខ្ទប់មាត់ភរិយាមិនអោយសម្លេងយំខ្សឹកខ្សួលបានឮទៅ ដល់ត្រចៀកពួកយោធាខ្មែរក្រហម រួចតាមលួចមើលគ្រប់កាយវិការ របស់កូនទាំងបីជាចុងក្រោយ នៅមុនពេលក្រុមយោធានាំពួកគេ ចេញដំណើរទៅ ។

- សូមព្រះជួយតាមថែរក្សាកូនអោយសុខសប្បាយជានិច្ច!

លោកគ្រូជូនពរកូនប្រុសស្រីតែក្នុងចិត្តស្ងាត់ៗ ។ អ្នកគ្រូចរណៃ ក៏ទ្រោបលើស្មាស្វាមីយំខ្សឹកខ្សួលដោយក្តីស្រណោះអាល័យ ចំពោះកូនទាំងបីដែលធ្វើដំណើរចេញទៅ...

- រំសាយចិត្តទៅអូនណៃ... អូនត្រូវតែពង្រឹងស្មារតី ញញឹមនាំ ជោគសេរីមង្គលជូនដំណើរកូនយើងណា៎..! (លោកគ្រូពេទ្យស្រដី ផង អង្អែលខ្នងភរិយាថ្នមៗ លួងលោមចិត្តផង)

CHANBOKEO.COM

- ប៉ុន្តែ... បងចិត្រអើយ តើអោយអូនញញឹមម្តេចនឹងចេញទៅ
កាលបើយើងឃើញកូនត្រូវគេវាយធ្វើបាបនឹងភ្នែក តែយើងបែរជា
គ្មានលទ្ធភាពអ្វីអាចជួយគេបានបន្តិចសោះ...
- ណៃអើយ! ធ្វើម៉េចបើស្ថានការណ៍កៀបសង្កត់ជីវិតរបស់យើង
រហូតដល់យើងគ្មានលទ្ធភាពនឹងធ្វើអ្វីបានទៅហើយ មានតែរំងាប់ ចិត្ត
ហើយបន់ស្រន់ទេវតាអោយលោកតាមថែរក្សាពួកគេតែម្យ៉ាង ប៉ុណ្ណោះ ។ តាំងចិត្ត
តាំងស្មារតីឡើងអូន! កុំតក់ស្លុតរហូតបាត់សតិ អីណា... បើសិននៅមានថ្ងៃស្អែក...
បងសង្ឃឹមថាយើងនឹងបានជួប
កូនប្រុសកូនស្រីទាំងអស់របស់យើងមកវិញមិនខាន...!

ឃើញស្វាមីខំពោលលើកកម្លាំងចិត្តដូច្នោះ អ្នកគ្រូក៏ខំអត់ធ្មត់
យកដៃជូតទឹកភ្នែកចេញហើយក៏លើកដៃបួងសួងឡើង ៖
- សូមអោយកូនម្តាយគ្រប់ៗគ្នាប្រទះតែសេចក្តីសុខសប្បាយហើយ
ឆាប់បានវិលមកជួបម៉ាក់ប៉ាវិញដោយសុវត្ថិភាពណាកូនណា!!

មួយស្របក់ក្រោយមក លោកគ្រូពេទ្យក៏នាំភរិយាដើរត្រឡប់
មកខ្ទមពួណាតវិញ ស្រាប់តែប្រទះនឹងប៉ុរីឈរទេរាចាំនៅមុខផ្ទះ
សំដែងទឹកមុខរន្ធត់តក់ស្លុតយ៉ាងចម្លែក ។
- មានការអ្វី ប៉ុរី កូន? (លោកគ្រូពេទ្យសួរ)
- អំបាញ់មិញ មានក្រុមពួកយោធាដើរមកកត់ឈ្មោះ ឲ្យបុរសៗ
ទាំងអស់នៅក្នុងភូមិរៀបឥវាន់ចេញដំណើរព្រឹកស្អែកនេះជាចាំបាច់
វៀរលែងតែបុរសចាស់ៗបួនដប់នាក់ទេ ដែលអាចនៅធ្វើការក្នុង ភូមិបន្តទៅទៀតបាន
ដូចជាអ៊ីណាតជាដើម ។

លោកគ្រូពេទ្យធ្លាក់ថ្លើមក្តុក ភ្ញាក់ស្រឡាំងកាំងដូចធ្លាក់ពីលើ មេឃដូច្នោះឯង ។ រាត្រីនោះ
ស្រីម៉ៅអង្គុយបីកូនទ្រាបក្បាលលើ ស្មាប៉ុរីជាស្វាមី
យំសសឹកខ្សឹកខ្សួលអួលក្នុងដើមទ្រូងដោយការទ្រាំ ទប់ចិត្តមិនបាន
ដែលប៉ុរីនឹងត្រូវចេញដំណើរវេលាព្រឹកស្អែកនេះ ។ រីអ្នកគ្រូចរណៃវិញក៏មិនខុសគ្នាប៉ុន្មានឡើយ
ទំនងដូចជាយ៉ាប់ជាង ទៀតផង ត្បិតអ្នកគ្រូទើបតែព្រាត់កូនបីនាក់ថ្មីៗនេះឯង ។ ពេល នេះ

CHANBOKEO.COM

សមាជិកពិសេសពីរនាក់ទៀតក្នុងគ្រួសារ កំពុងមានដំណើរ
ឃ្លាតចេញពីជីវិតរបស់អ្នកគ្រូទៀតហើយ...

នៅរវាងពាក់អាធ្រាត លោកគ្រូពេទ្យឡើងស្លៀកខ្មៅពាក់ខ្មៅ
ហើយដើបដាស់ប្រពន្ធកូនទាំងយប់ងងឹត ៖

- ណែ! ស្រីម៉ៅ! ប៊ុរីដើបឡើង (លោកស្រដីខ្សិបៗ)
- បងមានគំរោងការណ៍អ្វីមែនទេ? (អ្នកគ្រូចរណៃសួរខ្សិបៗ)
- មែនហើយ! បងគិតថា ពួកខ្មែរក្រហមកំពុងតែបំបែកកម្លាំង របស់ពួកអ្នកស្រុក
កុំអោយពួកយើងមានឱកាសដើបតដៃបាន ។ ពួកយោធាអង្គការបំបែកក្រុមគ្រួសារ
អោយរស់នៅបែកខ្ញែកគ្នា យ៉ាងនេះ មានន័យថា គេកំពុងតែបំបាក់ស្មារតី និងកម្លាំងចិត្តរបស់
យើងហើយ កុំអោយយើងនៅសល់ភាពក្លាហាននឹងដើបតដៃគេវិញ
បាន ។ ដូច្នេះ ពួកខ្មែរក្រហមនោះនឹងក្លាយជាអ្នកឈ្នះរៀងរហូត!
- ហើយចុះពេលនេះ លោកប៉ាមានគំរោងអ្វីដែរទៅ? (ប៊ុរីសួរ)
- ប៉ាមិនចង់ធ្វើកញ្ជះជនពាលទេ ។ ពួកនេះសាហាវព្រៃផ្សៃគ្មាន មនុស្សធម៌ក្នុងខ្លួនអ្វីសោះ ។
ពីរអាទិត្យកន្លងមក ពួកវាមិនបាន ធ្វើអ្វីអោយអ្នកស្រុកមានការរំភើបសោមនស្ស
នឹងការរំដោះរបស់ អង្គការអ្វីបន្តិចឡើយ ក្រៅតែពីធ្វើអោយអ្នកស្រុកតក់ស្លុតរន្ធត់
ដោយភាពព្រៃផ្សៃយង់ឃ្នងរបស់យោធាអង្គការតែប៉ុណ្ណោះ ។ ប៉ា គិតថា...
នឹងបបួលប៊ុរីរត់គេចខ្លួនមួយរយៈពេលប្រសើរជាង ។

អ្នកគ្រូចរណៃឮដូច្នោះក៏ស្រដីទាំងភ្ញាក់ផ្អើលថា ៖

- បងចង់នាំកូនរត់គេចទៅខាងណាវិញ?
- ពេលនេះពួកខ្មែរក្រហមចូលក្រុង ឯពួកយើងគិតរត់ទៅព្រៃវិញ
- គ្មានអាវុធ គ្មានក្រុម គ្មានបណ្តាញអ្វីសោះយ៉ាងនេះ តើបងនឹង រស់យ៉ាងណាទៅ?
- អោយតែមានជីវិត បងនឹងប្រើសតិប្រាជ្ញាជាផ្លូវ...សង្ឃឹមថាជីវិត របស់បងពេលនោះ
គង់មានភាពប្រសើរជាជាងលូនក្បាលក្រាប យល់ព្រមទទួលកំណោណ្ឌរបស់ពួកខ្មែរក្រហម
ហើយដើរចេញពី ក្រុមគ្រួសារយ៉ាងងាយៗដូច្នេះទៅដែរ ព្រោះហោចណាស់ បងរស់
នៅមានជីវិតដ៏សេរី មិននៅផឹកទឹកក្រោមក្លៀកពួកវារួចហើយរង់ចាំ
ថ្ងៃស្លាប់តែម្យ៉ាងនោះឡើយ ។ ប៊ុរី! កូនព្រមទៅតាមប៉ាទេ?

ប៊ុរីបែរទៅមើលស្រីម៉ៅនិងកូន បន្តិចមកក៏ឆ្លើយថា ៖

CHANBOKEO.COM

- កូននៅក្មេងជាងប៉ា គួរតែមានសេចក្តីក្លាហានជាងលោកប៉ាដែរ!
បើលោកប៉ាមានសតិស្មារតីរឹងប៉ឹងដល់ម្លឹង កូនមិនខ្លាច មិនរាថយ នឹងដើរតាមលោកប៉ាទេ ។
យើញកូនឆ្លើយដូច្នោះ លោកគ្រូពេទ្យក៏ញញឹមឡើង ។ គួរឲ្យ
ចម្លែកណាស់... ពេលនោះ អ្នកគ្រូចរណៃបែរជាស្ងួតទឹកភ្នែកអស់
រលីង ថ្វីបើដឹងថា លោកគ្រូពេទ្យបំរុងនឹងចេញដំណើរក្នុងពេល បន្តិចទៀតនេះទៅហើយក្តី ។
ភ្លាមនោះ អ្នកគ្រូស្រដីសួរថា ៖
- បងមានដំណើរចេញទៅខាងណាដែរ ពេលនេះ ?
- មិនទាន់ដឹងទេ... ប្រហែលចេញទៅក្រោមជំនៀរទន្លេសាប...
- អូហ៍... ម៉េចបានបងចេញខាងហ្នឹងវិញ ?
- ព្រោះខ្មែរក្រហមប្រហែលជារៀបជើងព្រួលទប់ស្កាត់ផ្លូវទល់ដែន
ខាងលិចមិនអោយអ្នកប្រឆាំងរត់រួចឡើយ ។ ដូច្នេះ បើយើងដើរ
ឆ្ពោះទៅទិសខាងលិចច្បាស់ជាជាប់អន្ទាក់ពួកវាមិនខាន ។
- បើសិនមានឱកាស សូមបងផ្តល់ដំណឹងអោយអូនដឹងផងណា៎!
- បាទ! តាមដែលបងអាចធ្វើបាន ។ អូនណៃក៏ដូចគ្នាដែរ ។ សូម អូនថែខ្លួន
ថែកូននិងចៅយើងអោយសុខសប្បាយ ។ យើងគ្រាន់ តែបែកគ្នាមួយពេលទេ ។
បើសិនថ្ងៃស្អែកនៅមាន យើងនឹងជួប គ្នាវិញមិនខាន...
កុំលះបង់ក្តីសង្ឃឹមអោយសោះណា៎អូន!!
មានប្រសាសន៍ចប់ លោកគ្រូពេទ្យក៏ស្រវាអោបភរិយាយ៉ាង ណែនជាការលាគ្នាជាចុងក្រោយ ។
ចំណែកប៊ុរីវិញ ក៏លើកកូនបី ថែថើបឡើងអស់ចិត្តទើបហុចទៅអោយស្រីម៉ៅវិញ ៖
- មើលកូនផងណា៎អូន ហើយរក្សាខ្លួនអោយល្អ... បងពិតជាវិល ត្រឡប់មកវិញរកអូនមិនខាន
នៅថ្ងៃណាមួយ... ចាំបងណា៎អូន!!
ប៊ុរីក៏ស្រវាអោបភរិយាថើបដោយក្តីស្រឡាញ់ផង ដោយដួងចិត្ត អួលអាក់ផង
ដែលគេត្រូវបែកពីនាងទៅដោយនាងកំពុងតែមាន កូនខ្ចីផង ។ ប៉ុន្តែ តើអោយគេធ្វើដូចម្តេចទៅ
បើគេមិនរត់គេចខ្លួន ទៅទេ ក៏គង់អង្គការចាប់បញ្ជូនរូបគេអោយចេញទៅឆ្ងាយដដែល
ជាងដែល... ស្រីម៉ៅដាក់មុខចុះ ស្រដីអ្វីមិនរួចមួយម៉ាត់ឡើយ បានត្រឹមតែស្រក់ទឹកភ្នែកម្យ៉ាងគត់
ដើម្បីរំសាយចិត្តព្រួយបារម្ភ ។
បន្តិចមក អ្នកទាំងពីរក៏ដើរលបៗគេចទៅទាំងយប់ងងឹត...

CHANBOKEO.COM

នៅក្នុងខ្ទមកញ្ជាស់របស់ពូណាត ស្រីម៉ៅនិងម្ដាយ អង្គុយអោប ផ្ដល់កម្លាំងចិត្តចំពោះគ្នាទៅវិញទៅមក ត្បិតអ្នកទាំងពីរគ្មានឱកាស នឹងជូនដំណើរបុគ្គលជាទីស្រឡាញ់របស់គេបានឡើយ សូម្បីពូណាត និងមីងថនក៏ទប់ចិត្តថាមិនរន្ធត់ចិត្តមិនបានឡើយ កាលបើឃើញ ក្រុមគ្រួសាររបស់អ្នកគ្រូត្រូវបែកគ្នាយ៉ាងតក្កហល ។

ព្រហាមស្វាងពន្លឺ....

អ្នកគ្រូចរណៃដើបស្ទៀកពាក់ខោអាវចាស់ៗបំរុងនាំស្រីម៉ៅដើរ ទៅកន្លែងដែលអង្គការណាត់អោយជួបជុំគ្នាធ្វើការ ស្រាប់តែមាន ពួកយោធាបីបួននាក់ជិះកង់មកដល់ ។ មានម្នាក់ស្រែកសួរមកថា ៖

- មិត្តមីងអើយ ! មិត្តពូនៅផ្ទះនេះទៅណាអស់ហើយ មិនឃើញ ចេញទៅកត់ឈ្មោះធ្វើដំណើរដូចដែលអង្គការលើបានណាត់សោះ ។ តើពេលនេះ គាត់ទៅណាអស់ហើយ ?

ភ្លាមនោះ អ្នកគ្រូយើងបុកពោះក្ដុកៗតែម្ដង តែខំប្រឹងលាក់ ភាពតក់ស្លុតនៅក្នុងពោះ ហើយត្រដរប្រឹងឆ្លើយវិញថា ៖

- អូហ៍ ទីនេះមានតែមនុស្សប្រុសចាស់ម្នាក់ ដែលទទួលនាទីជា អ្នកវែកទឹក ក្រៅពីនោះសុទ្ធតែស្រីៗទេ ក្មួយអើយ !

ស្រាប់តែយោធានោះបើកភ្នែកក្រឡោតឡើង ៖

- កុហក ! ម្សិលមិញកងឈ្លបយោធាបានដើរកត់ឈ្មោះ ឃើញ មានមនុស្សប្រុសបីនាក់នៅផ្ទះនេះ ម៉េចក៏នៅសល់តែម្នាក់អីចឹង ? មិត្តមីងឯងកុំវៀនកុហកអោយសោះ ប្រយត្ន័ងាប់ !

អ្នកគ្រូក្ដី ស្រីម៉ៅក្ដី ឬសូម្បីតែមីងថន និងពូណាត ក៏នឹកភ័យ ជ្រួលក្នុងពោះដែរ ដែលខំប្រឹងកុហកទាំងមុខស្មើធេង ។

- ក្មួយអើយ ! តើអោយមីងប្រាប់ថាយ៉ាងណាបើយើងពិតជាគ្មាន មនុស្សប្រុសនៅទីនេះប្រាកដមែន (អ្នកគ្រូទទូច)

ប៉ុន្តែ នាយយោធានោះមិនសុខចិត្តទេ ។ គេមានមុខកាចណាស់ មើលទៅដូចជាចង់ស៊ីសាច់អ្នកគ្រូយើងទាំងរស់អញ្ជឹង ។ ភ្លាមនោះ គេក៏បញ្ជាកងសមាជិករបស់ខ្លួនភ្លាម ៖

CHANBOKEO.COM

- មិត្តទាំងបីឡើងឆែកផ្ទះកញ្ជាស់មួយនេះភ្លាម ។ បើមានខោអាវ មនុស្សប្រុសចម្លែក ឆាប់យកចេញមក!

ពួកនោះទម្លាក់កង់ចោលព្រួស ឡើងលើខ្ទមឆែកយ៉ាងរហ័ស ។ អ្នកទាំងអស់គ្នានៅលើខ្ទមធ្វើមុខស្វាយល្អូកទាំងអស់គ្នា ត្បិតនឹកភើតពោះដោយឃើញពួកនោះឡើងឆែកផ្ទះ ។ ក្រោយពីកកាយ អស់មួយស្របក់មក ពួកនោះក៏ចេញមកវិញ ៖

- អត់ឃើញមានអីទេ មិត្តបង! (ពួកនោះរាយការណ៍)

- អឺ! អោយវាអញ្ចឹងទៅចុះ!

នាយកងយោធារូបនោះលាន់មាត់ ទំនងហាក់ដូចខកចិត្តណាស់ ដែលចាប់កំហុសអ្នកផ្ទះមួយនោះមិនបាន ។ គេក៏ជ្រួញចិញ្ចើមបែរ មកសួរកូនចៅម្តងទៀត ៖

- មិត្តមួយណាដែលដើរកត់ត្រាចំនួនបុរសតាមផ្ទះ ពីម្សិលមិញ ?

- គឺខ្ញុំខាងនេះ! (នាយម្នាក់ក្នុងចំណោមបីនាក់នោះឆ្លើយ)

- ហើយមិត្តឯងបានប្រទះមនុស្សប្រុសប៉ុន្មាននាក់នៅផ្ទះនេះ ?

- ជួបតែម្នាក់ទេ តែគេបានប្រាប់ថាមានបីនាក់ ។

- ហើយចាំមុខគេទេ ថាមនុស្សដែលមិត្តឯងចុះឈ្មោះនោះមុខមាត់ យ៉ាងម៉េច ?

- បាទ!... គឺ មិនចាំទេមិត្តបង! គ្រាន់តែចាំថាបានកត់ឈ្មោះបាន បីនាក់ប៉ុណ្ណោះ ។

ផូង! នាយកងយោធាទាញកាំភ្លើងគាស់កៃបាញ់កូនកងយោធា របស់ខ្លួនម្នាក់នោះប្រកាច់ស្លាប់នៅនឹងឆ្អក់ខ្យល់មួយរំពេច ។ នាយ កងនោះស្រដីបន្ថែមថា ៖

- ធ្វើការខ្ជីខ្ជាយ៉ាងនេះ ទុកក៏មិនចំណេញ ដកចេញក៏មិនខាតដែរ!

ថាចប់នាយយោធានោះឡើងជិះកង់ចេញទៅ ។ ចំណែកប៉ុន្មាន នាក់ទៀតក៏ឡើងជិះកង់ចេញតាមក្រោយទៅដែរ ដោយមិនខ្វល់ នឹងយកភ្នែកមើលសាកសពមិត្តរបស់ខ្លួន ដែលដួលដេកស្លាប់នៅ ក្នុងទីធ្លាមុខផ្ទះរបស់ពូណាតឡើយ ។ អ្នកគ្រូចរណៃនិងស្រីម៉ៅតក់ ស្លុតក្នុងចិត្តណាស់ កាលបើប្រទះហេតុការណ៍យ៉ាងសាហាវយង់ ឃ្នងដូច្នោះ ។ ភ្លាមនោះ អ្នកគ្រូក៏បែរមកសួរពូណាតថា ៖

- បងណាតយកខោអាវរបស់ប្ដីនិងកូនរបស់ខ្ញុំទៅលាក់ឯណា បាន ជាពួកវារកមិនឃើញដូច្នេះ ?

CHANBOKEO.COM

ពូណាតក៏ងើបមុខឆ្លើយវិញថា ៖

- មិនបានយកទៅលាក់ឯណាទេ គឺយកទៅដូរអង្ករម្ង៉ៃមួយៗ អស់ ទៅហើយ នៅសល់ពីរបីបន្លាស់នោះ ខ្ញុំបានបុកម៉ាឃ្លឿជ្រលក់ អោយវាខ្មៅទុកគ្រាន់ពាក់ទៅធ្វើការ... ឥឡូវខ្ញុំកំពុងដាក់ហាលនៅ ស្នូឬស្សី កៀនផ្ទះយើងខាងនោះ ។

អ្នកគ្រូបែរភ្នែកមើលទៅតាមដៃដែលពូណាតចង្អុល ក៏ឃើញខោអាវខ្មៅពីរបីដាក់ហាលនៅទីនោះមែន ក៏លាន់មាត់ថា ៖

- អរគុណបងណាតណាស់! បើកុំតែបានបង ម្ល៉េះសម ពួកខ្ញុំ វេទនាធំហើយពេលនេះ ។

- វាជារឿងថែងន្យទេ មីអូនអើយ! ការពិត បងមិនបានគិតវែងឆ្ងាយដល់ម្លឹងឡើយ ។ នោះប្រហែលជារាសីនាងទាំងពីរនៅខ្ពស់ ហើយទើបទេវតាលោកបង្វែរផ្លូវគ្រោះអោយទៅជាបែបនេះ ។

ថាហើយ ពូណាតក៏លីចបទៅកាប់រណ្ដៅកប់សពយោធាមួយរូបនោះបាត់ទៅ ។ ទ្រាំមើលនឹងភ្នែកមិនបាន អ្នកគ្រូក៏ចេញទៅជួយគាត់ដែររហូតដល់ចប់ចុងចប់ដើម ។

ចាប់តាំងពីថ្ងៃនោះមក អ្នកគ្រូក៏រស់នៅស្ងៀមស្ងាត់ជាមួយស្រីម៉ៅនិងចៅស្រីព្រមទាំងក្រុមគ្រួសារពូណាតមីងថន ហើយក៏លែងបានឮដំណឹងអ្វីទាំងអស់ពីប្ដីនឹងកូនគ្រប់ៗគ្នា ។ អ្នកគ្រូណៃបានប្រែ ទៅជាមីងណៃយ៉ាងសាមញ្ញដោយគ្មាននរណាម្នាក់ដឹងប្រវត្តិសោះ ឡើយ ។ ថ្វីបើគ្រានោះមីងមានសេចក្ដីនឹករលឹកយ៉ាងធំធេងចំពោះ កូននិងប្ដីយ៉ាងណា ក៏ដោយក៏មីងមិនអាចបញ្ចេញអារម្មណ៍បង្ហាញ មកក្រៅបានឡើយ ។ អ្នកស្រុកជាច្រើនបានបាត់បង់ជីវិតជាបន្តៗ ដោយការសម្លាប់យ៉ាងរង្គាលដែលជាស្នាដៃរបស់ពួកយោធាខ្មែរ ក្រហម ព្រោះតែអ្នកស្រុកទាំងនោះមិនអាចគ្រប់គ្រងអារម្មណ៍របស់ ខ្លួនបាន នៅពេលដែលអង្គការពង្រាត់ប្ដីពង្រាត់កូនជាទីស្រឡាញ់ របស់គេទៅ ។ ខ្លះទៀតជាអតិតបញ្ញវ័ន្តឬមន្ត្រីរដ្ឋការលួចលាក់ខ្លួន តែត្រូវអង្គការស៊ើបដឹងហើយក៏ត្រូវគេចាប់អូសយកទៅវាយ សម្លាប់ចោលឲ្យស្លាប់ហាលវាល ហើមពេញវាលស្រែគ្មានដីកប់ ។ ខ្លះទៀតក៏ឈឺស្លាប់ដោយសារដាច់បាយ ដោយសារធ្វើការហួស កម្លាំង ឬក៏ដោយសារមានជំងឺតែគ្មានពេទ្យ គ្មានថ្នាំព្យាបាល ។ អនិច្ចា

CHANBOKEO.COM

ជីវិតអ្នកស្រុកទាំងឡាយនោះណាស់! ពេលនោះ អ្នកស្រុក ណាក៏ដូចជាអ្នកស្រុកណាដែរ
គឺគេបានត្រឹមតែដង្ហោយហៅតែ សង្ខារ
និងការយាងប្រោសរបស់ព្រះពីស្ថានលើតែម្យ៉ាងប៉ុណ្ណោះ...

*oooooooooooooooooooooo*

*oooooo*

*o*

CHANBOKEO . COM

# វគ្គទី៥
# បេះដូងរហែក

*ក្រុងបាត់ដំបង ដងស្ទឹងសង្កែ*

*ខែមិនា ១៩៧៩...*

នាយសល់ដេកស្តូកស្តឹងអោបដៃនៅលើក្តារទូកកំប្រុនៗ មិន ដើប មិនបើកភ្នែក មិននិយាយអ្វីពីរថ្ងៃហើយ ។ កាលពីព្រលប់ ម្សិលមិញ ពូប្ញូរនៅអង្គុយចាំផ្លូវមីងណៃយូរពេកមិនឃើញត្រឡប់ មកវិញ ក៏ដាច់ចិត្តលីនាយសល់ត្រឡប់មករកទូកវិញ ដោយមាន នាងតូចមុំរត់យំតាមពីក្រោយផង ដែលនាងតូចបានបាត់រូបជីដូន ទៅដោយមិនដឹងហេតុផល ។ ពេញមួយយប់ នាងតូចយំរកយាយ មិនឈប់ឡើយ តែមីងណៃនៅតែបាត់ស្រមោលសូន្យ មិនឃើញ គាត់វិលមកវិញសោះ ។ ព្រឹកនេះ ពូប្ញូរនឹកមិនអស់ចិត្តសោះ ក៏ដាច់ចិត្តហៅនាងតូចមកផ្តាំ ថា ៖

- ស្រីមុំ! ចៅកុំទៅណាចោលពូសល់ ឮហើយនៅ ? នេះបាយ និងសាច់ត្រីចៀន បើឃ្លានចៅញ៉ាំទៅណ៎! ហើយកុំចេញទៅលេង នៅខាងក្រៅប្រយត្ន័ធ្លាក់ទឹក ឮហើយនៅចៅតូច ?
- ចា៎ស តា! (នាងតូចងក់ក្បាល)
- តាចេញទៅរកថ្នាំអោយពូសល់ ហើយទៅតាមរកយាយរបស់ចៅ ផង ។ បន្តិចទៀត តាមកវិញហើយ ។ កុំដើរទៅណ៎អោយសោះ ណាចៅណ៎!
- ចា៎ស!

ពូប្ញូរយកដៃអង្អែលក្បាលនាងតូច ហើយក៏ស្រវ៉ាទាញមួយស្លឹក ត្នោតមកពាក់ ដើរឡើងច្រាំងចេញទៅ ដោយមានដាក់អង្ករ និង កំទេចមាសដែលសន្សំបានពីការដោះដូរត្រីនោះ

CHANBOKEO.COM

យកទៅជាមួយ បំរុងនឹងយកទៅឌូរថ្នាំអោយនាយសល់ ។ គ្រាន់តែពូបួរចេញទៅ បានបន្តិច នាងតូចក៏ងើបភ្លែតដើរចេញពីទូកមកឈរនៅខាងក្រៅ បែរឆ្វេងបែរស្តាំហើយក៏យំវ៉ាឡើង ៖

- យាយ! យាយអើយ...! (នាងមុំយំហៅជីដូន)

ប៉ុន្តែយាយណៃនៅតែមិនឃើញមកដដែល ។ នាងតូចបែរក្រោយឃើញនាយសល់គេងស្ដូកស្ដឹង ក៏នឹកភ័យយ៉ាងណាមិនដឹង ស្រាប់តែដើរស្ទួស្ទានរកចេញពីទូកទៅរកច្រាំង ។ ចៃដន្យ នាងនៅ តូចណាស់ មិនអាចទប់ខ្លួនបានក៏រអិលជើងធ្លាក់ទឹកប្រូង សមនឹង មិនទាន់ចេះហែលទឹកផង ក៏បម្រះប្រូងៗបែកទឹកខ្វាយ ឈ្លក់ទឹក តែម្នាក់ឯងគួរអោយវេទនា ។ រំពេចនោះ ស្រាប់តែមានបុរស ចំណាស់មួយមាឌស្គមខ្ពស់ ហក់មកពីត្រង់ណាមិនដឹង រត់ចុះទឹកមក ជួយស្រង់កុមារីឡើងមកលើគោកយ៉ាងរហ័ស ។

- ចៅស្រីមិនអីទេ ?

បុរសនោះសួរនាងតូចផង ដោះក្រមាពីករបស់គាត់មកជូតខ្លួន អោយកុមារីផង ។ នាងតូចឈ្លក់ទឹកក្អកខេះៗមួយស្របក់ ក៏ងើប មុខឡើងសម្លឹងបុរសនោះ រួចស្រាប់តែនាងស្រដីថា :

- មុំចង់បានយាយ! មុំចង់បានយាយមកវិញ...

នាងតូចស្រដីផងយំផងគួរអោយអាណិត ។ បុរសនោះក៏ឡើង អង្គុយគែមទូក ហើយស្រវាចាប់នាងតូចមកអោយអង្គុយលើភ្លៅ របស់គាត់ ៖

- ឈប់យំទៅចៅ! បន្តិចទៀត យាយមករកចៅវិញហើយ!

តែនាងតូចយំសសឹកមិនព្រមបាត់សោះ ។ បុរសនោះក៏នៅ ស្ងៀម ព្រោះនឹករកពាក្យអ្វីមកនិយាយជាមួយនាងតូចទៀតមិនបាន ថែមទៀត ។ នាងតូចយំសសឹកមួយស្របក់ ស្រាប់តែទុចដឹក់ឈប់ យំឈឹងតែម្ដង កាលបើនាងក្រឡេកឃើញបុរសនោះអង្គុយសម្រក់ ទឹកភ្នែកតាមនាងដែរ ។ ស្រីមុំបើកភ្នែកធំៗ សម្លឹងមុខបុរស ចំណាស់ ដែលមានរូបរាងស្គាំងស្គមនោះ យ៉ាងពិនិត្យពិច័យ ទំនង ដូចជានឹកឆ្ងល់ក្នុងចិត្ត ថាតើគាត់ជានរណាគេ ?

- តា...! តាយំធ្វើអ្វី ?

CHANBOKEO.COM

នាងតូចសួរ ។ បុរសនោះភ្ញាក់ព្រើតដែលគាត់បានស្រក់ទឹក ភ្នែកមកដោយមិនដឹងខ្លួន ។ គាត់ក៏យកដៃជូតទឹកភ្នែកពីរង្វង់មុខដ៏ ជ្រីវជ្រួញរបស់គាត់យ៉ាងរហ័ស ហើយក៏ខំញញឹមបន្លប់នាងតូច រួច មានប្រសាសន៍ឡើងថា ៖

- គឺតា... កំពុងយំអាណិតចៅនោះអី! នែ៎ះ ចៅឃ្លានបាយហើយ ឬនៅ ? បើឃ្លាន ចាំតាបញ្ចុកណា៎!

នាងតូចងក់ក្បាល សម្លឹងមុខបុរសចំណាស់ម្តងទៀត ។ មែន ហើយ! ពិតមែនតែគាត់ស្គាំងស្គម មុខជ្រួញៗ មានដុះពុកមាត់ ប្រុយៗលើកមុខ មិនគួរអោយល្អមើលអ្វីបន្តិចសោះ ចំណែកសក់ វិញ សផងខ្មៅផងលាយគ្នា តែមើលទៅគាត់ហាក់ដូចជាស្លូតបូត ហើយសម្តែងឥរិយាបថហាក់ដូចជាស្រឡាញ់នាងតូចណាស់ ។ នាង តូចហារមាត់ទទួលបាយដែលបុរសចំណាស់ដួសបញ្ចុកបណ្តើរ លួច មើលមុខគាត់បណ្តើរ ។ មួយស្របក់ នាងតូចសួរគាត់ថា ៖

- តាឈ្មោះអី ?

បុរសនោះភ្ញាក់ព្រើតដែលនាងតូចចេះនឹកសួរឈ្មោះគាត់ ។

- តាឈ្មោះ...តាសុខ
- តាសុខ ? ម៉ុំអត់ដែលឮ...
- មកពីតាមិនដែលបានមកលេងចៅនោះអី ។ ពេលនេះ ចៅចង់ ទៅលេងផ្ទះរបស់តាម្តងទេ ?
- ចា៎ស! ផ្ទះតានៅណា៎ ?
- នៅឆ្ងាយ... បើចៅចង់ទៅ ចាំតានាំទៅលេង ?
- នៅផ្ទះតា មានយាយណៃទេ ?

តាសុខភ្ញាក់ព្រើតកាលបើចៅស្រីតូចនេះចេះស្រដីសួរសព្វបែប យ៉ាងនេះ ។

- ហើយបើអត់មានយាយណៃ ចៅទៅលេងផ្ទះតាទេ ?

តាសុខសួរ ។ នាងតូចឮហើយគ្រវីក្បាល ៖

- អត់ទេ! ម៉ុំចង់បានយាយណៃ ។
- ពេលនេះ យាយរបស់ចៅមិននៅ ចៅនៅលេងជាមួយតាសិន ទៅណា៎!

មានប្រសាសន៍ចប់ គាត់ក៏លើកពនាងតូចដើរឡើងច្រាំងចេញ ទៅ ស្រាប់តែនាងតូចយំរ៉ាឡើង ៖

CHANBOKEO.COM

- អត់ទេ! មុំមិនទៅទេ... មុំចង់បានយាយ... មុំចង់បានយាយវិញ

នាងតូចក៏បម្រះរត់ចុះពីដៃតាសុខសំដៅមករកទូករបស់នាងតែ ត្រូវតាសុខចាប់ជាប់ជាថ្មី...

- បើចៅទៅផ្ទះតា ចៅនឹងបានជួបយាយរបស់ចៅហើយ ។

កំពុងតែបបួលនាងតូច ស្រាប់តែ ៖

- ឈប់សិន! ល្បងបំរុងនាំចៅស្រីរបស់ខ្ញុំទៅណាំដែរហ្នឹង ?

តាសុខងាករឹងយ៉ាងរហ័ស ក៏ប្រទះនឹងពូបូរដើរចុះពីថ្នល់ភូមិ មកដល់ចំណតទូក ។ គ្រាន់តែឃើញមុខពូបូរ គាត់ក៏ឈ្ងោកមុខចុះ នៅស្ងៀមមួយស្របក់ក៏ឆ្លើយថា ៖

- ខ្ញុំឃើញគេធ្លាក់ទឹកក៏ចុះមកជួយ ហើយក៏ចង់នាំគេទៅលេងផ្ទះ ត្បិតខ្លាចនាងនៅតែម្នាក់ឯងនឹងធ្លាក់ទឹកសាជាថ្មីទៀត ។ ម្យ៉ាងក្មួយប្រុសខាងនោះនៅតែសម្ងំគេងលក់មិនឃើញក្រោកមកសោះ ។

ពូបូរសម្លឹងមុខពូសុខ ទំនងចង់ដឹងថាតើពូសុខនិយាយទៀងត្រង់ឬក៏មានបំណងចង់ចាប់ក្មេង ? តែលុះឃើញកិរិយារបស់គាត់ ហាក់ដូចជាមិនមានពិរុទ្ធអ្វី ពូបូរក៏នៅស្ងៀម ហើយស្រដីថា ៖

- នាយសល់គេឈឺពីរថ្ងៃហើយ គ្រុនក្តៅសន្ធឹងសន្ធៃមិនដឹងខ្លួនទេ បរិភោគថ្នាំឫសឈើហើយក៏មិនឃើញបានគ្រាន់បើសោះ ។

តាសុខសម្លឹងមុខនាយសល់ ដែលដេកធ្វើមុខខៀវស្លេកៗលើ ទូក ហើយក៏ស្រដីថា ៖

- គេប្រហែលជាមានជំងឺគ្រុនចាញ់ ឬក៏គ្រុនសន្និបាទអី ហ្នឹងឯង ។

- ម៉េចក៏ល្បងឯងដឹង ?

- គឺ... ខ្ញុំចេះតែស្មានៗទៅ...

- ចុះល្បងដឹងទេ ថាមានថ្នាំអ្វីដាក់អោយជាបាន ?

- ខ្ញុំមិនដឹងទេ... ចាំខ្ញុំទៅដើរសួរអ្នកស្រុកអោយ ។ អញ្ចឹង ខ្ញុំលា ទៅវិញសិនហើយណាំ!

ថាហើយពូសុខក៏បែរមើលស្រីមុំរួចក៏សួរពូបូរថា ៖

- បើខ្ញុំសុំនាងតូចទៅលេងផ្ទះខ្ញុំម្តងម្កាលបានទេ ?

- ខ្ញុំមិនស្គាល់ផ្ទះល្បងផង តើអោយខ្ញុំអនុញ្ញាត្តម្តេចកើត ?

- អញ្ចឹង ចាំថ្ងៃណាទំនេរ ខ្ញុំនឹងនាំអោយទៅស្គាល់...

- បាទ! ហើយចុះល្បងឈ្មោះអ្វីដែរ ?

- គាត់ឈ្មោះតាសុខ (ស្រីមុំឆ្លើយយ៉ាងលឿនហាក់ចង់អួតថា នាង ចាំឈ្មោះគាត់ច្បាស់ណាស់)

CHANBOKEO.COM

ពូសុខញញឹម កាលបើឮនាងតូចហៅឈ្មោះគាត់ចំៗ ។

- ខ្ញុំវិញឈ្មោះសំបូរ ហៅបូរទទេៗក៏បាន ។ ថ្ងៃក្រោយទំនេរសូម ល្បងមកលេងខ្ញុំផង ។

ពូបូរស្រែកផ្តាំពីក្រោយ ។ ពូសុខក៏ទាញក្រមាជូតក្បាលដើរ ឡើងច្រាំងទៅ ស្រាប់តែ ៖

- តា! ម៉ុំចង់ទៅដែរ...! (នាងតូចកូកហៅ)

ពូសុខបែរក្រោយយ៉ាងរហ័ស កាលបើឮស្រីម៉ុំហៅ ។

- តានាំម៉ុំទៅជួបយាយណៃណា៎! ណា៎! (នាងតូចទទូច)

ឃើញទឹកមុខរបស់នាងម៉ុំ ពូសុខនឹកអាណិតនាងគ្រលួចចិត្តតែ ម្តង ។ គាត់ក៏ដើរថយក្រោយត្រឡប់មកវិញ ។ ពូបូរឈរមើលចំហ មាត់ឆ្ងង នឹកឆ្ងល់ក្នុងចិត្តដែលនាងតូចម៉ុំរត់តាមបុរសចម្លែក ធ្វើឬក ហាក់ដូចជានាងធ្លាប់ស្គាល់គាត់ពីអង្កាល់ណាមកអញ្ចឹង ។ ស្រាប់តែ នាងម៉ុំរត់ទៅអោបជើងបុរសចំណាស់ ។

- តា! ម៉ុំទៅដែរ... ទៅរកយាយណៃ!

ទ្រាំមិនបាន ពូសុខក៏ឱនត្រកងនាងឡើង ហើយសួរពូបូរថា ៖

- ប្អូនទុកចិត្តបងទេ បើបងនាំនាងតូចទៅលេងផ្ទះបង ?

ពូបូរធ្វើអេះអុញ នឹកក្នុងចិត្តថា ៖

- ចុះបើបងណៃមកវិញរកចៅមិនឃើញ តើអោយខ្ញុំទៅតាមរក នាងតូចនៅឯណាទៅ ?
- នៅផ្ទះថ្មចុងស្ពានថ្មី...
- ហ្ន៎ស ? ក្រែងកន្លែងនោះជាកន្លែងប៉ុស្តិ៍ទាហានវៀតណាមកាន់ កាប់ហ្នី ? ហេតុអ្វីក៏.... ?
- មែនហើយ... ខ្ញុំជាកម្មករនៅទីនោះ ។ គេហៅខ្ញុំថា សុខហុង ។
- ល្បងឯងចេះនិយាយយួនផងហ្នែស ?
- អត់ទេ... និយាយបារាំងបោយបានខ្លះៗនោះអី ។
- អូហ៍ ល្បងចេះបារាំងផង ?
- បន្តិចបន្តួច គ្រាន់តែម៉ាលោះក្រពះប៉ុណ្ណោះឯង

ពូបូរលួចមើលពូសុខម្តងទៀត ហើយនឹកក្នុងចិត្តថា ៖

- មើលទៅបុរសនោះ មានតម្រេះស្តុកស្តម្ភហើយ ទើបចេះបារាំង និយាយជាមួយពួកទាហានវៀតណាមបាន ។ តើគេជានរណា ?

CHANBOKEO.COM

ដោយឃើញស្រីមុំមាននិស្ស័យនឹងពូសុខយ៉ាងជិតដិត ពូបូរមិនដាច់ចិត្តធ្វើអោយនាងបាក់ទឹកចិត្តវិញឡើយ ។ ណាមួយ គ្រានោះ ខ្មែរម្នាក់ៗក្រីក្រអត្តខាត់ណាស់ គ្មាននរណាមានអង្ករលើសសម្រាប់ ចិញ្ចឹមកូនអ្នកដទៃទេ ។ ដូច្នេះ ពូសុខក៏ប្រហែលជាគ្មានសមត្ថភាព ចិញ្ចឹមនាងមុំដែរ ។ មើលទៅរូបរាងគាត់ចុះ ស្គមក៏ស្គមហើយចាស់ ជ្រីវជ្រួញទៀត ប្រហែលជាគាត់គ្មានបំណងអ្វីអាក្រក់លើនាងមុំ ឡើយ ។ នៅទីបំផុត ពូបូរក៏ដាច់ចិត្តប្រថុយអោយពូសុខនាំនាងតូច ទៅលេងផ្ទះគាត់មួយថ្ងៃ ។ បន្តិចមក ពូបូរចែវទូករហូតដល់ក្បែរ ស្ពានថ្មថ្មី ពូសុខលើកដៃសុំទាហានវៀតណាម រួចនាំនាងតូចដើរឡើងច្រាំងទៅ ។ ចំណែកគាត់ក៏ចតទូករង់ចាំពូសុខនាំស្រីមុំត្រឡប់ មកវិញនៅពេលល្ងាច ។ លុះអង្គុយបានមួយស្របក់ ពូបូរក៏នឹកភ្នក ទៅដល់មីងណៃ ៖

- យី! តិចបងណៃត្រឡប់មកនរាវិញ រកទូកយើងនៅកន្លែងដើម វិញមិនឃើញ តើគាត់នឹងព្រួយចិត្តយ៉ាងណា ?

ដោយនឹកឃើញដូច្នោះ ពូបូរក៏ដាច់ចិត្តចែវទូកត្រឡប់ទៅចត នៅកំពង់ចម្លងភូមិនរាវិញ រួចហើយក៏បង្កាត់ភ្លើងដាំថ្នាំអោយនាយ សល់បរិភោគ ។

សូមថ្លាថ្លែងពីមីងណៃយើងម្តង...

ក្រោយពីបាត់ស្មារតីអស់ជាយូរមក មីងណៃក៏ភ្ញាក់ស្មារតី មកវិញ ស្រាប់តែនឹកចម្លែកក្នុងចិត្តយ៉ាងអស្ចារ្យ ។ មុននេះ គាត់ ចាំបានថា គាត់បានដួលសន្លប់នៅកណ្តាលទីធ្លាផ្លូវថ្នល់មុខពេទ្យធំ ទាំងកណ្តាលយប់ ។ ពេលនេះ ហេតុអ្វីគាត់បែរជាមកសម្រាន្តនៅ លើគ្រែមួយ ក្នុងផ្ទះថ្មរបស់នរណាមិនដឹង ? មីងខំប្រឹងត្រដរងើប ឡើងទាំងទីងទោងដើរចេញពីបន្ទប់ដំណេកចេញមកក្រៅ ស្រាប់តែមីងយើងភ្ញាក់ព្រើត រន្ធត់ក្នុងចិត្តយ៉ាងក្រៃលែងដែលគាត់បានមក ឈរនៅលើគេហដ្ឋានមួយ ដូចជាផ្ទះរបស់គាត់និងលោកគ្រូពេទ្យ វិចិត្របេះដាក់តែម្តង ។ មីងណៃព្រឺក្បាលខ្លាក ៖

- នេះ ខ្ញុំយល់សប្តិ ឬក៏ខ្ញុំកំពុងប្រទះការពិត ?

មីងណៃឃើញមានចានស្រោក់ដាក់បាយកក និងត្រីងៀតពីរដុំ ព្រមទាំងទឹកមួយផ្តិលដាក់លើតុក្បែរគ្រែ ទំនងជានរណារៀបទុក អោយគាត់ពិសារពេលភ្ញាក់ឡើង ។   មីងណៃងើបដើរចុះ ដើរឡើង ក្នុងផ្ទះ ឡើងលើចុះក្រោម ចុះក្រោមឡើងលើវិញ ។ ថ្វីបើផ្ទះនោះ គ្មានការតុបតែងអ្វីក្រៅពីតុទូកំបែកកំបាក់ចាស់ៗ រប៉េះរប៉ោះ ប៉ុន្តែ តួសំបកផ្ទះ គឺជាផ្ទះរបស់មីងណៃពិតណាស់ ឥតក្លែងក្លាយបន្តិច ទេ...

CHANBOKEO.COM

គឺជាផ្ទះនៅប្រឹបស្ទឹងសង្កែ ដែលគាត់តែងតែគិតរិះរកគ្រប់មធ្យោបាយរៀងរាល់ថ្ងៃដើម្បីអោយបានត្រឡប់មកទីនេះវិញ... ចុះ ហេតុអ្វី ថ្ងៃនេះគាត់បានមកដល់ទីនេះដោយឯកឯងអញ្ចឹង ? តើ នរណា... នរណានាំគាត់មក៏ ?

មិងណៃបែររកមើលមិនឃើញមាននរណាម្នាក់ នៅក្នុងផ្ទះនោះឡើយ ។ មីងណៃដើរចុះទៅក្រោយផ្ទះ ឃើញលំនៅដែលតាខេម និងយាយលឿមធ្លាប់ស្នាក់នៅ ឃើញដើមស្វាយ ដើមដូង ដើម ម៉ាក់ប្រាងដុះនៅដដែល ។ ប៉ុន្តែ អ្វីដែលបាត់នោះគឺ... ប្ដីនិងកូនៗ ទាំងអស់របស់គាត់គ្រប់ៗគ្នា ។ ស្រមោលអនុស្សាវរីយ៍ទាំងឡាយបានអណ្ដែតលេចធ្លោឡើង ក្នុងអារម្មណ៍ស្ត្រីចំណាស់របស់យើង ។ មីងណៃញីភ្នែកម្ដងហើយម្ដងទៀត ក្រញីសក់ផង ក្ដិចខ្លួនឯងដល់ ទៅពីរបីដងផង ក្រែងលោទិដ្ឋភាពដែលគាត់កំពុងប្រទះឃើញ នោះគ្រាន់តែជាការយល់សប្ដិ៍ស្រមើស្រម័យ តែ... មិនមែនឯណា! គាត់មិនបានយល់សប្ដិទេ! គឺគាត់បានមកដល់ដីភូមិ ផ្ទះចាស់របស់គាត់នៅប្រឹបនឹងមាត់ស្ទឹងសង្កែនោះពិតប្រាកដមែន ។

មីងណៃឈរទ្រោបមុខលើផ្ទាំងទ្វាររបងខាងមុខផ្ទះ ស្រក់ទឹក ភ្នែកច្រោក... នឹកដល់ប្ដីសម្លាញ់របស់គាត់ នឹកទៅដល់កូនប្រុស កូនស្រីដែលបានបែកពីគាត់ទៅ... ពេលនេះ ផ្ទះរបស់គាត់នៅឈរ ជង្រ្កឹងដដែល ប៉ុន្តែបាត់ម្ចាស់អស់រលីង... ភ្លាមនោះ មីងណៃមានអារម្មណ៍ថា បេះដូងរបស់គាត់ពុះកញ្ជ្រោលឡើងដោយការអួលអាក់ និងក្ដីនឹករលឹកយ៉ាងធំធេងចំពោះប្ដីនិងកូន...

មួយស្របក់មក គាត់ក៏បែរក្រោយសម្លឹងដំបូលផ្ទះ ហើយ ពោលខ្សិបៗ ៖

- ប្ដីសម្លាញ់! បងនៅឯណា ? កូនម្ដាយអើយ... ថ្ងៃណាម៉ាក់បាន ជួបជុំកូនវិញម្ដងទៀត ?

មីងណៃអួលដើមកស្រក់ទឹកភ្នែកសាជាថ្មី ។ បន្តិចមកក៏លើក ដៃប្រណម្យឡើង ៖

- សូមអរគុណបារមីសក្ដិសិទ្ធិ និងបុគ្គលដែលនាំរូបខ្ញុំឲ្យមកឃើញ ទីនេះសាជាថ្មី! បើសំណាងខ្ញុំនៅមានពិតមែន សូមអោយខ្ញុំបាន ជួបប្ដីកំពូលដួងចិត្តរបស់ខ្ញុំនិងកូនគ្រប់គ្នាកុំបីខាន! !

បន្ទាប់មក មីងណៃក៏ខាំម្រាមដៃរបស់គាត់ ច្របាច់យកឈាម មកគូររូបផ្កាចំប៉ាញីឈ្មោលមួយគូលើផ្ទាំងទ្វាររបង រួចសរសេរថា ៖

- ណៃស្រឡាញ់បងចិត្រ! ណៃស្រឡាញ់កូនគ្រប់គ្នា! សូមអោយ យើងបានជួបគ្នាវិញឆាប់ៗនេះ!

CHANBOKEO.COM

មីងណៃយកដៃជូតទឹកភ្នែក សម្លឹងមើលទៅផ្ទះរបស់គាត់ម្តង ទៀត ។ ថៃដន្យ ស្រោប់តែគាត់នឹកភ្នកទៅដល់ចៅស្រីតូចរបស់ គាត់ដែលទុកចោលអោយនៅជាមួយពូបូរតាំងពីម្សិល ។ រីឯនាយ សល់វិញក៏មិននឹងជាយ៉ាងណាទៅហើយទេ ។ មែនហើយ! គាត់ ត្រូវតែត្រឡប់ទៅតាមរកចៅស្រីរបស់គាត់មកវិញ... ចៅមុំជាទ្រព្យ ជីវិតចុងក្រោយរបស់គាត់ដែលនៅសល់ ។ គាត់មិនអាចបាត់ បង់រូបនាងទៅបានឡើយ ។ ភ្លាមនោះ មីងណៃក៏ប្រញាប់ប្រញាល់ ទាញទ្វាររបងបិទ ហើយលើកក្រមាទទូរដើរចេញទៅ ដោយមិន បានបរិភោគអាហារ ដែលគេបានទុកនៅលើតុអោយគាត់ពិសារ នោះឡើយ ។

តាមផ្លូវ គ្មានចរាចរទេ ។ យូរៗមីងឃើញអ្នកស្រុកមួយៗ ខិន ឈ្សោកធ្វើការសំអាតតាមផ្ទះនិមួយៗ តាមបណ្តោយដងផ្លូវប្របស្ទឹង នោះ ប៉ុន្តែគ្មាននរណារាក់ទាក់សួរសុខទុក្ខនរណាទេ ទំនងដូចជា បាក់ស្បាតដោយសាររបបផ្តាច់ការរបស់ខ្មែរក្រហម និងសង្គ្រាម រវាងខ្មែរក្រហមនិងទព័វៀតណាមហើយ ។ បែរមើលទៅអ្នកដែល កាន់កាប់ផ្ទះនិមួយៗសុទ្ធសឹងជាទាហានវៀតណាមទាំងអស់ ។ មាន ផ្ទះខ្លះ គេបាំងរបងខ្ពស់ជិតឈឹង មិនអាចមើលពីក្រៅឃើញ ឡើយ ។ តាមមើលទៅ មុំដងស្ទឹងនោះគ្មានខ្មែររស់នៅទេ មាន តែពពួកកម្លាំងទ័ពវៀតណាមប៉ុណ្ណោះ ។ ពេលនេះមីងណៃសង្កេត ឃើញថាពពួកកងទាហានវៀតណាម ហាក់ដូចជាបន្ធូរបន្ថយឃ្លៀប របស់គេបន្តិចចំពោះអ្នកស្រុកទូទៅ មិនសូវជាតឹងតែងដូចឃ្លៀប អង្គការខ្មែរក្រហមទេ ប៉ុន្តែទោះជាយ៉ាងណា ក៏គេមិនចូលចិត្តឲ្យ អ្នកស្រុកសួរពួកគេពីអ្វីឡើយ ។ បើគេចេញបញ្ជា គឺបញ្ជាហើយ គ្មានតវ៉ា បើពុំនោះសោត... ហ៊ឺ! តើនរណាទៅហ៊ានទៅជជែកតវ៉ា នឹងគ្រាប់កាំភ្លើងនោះ ?

មួយស្របក់មក មីងក៏មកដល់ចុងស្ពានថ្ម រួចហើយក៏ដើរឆ្លង ថ្នល់បង្ហួសទៅនរា ។ ពពួកទាហានវៀតណាមដែលនៅយាមក្បាល ស្ពានហាក់ដូចជាចំណាំគាត់បាន ក៏មិនឮសួរនាំអ្វីដែរ ។ ម្យ៉ាងដោយ គាត់ដើរដៃទទេ គ្មានយកអ្វីតាមខ្លួនផង គេក៏បណ្តោយអោយគាត់ ដើរឆ្លងទៅដោយសម្រួល ។

មិនយូរប៉ុន្មាន គាត់ក៏បានមកដល់ជំរកចាស់...

- បូរ! សល់! មុំអើយ!

CHANBOKEO.COM

ឮសម្លេងមីងណៃកួកហៅ ពូបូរត់ចេញពីទូកមកទាំងញញឹម ៖

- បងណៃ! បងមិនអីទេឬ? បាត់រូបបងមួយយប់ ខ្ញុំភ័យគេង មិនលក់សោះ!

មីងណៃប្រឹងញញឹមទាំងអស់កម្លាំងល្អិតល្ហៃ ៖

- បងមិនអីទេ! ហើយចុះនាយសល់និងចៅមុំយ៉ាងណាហើយ ?

ឮសំនួរនេះ ពូបូរស្លោះទឹកមុខតែម្តង ៖

- ក្មួយសល់ដូចជានៅតែគ្រុនសន្ធំដដែល មិនឃើញដើបមករក បាយទឹកទេ ។

- ចុះឯណាចៅមុំ ? ម៉េចមិនឃើញ ?

មីងណៃសួររន្ថើនដោយក្តីព្រួយបារម្ភ ។

- នាងទៅលេងផ្ទះតាម្នាក់ ។

- តាម្នាក់ ? តាមួយណា ? បូរស្គាល់គាត់ហ្ន៊ៃស ?

ពូបូរអេះអុញមិនដឹងពន្យល់យ៉ាងម៉េច ។

- យ៉ាងម៉េច ? ចៅមុំនៅឯណា បូរ ?

- នាងទៅលេងផ្ទះល្បងសុខនៅចុងស្ពានថ្ម...

- ហើយម៉េចក៏បណ្តោយនាងអោយទៅយ៉ាងនេះ ? តើមានដឹងទេ ថាគេនោះជាមនុស្សល្អឬក៏យ៉ាងណា ? បូរឆាប់ទៅតាមរកចៅមុំមក អោយបងវិញភ្លាម...ពុំនោះសោត បងនឹងខឹងបូរអស់មួយជីវិត ។

មីងណៃស្រដីទាំងរលីងរលោងទឹកភ្នែក ដោយក្តីបារម្ភចំពោះ ចៅស្រីរបស់គាត់ ។ ដោយក្តីអន្ទះសា មីងណៃក៏ទាញច្រវាទូកចែវ រឹងត្រឡប់ឡើងសំដៅទៅបាត់ដំបង ។

- បងណៃទៅណា ?

- បងទៅរកចៅមុំ ។ បូរត្រូវតែនាំបងទៅរកនាងមកវិញអោយ ឃើញ ។

មីងណៃស្រដីទំនងខកចិត្តនឹងពូបូរដែលបណ្តោយអោយនាងមុំ ទៅលេងផ្ទះនរណាមិនដឹង ។ ពូបូរលែងមាត់តែម្តង ត្បិតដឹងខ្លួន ខុស ។ គាត់ក៏ទាញដៃមីងណៃអោយអង្គុយចុះ ហើយក៏ចាប់ច្រវា ចែវទៅរកបុរសដែលគាត់បានជួបពីព្រឹកមិញ ។ ពូបូរចែវទូក បណ្តើរលួចមើលមីងណៃបណ្តើរ ឃើញគាត់ធ្វើមុខស្រងូត ។ រីឯ រង្វង់ភ្នែករបស់គាត់វិញ ក៏នៅដក់ជាប់ទឹកភ្នែកមិនទាន់ស្ងួតនៅ ឡើយដែរ ។

ពូនឹកស្តាយក្រោយណាស់ដែលចិត្តល្អរហូតដល់ហ៊ាន

CHANBOKEO.COM

បណ្តោយអោយនាងមុំទៅលេងផ្ទះមនុស្សចម្លែករហូតដល់ធ្វើអោយ
មីងណៃពិបាកចិត្តបែបនោះសោះ ។
- បងណៃកុំភ័យអី! ចាំប្អូនទៅតាមរកនាងមកជូនបងវិញ ។
ពូប្អូនខំស្រដីលួងលោម តែមីងណៃនៅតែឈ្ងោកមុខស្ងៀម
ហាក់មិនបានឮឡើយ ។ បន្តិចមក គេក៏បានមកដល់ចុងស្ពានថ្ម ។ ពូប្អូនឈប់ទូកហើយហាក់ឡើង
តាមទៅរកតាសុខភ្លាម ។ ថៃដន្យ នៅផ្ទះចុងស្ពាននោះ មានសុទ្ធតែទាហានវៀតណាម
និយាយគ្នា ស្តាប់មិនបានសោះ ។ លុះនិយាយឆ្ការដៃឆ្ការជើងអស់ចិត្តហើយ ពូ
ប្អូននៅតែមិនបានចម្លើយតបងដែល ។ ទីបំផុតក៏ត្រូវត្រឡប់ក្រោយ វិញ ។
មីងណៃឃើញទឹកមុខរបស់ពូប្អូនក៏ដឹងថា ពូប្អូនរកនាងមុំមិន ទាន់ឃើញនៅឡើយទេ ។
មីងណៃមិនអស់ចិត្តក៏សួរថា ៖
- ប្អូន! បុរសដែលនាំនាងមុំទៅនោះឈ្មោះអ្វីដែរ ? គេមានអាយុ ប្រហែលប៉ុន្មាន ?
- ល្បែងនោះប្រាប់ថាឈ្មោះ សុខហុង ហៅសុខ ចំណាស់សែប្លាយ ឬហាសិប
ធ្វើការជាកម្មករនៅផ្ទះថ្មចុងស្ពានថ្មី ។
មីងណៃឮហើយក៏ស្ទុះឡើងរឹងទៅភ្លាម ។ ពូប្អូនមិនអស់ចិត្តក៏
រត់តាមក្រោយមីងណៃត្រឹកៗទៅដែរ ។ ភ្លាមនោះ មីងណៃនិយាយ
បារាំងសួរនាយកងម្នាក់ដែលនៅយាមប៉ុស្តិ៍ ស្រាប់តែនាយបើកភ្នែក ធំៗឆ្លើយជាបារាំងវិញ ថា ៖
- មីងស្គាល់តាសុខហុងដែរ ?
- មិនស្គាល់ទេ តែគាត់ស្គាល់ប្អូនប្រុសរបស់ខ្ញុំ (មីងណៃឆ្លើយជា បារាំង)
រួចគាត់បានសុំចៅស្រីខ្ញុំមកលេង ហើយមិនឃើញនាំ
ចៅស្រីរបស់ខ្ញុំត្រឡប់មកអោយពួកយើងវិញ ទើបយើងតាមមក រកតែម្តង ។ លោក
ស្គាល់ផ្ទះរបស់តាសុខហុងហ្នឹងទេ ?
- ស្គាល់! តែពេលនេះ ខ្ញុំកំពុងជាប់វេនយាម មិនអាចជួយនាំផ្លូវ បានទេ ។
- អញ្ចឹងប្រាប់ផ្លូវខ្ញុំមក៏ ចាំខ្ញុំទៅតាមគាត់ ដោយខ្លួនឯង ។
នាយទាហាននោះក៏ទាកក្រដាសគូរខ្វៀកៗ ដាក់លេខផ្ទះចំណាំ
ហើយលើកដៃចង្អុលទៅខាងត្បូងផ្លូវថ្នល់ប្រហមាត់ស្ទឹង ហើយស្រដី ជាបារាំងថា ៖
- ទៅតាមហ្នឹងទៅឃើញហើយ ។

CHANBOKEO.COM

មីងណៃទទួលក្រដាសមកអាន ស្រាប់តែភ្ញាក់ព្រើត ព្រោះនោះតម្រុយទៅផ្ទះចាស់របស់មីងណៃទេតើ ។ ភ្លាមនោះ បេះដូងគាត់រណ្តំភិបៗស្ទើរតែធ្លាយទ្រូងមកក្រៅ ។ តើគាត់មានសម្ពន្ធ័ប្រផ្នូលអ្វី ចម្លែកដល់ម្លឹងដែលគាត់ត្រូវត្រឡប់មកជំពាក់នឹងអាថ៌កំបាំង ក្នុង ផ្ទះចាស់របស់ខ្លួនគាត់យ៉ាងនេះ ?

មីងណៃលានាយកងស្មុះឆ្លងថ្នល់ដើរសំដៅទៅត្បូងយ៉ាងលឿន ស្លេវ ។ ពូបូរក៏ស្ទុះដើរតាមពីក្រោយដែរ ប៉ុន្តែលុះដើរមកដល់ ត្រើយម្ខាងថ្នល់ ស្រាប់តែក្រុមទាហានវៀតណាមឃាត់គាត់មិនឲ្យ ដើរបន្តទៅមុខទៀតទេ ថែមទាំងធ្វើដៃជាសញ្ញាអោយគាត់ត្រឡប់ ក្រោយទៀតផង ។ ពួកគេមិនបានឃាត់មីងណៃទេ មើលទៅ ប្រហែលជាគេគិតថាជាស្រីហើយបានជាមិនសូវបន្តឹងវិន័យ ។ តែពូបូរមិនអស់ចិត្តសោះ ដែលបណ្តោយឲ្យមីងណៃទៅតាមរកស្រីម៉ុំ តែម្នាក់ឯងក៏ទទូចសុំជាបារាំងផង ជាខ្មែរផងតាមដែលគាត់ចេះ ដើម្បីសុំជូនមីងណៃឲ្យទៅដល់ទីដៅ ។ ថៃដន្យ ពួកទាហាននោះ កាចៗណាស់ ។ គេមិនមានចិត្តមេត្តាដល់ពូបូរឡើយ ។ កាលបើពូទទូចច្រើនពេក ទាហានម្នាក់ក៏យកត្រាកាំភ្លើងមកគោះស្មាពូបូរផាំងខ្ទាតពូច្រឡោតថយក្រោយវិះផ្ងារពោះ ។ ឃើញកិរិយាកាចៗដូច្នោះ ពូបូរក៏បិទមាត់ដកខ្លួនថយយ៉ាងលឿនដើម្បីរក្សាសុវត្ថិភាព ។

ចំណែកមីងណៃក៏ធ្វើដំណើរយ៉ាងរហ័ស សំដៅផ្ទះចាស់របស់គាត់តាមដែលនាយទាហាននោះគូសប្រាប់ ។ មួយស្របក់ក្រោយ មកគាត់ក៏បានមកដល់ទីនោះដូចប្រាថ្នា ។ មីងណៃក៏បើកទ្វាររបង ដើរចូលទៅ ។ ពេលនោះគាត់ប្រទះនឹងមនុស្សស្រីម្នាក់ក្នុងវ័យ ប្រហែលជាសាមសិបឆ្នាំកំពុងបោសផ្ទះ ។

- រកអាណាគេ មីង ? (ស្ត្រីម្នាក់នោះសួរមីងណៃ)
- គឺខ្ញុំមករកតាសុខហុង គាត់នៅផ្ទះដែរទេ ? (មីងណៃតប)
- អូហ៍ មិនទាន់មកវិញទេ ។
- ប្រហែលថ្មើរម៉ានបានមកវិញ នាងអូន ?
- អត់ដឹង...
- ហើយចុះនាងអូនឈ្មោះអី ហើយត្រូវជាអ្វីនឹងតាសុខហុងដែរ ?

ស្ត្រីនោះនៅស្ងៀម មួយស្របក់ ក៏និយាយថា ៖

- ឈ្មោះកាជេន ជាប្រពន្ធរបស់គាត់ ។

CHANBOKEO.COM

មីងណៃញញឹមឡើង ៖

- អញ្ចឹង នាងអូនមិនទើសទាល់ទេ ដែលបងមករកប្ដីរបស់នាង ?

នាងគ្រវីក្បាល ហើយឆ្លើយថា ៖

- រឿងគាត់គឺតាមតែរឿងរបស់គាត់ទៅ ។ ឯរឿងខ្ញុំគឺរឿងខ្ញុំ មាន ទាក់ទងអ្វីនឹងគ្នាឯណា ? សួរច្រើននេះច្រើន ដល់ហើយ !

មីងណៃឮដូច្នោះក៏ជ្រួញចិញ្ចើម ព្រោះស្ត្រីមួយរូបនោះនិយាយ ចាប់ចុងព្រយុងដើមស្ដាប់មិនយល់សោះ ។ មើលទៅប្ដីប្រពន្ធមួយ គូនេះ មានវិបត្តិអ្វីម្យ៉ាងហើយ ។

- ចុះនាងអូនមានឃើញតាសុខហុងនាំកុមារីតូចមួយ អាយុបួនឆ្នាំ មកទីនេះដែរទេ ថ្ងៃនេះ ?

- យី ! សួរទៀតហើយ ? ឈប់សួរខ្លះមិនបានទេហ្អី ?

ភ្លាមនោះ មានស្រីក្មេងម្នាក់បើកទ្វាររបងដើរចូលមក ។ គ្រាន់តែដាក់ភ្នែកឃើញភ្លាម មីងណៃឧទានឡើងទាំងភ្ញាក់ផ្អើលថា ៖

- បារមី ! កូនមាសម្ដាយ !

រួចហើយគាត់ស្ទុះរឹងទៅអោបនាងមួយរំពេច ។ មែនហើយ ! នោះគឺជាបារមីកូនស្រីរបស់គាត់ទាំងសាច់ទាំងឈាម ។ បារមីឈរ ទ្រឹងដោយការភ្ញាក់ផ្អើល ធ្វើទឹកភ្នែករលីងរលោង តែមិនព្រម ស្រវាអោបគាត់ដូចកាលម្សិលមិញ ដែលនាងបានប្រទះម្ដាយនាង នោះឡើយ ខុសអ្វីពីមីងណៃដែលមានសេចក្ដីសោមនស្សរំភើបចិត្ត បំផុតដែលគាត់បានជួបកូនស្រីរបស់គាត់វិញ ។ គាត់ស្រវាអោបកូន ផងយំផងដោយរកពាក្យអ្វីមកនិយាយមិនបាន ។ តែលុះដល់ឃើញ កិរិយារបស់កូនទំនងប្លែកចំពោះគាត់ពេក មីងណៃក៏ជូតទឹកភ្នែក ហើយ សួរកូនស្រីថា ៖

- មានរឿងអ្វីហ្នឹងកូនស្រីម្ដាយ ? ហេតុអ្វីកូនសម្ដែងកិរិយាហាក់ ដូចជា... ដាក់ម៉ាក់អញ្ចឹង ?

បារមីមិនឆ្លើយទេ គ្រាន់តែឈ្ងោកមុខស្រក់ទឹកភ្នែកស្ងៀមស្ងាត់ តែប៉ុណ្ណោះ ។ រំពេចនោះ មានបុរសម្នាក់ជិះកង់ឌុបក្មេងស្រីចូល មកដល់មុខផ្ទះ តាមទ្វាររបងដែលមីងណៃបានបើកចំហចោល ។

- នោ៎ះ ! តាសុខហុងមកវិញហើយ (កាដេនលាន់មាត់)

មីងណៃបែរភ្លែតឃើញកុមារីនោះភ្លាមក៏ស្រែកភ្លាត់សម្លេង ៖

- ចៅមុំ !

CHANBOKEO.COM

ឃើញជីដូនកាលណា នាងតូចក៏ហក់ចុះពីលើរានកង់ស្ទុះហក់ រកមកអោបកគាត់យ៉ាងរហ័ស ៖

- យាយ ! យាយ! (នាងតូចអោបកយាយផង ហៅផង)

មីងណៃត្រេកអរណាស់ដែលបានជួបចៅវិញរហូតដល់ភ្លេចអ្នក ជុំវិញខ្លួនអស់ គិតតែពីស្រវាចៅ អោបថើបដោយក្ដីត្រេកអរដែល ឃើញនាងសុខសប្បាយ ។

- មុំ! នឹកយាយទេចៅ ?

- នឹក! មុំនឹកយាយធំណាស់!

- យាយក៏នឹកចៅដែរ ។ នេះចៅញ៉ាំបាយហើយឬនៅ ?

- ញ៉ាំរួចហើយ (នាងតូចងក់ក្បាល) តាសុខអោយបាយមុំញ៉ាំ!

ឮឈ្មោះនោះភ្លាម មីងណៃក៏ងាករកមើលតាសុខ ស្រាប់តែ ប្រទះនឹងបុរសចំណាស់ម្នាក់ រាងស្គមខ្ពស់ សក់ល្បាយអាចម៍ខ្លា កំពុងឈ្ងោកមុខឈររេរាៗក្បែរនោះ ស្រាប់តែគាត់ខំទាញខ្សិបៗនៅ ក្នុងមាត់របស់គាត់ឡើងថា ៖

- បងចិត្រ ? ពុទ្ធោ! ប្ដីសម្លាញ់របស់អូន...!

ទឹកភ្នែកពីរតំណក់ក៏ហូរធ្លាក់ចេញមកពីរង្វង់ភ្នែករបស់មីងភ្លាម ដោយមិនដឹងខ្លួន ។ បេះដូងរបស់គាត់ក៏កញ្ច្រោលឡើងស្ទើរធ្លាយ ទ្រូងមកក្រៅ ។ មីងក៏ស្ទុះដើបរឹង បំរុងនឹងរត់ទៅស្រវាអោបប្ដី អោយសមស្មើនឹងសេចក្ដីនឹករលឹករបស់គាត់ទៅហើយ ស្រាប់តែ គាត់ដាក់ភ្នែកឃើញស្រីម្នាក់ឈ្មោះកាជេននោះនៅឈរពីក្រោយខ្នង បុរស ហើយឃើញបារមីឈរទ្រោបក្បាលនឹងជញ្ជាំងផ្ទះ យំសសឹក តែម្នាក់ឯង ។ មីងណៃក៏ទុចដំណើរដឹក ៖

- ពេលនេះ បងចិត្របានក្លាយជាប្ដីរបស់ស្ត្រីមួយរូបនោះទៅហើយ មែនទេ ? (មីងណៃស្រដីនៅក្នុងចិត្តតែម្នាក់ឯង) ដូច្នេះ ណៃគ្មាន សិទ្ធិប្រកាន់រូបគាត់ជារបស់ណៃតទៅទៀតបានឡើយ...! យើងបាន បែកគ្នាច្រើនឆ្នាំហើយ មិនដឹងថាបងប្រែប្រួលចិត្តយ៉ាងណា... ? តើបងនៅស្រឡាញ់ណៃដូចដែលបងធ្លាប់ប្រាប់ណៃនោះ ឬក៏បង បោះបង់ចិត្តស្រឡាញ់ណៃ ហើយបណ្ដុះដួងចិត្តថ្មីសំរាប់នារីថ្មី ក្នុង ជីវិតបងទៅហើយ ?

មីងណៃឈរធ្មឹងធ្វើស្រឡាំងកាំង ភាំងស្មារតី មិនដឹងថានឹង ត្រូវប្រព្រឹត្តកិរិយាយ៉ាងណាអោយសមរម្យឡើយ ។ ព្រះអើយ! ពេលនេះ មីងមានអារម្មណ៍ថាចុកចាប់នៅក្នុងដើមទ្រូងអ្វីម្ល៉េះទេ! ថ្ងៃមុន គាត់បែកពីប្ដីរបស់គាត់ មីងណៃដេកបន់ដើរបន់ សូមអោយ ឆាប់បានជួបប្ដីរបស់គាត់វិញ ។

CHANBOKEO.COM

តែលុះដល់បានជួបគ្នាវិញហើយ ស្រាប់តែគាត់បែរជាមិនអាចលើកដៃស្រវាអោបប្ដី សម្ដែងសេចក្ដីនឹករលឹករបស់គាត់បានដូចបំណងដែលគិតទុកនោះសោះ ។ ហេតុអ្វីទៅបានជាទេវតាដាក់ទោសគាត់ខ្លាំងម្ល៉េះ ?

មីងណែឈរសម្លឹងមុខលោកគ្រូពេទ្យ ដោយក្ដីរន្ធត់ញាប់ញ័រ ក្នុងចិត្តជាទីបំផុត ។ បែរទៅលោកដុកទ័រវិចិត្រដ៏ស្គាំងស្គមនោះ វិញ ក៏មិនខុសគ្នា ។ កិរិយារបស់លោកក៏ស្ទាក់ស្ទើរចំពោះភរិយា មិនខុសពីមីងណែយើងប៉ុន្មានឡើយ ទំនងហាក់ដូចជាលោកមាន អារម្មណ៍ជំពាក់ស្មុគ្រស្មាញយ៉ាងខ្លាំង នៅក្នុងជំរៅចិត្តមិនខុសពីមីងណែប៉ុន្មានដែរ ។ ថ្វីបើ លោកមិនបានដើបមុខសម្លឹងមីងណែអោយ ចំក្រសែភ្នែកក៏ដោយ ក៏មីងណែដឹងថាលោកគ្រូពេទ្យបានលួចចោលកន្ទុយភ្នែកតាមដានកិរិយាមីងណែមិនពព្រិចឡើយ ។ ទាំង អស់គ្នាឈរស្ងៀមស្ងាត់លួចយំខ្សឹកខ្សួលតែក្នុងចិត្តរៀងៗខ្លួន មិន មាននរណានិយាយអ្វីរកនរណាថាម៉េចឡើយ ។ ពេលវេលាក៏ចេះតែ អណ្ដែតត្រសែតទៅមុខដោយក្រៀមក្រំក្រៃលែង...

មួយស្របក់ក្រោយមក...

មីងណែឈ្ងោកមុខប្រឹងលេបទឹកភ្នែកចូលពោះវិញហើយស្រវាចាប់ដៃចៅស្រីដើរចេញទៅក្រៅរបងផ្ទះ ដោយមិនមានស្រដីលា... ឯលោកដុកទ័រឃើញមីងដើរចេញទៅ ក៏បែរតាមសម្លឹងតាមមើលពីក្រោយដោយក្រសែភ្នែកដ៏សែនអាឡោះអាល័យ ។ មែនហើយ! តាំងពីប្រទះមុខមីងណែមក លោកគ្រូពេទ្យយើងរកនឹកនិយាយអ្វី មិនចេញមួយម៉ាត់សោះ... តើព្រោះហេតុអ្វីទៅ ? នៅពេលនោះ លោកក៏សម្លឹងមើលមីងណែមិនបានច្បាស់ដូចចិត្តប៉ងឡើយ ព្រោះទឹកភ្នែកវាបានវាតទី ដណ្ដើមប្រជ្រៀតគ្នាហូរចេញមកប្រឡែងកែវភ្នែករបស់លោកមិនព្រមឈប់ឈរ មិនខុសប៉ុន្មានពីមីងឡើយ...

មីងណែដើរចេញទៅយឺតៗ ក្នុងចិត្តគិតសង្ឃឹមថា មីងនឹងបានឮសម្លេងប្ដីស្រែកឃាត់គាត់ពីក្រោយ... នោះអាចបង្ហាញថាលោកគ្រូពេទ្យនៅមានសល់ចិត្តស្រឡាញ់ ចិត្តអាលោះអាល័យចំពោះមីងនៅ ឡើយ ថ្វីបើពេលនោះលោកមានភរិយាថ្មីទៅហើយ ។ បើលោក គ្រូពេទ្យពិតជាស្រដីហៅមីងពិតមែន មីងណែនឹងបែរត្រឡប់ទៅ រាប់រកប្ដីរបស់គាត់វិញហើយ... បើមិនបានជាគូនៃបនិត្យ ក៏គង់បាននិយាយគ្នា រំសាយចិត្តនឹករលឹកនិងក្ដីព្រួយបារម្ភ ដែលគាត់ធ្លាប់

CHANBOKEO.COM

មានចំពោះប្ដីយ៉ាងសែនពុះពោរនោះដែរ ។ ប៉ុន្ដែគួរអនិច្ចាណាស់!
មីងណៃឈានដើរកាន់តែឆ្ងាយពីផ្ទះទៅហើយ គាត់នៅតែមិនឮ
សំដីលោកគ្រូពេទ្យនិយាយអ្វីមួយម៉ាត់ ហៅគាត់អោយត្រឡប់ថយ ក្រោយទៅវិញសោះឡើយ ។
មីងយើងក៏បាក់កម្លាំងចិត្តអស់រលីង ពីខ្លួនតែម្ដង... ទឹកភ្នែករាប់លានតំណក់ក៏ហូរស្រក់ចុះមក...
    បែរទៅលោកវិញ ក៏រង់ចាំអោយមីងមកជិតរូបលោក
រួចហៅរាប់រករូបលោកសាជាថ្មីដូចគ្នាដែរ ។ បើមីងណៃស្រដីហៅ រូបលោក នោះមានន័យថា
មីងណៃនៅមានចិត្តចំពោះលោកនៅ ឡើយ ។ ពេលនោះ លោកនឹងមានអ្វីជាច្រើន
ចង់ប្រាប់មីងណៃ អោយបាននឹង ។ ថៃដន្យ លោកបានឈររង់ចាំមួយស្របក់ហើយ
នៅតែមិនឃើញមីងស្រដីអ្វីរកគាត់មួយម៉ាត់ដូចគ្នា ។ ផ្ទុយទៅវិញ មីងបែរជាធ្វើមុខស្រងូត
ស្លេកមុខដើរថយចេញទៅវិញដោយមិន មានស្រដីអ្វីមករកលោកសោះ
ធ្វើអោយលោកគ្រូពេទ្យខកចិត្តខក សង្ឃឹម... រួចហើយក៏សម្លឹងមីងណៃ
តាមពីក្រោយរហូតដល់បាត់ ស្រមោលគាត់ពីទីនោះទៅ ។ ទឹកភ្នែកក៏ចេះតែហូរចុះមកដោយ
ឯកឯងលើផ្ទៃមុខដ៏ជ្រីវជ្រួញរបស់លោកគ្រូពេទ្យយ៉ាងជោគជាំ...
- អូនណៃ! អូនបានទទួលបុរសម្នាក់នោះជាស្វាមី ចោលរូបបង យូរឆ្នាំហើយ...
តើអោយបងគួរគិតយ៉ាងណាចំពោះអូនបន្ដទៀត ? បេះដូងរបស់បងពិតជាឈឺចាប់ណាស់
ពេលដែលបងដឹងថា អូន ណៃបានក្លាយជាប្រពន្ធរបស់បុរសដទៃ... ប៉ុន្ដែបងកាត់មិនដាច់ពី
រូបអូនទេ... បងឃាត់ចិត្តបងមិនបានឡើយ ថាបងមិននឹកអូន! ជីវិតបងមួយ...
គឺរស់ដើម្បីរូបណៃរបស់បងតែម្នាក់គត់ ។ បេះដូង
របស់បងរង់ចាំការវិលត្រឡប់របស់ណៃជានិច្ច... តើជាតិនេះ បង
មានវាសនាបានរូបអូនមកគេងកើយទ្រូងបងជាថ្មីម្ដងទៀតដែរឬទេ
អូនណៃកំពូលដួងចិត្តរបស់បង ?.... បងស្រឡាញ់អូនណាស់ ដឹង ទេណៃ ?
    លោកគ្រូពេទ្យសួរចិត្តខ្លួនឯងម្ដងហើយម្ដងទៀតមិនព្រមឈប់ សោះ ។
សុរិយាកំពុងយាងលានភាល័យទៅហើយ... លោកគ្រូ ពេទ្យនៅតែឈរសំកុកស្ងៀមស្ងាត់
ដូចរូបចម្លាក់ឥតវិញ្ញាណនៅតែ មួយកន្លែង តាំងពីរសៀលមិនព្រមទៅណាមកណាឡើយ...

oooooooooooooooooooo

ooooooo

o

CHANBOKEO.COM

# វគ្គទី៦
# ព្យុះជីវិត

វាលទ្រា ខែមិនា ១៩៧៦...

នាព្រឹកមួយ...

មីងណៃកំពុងបីចៅស្រីផ្ទូតទឹក ពេលស្រីម៉ៅចេញទៅបោកគក់នៅឯស្រះក្រោយផ្ទះ ។ រីពូណាតវិញបានចេញទៅរែកទឹកដាក់រោង បាយការដ្ឋានតាំងពីព្រហាមបាត់ សល់តែមីងថនដែលនៅពពីម ពពើមលើផ្ទះតែម្នាក់ឯង ស្រាប់តែមានយោធាមួយក្រុមដើរហែហម ពួកគណៈឃុំគណៈស្រុកមួយចំនួនមកដល់មុខផ្ទះពូណាត ។ គ្រាន់តែឃើញហ្វូងពពួកយោធាខ្មែរក្រហមណែនណាន់ខ្នាន់ខ្នាប់ ដើរមក ដល់ធ្លាមុខផ្ទះពូណាត មីងណៃភើតពោះប្រហោងឆ្លុងប៉ុនចង្អេរតែ ម្តង នឹកពិភាល់ថាតើពួកគេមកធ្វើអ្វីនៅទីនោះ ? មីងណៃខំប្រឹង ទប់ស្មារតីមិនអោយរន្ធត់ញាប់ញ័រ រួចធ្វើពើហាក់មិនបានឃើញពួកគេទាំងនោះឡើយ ។ ភ្លាមនោះ នាយពលយោធាម្នាក់កូកហៅ ៖

- មិត្តមីង ចេញមកនេះ ! គណៈភូមិមានការចង់និយាយជាមួយ !

មីងណៃឮហើយក៏ម្ទីម្ទាទាញក្រមាឃ្លុំមុខ ហើយបីចៅដើរត្រុនៗ ទៅជិត រួចស្រដីថា ៖

- មិត្តប្អូនមានការអ្វីហ្នឹង ?
- គឺមិត្តគណៈធំៗចង់ប្តូរទីតាំង អោយគ្រួសារមីងទៅនៅកន្លែង ផ្សេងវិញ ។

មីងណៃភ្ញាក់ព្រើត ភ័យជ្រួចក្នុងពោះ នឹកគិតក្នុងចិត្តថា ៖

- តើពួកគេបំរុងបណ្តេញយើងអោយចេញទៅណា ? ពុទ្ធោអើយ ! បើយើងចេញពីទីនេះ ចុះពេលប្តីនិងកូនរបស់យើងវិលវិញ តើគេ នឹងតាមរកយើងម្តេចនឹងឃើញទៅ ?... ហ៊ឺ !... អនិច្ចា រាសីយើង អើយ ហេតុអ្វីក៏ចេះតែដាបទៅៗរាល់ថ្ងៃដូច្នេះទៅវិញ ?

CHANBOKEO.COM

ឃើញមីងណៃមិនស្ដី នាយកងយោធាមួយរូបនោះស្រដីបន្តទៅ ទៀតថា ៖
- គណៈភូមិ គណៈឃុំបានសង្កេតឃើញថា ដីទួលភូមិម្តុំនេះសក្តិ
សមនឹងសាងសង់ផ្ទះរបស់គណៈភូមិ ទើបយើងត្រូវប្តូរមិត្តមីងនិង
ក្រុមគ្រួសារអោយទៅនៅម៉ាកន្លែងទៀត ។ សូមរៀបចំតវ៉ាន់ដើម្បី លើកកន្លែងថ្ងៃនេះ ។
- ពុទ្ធោអើយ! អីក៏ទាន់ហាន់ដល់ម្លឹង ?
មីងណៃគិតក្នុងចិត្តតែ ម្នាក់ឯង ប៉ុន្តែមីងមិនហ៊ានប្រកែកអ្វីទេ
ក៏ឈ្ងោកមុខបីចៅស្រីដើរទៅក្រោយផ្ទះ ហៅនាងម៉ៅឲ្យមករៀប តវ៉ាន់យ៉ាងប្រញិបប្រញាប់ ។
ឯពួកកងយោធាអាវខ្មៅកន្សែងបង់ ក ខ្លះខៀវ ខ្លះក្រហម មានម៉ាក មានម៉ូដផ្សេងៗពីគ្នា
បានចេញ ដើរឆ្វាត់ឆ្វែងមើលដីធ្លីពាសពេញដីភូមិពូណាត ។ ពេលនោះ មីង
ណៃបានចាប់ភ្លឹកឃើញថា គណៈឃុំមួយរូប ក្នុងវ័យប្រមាណជាង ៤០ឆ្នាំ
ចេះតែតាមសម្លឹងមើលមុខមីងយើង មិនព្រមដាក់ភ្នែក សោះ
ធ្វើអោយមីងនឹកព្រួយរអារក្នុងចិត្តក្រៃលែង ។ បន្តិចមក មីងណៃដើរដឹកដៃមីងចន
ស្រីម៉ៅព្រមទាំងកូនងើត ដើរតាមពី ក្រោយយោធាពីររូបសំដៅខ្ទមចាស់មួយ ឯវាលស្រែ
ឆ្ងាយពីទួល ដីភូមិចាស់ប្រហែលជាងមួយគីឡូម៉ែត្រ ។ នៅទីនោះគ្មានស្រះទឹក
ទេហើយក៏គ្មានដើមឈើស៊ីផ្លែត្រឈឹងត្រឈៃដូចមុនដែរ មើលទៅ
គ្មានសក្តិសមជាទីរស់នៅអ្វីបន្តិចសោះ ប៉ុន្តែតើនរណាម្នាក់ទៅហ៊ាន
ប្រកែកនឹងបញ្ជារបស់អង្គការនោះ ? ពេលនោះ ពួកគាត់អាច
ស្ពាយយកមកបានត្រឹមតែមួយបង្វិចម្នាក់ប៉ុណ្ណោះ មិនអាចប្រមូលអ្វី
អោយបានច្រើនជាងហ្នឹងទៀតទេ ព្រោះកងយោធាមិនអនុញ្ញាត្តិ
អោយគាត់មានឱកាសរៀបចំអ្វីឡើយ ។
មីងណៃកំពុងតែដណ្តាំបាយ ស្រាប់តែពូណាតរត់មកដល់ទាំង ដង្ហក់ខ្យល់ ។
គ្រាន់តែក្រឡេកឃើញអ្នកទាំងអស់គ្នា ពូក៏យកដៃរឹត
ដើមទ្រូងរបស់គាត់ហើយស្រដីថា ៖
- ព្រះអើយ! ខ្ញុំស្មានថាយើងវង្វេងគ្នាបាត់ទៅហើយ... នេះពិតជា សំណាងមែន
ដែលគេមិនបានផ្លាស់ទៅនៅឆ្ងាយ កុំអីខ្ញុំមិនដឹងជា ទៅតាមរកអ្នកទាំងអស់គ្នានៅឯណាទេ ។
ទាំងអស់គ្នាញញឹមឡើងដែលពូណាតរកពួកគេឃើញ ។
រសៀលថ្ងៃជ្រេ ថ្ងៃនដែល...

CHANBOKEO.COM

កំពុងតែរៀបចំដួសបបរទទួលទាន ស្រាប់តែគណៈឃុំចំណាស់ ដែលធ្លាប់លួចឈរសម្លឹងមីងណៃ កាលពីថ្ងៃ ឯដីទួលភូមិចាស់នោះ បានជិះកង់តាមភ្លឺស្រែតែម្នាក់ឯង មកដល់ខ្ទមចាស់របស់មីងណៃ ។

- មិត្តប្អូន អញ្ជើញមកទីនេះមានការអ្វីដែរ ? (ពូណាតសួរ)

គណៈឃុំនោះញញឹមហើយឆ្លើយថា ៖

- គ្រាន់តែចង់មកមើលស្ថានភាពថាតើអ្នកទាំងអស់គ្នាមានការខ្វះ ខាតអ្វីខ្លះ នឹងអាលខ្ញុំប្រើកងយោធាអោយយកមកអោយ ។

មាត់ស្រដីខ្មើយៗ ឯភ្នែករបស់គណៈឃុំនោះក្រឡេវក្រឡេករេ វាំរកមីងណៃមិនឈប់ ។ ពូណាតឃើញដូច្នោះ ហាក់ដូចជាយល់ ស្ថានការណ៍ណាស់ ក៏ឆ្លើយវិញថា ៖

- យើងស្រួលបួលទេ មិត្តប្អូន! អរគុណណាស់ដែលមិត្តប្អូនមាន ទឹកចិត្តចំពោះយើង ។ សូមផ្តាំផ្ញើទៅអង្គការលើផង ដែលបញ្ជូន មិត្តប្អូនមកសួរសុខទុក្ខពួកយើង ។

ពូណាតនិយាយបញ្ចប់ តែគណៈឃុំមួយរូបនោះមិនបានស្តាប់ ទេ បែរជាងាកទៅសួរមីងណៃឯណោះ ថា ៖

- មិត្តឯងឈ្មោះអីដែរ ? អាយុប៉ុន្មាន ? មានប្តីទេ ហើយគេត្រូវ អង្គការចាត់តាំងទៅបំរើខាងណាដែរ ?

មីងណៃភ្ញាក់ព្រើតប្រហោងពោះធ្លុងតែម្តង ៖

- ពុទ្ធោអើយ! តើគេមកស៊ើបការណ៍អ្វីពីយើងហ្នឹង ? (មីងណៃ នឹកក្នុងចិត្ត)

ឃើញមីងណៃអេះអុញមិនឆ្លើយ ពូណាតក៏ឆ្លើយជំនួស ៖

- មីអូនវាឈ្មោះណៃ អាយុជាងសែហើយ មេម៉ាយបែកប្តីមិនដឹង ស្លាប់រស់ឬយ៉ាងណាទេ ឥឡូវនៅសល់តែកូននិងចៅ...

- អូហ៍! ជាងសែហើយ ? (គណៈឃុំនោះលាន់មាត់) ស្មានតែ សាមសិបអីតើ ឃើញសាច់ឈាមនៅក្មេងហើយស្រស់ស្អាត ប្លែក ខុសពីអ្នកភូមិដ៏ទៃៗនេះ ។

ពេលនោះ មីងណៃយល់ភ្លាមថាបុរសនោះមិនមែនមកស៊ើប ប្រវត្តិគាត់ទេ តាមពិតមករកញ៉ែគាត់ទៅវិញតើហ៍ ។ ថែងន្យ មីង ណៃមិនបានចូលចិត្តចរិតអកប្បកិរិយារបស់បុរសនោះឡើយ ថ្វីបើ រូបរាងរបស់គេ

CHANBOKEO.COM

សង្ហាលើសលោកគ្រូពេទ្យវិចិត្រយ៉ាងឆ្ងាយក៏ដោយ តែមីងគ្មាននិស្ស័យនឹងបុរសនោះបន្តិចសោះ ។ មើលទៅសំដីនិង ចរិតរបស់គេគោកហើយឆៅដល់ស្ងួរ ។ បើគន់មើលអោយយូរៗទៅ គឺទើសចិត្តមីងណៃរកអ្វីប្រៀបមិនបានឡើយ ។

គណៈភូមិនោះឈ្មោះគ្រេង នៅជជែកប៉ៃឡៃខឹងឯងអោយមីង ណៃជាច្រើន តែមីងមិនមានតបតអ្វីមួយម៉ាត់ទេ គ្រាន់តែទាញក្រមាទទួរហើយបីអោបចៅបន្លប់ការតក់ស្លុតនៅក្នុងចិត្តតែប៉ុណ្ណោះ ទុកអោយពូណាតជាអ្នកនិយាយបន្ថែមបន្លប់ផ្សេងៗ ។ ទំរាំបុរសនោះលា ចេញទៅវិញ ពេលជិតពាក់អាធ្រាតទៅហើយ ធ្វើអោយគ្រប់ៗគ្នា ងងុយគេងអស់កម្លាំងស្ទើរទ្រាំមិនបាន ។ រាត្រីនោះ មីងណៃរសាប់ រសល់ក្នុងចិត្តចម្លែកណាស់ លួចសំរាន្តស្រក់ទឹកភ្នែក នឹកប្តីផង នឹកកូនផង... ទើសចិត្តនឹង វត្តមានរបស់គណៈឃុំមួយរូបនោះផង ហើយក៏បារម្ភចំពោះសុវត្ថិភាពរបស់គាត់ និងគ្រប់ៗគ្នានៅក្នុងផ្ទះនោះផង ៖

- បងចិត្រអើយ... ពេលនេះ តើបងនៅឯណា ? សុខសប្បាយឬក៏ យ៉ាងណាដែរ ? ដឹងទេថាប្រពន្ធកំពុងតែនឹកបងខ្លាំងណាស់! តើ ថ្ងៃណាទើបអូនបានដឹងដំណឹងពីបង ? ត្រា ម៉ី សាល បុរី តើកូន សុខទុក្ខយ៉ាងដូចម្តេច ? មានបាយបរិភោគទេ ? កូនឈឺជាឬក៏ យ៉ាងណា ? ចុះការដើរដេករបស់កូនវិញនោះបានចល័តផ្លាស់ប្តូរ ប៉ុន្មានទីប៉ុន្មានកន្លែងហើយ ? តើថ្ងៃណា អង្គការឲ្យកូនវិលត្រឡប់ មកលេងផ្ទះម្តង ? ម៉ាក់នឹកកូនគ្រប់ៗគ្នា... ហើយបន់ស្រន់ជានិច្ចអោយកូនឆាប់បានវិលមកផ្ទះយើងជួបជុំគ្នាជាថ្មីម្តងទៀត! ម៉ាក់នៅរង់ចាំកូន..ឆាប់មកផ្ទះវិញណាំកូនណាំ... បងចិត្រ! អូននឹក បងខ្លាំងណាស់! នឹករកអ្វីប្រៀបស្មើមិនបានឡើយ... តើថ្ងៃណា យើងបានជួបគ្នាវិញ ? ប្តីសម្លាញ់! សូមផ្តល់ដំណឹងសុខទុក្ខអោយ ប្រពន្ធបានដឹងផង ណាំបងណាំ!

ទឹកភ្នែករាប់រយដំណក់ ក៏បានហូរមកមកប្រឡៃងនឹងរង្វង់មុខដ៏ស្គាំងស្គមរបស់មីងណៃ មិនអោយគាត់បានធ្មេចបានមួយស្រឡេត ណាឡើយ ពេញមួយរាត្រី ។

ព្រឹកព្រហាមថ្ងៃបន្ទាប់...

- បងណាត! (មីងណៃហៅ)

- បាទ!

- បងចេះកោរសក់ទេ ?

CHANBOKEO .COM

- ថីក៏មិនចេះ តែមីអូនចង់កោរសក់ធ្វើអ្វី ?

- ព្រោះខ្ញុំខ្លាចចៃវាមកទំនៅ ព្រោះសព្វថ្ងៃមានចៃវាមកក្រវែល ម៉្លុំៗនេះ ធ្វើអោយខ្ញុំធុញថប់ក្នុងចិត្តណាស់បង !

ពូណាតបាក់ដូចជាកាត់យល់សំដីរបស់មីងណៃភ្លាម ។ គាត់ក៏ស្ទុះរឹងស្រវាកាំបិតកោរសក់អោយមីងណៃរឹង ។ ស្រីម៉ៅនៅអង្គុយ បំបៅកូនក្បែរនោះ ធ្វើមុខស្រឡាំងកាំងមួយស្របក់ ក៏ពោលថា ៖

- បើដូច្នោះ ម៉ៅសុំអីប្រុសកោរសក់អោយម៉ៅផង បានទេអី ?

- ពុទ្ធោ ! ទៅទាំងប្ដីទាំងស្ករតែម្ដងឬអ្វី ថ្ងៃនេះ ?

ពូណាតលាន់មាត់ ប៉ុន្តែគាត់មិនប្រកែកទេ ។ មួយស្របក់ ក្រោយមក គាត់ក៏កោរសក់អោយអ្នកទាំងពីររួចរាល់ ។ កំពុងតែ ចាប់ផ្ដើមរើកបំរុងដើរទៅការដ្ឋានការងាររបស់គាត់ទៅហើយ ស្រាប់ តែ មិត្តគ្រងគណៈយុំយោធានោះជិះកង់មកដល់តែម្នាក់ឯង ៖

- អឺ ! អ្នកផ្ទះ នៅមិនទាន់ចេញទៅធ្វើការទេ ?

បុរសនោះស្រែកឡើង ។ អ្នកទាំងអស់ក៏ប្រញាប់ប្រញាល់រៀប ខ្លួនចែកផ្លូវគ្នាចេញទៅ ។ ស្រីម៉ៅរត់មុនគេ តាមផ្លូវក្រោយសំដៅ ទៅស្រិតអង្ករនៅសហករណ៍បាត់ទៅ ។ ឯមីងណៃបីចៅនៅដៃម្ខាង ដឹកដៃមីងថននៅដៃម្ខាង ដើរចេញទៅដែរ ។ ពូណាតក៏ឈ្ងោកមុខ គេចចេញទៅម្ខាង មិនមាននរណាឆ្លើយទៅនាយចំណាស់គណៈយុំ នោះឡើយ ។ ដោយឃើញពួកគេនាំគ្នាគេចមិនព្រមអើពើនឹងវ ត្តមានរបស់ខ្លួន មិត្តគណៈយុំនោះខឹងក្រេវតែម្ដង ។

- នែ៎ ! កើតអីហ្នឹង បានជាមិនមាននរណានិយាយអ្វីជាមួយយើង មួយម៉ាត់អញ្ចឹង ?

មិត្តគ្រងសួរទាំងមុខក្រហម រួចហើយក៏យកដៃកៀសក្រមា ដែលមីងណៃទទូរនោះ បំបែរមុខគាត់អោយនិយាយរកខ្លួន ស្រាប់ តែមិត្តគណៈយុំនោះភ្ញាក់ក្រញាង លាន់មាត់ថា ៖

- យី ! មិត្តឯងកើតអីហ្នឹងបានជាកោរសក់ ? មើលដោះក្រមាចេញ អោយយើងមើលអោយច្បាស់បន្តិចមើល !

មីងណៃភ័យស្លុតក្នុងចិត្តតែម្ដង តែខំទប់ស្មារតី នៅស្ងៀមមិន ហ៊ានតបតនឹងនាយធំម្នាក់នោះ ។

CHANBOKEO.COM

- មើល! ស្តាប់ភាសាមនុស្សមិនបានទេហីយ៉ាំងម៉េច ? ឆាប់ដោះ ក្រមាមកមើល៍
យើងសុំមើលមុខមិត្តឯងបន្តិច! (មិត្តគ្រេងគំហក)

មីងណៃបែរទៅរកពូណាត រកកម្លាំងចិត្ត ហើយក៏ព្រលែងដៃ មីងថន
រួចយកដៃមកទាញក្រមាចេញពីក្បាល ។

- ងាប់ហើយ ហេតុអ្វីក៏អស់រលីងយ៉ាំងនេះ ? (មិត្តគ្រេងស្រែក ទំនងខកចិត្ត) អាណាគេថ្លើមធំ
មកហ៊ានកោរសក់អោយមិត្តឯង រខិញរខុញពេញក្បាលអញ្ចឹង ?

- គឺខ្ញុំកោរដោយខ្លួនឯង (មីងណៃឆ្លើយ)

- កុហក!

គណៈឃុំនោះក៏យកដៃទះកំភ្លៀងមីងណៃផាំង ធ្វើអោយមីង ច្រឡោតដួលទោម្ខាង
វិះជ្រុះកូនង៉ានាងម៉ៅពីដៃ ។

- ឆាប់ប្រាប់មក៏! មិត្តឯងអោយនរណាគេកោរក្បាលអោយឡើង អាក្រក់អស់បែបនេះ ?
ម្សិលមិញ ស្អាតសមសួន គួរអោយបេតី
តែថ្ងៃនេះ បែរជាមានមុខដូចប្រេតអត់បាយ...

កោតតែគេហ៊ានបារដោយគ្មានសតិសោះ! បុរសនោះគិតតែពី និយាយរ៉ូងរ៉ាំង
មិនគិតពីចិត្តនរណា អារម្មណ៍នរណាទេ ។ គេយក អារម្មណ៍របស់គេ
ជាគោលកាត់សេចក្តីជីវិតអ្នកដទៃតែប៉ុណ្ណោះ ។

ទ្រាំនឹងភាពយង់ឃ្នងរបស់មិត្តគ្រេង លើមីងណៃមិនបាន ពូ ណាតក៏ដាក់ថាំងទឹកចុះ
ហើយបែរក្រោយឆ្លើយថា ៖

- ការពិត គឺខ្ញុំជាអ្នកកោរសក់អោយ... សូមមិត្តកុំវាយមិត្តណៃអី!

- អូហ៍ សារភាពហើយហ្អេស ? ម៉េចបានជាកោរអោយគេ ?

- ព្រោះមិត្តណៃកើតចៃ... អត់សាប៊ូកក់ទើបកោរសក់ទៅ ។

ឮដូច្នោះ មិត្តគ្រេងបែរមកសម្លឹងមុខមីងណៃ រួចសួរបន្តថា ៖

- កាលពីម្សិលមិញ យើងសួរថាមិត្តចាខ្វះអីខ្លះ ហេតុអ្វីក៏ឆ្លើយ ថា មានអស់ហើយ ?

- គឺ... ពួកយើងមិនហ៊ានរំខានមិត្តបង ចំពោះរឿងតូចតាចយ៉ាំង នោះ (មីងណៃឆ្លើយ)

មិត្តនោះសម្លក់មីងណៃ ហើយក៏ដើរទៅជិតពូណាត ស្រដីថា ៖

- មិត្តឯងថ្លើមធំធ្វើបានតែម្តងនេះទេ ។ ថ្ងៃក្រោយកុំធ្វើទៀត ឮ ហើយនៅ ?

CHANBOKEO.COM

ផាំង! ពូណាតស្ទាយមុខល្អូក ដួលទៅលើដីគ្រាំង! មិត្តគ្រេង ទាញចុងកាំភ្លើងខ្លីមកផ្លុំបង្ហួតទំនងសម្លុតស្មារតីអ្នកទាំងអស់ ហើយ ក៏ហក់ឡើងកង់ត្រឡប់ចេញទៅវិញទៅ ។

- បងណាត! (មីងថនទ្រហោរឡើង ហើយប្រវាប្រវារត់ទៅរកប្ដី ដែលដួលនៅលើដី)

គ្រាន់តែឮសម្លេងទ្រហោរយំរបស់មីងថនភ្លាម មិត្តគ្រេងក៏ទុច ដំណើររួចបត់កង់បែរក្រោយលើកកាំភ្លើងភ្ជង់ ៖

- ម៉េចហ្នឹង ? ទ្រហោរយំអាលោះអាល័យ ចង់ទៅតាមគ្នាណាស់ មែនទេ ? នេះយកមួយទៅ កុំនៅតម្លង់ ទើសត្រចៀកណាស់!

ផ្ទុង! មីងថនដែលព្រួលទៅលើពូណាតទាំងជំហរ ។ មីងណៃ តក់ស្លុតតក្កមាដែលប្រទះហេតុការណ៍យ៉ាងទន់ហន់ដូច្នោះ ។ គាត់ ស្ងួតទឹកមាត់អស់រលីង រកធ្វើអ្វីមិនកើតឡើយ ក្រៅតែពីអង្គុយនៅ ដី បីចៅស្រីទាំងញ័រដៃញ័រជើង ។ ស្រាប់តែមិត្តគ្រេងបែរមករក មីងហើយញញឹមដាក់គាត់ធ្វើមិនដឹង ទំនងចង់ប្រាប់ថា គេរីករាយ ណាស់ដែលគ្មានពូណាតនិងមីងថននៅទើសមុខគេតទៅទៀត ។

ក្រោយពីមិត្តគ្រេងជិះកង់ចេញទៅបាត់ មីងណៃក៏ដាក់ចៅចុះ ហើយស្រវាចបកាប់ជីកដីកប់សពទាំងពីរ នៅក្បែរកាច់ជ្រុងភ្លឺស្រែ មិនឆ្ងាយពីខ្ទមប៉ុន្មានឡើយ ។

- បងណាត! បងថន! ប្អូនជំពាក់គុណបងច្រើនណាស់! ជាតិ នេះ ប្អូនគ្មានឱកាសបានសងគុណបងទេ ។ បើជាតិក្រោយមាន មែន សូមអោយប្អូនមានឱកាសសងគុណបងទាំងពីរវិញផង ។

មីងយើងកាយដីកប់សពបណ្ដើរ យំបណ្ដើរ ដង្ហក់ខ្យល់ស្ទើរតែ ដាច់ដង្ហើមខ្លួនឯងម្ដងៗបណ្ដើរ ។ ថ្ងៃនោះ គាត់មិនបានទៅធ្វើ ការទេ ព្រោះអាល័យតែកប់សពពូណាតនិងមីងថន ម្ល៉ោះហើយពួក កងឈ្លបយាមការដ្ឋានបាយរួម មិនព្រមបើកបបរអោយមីងពិសារ ឡើយ ។

មីងណៃត្រូវបង្ខំចិត្តដើរត្រឡប់មកខ្ទមវិញទាំងពោះទទេ...

ស្រីម៉ៅឃើញម្ដាយអត់មានរបបអាហារ ក៏ដួសរំលែកចំណែករបស់ នាងចែកទៅម្ដាយ តែមីងណៃគ្រវីក្បាល ៖

- អរគុណណាស់ម៉ៅ! ម៉ែមិនអីទេកូន! ម៉ៅមានកូនតូច ត្រូវតែ បរិភោគអោយគ្រប់គ្រាន់ ។ បន្តិច ចាំម៉ែទៅលួចបេះននោងស្ងោរ ហុត នោះម៉ែនឹងបាត់ឃ្លានហើយ ។

CHANBOKEO.COM

មីងណៃនិយាយផ្ដល់កម្លាំងចិត្តកូនស្រី មិនអោយនាងបាក់ទឹក
ចិត្តព្រោះការតក់ស្លុតនឹងហេតុការណ៍អ្វីទាំងឡាយ ដែលកើតឡើង
ក្នុងជីវិតរបស់នាងប៉ុន្មានខែកន្លងមកនេះ ។ តាមការពិតទៅនោះ គាត់មិនហ៊ានទៅលួចបេះទេ
ព្រោះខ្លាច...
រសៀលថ្ងៃដដែលនោះ មីងណៃខំត្រដេរត្រដរទៅធ្វើការវិញ ទាំងអស់កម្លាំងល្ហើយ ។
គាត់ចងចៅស្រីនឹងក្រមាឆ្នូតពីមុខ រួច ហើយប្រឹងរែកជីរទាំងហត់គយូស
មិនហ៊ានសំរាកឡើយ ។ យប់ នោះ មីងមានអារម្មណ៍ថាហេវហត់ចម្លែកណាស់ ។ មែនហើយ!
មីងណៃអត់បានទទួលអាហារព្រឹកផង តក់ស្លុតនឹងមរណភាពរបស់ ពូណាតមីងចនផង
ធ្វើការច្រើនហួសកម្លាំងផង... ទើបបានជា ដូច្នោះ ។
គាត់គិតថាប្រហែលជាគាត់រត់មិនផុតយប់នោះទេ...
ចៃដន្យ ស្រាប់តែមានសតិមួយមកដាស់គាត់ភ្លាម ៖
- ណៃអើយ! កុំបណ្ដោយអោយអ្វីៗជុំវិញខ្លួនបំបាក់កម្លាំងចិត្តនាង បានអោយសោះ ។
នាងមិនមែនជាបងាចារទេ ហើយក៏មិនមែនជា មនុស្សកម្លោលល្ងង់ឆប់ជិតដែរ ។
នាងត្រូវតែប្រើសតិបញ្ញា ដោះ ស្រាយជីវិតនាងឡើង ។ ពិតមែនតែប្ដីនិងកូនចៅរបស់នាង បាន
បែកពីនាងទៅមែន... តែគេមិនទាន់ស្លាប់ឯណា ? បើនាងដេក
អស់សង្ឃឹមផ្ដេកផ្ដួលស្លាប់បាត់ទៅ តិចលោកូនចៅគេខកចិត្តពេល
គេត្រឡប់មកផ្ទះរកនាងមិនឃើញ...! ឯប្ដីនាងវិញ តើគេនឹងខក ចិត្តយ៉ាងណា
កាលបើប្រពន្ធរបស់គេគ្មានសតិរឹងប៉ឹង រង់ចាំការវិល ត្រឡប់របស់ប្ដីនោះ ?
- តើអោយខ្ញុំធ្វើយ៉ាងណា ? (ណៃសួរសតិរបស់ខ្លួនឯង) មធ្យោ បាយស្រាយពោះនោះ
មានតែម្យ៉ាងទេ គឺលួច... ហើយលួចនោះ គឺជាអំពើឧក្រិដ្ឋកម្ម...
- ណៃអើយ! ពួកដែលប្លន់យករបស់របរអ្វីៗពីយើងទាំងរំលោភ នោះទេតើដែលជាឧក្រិដ្ឋជន ។
យើងគ្រាន់តែលួចរបស់ដែលយើង ដាំដោយកម្លាំងឯងកៀនៗផ្ទះ នោះយើងមិនមែនជាឧក្រិដ្ឋជន
ដូច អង្គការបានចោទយើងនោះទេ ។ យើងលួចខ្លួនឯង ព្រោះជីវិត
យើងស្ថិតនៅក្រោមការគម្រាមកំហែងនៃអង្គការឧក្រិដ្ឋ ។ បើអ្នក មិនធ្វើ នោះអ្នកនឹងស្លាប់
លែងបានជួបមុខមនុស្សជាទីស្រឡាញ់ របស់អ្នកហើយ ។

CHANBOKEO.COM

មីងណៃគិតឃើញដូច្នោះ ក៏ដាច់ចិត្តដើរចេញពីខ្ទមចេញលួច
បេះដំណាំរបស់គាត់ជាលើកដំបូង ។ មីងយើងប្រឹងធ្វើទាំងញ័រដៃ ញ័រជើង
ខ្លាចពពួកភ្នែកច្រមុះអង្គការចាប់ពិរុទ្ធបាន ។ បន្តិចមក គាត់ក៏ចំអិនបន្លែដួសចែកកូនស្រី ៖

- ម៉ៅ បរិភោគបន្តិចទៅកូន ។

ស្រីម៉ៅមិនហ៊ានអោយម្ដាយបាក់ទឹកចិត្តទេ ។ នាងយកស្លាប
ព្រាដួសទឹកស្ងោរបន្លែសាបៗអត់អំបិលនោះ ចំអែតពោះបណ្ដើរ លួចមើលមុខម្ដាយបណ្ដើរ ។
តាមពិត មីងណៃរឹងប៉ឹងជាងស្រីម៉ៅ ច្រើនណាស់ ទាំងប្រាជ្ញាស្មារតីនិងកម្លាំង ។
នេះបើកុំតែបានមីង ណៃ ម្ល៉េះសមស្រីម៉ៅមិននឹងជាពិបាកយ៉ាងណាទេ ។ ឃើញកូនស្រី
បរិភោគដោយអំណរ មីងណៃក៏ញញឹមឡើងលើកកម្លាំងចិត្តរបស់
កូនអោយមានអារម្មណ៍រឹងប៉ឹងមកវិញ ។

នៅរំលងពាក់អាធ្រាត...

មីងណៃដើរចេញមកពីលួចជីកដំឡូងនៅក្រោយផ្ទះ បំរុងថានឹង ទុកយកទៅដូរត្រីអ្នកស្រុក
យកមកអោយស្រីម៉ៅបរិភោគ ព្រោះ នាងកាន់តែស្គមទៅៗរាល់ថ្ងៃ មើលមិនយល់ ។
ស្រាប់តែមានដៃ មួយមកខ្ទប់មាត់មីងយើង អូសចេញសំដៅគុម្ពោតមួយយ៉ាងលឿន តែម្ដង ។
មីងណៃភិតភ័យណាស់ ក៏ប្រឹងរើបម្រះយ៉ាងអស់ទំហឹង តែរើមិនរួច
ដោយព្រោះភាពស្គាំងស្គមរបស់គាត់ ក៏បណ្ដោយឲ្យ
មនុស្សម្នាក់នោះអូសគាត់ចូលគុម្ពោតមួយកៀនភ្លឺស្រែ ។

- ណៃ! គឺបងទេតើហ៎ អូន!

មីងណៃភ្ញាក់ព្រើត ស្ដាប់សំដីមួយនោះបានភ្លាម ៖

- បងចិត្រ ? (មីងណៃលាន់មាត់ខ្សឹបៗ)
- មែនហើយ! គឺបង!
- ប្ដីសម្លាញ់! អូននឹកបងណាស់!

មីងណៃស្រវាអោបប្ដីរបស់គាត់យ៉ាងណែន ដោយដួងចិត្តរំភើប
រហូតដល់ស្រក់ទឹកភ្នែកមិនដឹងខ្លួន ។ អ្នកទាំងពីរស្រវាអោបគ្នាទៅ
វិញទៅមកយ៉ាងយូរព្រោះតែក្ដីនឹករលឹកចំពោះគ្នាក្រៃលែង ។ មីង
ណៃរកនឹកពាក្យអ្វីមកនិយាយមិនចេញទេ ក្រៅតែពីបណ្ដោយអោយ
ចង្វាក់បេះដូងដ៏សែនរន្ធត់ញាប់ញ័ររបស់គាត់ ឆ្លើយសាសងតបទៅ

CHANBOKEO.COM

សំនៀងរណ្តំរបស់បេះដូងលោកគ្រូពេទ្យ ជាជំនួសវិញតែម្យ៉ាង ប៉ុណ្ណោះ ។ ពេលនោះ មីងយើងត្រេកអរសោមនស្សក្នុងចិត្តឥត ឧបមា ។ ភាពល្ងង់ល្ងើយអស់កម្លាំង កាលពីព្រលប់នោះ ក៏រលាយ អស់រលីង នៅសល់តែដួងចិត្តដ៏សែនរំភើបរីករាយឥតអ្វីប្រៀប បាន ។

ក្រោយពីផ្ទាក់ផ្ទមដួងចិត្តរបស់គ្នាទៅវិញទៅមក អស់ជា យូរម៉ោងកន្លងទៅ... មីងណៃក៏សួរលោកគ្រូពេទ្យថា ៖

- ហេតុអ្វី បងមករកអូនឃើញ ?
- គឺបងបានមកលួចតាមដានអូនពីរបីថ្ងៃហើយ ។
- តើពេលនេះ បងជ្រកពួនឯណាដែរ ?
- បងនៅរនាម ជាមួយពួកខ្មែរសមួយក្រុម...
- ហើយចុះប៊ុរី... ?
- យើងត្រូវពួកខ្មែរក្រហមដេញបាញ់ កាលពីថ្ងៃដែលយើងរត់ ចេញពីភូមិវាលទ្រានេះទៅ ។ ប៊ុរីក៏រត់បែកខ្ញែកផ្លូវពីបង វង្វេងគ្នា តាំងពីថ្ងៃនោះមកម្ល៉េះ ។ មិនដឹងថា គេមានសុខទុក្ខយ៉ាងណាហើយ ទេ ពេលនេះ ។ តែអូនកុំទាន់ប្រាប់អ្វីដល់ស្រីម៉ៅអី ក្រែងកូនយើង គ្នាពិបាកចិត្ត ។ នៅស្ងៀមៗធ្វើធម្មតាសិនទៅ ។

មីងណៃផ្ទេកកេសាលើស្មាប្តី ទទួលសេចក្តីសុខជាថ្មី ក្នុងរង្វង់ ដៃដ៏សែនកក់ក្តៅរបស់លោកគ្រូពេទ្យ ។

- អូននឹក... ហើយបារម្ភពីបងណាស់ បងដឹងទេ ?
- បាទ! បងក៏នឹកអូនរាល់ថ្ងៃដូចគ្នាដែរ ។

លោកគ្រូពេទ្យស្រដីផង ថៃថើបភរិយាផងដោយក្តីរលីក ។

- ចុះបងទៅវិញអង្កាល់ ? (មីងណៃសួរ)
- បន្តិចទៀត បងទៅវិញហើយ ។ ណេះ! អូនយករបស់នេះទុក តាមខ្លួនទៅ ក្រែងលោអូនត្រូវការដោះទាល់ម្តងមួយយាម ។

លោកគ្រូពេទ្យចាប់ដៃប្រពន្ធដាក់របស់អោយ ៖

- គឺជាមាសពីរតម្លឹងដែលបងដូរត្រីបាន ។ បើថ្ងៃក្រោយមាន ឱកាស បងនឹងលួចមកសួរសុខទុក្ខអូនទៀត ។ អូហ៍.. ហើយ ម៉េចបានជាអូនកោរសក់អស់អញ្ចឹង ណៃ ?
- ព្រោះ... ថៃវាតាមបឺតឈាមណៃពេកនោះអី ?
- សង្ស័យតែថៃឈ្មោលហើយ !

CHANBOKEO.COM

- យី! ម៉េចក៏បងនឹងកើត ?

- ព្រោះប្រពន្ធបងស្អាតនោះអី... ណៃ! អូនកោរសក់ដូច្នេះ ល្អហើយ ដើម្បីកុំអោយមានគេលួចឆក់យកអូនពីបេះដូងបងទៅ...

មីងណៃញញឹម ៖

- ឆក់យ៉ាងណាក៏មិនទៅដែរ ព្រោះណៃស្រឡាញ់តែបងចិត្រម្នាក់គត់ គ្មានថ្ងៃប្តូរចិត្តបានឡើយ ។

ឮដូច្នេះ លោកគ្រូពេទ្យរំភើបចិត្តណាស់ ក៏ឈ្ងោកអោនថើបភរិយាជាថ្មីម្តងទៀតដោយចិត្តស្នេហាយ៉ាងធំធេង ។ មីងណៃក៏បិទភ្នែកទទួលយកនូវសុភមង្គលដ៏កក់ក្តៅនោះ យ៉ាងពេញចិត្តពេញ ថ្លើម ។ ថ្វីបើការជួបគ្នារបស់គាត់មានរយៈពេលខ្លី តែវាជាពេលដ៏មានតម្លៃបំផុតសម្រាប់លោកគ្រូពេទ្យនិងភរិយា ។

- ថែខ្លួនណា៎បង! (មីងណៃផ្តែផ្តាំ)

- បាទ! អូនក៏អញ្ចឹងដែរ ។ អូនត្រូវតែរក្សាចិត្តអោយរឹងប៉ឹងឡើង ណា៎ ។ មិនយូរមិនឆាប់ យើងនឹងបានរស់នៅជួបជុំគ្នាសាជាថ្មីទៀត មិនខាន ។

- ចា៎សបង!

លោកគ្រូពេទ្យដើបឡើងបំរុងនឹងដើរលបៗចេញទៅ ស្រាប់តែមានពិលឈ្មួលឆ្វាចៗមកលើអ្នកទាំងពីរ ព្រមទាំងសម្រែកសួរ មកថា ៖

- នរណា ? ធ្វើអីហ្នឹង ?

លោកគ្រូពេទ្យខំរត់គេចទៅម្ខាងយ៉ាងរហ័ស តែគេចមិនទាន់ ត្រូវយោធាម្នាក់នោះបញ្ចាំងពិលចំឃើញលោកភ្លាម ។

- ឈប់សិន! កុំរត់ទៅណា៎!

តែលោកគ្រូពេទ្យមិនព្រមឈប់ទេ គិតតែពីរត់គេចថែមទៀត ស្រាប់តែយោធានោះលើកកាំភ្លើងបាញ់ផាំង ចំកំភួនជើងស្តាំរបស់ លោកគ្រូពេទ្យដួលប្រួសទៅដីខ្វាយឈាមព្រាត ។

- បងចិត្រ!

មីងណៃឧទានខ្សិបៗក្នុងមាត់ ហើយក៏ស្ទុះរត់ទៅឃាត់ ៖

- មិត្តបង! កុំបាញ់គាត់អី !

CHIANBOKEO.COM

យោធានោះក៏លើកពិលឈ្លួលមុខមីងណៃ ស្រាប់តែលាន់មាត់ ឡើងថា ៖

- មិត្តណៃទេហ្អ៊ែស ? ហេតុអ្វីមកលាក់ខ្លួនទីនេះ ជាមួយបុរស អញ្ចឹង ? នឹងទេថាវាខុសសីលធម៌... ត្រូវទោសកំទេចចោល ?

ក្នុងរបបខ្មែរក្រហម ពាក្យថាកំទេចចោលមានន័យថា សម្លេះ ជីវិត ។ មីងណៃឮដូច្នោះ ក៏ញ័រខ្លួនគគ្រីកឡើងដោយក្តីតក់ស្លុត តែក៏ខំកាត់ចិត្តរកវិធីអង្វរដើម្បីជួយយកអាសារជីវិតរបស់ប្តី ។

- ខ្ញុំមិនបានលាក់ខ្លួនអ្វី ជាមួយបុរសនេះទេ ។ ខ្ញុំមករកជីកដីបត់ ជើង ហើយគាត់ក៏មករកបត់ជើងដែរ ទើបដើរជំពប់គ្នាធ្លាក់ពីលើភ្លឺ ស្រែមក.. ទទួលពេលនោះ មិត្តបងមកដល់ល្មម ។

មិត្តយោធាម្នាក់នោះ រេពិលចុះឡើង ធ្វើអោយមីងណៃឃើញ មុខបុរសនោះច្បាស់តែម្តង គឺគ្មាននរណាក្រៅពីមិត្តគ្រេង គណៈឃុំ មួយរូបនោះឡើយ ។

- តើមិត្តគ្រេងមកទីនេះធ្វើអ្វីទាំងយប់ ? (មីងណៃនឹកឆ្ងល់ក្នុង ចិត្ត) ឬក៏មកលបលួចតាមដានសកម្មភាពរបស់ខ្ញុំ ?

រំពេចនោះ មិត្តគ្រេងស្រដីថា ៖

- កុហក! ប្រាប់ភ្លាមមកថាគេជាប្តីរបស់មិត្តណៃឯង!

- មិនមែនទេ មិត្តបង! (មីងណៃប្រកែក)

- ច្បាស់ហើយហ្អែស ? (មិត្តគ្រេងសួរផ្ទាន់)

- ច្បាស់ហើយ! (មីងណៃតប) សូមមិត្តបងដោះលែងគេទៅ... គេគ្មានកំហុសអ្វីទេ ។

- យើងមិនជឿទេ! បើមិត្តម្នាក់នេះមិនមែនជាប្តីរបស់មិត្តណៃឯង ហេតុម្តេចក៏ហ៊ានចេញមុខការពារគេម្ល៉េះ ?

មីងណៃរន្ធត់ចិត្តណាស់ ដែលត្រូវមិត្តគ្រេងគណៈឃុំជាន់កែង យ៉ាងដូច្នោះ តែគាត់ក៏បារម្ភដល់សុវត្ថិភាពរបស់លោកគ្រូពេទ្យខ្លាំង ណាស់ដែរ ។ ឃើញយោធាឈរភ្ជង់ប្តីរបស់គាត់ មិនព្រមដាក់ កាំភ្លើងសោះ មីងក៏លើកដៃសំពះអង្វរឡើង ៖

- មិត្តបងអើយ! កុំសម្លាប់មនុស្សដែលគ្មានទោសអី! ការពិត ខុសមកពីខ្ញុំទេ ដែលដើរជល់គាត់មុនធ្វើអោយគាត់ដួលគ្រេចជើង ទើបបានជារឿងអញ្ចឹងទៅ! វណ្ណៈដូចមិត្តបង មិនបាច់ប្រើកាំភ្លើង នាំតែអស់គ្រាប់ទេ ។ មើលចុះ! គេស្គមហើយចាស់ទៀត ថែម ទាំងកំបាក់កំពុកយ៉ាងដូច្នេះ តើគួរអោយស្រឡាញ់ម្តេចកើត ?

CHANBOKEO.COM

មិត្តគ្រេងមិនអស់ចិត្តនឹងកិរិយាមីងណៃទេ ។ នាយនោះជ្រួញ ចិញ្ចើមមួយស្របក់ក៏និយាយថា ៖

- បើជនម្នាក់នេះមិនមែនជាប្ដីរបស់មិត្តណៃ តើប្ដីរបស់មិត្តមែន ទែននៅឯណាដែរ ?
- គឺ...ខ្ញុំមិនដឹងទេ ព្រោះបែកគ្នាតាំងពីថ្ងៃដែលអង្គការរំដោះយក ប្រទេសខ្មែរបានម្ល៉េះ ។
- មានន័យថា មិត្តណៃជាស្រីមេម៉ាយ មែនទេ ?
- មិនចំទេ ព្រោះមិនទាន់ដឹងថា គាត់ស្លាប់ឬរស់នៅឡើយ...
- ប៉ុន្តែយើងមានអ្វីអោយមិត្តណៃធ្វើការពិសោធន៍ ថាមិត្តណៃពិតជា និយាយស្មោះចំពោះអង្គការដែរឬទេ ?
- អោយខ្ញុំធ្វើយ៉ាងណា ក៏បាន សុំអោយតែមិត្តបងសូមដោះលែង បុរសនេះទៅណា៎!
- មែនហ្អ៎ស ? ធ្វើយ៉ាងណាក៏បាន មែនហ្អ៎ស ?
- ចា៎ស...ពិតហើយ!
- បើដូច្នេះ មិត្តណៃឯងហ៊ានចាប់ដៃរៀបការជាប្រពន្ធរបស់យើង ទេ ? បើសុខចិត្ត នោះយើងនឹងដោះលែងគេឥឡូវនេះភ្លាម ។

មីងណៃអេះអុញ ។ លុះបែរមើលទៅប្ដីរបស់នាងឃើញលោក គ្រូពេទ្យបែកញើសសស្រាក់ ដោយក្ដីឈឺចាប់ ។ កាលបើឮពាក្យ សម្ដុតរបស់មិត្តយោធានោះ លោកគ្រូពេទ្យក៏ស្រដីឃាត់ប្រពន្ធ ៖

- ណៃ! កុំធ្វើតាមគេអី...!
- ចេះតវ៉ាស្អីដែរ មិត្តឯង ? (មិត្តគ្រេងគំហកអោយលោកគ្រូ ពេទ្យ) នៅឲ្យស្ងៀម! យើងមិនបានសួរមិត្តឯងទេ! យើងសួរ មិត្តណៃតើហ៎!

ផាំង! ផាំង! មិត្តគ្រេងបាញ់រះ បញ្ឆិតក្បាលលោកគ្រូពេទ្យ ។

- កុំ!... (មីងណៃស្រែកភ្លាត់សម្លេង ហើយលុតជង្គង់ចុះ យកដៃ កាន់ចុងកាំភ្លើងមិត្តគ្រេង លុតជង្គង់សំពះអង្វរភ្លាមតែម្ដង) កុំអី... ណៃយល់ព្រមតាមមិត្តបងហើយ! សូមដោះលែងគាត់ទៅ...
- ណៃ! (លោកគ្រូពេទ្យស្រែកទាំងរន្ធត់ ត្បិតហួសចិត្តដែលមីង ណៃចាញ់សម្ដុតគេ ហើយដែលលោកគ្មានលទ្ធភាពនឹងជួយអ្វីបាន)
- ហ៊ាសៗ! ល្អ! ព្រហាមនេះ មិត្តណៃឯងត្រៀមខ្លួនទៅ!

CHANBOKEO.COM

មិតគ្រែងសើចរលាក់យ៉ាងសប្បាយ ។ ពេលនោះ លោកគ្រូពេទ្យនិយាយអ្វីលែងចេញហើយ ។ លោកសម្លឹងមុខប្រពន្ធយ៉ាង យូរ ថែមទាំងគិតក្នុងចិត្តថា ៖

- ហេតុអ្វីអូនធ្វើយ៉ាងនេះ ណៃ ? ដឹងទេ ថាចម្លើយរបស់អូនមួយ ម៉ាត់នេះ មិនខុសពីអូនយកកាំភ្លើងមកបាញ់សម្លាប់ជីវិតរបស់បង ទាំងរស់នោះឡើយ ។

លោកគ្រូពេទ្យញាប់ញ័រក្នុងចិត្តណាស់ នឹងរកពាក្យអ្វីមកស្រដី មិនបានទេ ។ ចំណែកមីងណៃវិញ រិតតែតក់ស្លុតណាស់ទៅទៀត ត្បិតគាត់មិនត្រឹមតែបារម្ភពីការព្រាត់ប្រាសស្វាមីរបស់គាត់ទេ ថែមទាំងត្រូវមកមានចំណងជាមួយមនុស្សដែលមីងស្អប់បំផុតនោះថែមទៀតផង ។

- នៅអេះអុញស្អីទៀត ម៉េចក៏មិត្តឯងមិនចេញទៅ ? (មិត្តគ្រែង ដេញលោកគ្រូពេទ្យ) ទៅហើយ កុំត្រឡប់មកអោយមើសមុខទើស មាត់យើងសាជាថ្មីឲ្យសោះ ឮហើយនៅ ? បើមិនស្ដាប់... គឺងាប់ !

លោកគ្រូពេទ្យសម្លឹងមុខមីងណៃមួយស្របក់ សម្ដែងនូវក្ដីឈឺ ចាប់និងក្ដីអស់សង្ឃឹមក្នុងចិត្ត រួចហើយក៏ប្រឹងក្រោកដើរតតេះតតះ ចេញទៅ...
មីងណៃសម្លឹងតាមមើលស្រមោលលោកគ្រូពេទ្យពី ក្រោយ ទាំងឱរាន្ធត់ញាប់ញ័រ រួចហើយប្រឹងលេបទឹកភ្នែកក្ដឹកៗ លាក់អារម្មណ៍ មិនអោយបុរសចិត្តកំណាចនោះបានឃើញឡើយ ថ្វីបើគាត់ចង់តែស្រែកទ្រហោរយំឲ្យបែកអាកាសយ៉ាងណាក៏ដោយ...

តើស្រីមួយណាទៅដែលមិនស្រឡាញ់ប្ដី ? តើស្រីមួយណាទៅដែលសុខចិត្តអោយគេបាញ់សម្លាប់ប្ដីនៅនឹងមុខកើតនោះ ? ថ្វីបើ ពេលនេះ មីងណៃដឹងថាលោកគ្រូពេទ្យខឹងច្រឡោតនឹងមីងយ៉ាង ណាក៏ដោយ ក៏មីងមិនអាចបណ្ដោយអោយមិត្តគ្រែងលើកកាំភ្លើងកេះកៃសម្លាប់ប្ដីរបស់គាត់នៅនឹងមុខដូច្នោះបានជាដាច់ខាត ។ មីង សុខចិត្តពលីសព្វបែបយ៉ាងដើម្បីអោយប្ដីគាត់បានរស់រានមានជីវិត រស់ដើម្បីទៅតាមថែរក្សាកូនរបស់គាត់ទាំងឡាយដែលបាត់ខ្លួនទៅ.. គាត់សុខចិត្តបូជាខ្លួនគាត់ដើម្បីប្ដូរសុំជីវិត អោយប្ដីបានរស់នៅ សាជាថ្មីម្ដងទៀត...

ឱ! នេះហើយឬ រសជាតិរបបខ្មែរក្រហមរំដោះកម្ពុជា ?

CHANBOKEO.COM

*ooooooooooooooooooooo*

*oooooo*

*o*

CHANBOKEO.COM

# វគ្គទី៧
# កម្លាំងចិត្ត

ដងស្ទឹងសង្កែ ក្រុងបាត់ដំបង...

ខែមិនា ១៩៧៩...

មីងណៃដើរដឹកដៃចៅដើរចេញពីរបងផ្ទះផុតមក ទាំងដួងចិត្តសែនមហាក្រៀមក្រំពោរពេញទៅដោយសេចក្តីទុក្ខយ៉ាងជ្រៅ រកអ្វីមកប្រៀបស្មើមិនបានឡើយ ។ ជើងគាត់ដើរទៅមុខពិតមែន ប៉ុន្តែចិត្តរបស់គាត់នៅផ្ញើឯផ្ទះចាស់របស់គាត់ឯណោះ... លុះដើរចេញ មកបានប្រហែលជាង៥០ម៉ែត្រស្រាប់តែគាត់គាំងជើងដើរទៅ ទៀតលែងរួចតែម្តង ។ មីងណៃក៏ទ្រោបមុខលើគល់ឈើដ៏ធំមួយនៅមាត់ស្ទឹង សម្រក់ទឹកភ្នែកយ៉ាងខ្លោចផ្សា...

ពេលនោះ មីងណៃមានអារម្មណ៍ថា ខ្លួនគាត់កំពុងតែក្លាយខ្លួន ដូចនាងបដាចារហើយ... ប៉ុន្តែបដាចារបុរាណ ព្រាត់ព្រោះប្តីស្លាប់ កូនស្លាប់ ។ ចំពោះមីងវិញ ជាបដាចារសម័យថ្មី ខំពលីជីវិតរបស់ ខ្លួនដើម្បីរក្សាជីវិតប្តី តែពេលនេះ គេបែរជាមានឱកាសសាងសុភមង្គលជាមួយស្ត្រីផ្សេង... ចំណែកកូនរបស់មីង ដើរវង្វេងបែក ចេញគ្រប់ទិសហើយគាត់ក៏គ្មានលទ្ធភាពដើរប្រមូលរូបគេ អោយ មកជួបជុំគ្នាដូចមុនវិញបាន... ខ្លួនមីងបែរមករស់អនាថាគ្មានកោះ គ្មានត្រើយ គ្មានអនាគត... មីងកណ្តោចកណ្តែងក្នុងចិត្តណាស់ ឈឺចុកចាប់ក្នុងបេះដូងណាស់... ទោះបីជាសម្រក់ទឹកភ្នែករាប់រយ លានសែនតំណក់ក៏មិនអាចបន្ធូរសេចក្តីតានតឹងសោកាក្នុងដើម ទ្រូងរបស់មីង អោយធូរស្រាលបានដែរ ។ នេះហើយឬលទ្ធផលនៃ អំណាចរបបខគ្រិដ្ឋ ខ្មែរក្រហម ? មើលចុះ គេសម្លាប់មនុស្ស គេបំបែកបំបាក់គ្រួសារ គេធ្វើអោយពលរដ្ឋខ្មែរគ្រប់ៗគ្នាក្លាយទៅជា មនុស្សពិការ ទាំងកាយទាំងចិត្ត ទាំងសតិនិងប្រាជ្ញា... នៅក្នុង នោះ មានមីងណៃនិងក្រុមគ្រួសារដែលជាជនរងគ្រោះផងដែរ ។ នេះហើយ ល្បិចបំបាក់ទឹកចិត្ត និងវិធីបំបែកកម្លាំងអ្នកតដៃ របស់

អង្គការខ្មែរក្រហម! តើពួកគេដែលកាន់អំណាចទាំងនោះមានវិបត្តិ ក្នុងជីវិតយ៉ាងណាទៅ ទើបបានជាគេក្លាយជាមនុស្សដែលគ្មានសតិ គ្មានសេចក្ដីស្រឡាញ់ គ្មានទឹកចិត្តមេត្តាចំពោះមនុស្សជាតិដូចគ្នា យ៉ាងដូច្នេះ ? តើសព្វថ្ងៃនេះ ពលរដ្ឋខ្មែរប៉ុន្មានលាននាក់ដែលបានក្លាយខ្លួនជាបដាចារស្រី បដាចារប្រុស បដាចារក្មេង បដាចារចាស់ នៅក្នុងប្រទេស ចាប់តាំងពីពួកខ្មែរក្រហមឡើងកាន់អំណាចមក ? គិតៗទៅ របបកម្មុយនិស្ត គួរអោយខ្លាចរអារណាស់!! អ្នករង គ្រោះបាក់ស្បាតនឹងរបបនេះ តែងតែដេកបន់អោយជាតិក្រោយ កើតមក បានចៀសផុតជីវិតបែបនេះទៀត ប៉ុន្តែ អ្នកកាន់អំណាច បែរជាដេកបន់អោយគេបាន កើតម្ដងទៀតក្នុងរបបដែល ព្រោះ នឹងគេមានអំណាចសព្វបែបយ៉ាង... ជាពិសេសនោះគឺ អំណាច ដែលគេអាចកាត់ក្ដីដោយមិនបាច់ប្រើតុលាការ អាចសម្លាប់មនុស្ស ដោយមិនបាច់មានហេតុផល មិនបាច់ជាប់ទោសឧក្រិដ្ឋ!!

កាលបើឃើញជីដូនស្រក់ទឹកភ្នែក យំខ្សឹកខ្សួលសោកសង្រែង ដូច្នោះ នាងតូចមុំក៏ធ្វើមុខស្លូតយកដៃអង្រួនជីដូន ៖

- ម៉េច... យាយយំអញ្ចឹង.. ?

មីងណៃឮដូច្នោះ ក៏យកដៃផ្ដិតទឹកភ្នែក ហើយសំរួតខ្លួនចុះ ស្រវាអោបចៅយ៉ាងណែន ៖

- យាយឈឺពោះបន្តិចបន្តួចទេណា៎ចៅ...កុំភ័យអី...!

មីងណៃដាក់ខ្លួនអង្គុយចុះផ្អែកនឹងដើមឈើ ទើបលើកចៅស្រី អោយអង្គុយលើភ្លៅរបស់គាត់... ឯភ្នែករបស់គាត់វិញសម្លឹងខ្សែ ទឹកហូររេញៗនៅក្នុងស្ទឹង... តើមីងណៃកំពុងគិតអ្វី ? កំពុងគិតរកធ្វើអត្តឃាតទេដឹង ?

លុះយំអស់ចិត្តអស់ចង់ហើយ មីងណៃលើកចៅពឡើង ដើរ ចុះទៅក្នុងស្ទឹង ស្រាប់តែ...

- ម៉ាក់!

ឮសម្លេងស្រែកហៅពីក្រោយ មីងណៃភ្ញាក់ព្រើតបែរមករក ម្ចាស់សម្លេង ក៏ឃើញបារមីរត់តាមពីក្រោយមកដល់ ហើយស្រវា អោបគាត់ជាប់ពេញរង្វង់ដៃរបស់នាង ៖

- ម៉ាក់! កុំសម្លាប់ខ្លួនអី..ម៉ាក់... ម៉ីស្រឡាញ់ម៉ាក់ណាស់... មិនចង់ អោយម៉ាក់ឃ្លាតទៅណាចោលកូនទេ... កូនបែកម៉ាក់យូរឆ្នាំហើយ... កូននឹកម៉ាក់ណាស់!! ម៉ាក់...!

CHANBOKEO.COM

មីងណៃរន្ធត់ចិត្តណាស់ដែលកូនរបស់គាត់នៅមានចិត្តស្រឡាញ់ គាត់ជាម្ដាយនៅឡើយ ។ មែនហើយ! មុននេះបន្តិច គាត់ហាក់ដូច ជាស្រម័យផ្ដេសផ្ដាស រកនឹកចង់ធ្វើបាបខ្លួនរំលត់ទម្ងន់ទុក្ខសោក នោះពិតមែន ។ តែពេលនេះ គាត់បានដូរចិត្តវិញហើយ កាលបើ គាត់បានឃើញមុខកូននិងបានឮពាក្យដែលកូនហៅគាត់ថា ម៉ាក់!... មួយម៉ាត់នេះបានក្លាយជាកម្លាំងចិត្ត យ៉ាងធំធេងដល់មីងណៃរបស់ យើង រកអ្វីមកប្រៀបស្មើមិនបានឡើយ ។

- ម៉ី! កូនមាសម្ដាយ! ម៉ាក់ក៏ស្រឡាញ់កូនដូចគ្នាដែរ កូន!

មីងណៃស្រវាអោបកូន យំផងសើចផង ដោយក្ដីរំភើបក្នុងចិត្ត ជាលើកដំបូង ដែលគាត់មិនដែលមានអារម្មណ៍ល្អបែបនេះ យូរឆ្នាំ មកហើយ ។ គាត់ថើបកូនស្រីរបស់គាត់ម្ដងហើយម្ដងទៀតមិនអស់ ចិត្តសោះឡើយ ។

- ម៉ាក់! អោយកូនសូមទោសដែលថ្ងៃមុនកូនរត់ចោលម៉ាក់ ដោយ មិនបានជំរាបហេតុផល...

(បារមីប្រណម្យសំពះម្ដាយសុំទោស)

មីងណៃជូតទឹកភ្នែកខ្លួនឯង ហើយក៏ជូតទឹកភ្នែកអោយកូន មួយស្របក់មកក៏មានប្រសាសន៍ថា ៖

- មិនអីទេកូន! ថ្ងៃនេះ ម៉ាក់សប្បាយចិត្តហើយ ដែលម៉ាក់បាន ជួបកូនស្រីរបស់ម៉ាក់វិញ ។

ថ្វីបើបេះដូងមួយចំណែករបស់មីងណៃនៅមានភាពអាប់អួរនៅ ឡើយ តែមួយចំណែកទៀត មីងកំពុងតែទទួលសុភមង្គលភ្លឺស្វាង ដែលកូនស្រីរបស់គាត់ វិលត្រឡប់មករកគាត់វិញ ។ នៅក្រោម ដើមអំពិលដ៏ធំមួយដើមដែលដុះប្រមាត់ស្ទឹង មីងណៃ នាំចៅស្រី និងបារមីអង្គុយចុះដើម្បីសាកសួរនាំកូនស្រីអំពីជីវិតរបស់នាង អស់ រយៈកាលជិតបួនឆ្នាំកន្លងទៅ ។

- បារមី! ពេលនេះ កូននៅជាមួយលោកប៉ាមែនទេ ?
- ចាសអត់ទេ! ខ្ញុំទើបតែជួបគាត់ថ្មីៗដែរ មិនទាន់មានឱកាស បាននិយាយអ្វីជាមួយគ្នានៅឡើយទេ ។
- អូហ៍ អញ្ចឹង កូនស្នាក់នៅឯណា ?
- នៅជាមួយមិត្តពីរបីនាក់ រត់មកជាមួយគ្នា នៅម្ដុំវត្តសូភី ។ មិត្ត ម្នាក់របស់កូនគេមានបងប្អូនមានផ្ទះនៅទីនោះ ។

CHANBOKEO.COM

- ហើយចុះកូនរកស៊ីរកចុកយ៉ាងណាដែរទៅកូន ?

- គឺកូនជួយម្ចាស់ផ្ទះធ្វើនំបញ្ចុកវែកលក់តាមភូមិ ។

- ពុទ្ធោកូនម្តាយ !

មីងណៃចាប់ដៃកូនមកអង្អែល ឃើញដៃនាងគ្រិនមើលមិន យល់ឡើយ ។

- ប៉ុន្មានឆ្នាំមកនេះ កូននឿយហត់ណាស់មែនទេ ម៉ី ?

បារមីឈ្ងោកមុខមួយស្របក់ ទើបស្រដីថា ៖

- គឺរិះតែអស់ជីវិតម្តងៗទៅហើយណា៎ម៉ាក់... ប៉ុន្តែ សំណាងកូនល្អ ទើបមានជីវិតសល់មកដល់សព្វថ្ងៃនេះ ។

- ហើយចុះកូនមានដែលបានទទួលដំណឹងអ្វីពីបងត្រានិងប្អូនសាល ដែរទេកូន ?

- កាលដំបូង... ធ្លាប់ឃើញគ្នាម្តងម្កាលដែរ ប៉ុន្តែនៅរវាងឆ្នាំ៧៨ រហូតមកទល់ឥឡូវនេះ កូនមិនដែលបានជួបគេទាំងពីរទេ ។

មីងណៃឈ្ងោកមុខ នឹកទៅដល់កូនប្រុសទាំងពីររបស់គាត់ រួច ហើយក៏ដកដង្ហើមយូបន្តូរទ្រូង ៖

- ម៉ាក់គិតថា កូនម៉ាក់ជាមនុស្សឆ្លៀវឆ្លាតហើយក្លាហាន ពិតជា អាចឆ្លងកាត់នូវឧបសគ្គទាំងឡាយ ដើម្បីមកជួបម៉ាក់វិញឆាប់ៗ នេះ មិនខានឡើយ ។

មីងណៃយកដៃជ្រោងសក់កូនស្រី សម្លឹងមុខនាងជាថ្មី ៖

- ម៉ី ! ប្រាប់រឿងមួយដល់ម្តាយបានទេកូន ?

- ចា៎ស ! អោយតែកូនដឹង នឹងជំរាបម៉ាក់ទាំងអស់ ។

- គឺ ម៉ាក់ចង់សួរថា ហេតុអ្វីកូនតក់ស្លុតរន្ធត់ស្មារតីម្ល៉េះ ពេលកូន បានប្រទះមុខយុវជនដែលនៅលើទូក កាលពីថ្ងៃមុននោះ ?

ស្រាប់តែយុវតីថ្លោះទឹកមុខធ្វើភិតភ័យសាជាថ្មី ។ ឃើញកូន ញ័រដៃញ័រជើង មីងណៃក៏អោបកូនបបោសខ្នង អោយបាត់ភ័យ ។

មួយស្របក់មក គាត់មើលមុខនាង ហើយសួរថា ៖

- និយាយបានហើយឬនៅកូន ? ម៉ាក់ចង់ដឹងណាស់ នឹងអាល ម៉ាក់អាចជួយដោះស្រាយអោយកូន ។ ម៉ាក់មិនចង់ឃើញកូនរស់ នៅក្នុងក្តីភិតភ័យដូច្នេះឡើយ ។

មាណវីយកដៃជ្រោងសក់ឡើង ហើយងើបមុខសម្លឹងម្តាយ របស់នាង ស្រង់យកភាពកម្លាំងចិត្តបន្តិចទើបស្រដីតបថា ៖

CHANBOKEO.COM

- គេឈ្មោះមិត្តស៊ិន ជាកងឈ្លបម្នាក់របស់អង្គការ ដែលកូនបាន ជួប ពេលកូនត្រូវអង្គការចាត់តាំង (កេណ្ឌ) អោយទៅរែកដីលើក ទំនប់នៅកំពីងពួយ ។ គេជាមនុស្សសាហាវណាស់ ។ គេបំរើអង្គ ការដោយស្ម័គ្រចិត្តបំផុត គ្មាននរណាធ្វើដូចទេ ។ អ្នកដែលឈឺដួល នៅកន្លែងជីកទំនប់នោះ គ្មានឱកាសបានទៅរកពេទ្យហ្មព្យាបាលទេ ផ្ទុយទៅវិញ នាយនោះចេញបញ្ជាអោយកប់ពួកគេទាំងរស់ ។ មាន យុវជន យុវនារីច្រើននាក់ណាស់ ដែលបានស្លាប់បាត់បង់ជីវិត ហើយដែលត្រូវកប់នៅជើងទំនប់ដ៏ធំនោះ ។

- ចុះគេធ្វើអ្វីចំពោះកូនខ្លះទៅ បានជាកូនខ្លាចគេដល់ម្លឹងនោះ ?

បារមីយកដៃជូតទឹកភ្នែកដែលកំពុងហូរស្រក់ចុះមកលើផ្ទៃមុខ ហើយក៏ឆ្លើយវិញថា ៖

- គឺគេបានមកចូលស្នើអង្គការ សុំចាប់ដៃកូន ជាប្រពន្ធនោះអីម៉ែ! កាលនោះកូនទើបតែមានវ័យ១៦ឆ្នាំ គឺនៅក្មេងណាស់ សំរាប់គិតគូរ រឿងដូច្នោះ ប៉ុន្តែគេទទូចសុំស្នើរូបកូនម្តងហើយម្តងទៀត ។ នៅ ទីបំផុត អង្គការក៏សំរេចអោយកូនចាប់ដៃបុរសនោះជាគូតែម្តង ។

- ពុទ្ធោ! កូនម្តាយ...! (មីងណៃលាន់មាត់ឡើង)

បារមីយំសសឹកស្រវាអោបម្តាយ ។ លុះយំខ្សឹកខ្សួលអស់ចិត្ត ហើយទើបនាងបរិយាយសាច់រឿងបន្តទៅទៀតថា ៖

- តែកូនសំរេចចិត្តហើយថាមិនទទួលរូបគេនោះជាគូជីវិតឡើយ ។

- ហើយចុះ កូនធ្វើយ៉ាងណា ទើបអាចរត់គេចពីគេមកបានដោយ សុខសប្បាយយ៉ាងនេះ កូន ?

- ការពិត វាជាប្រថុយជីវិតបំផុតណាម៉ាក់! គេជាមេឃាដករ ធ្លាប់ សម្លាប់មនុស្សមិនញញើតដៃឡើយ ។ កូនមានអារម្មណ៍ថា កំពុង តែធ្លាក់ចូលនរកទាំងរស់ ក៏នាំមិត្តនារីពីរបីនាក់លួចរត់ តែត្រូវពួក គេតាមបាញ់ស្លាប់អស់ម្នាក់ ក្រៅពីនោះក៏រត់ចែកផ្លូវគ្នា ។ សំណាង ល្អ កូនបានរត់គេចរួចខ្លួនរហូតមកដល់អូរតាគី ហើយឆ្លងមកនៅ ភូមិត្រាង លួចសុំអ្នកស្រុកស្នាក់បានបីបួនថ្ងៃក៏ត្រូវ អង្គការតំបន់ ផ្សេងក្រុមផ្សេងចាប់ខ្លួនបាន ។ បន្ទាប់មក គេបញ្ជូនកូនទៅចល័ត ធ្វើស្រែតាមវាល ។ ច្រើនខែក្រោយមក កូនក៏បានជួបនឹងលោកប៉ា ម្តងតែមិនហ៊ាននិយាយរកគាត់ទេ ព្រោះយើងត្រូវរក្សាសុវត្ថិភាព របស់យើងរៀងៗខ្លួន ។ កូនគ្រាន់តែបានញញឹមដាក់គាត់ ផ្តល់ជា សញ្ញា ថាកូនសុខសប្បាយតែប៉ុណ្ណោះ ។

មីងណៃបបោសខ្នងលួងលោមកូនស្រីជាថ្មី ។

- ពេលនេះ ម្ដាយធូរទ្រូងណាស់ដែលកូនម្ដាយបានសុខសប្បាយ ។ ប៉ុន្ដែ
អ្វីដែលម្ដាយនៅឆ្ងល់នោះ គឺបុរសដែលធ្វើបាបកូននោះ ។
ម៉ាក់គិតថានាយសល់មិនមែនជានាយម្នួយនោះទេ ព្រោះគេជាក្មេង
ដែលមានទឹកចិត្តស្លូតបូតហើយនឹងទុក្ខធុរៈញាតិណាស់...
- ជួនកាល ពេលគេក្លាយជាខ្លាបាក់ចង្កូម គេអាចបន្លំខ្លួនជាមនុស្ស ល្អ
ដើម្បីកុំអោយអ្នកស្រុកចាប់ពិរុទ្ធបាននោះអី ។
- អឺ! សមហេតុផលដែរ ប៉ុន្ដែគេមិនអាចធ្វើពើជាមនុស្សល្អបាន យូរទេ មិនយូរមិនឆាប់
ចរិតកាចយង់ឃ្នងវានឹងផុសផ្លោឡើងមក មិនខាន ។ ពេលនេះ
កូនចង់សាកល្បងជាមួយម៉ាក់ទេ ?
- សាករឿងអ្វីទៅម៉ាក់ ?
- គឺសាករឿងនាយសល់ ថាតើគេជាមិត្តស៊ិនដែលធ្វើបាបកូននោះ មែនដែរឬទេ ?
- កូនមិនហ៊ានទេ... ខ្លាច...
- តែម៉ាក់មានមធ្យោបាយ...
- ធ្វើយ៉ាងម៉េចទៅ ម៉ាក់ ?
- អឺ! ចាំម៉ាក់ប្រាប់ពេលណានឹងលទ្ធផល ។ ចុះពេលនេះ កូន
ស្នាក់នៅជាមួយលោកប៉ាវិញហើយមែនទេ ?
- នៅទេ... ព្រោះកូនឃើញគាត់មានគ្នីគ្នា...មិនហ៊ានរំខាន...
បារមីនិយាយដល់នេះ ក៏ដាក់ទឹកមុខជ្រប់ ធ្វើអោយមីងណៃ យើងរំជួលចិត្តសាជាថ្មីម្ដងទៀត ។
បន្តិចមក គាត់ក៏ញញឹមបន្លប់ ថា ៖
- បើអញ្ចឹង កូនទៅស្នាក់ជាមួយម្ដាយសិនទៅ ។
- អត់ទេ... បើសិនជាមាននាយម្នាក់នោះ កូនមិនទៅទេ ។
- គេធ្វើអ្វីកូនមិនកើតទេ ព្រោះពេលនេះ គេកំពុងឈឺធ្ងន់ណាស់ ។
- ហើយចុះពូម្នាក់ដែលជាប្ដីថ្មីរបស់ម៉ាក់នោះ ?
- នាយបូរនោះហ្ស៎ ? អត់ទេ.. គេគ្រាន់តែជាប្អូនធម៌របស់ម៉ាក់ តែប៉ុណ្ណោះ មិនមែនជាប្ដីទេ ។
- ប៉ុន្ដែមិត្តលមិញកូនបានឮលោកប៉ាមានប្រសាសន៍ថា... ថា...
- ថា យ៉ាងម៉េចទៅកូន.. ?

CHANBOKEO.COM

*- គឺ... អត់មានអីទេម៉ែ...! (បារមីប្ដូរប្រយោគ) ខ្ញុំគិតថានឹងទៅស្នាក់នៅជាមួយមិត្តភក្តិរបស់ខ្ញុំមួយពេលសិនចុះ ចាំស្អែកកូនទៅ ជួបម៉ាក់នៅឯទូកចាំយើងជជែកគ្នាទៀត ។ កូនសូមជំរាបលាសិន ហើយ ប្រញាប់ខ្លាចម្ចាស់ផ្ទះគេខឹងចាំមើលផ្លូវកូនយូរពេក ។*

*បារមីលើកដៃសំពះម្ដាយ ទទួលដាក់ភ្នែកទៅឃើញនាងតូចមុំ ក៏លើកពនាងឡើង ៖*

*- នេះជាកូនស្រីរបស់បងម៉ៅមែនទេម៉ែ ? អោយកូនសុំយកនាង ទៅគេងជាមួយម៉ាយប់ចុះដើម្បីទុកឲ្យម៉ាក់បានសំរាកផង ។*

*មីងណៃងក់ក្បាល ឈរសម្លឹងកូនដែលលើក្រមាទទូរ រួចហើយក៏អោបកនាងតូចមុំឡើងច្រាំងដើរចេញទៅ ៖*

*- មុំ! បើម៉ាក់ចង់ទៅរកកូន តើត្រូវទៅរកឯណា ?*

*មីងណៃស្រែកសួរ ។ បារមីងាកក្រោយហើយឆ្លើយវិញថា ៖*

*- នៅផ្ទះយាយប៉ែនលក់នំបញ្ចុក ។ នៅម្តុំវត្តសូភីនរណាក៏ស្គាល់គាត់ដែរព្រោះគាត់រស់នៅទីនោះតាំងពីយូរយាមកហើយ ។*

*ថាហើយនាងក៏ដើរចេញទៅ ។ មីងណៃឈរមើលកូនស្រីដើរ ចេញទៅទាំងទឹកចិត្តក្ដុកក្ដួល ។ ចម្លែកណាស់! ហេតុអ្វីបារមីមិន ព្រមហៅម្ដាយអោយទៅជាមួយ ? ការពិតធិតារបស់យើងកំពុង មានបំណងទុកឱកាសអោយម្ដាយរបស់នាង រកពេលវេលានិយាយជាមួយឪពុកនាងតែពីរនាក់ទេតើ ។*

*លុះកូនដើរចេញបាត់ទៅ មីងណៃដាក់ខ្លួនចុះអង្គុយផ្អែកគល់ អំពិល សម្រក់ទឹកភ្នែកម្ដងទៀតសាជាថ្មីតែម្នាក់ឯង... យូរៗម្ដង មីងណៃលួចបែរសម្លឹងមើលទៅដំបូលផ្ទះចាស់របស់គាត់ស្រម័យ នឹកទៅដល់អតីតកាលដ៏រុងរឿងដែលគ្រួសារគាត់ធ្លាប់បានទទួល ។ ថ្ងៃនេះអ្វីៗបានផ្លាស់ប្ដូរអស់រលីង ។ កូនរបស់គាត់បានព្រាត់បែក បាក់ខ្ចាត់ខ្ចាយ ។ ខ្លះបាត់ខ្លួនមិនមានដំណឹង ។ ខ្លះដើរជ្រកខ្លួន ពួននៅផ្ទះអ្នកដទៃ ។ ឯរូបគាត់រសាត់អណ្ដែតមករស់នៅលើទូក របស់យុវជនអនាថាម្នាក់... ប៉ុន្តែ ប្ដីរបស់គាត់វិញបែរជាមកគេង សោយសុខតែម្នាក់ឯងជាមួយប្រពន្ធថ្មី... ហ៊ឺ!... គិតៗទៅ មីងណៃកាន់តែចុកចាប់ក្នុងឱរាកាន់តែខ្លាំងឡើងៗ... ស្ទើរតែគាំងបេះដូងផុតដង្ហើមលាលោកនោះទៅវិញម្ដងៗទៅហើយ...*

CHANBOKEO.COM

- បងចិត្រ... បងបានប្រាប់អូនថា បើសិននៅមានថ្ងៃស្អែក យើង ត្រូវតែរក្សាសេចក្ដីសង្ឃឹមរបស់យើងជានិច្ច... សង្ឃឹមរង់ចាំជួប គ្នាវិញ ក្នុងសុភមង្គលថ្មីមួយដែលអូននិងបងបានរស់នៅជាមួយគ្នា មានកូនៗជុំជិតខ្លួនយើង... អូនក៏បានរក្សាសេចក្ដីសង្ឃឹមនោះ មិន ដែលនឹកលះបង់ម្ដងណាទេ ព្រោះអូនគិតថា យើងនឹងបានជួបគ្នា វិញប្រាកដមែន ។ ឥឡូវនេះ... ថ្ងៃស្អែកនោះបានមកដល់ហើយ... ប៉ុន្តែ... លទ្ធផលចុងក្រោយ មិនបានធ្វើអោយអូនជួបបងវិញទេ... អូនបានក្លាយជាមនុស្សគេងអោបទឹកភ្នែក... រីឯបងវិញថ្នាក់ថ្នម ប្រពន្ធថ្មី... តើ... នេះឬថ្ងៃស្អែករបស់បងសំរាប់ផ្ញើណៃ ?

មីងណៃក្រញីសក់ដែលទើបតែកោរដុះវិញខ្លីៗ...

- ឱ ! សក់ដែលធ្លាប់តែខ្មៅរលើបអើយ...! ខ្ញុំបានកោរអ្នកចោល ដើម្បីរង់ចាំបុរសម្នាក់ម្នាក់នោះ ។ ពេលនេះ ប្រហែលជាខ្ញុំគ្មាន ឱកាសស្គាល់រូបអ្នកជាថ្មីទេ ព្រោះបុរសនោះបានធ្វើដំណើរចាក ចេញពីជីវិតរបស់ខ្ញុំទៅហើយ គ្មានថ្ងៃដែលគេនឹងវិលត្រលប់វិល វិញ មករកខ្ញុំឡើយ... កូនម្ដាយអើយ ! ពេលនេះ កូននៅឯណា ? ឆាប់មករកម៉ាក់ផង... ម៉ាក់កណ្ដោចកណ្ដែងក្នុងចិត្តណាស់កូន...! តើឲ្យម៉ាក់តស៊ូប្រឹងរស់ដើម្បីអ្វី កាលបើកូននិងប្ដីបែកពីដើមទ្រូង ទៅអស់គ្រប់គ្នាយ៉ាងនេះ ? ឱ ! ទេវតាអើយ ! ហេតុអ្វីក៏ដាក់ទោស ទណ្ឌកម្ម ស្ត្រី ដែលមានចិត្តភក្ដីចំពោះគូស្នេហារបស់ខ្លួន ដោយឥត មេត្តាប្រណីអ្វីបន្តិចសោះអញ្ចឹង ?

ព្រលប់សន្ធិយា ឈានចូលដល់រាត្រីទៀតទៅហើយ មីងណៃ នៅតែសំកុកទីនោះដដែល... គាត់មិនបាននឹងថា ពេលវេលាបាន ធ្វើដំណើរកន្លងដល់ណាទេ នឹងត្រឹមតែថា រូបគាត់កំពុងក្លាយជានាង បដាចារមួយរូបក្នុងរឿងជីវិតសម័យថ្មីហើយ... ពេលនោះ មីងមាន អារម្មណ៍ថា វិញ្ញាណរបស់គាត់កំពុងតែរកផ្លូវរត់គេចពីរូបកាយ របស់គាត់ចេញទៅហើយ... តើមីងណៃនៅសល់កម្លាំងចិត្តអ្វីទៅ នឹងអាចទាញឲ្យព្រលឹងវិញ្ញាណរបស់គាត់វិលវិញ មករករូបកាយ ដែលពោរពេញ ទៅដោយក្ដីអស់សង្ឃឹមនិងដួងចិត្តសោកានឹមហា ធំធេងនោះបាន ?

សង្គ្រាមរវាងខ្មែរក្រហមនិងកងទ័ពវៀតណាម នៅតែបន្ត យ៉ាងគ្រាំគ្រេង ក្នុងដែនដីខេត្របាត់ដំបងនៅឡើយ មិនខុស ឡើយពីសន្ទឹកបេះដូងរបស់មីងណៃដែល កំពុងទទួលកំស្ទួលព្យុះ សង្ឃរានៃក្ដីទុក្ខសោកគ្មានគ្រាស្រាកស្រាន្តនៅពេលនោះដែរ...

CHANBOKEO.COM

*ooooooooooooooooooo*

*oooooo*

*o*

CHANBOKEO.COM

# វគ្គទី៨
# អម្រិតស្នេហ៍

នៅលើទេនសយនាពណ៌ផ្កាឈូកស្រស់ មានការតុបតែងសែន ប្រណិតប្រៀបហាក់ស្រីង្គារត្រៃត្រឹង្ស លោកគ្រូពេទ្យវិចិត្របានប្រទះ ឃើញទេពធិតាមួយរូបយ៉ាងស្រស់ស្អាតសោភាមួយរូប ស្ថិតក្នុង សម្លៀកពស្ត្រាល្អពណ៌រាយ ប្រចាប់ញញឹមស្រស់បំព្រងប្រកបដោយ ទឹកដមមន្តស្នេហ៍សែនអម្រិត មករករូបលោក ធ្វើអោយបេះដូង របស់លោករណ្តំរំភើបញាប់ញ័រ ដោយក្តីបេតីប្រតិពទ្ធ័មហាធំធេង រកអ្វីប្រៀបពុំបានឡើយ ។ កល្យាណីញញឹមស្រស់ណាស់...! ស្នាម ថ្ពាល់ខួចទាំងគូរបស់ធិតា ហាក់ដូចជាបង្កប់នូវទេពមន្តស្នេហ៍ យ៉ាង ចម្លែកមួយ ដែលមានអំណាចអង្រួនបេះដូងរបស់លោកគ្រូពេទ្យឲ្យ កើតមានអារម្មណ៍ស្រើបស្រាលមហិមា ចង់តែស្ទុះហាក់ទៅរកបីបម ត្រកងអង្អែលថៃថើបថ្នាក់ថ្នម ទៅតាមកំស្ងួលដួងចិត្តស្នេហារបស់ លោកចំពោះទេពធិតាអង្គនោះក្រៃលែង ។

- ចរណៃ កំពូលដួងចិត្តរបស់បង...!

លោកគ្រូពេទ្យឧទានហៅឈ្មោះទេពធិតានោះ ខ្សឹបៗនៅក្នុង ចិត្តតែម្នាក់ឯង ស្រាប់តែទេវីបែរក្រសែនេត្រាមកសម្លឹងចំរូបលោក ហើយញញឹមសាជាថ្មី ព្រមទាំងដើបដើរមកជិតលោកទៀតផង ។ លោកគ្រូពេទ្យញាប់ញ័រក្នុងចិត្តណាស់ កាលបើបានឃើញទេពធិតា ដើរមកជិត ។ លុះមកដល់ចំពីមុខលោកគ្រូពេទ្យភ្លាម ធិតាក៏លូក ហត្ថាហុចចំពោះលោកគ្រូពេទ្យ ហើយមានសវនីយ៍យ៉ាងពិរោះ ស្រទន់ថា ៖

- ឯណាទៅដួងចិត្តដែលបងថាប្រគល់អោយអូននោះ ? ពេលនេះ អូនមកទទួលយកពីបង តាមពាក្យដែលបងធ្លាប់សន្យាជាមួយអូន ហើយ... តើដួងចិត្តរបស់បងនោះនៅឯណា ?

CHANBOKEO.COM

តើបងមានសល់ បំណែកដួងចិត្តបេតីប្រតិព័ទ្ធរបស់បង សំរាប់ប្រគល់អោយអូន ទៀតដែរឬទេ... ?

លោកគ្រូពេទ្យឮហើយ ក៏ញញឹមឡើង រួចលាតបាតដៃទៅ ឈោងចាប់ហត្ថាទេពធិតាយ៉ាងណែនព្រមទាំងស្រដីថា ៖

- ដួងចិត្តរបស់បង..ជីវិតរបស់បង... ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ ណៃ តាំងពីយូរណាស់មកហើយ! បងបានប្រគល់អោយអូន តាំងពី ថ្ងៃដែលបងជួបអូនលើកដំបូង នៅថ្ងៃចូលឆ្នាំខ្មែរ ឯវត្តកណ្តាល ឆ្នាំ១៩៥៨នោះមកម៉្លេះ... ចង់អោយបងរស់ ឬចង់អោយបងស្លាប់ នោះ អូនបញ្ជាតាមចិត្តចុះ!... អូនពិតជានឹងបានឃើញលទ្ធផល តាមចិត្តដែលអូនប្រាថ្នា...

ភ្លាមនោះ លោកគ្រូពេទ្យមានអារម្មណ៍ថា លោកបានក្លាយខ្លួន ទៅជាទេវបុត្រមួយព្រះអង្គយ៉ាងសង្ហា ឈរកាន់ដៃទេពធិតាចរណៃ អណ្តែតនៅលើស្ថានសួគ៌ស្រីង្គាដ៏សែនល្វឹងល្វើយមួយ... លោកគ្រូពេទ្យរន្ធត់រំភើបស្រៀវស្រើបក្នុងចិត្តអ្វីម៉្លេះទេ ។ រំពេចនោះ លោក គ្រូពេទ្យមានអារម្មណ៍ ថាខ្លួនរបស់លោកកំពុងតែឈ្លក់វង្វេងទៅ ក្នុងកាមារម្មណ៍យ៉ាងស្រើបស្រាល រហូតពុំអាចទប់ចិត្តបានតទៅ ទៀតឡើយ ។ លោកក៏លាតរង្វង់ដៃ ស្រវាអោបថើបមត្រកងរាងកាយទេពធិតា ប្រព្រឹត្តកាយាទៅតាមអនុភាពកំស្ទួលនៃដួងចិត្តបេតី ប្រតិពទ្ធ័ស្នេហាចំពោះស្រស់កល្យាណី ដោយក្តីភ្លើតភ្លើនញាប់ញ័រ ក្រៃលែង ។ ពេលនោះ ទេវបុត្ររបស់យើងបានទទួលអារម្មណ៍ថ្មី មួយថា ខ្លួនលោកកំពុងទទួលនូវសុភមង្គលនិងភាពកក់ក្តៅយ៉ាង សុខដុមរមនារកពាក្យអ្វីមកបរិយាអោយសមស្មើមិនបានឡើយ ៖

- អូនណៃ... បេះដូងតែមួយរបស់បង!

ទេពធិតាញញឹមយ៉ាងស្រស់តបមករកលោកវិញ បង្ហាញនូវចិត្ត ស្មោះស្មគ្រ័ចំពោះទេវបុត្ររបស់យើងយ៉ាងត្រចះត្រចង់ ស្រាប់តែ.. ផ្ទូង! សូរគ្រាប់កាំភ្លើងមួយគ្រាប់បានហោះមកទំលុះដើមទ្រូងទេពធិតាធ្វើអោយរាជនីដាច់ដង្ហើមក្ស័យមរណាមួយរំពេច ដោយមិនបាន ស្រដីលាលោកគ្រូពេទ្យមួយម៉ាត់ឡើយ ។

- អូនណៃ...!!!

CHANBOKEO.COM

លោកគ្រូពេទ្យស្រែកឧទានឡើង ហើយស្រវាអោបកាយធិតា យ៉ាងណែនពេញរង្វង់ដោយក្តីរន្ធត់តក់ស្លុត ។ ឈាមរបស់ធិតាហូរ ស្រក់ប្រឡាក់ជោគខ្លួនរបស់លោក... បន្តិចមកលោកក៏ឱនឈ្ងោក ថើបផ្តាល់ឆរីកំពូលដួងចិត្តជាចុងក្រោយ រួចហើយក៏ផ្តេកកាយធិតាទៅលើកំរាល ។ បន្ទាប់មក លោកគ្រូពេទ្យងាកហាក់រឹងតតាំងនឹង បុរសចិត្តឫស្យាដែលបានលើកកាំភ្លើងបាញ់សម្លេះជីវិតរបស់ទេព ធិតា ។ ស្រាប់តែ... ផ្ទង! គ្រាប់កាំភ្លើងទីពីរបានហោះមកទម្លុះ ខ្លួនលោកគ្រូពេទ្យធ្លាយពីម្ខាងទៅម្ខាង បាញ់ឈាមព្រលឡើងយ៉ាង គគុក ។ លោកក៏ដួលត្មោល ទៅលើដើមទ្រូងទេវីកំពូលដួងចិត្តរបស់លោក ដែលកំពុងសន្នឹងស្លូកស្តឹង... ៖

- អូនណែ... បងនឹងទៅតាមអូនហើយ... ពេលនេះ យើងលែងបែកគ្នាតទៅទៀតហើយណា៎អូន...!!

លោកគ្រូពេទ្យបិទភ្នែកផ្តេកថ្ពាល់លើទ្រូងស្រស់កល្យាណ...

ស្រាប់តែ... ផាំង! គ្រាប់កាំភ្លើងទីបីបានលាន់ឮឡើងលាន់ខ្ទ័រ ម្តងទៀត ។ លោកគ្រូពេទ្យខំបើកភ្នែកបែររកមើល ឃើញបុរស កំណាចនោះដួលត្មោលទៅលើដីដេកស្លាប់បិទភ្នែកមិនជិត ហើយ ឃើញស្ត្រីមួយរូបកំពុងឈរកាន់កាំភ្លើងពីចម្ងាយ ។ បន្ទាប់មកស្ត្រី នោះក៏ស្ទុះមកលើករូបលោកឡើង ថែមទាំងស្រដីថា ៖

- ខ្ញុំមិនអាចបណ្តោយអោយលោកស្លាប់បានឡើយ ។ លោកត្រូវតែ ត្រឡប់ទៅផ្ទះវិញ!

ស្រាប់តែលោកគ្រូពេទ្យគៀសដៃស្ត្រីនោះចេញហើយវាចាថា ៖

- ទេ! ខ្ញុំមិនទៅទេ... ខ្ញុំមិនទៅណាទាំងអស់! នាងឆាប់ថយ ពីខ្ញុំទៅ! ខ្ញុំមិនទៅតាមនាងទេ ។

- ម៉េចលោកស្រដីយ៉ាងនេះ ? ខ្ញុំបានសង្គ្រោះជីវិតរបស់លោក... ហេតុអ្វីលោកធ្វើយ៉ាងនេះដាក់ខ្ញុំ ?

តែលោកគ្រូពេទ្យមិនស្តាប់ទេ... បែរជាប្រឹងងើបក្រោកមកបី ត្រកងកាយទេពធិតាចរណៃឡើង ហើយដើរចេញទៅ ។ រំពេច នោះ ស្ត្រីរូបនោះស្ទុះស្រែកឃាត់ជាថ្មី ៖

- បងសុខហុង! ហេតុអ្វីបងធ្វើយ៉ាងនេះដាក់ខ្ញុំ ? បងសុខហុង..! ម្តេចបងទៅបីថ្នាក់ថ្នមស្រីម្នាក់នោះ ? ចុះខ្ញុំ ? ខ្ញុំឯនេះ តើបងយករូបខ្ញុំទៅទុកនៅត្រង់ណាវិញ ?

លោកគ្រូពេទ្យយកដៃគៀសស្ត្រីនោះចេញហើយគំហកថា ៖

- ចៀសចេញមើស៍...! កុំរំខានជីវិតយើងនិងប្រពន្ធរបស់យើង!

CHANBOKEO.COM

រួចហើយ លោកក៏ស្ទុះបីត្រកងសាកសពទេពធិតាដើរទៅមុខ មិនព្រមងាកក្រោយវិញបន្តិចឡើយ ស្រាប់តែ... ផាំង! សូរសៀង គ្រាប់កាំភ្លើងទីបួនលាន់ឮម្ដងទៀតយ៉ាងខ្ទ័រខ្ទារ... ថៃដន្យ លោកគ្រូពេទ្យលែងមានទឹកចិត្តចង់បែររក មើលព្រឹត្តិការណ៍អ្វីទៀតហើយ... មិនដឹងថាគ្រាប់កាំភ្លើងទីបួននោះ បានហោះមកទម្លុះបេះដូងរបស់ លោក ឬក៏ហោះទៅទម្លុះបេះដូងនរណាផ្សេងម្នាក់ទៀតដែរទេ ។ លោកគ្រូពេទ្យដឹងត្រឹមតែថា ពេលនោះ ចិត្តរបស់លោក អារម្មណ៍ របស់លោក វិញ្ញាណរបស់លោក បានអណ្ដែតហោះឡើងទៅជាមួយ ទេពធិតាចរណៃកំពូលដួងចិត្តនោះបាត់ទៅហើយ ដោយគ្មានសោកស្ដាយស្រណោះនរណាដែលនៅឯក្រោយឯណោះហើយ ។ រំពេច នោះ ស្រាប់តែទេពធិតាចរណៃបើកនេត្រាឡើង ញញឹមដាក់លោកគ្រូពេទ្យរបស់យើងយ៉ាងពព្រាយសាជាថ្មី ចាប់ដៃលោកហោះឡើង ទៅលើវេហាស៍ ។ លោកគ្រូពេទ្យរំភើបសោមនស្សណាស់ ដែល បានឃើញទេវីមានស្មារតីមកវិញ ក៏ឧទានហៅធិតាថា ៖

- អូនណៃ!... អូនណៃរបស់បង! អូនណៃ!

លោកគ្រូពេទ្យស្រែកហៅម្ចាស់ដួងចិត្ត រហូតដល់ភ្ញាក់កន្ត្រាក់ អស់ ទាំងខ្លួន ។ លុះលោកបើកភ្នែកឡើង ស្រាប់តែភ្ញាក់ព្រើត ព្រោះពេលនោះ លោកបានក្លាយទៅជាបុរសចំណាស់មួយរូបមានសក់ល្បាយអាចម៍ខ្លានិងរូបកាយដ៏ស្គាំងស្គមស្លេកស្លាំង ។ លោក ស្ទាបមើលខ្លួនឯង ឃើញខ្លួនទទេ បាត់អាវទៅណាមិនដឹង សល់តែ ខោខ្លីជាប់ខ្លួន ។ ការពិត លោកមិនដែលសំរាន្តដោះអាវសោះ ជា យូរឆ្នាំមកហើយ ។ មិនថាពេលណាទេ គឺលោកត្រូវតែពាក់អាវជិត ខ្លួនជានិច្ច ដើម្បីការពារ នៅពេលមានអាសន្នត្រូវរត់គេចខ្លួននោះ លោកនឹងមានខោអាវស្លៀកពាក់ជាប់នឹងខ្លួន ។ ថ្ងៃនេះ ហេតុដូចម្ដេចបានជាលោកបាត់អាវពីខ្លួនយ៉ាងនេះ ? លោកក៏ដើបឡើងដើរ ជុំវិញបន្ទប់ ចង់រកមើលក្រែងមានអ្វីប្លែកខុសធម្មតា ប៉ុន្តែ លោក នៅតែឃើញអ្វីៗនៅកន្លែងដដែលតាមតែទម្លាប់ដែលទុកដាក់អីវ៉ាន់ មុនចូលដំណេក ខុសប្លែកអ្វីតែខោអាវរបស់លោកដែលបានពាក់ កាលពីយប់មិញ បែរជាមានគេយកទៅបោកគក់ដាក់ហាលនៅស្នួរ ចំហៀងផ្ទះឯណោះយ៉ាងព្រងើយ ។ បន្តិចមក

CHANBOKEO.COM

លោកក៏ចុះដើរទៅ ជាន់ក្រោម ប៉ុន្តែ មិនបានប្រទះនរណាទាំងអស់ គឺស្ងាត់ច្រៀបតែ ម្ដង ឮតែសូរសៀងខ្យល់ បក់ស្លឹកឈើខ្សាកៗលើដំបូល និង សម្លេងសន្ទឹករថយន្តទាហានវៀតណាម ដឹកទំពាចរកាត់មុខផ្ទះចេញ ទៅតែប៉ុណ្ណោះ ។

ថ្ងៃរះភ្លឺច្បាស់ពីទិសបូព៌ា...

លោកគ្រូពេទ្យស្លៀកពាក់រៀបចំខ្លួន បំរុងចេញទៅធ្វើការឲ្យ គេ តាមដែលអង្គការថ្មីបានចេញបញ្ជា ។ នៅក្នុងចិត្តវិញ លោក គិតមិនអស់មិនហើយសោះ អំពីប្រផ្នូលក្នុងចិត្តរបស់លោក នាព្រឹក នេះ ។ ណាមួយទៀត លោកមានអារម្មណ៍ថា ហាក់ដូចជាមិនមាន កម្លាំងចេញទៅធ្វើការសោះ ព្រោះត្បិតដួងចិត្តខ្វល់ខ្វាយហាក់ចង់ តាមរកអ្វីម្យ៉ាង...

បន្តិចមក លោកក៏ដើរទៅរៀបគ្រែបត់ភួយទុកដាក់អោយល្អ តាមទម្លាប់ដែលលោកធ្លាប់ធ្វើរាល់ព្រឹក តាំងតែលោកបែកពីប្រពន្ធ មក ។ លុះលោកលើកខ្នើយឡើងរលាស់ ស្រាប់តែបានប្រទះនឹង កញ្ចប់ក្រណាត់សមួយនៅក្រោមខ្នើយ ក៏ភ្ញាក់ព្រើតតែម្ដង ព្រោះ លោកមិនដែលមានដាក់អ្វីក្រោមខ្នើយម្ដងណាឡើយ ។ លោកគ្រូពេទ្យយើងលូកស្រវាកញ្ចប់នោះមកលាតមើលយ៉ាងរហ័ស ។ នោះ គឺជាកូនកន្សែងដៃមួយដែលខ្ចប់ចិញ្ចៀនមួយវង់ ខ្សែកមួយដែល មានបន្ដោងប្រអប់រូបបេះដូង រូបថតក្រុមគ្រួសាររបស់លោកមួយ សន្លឹក និងកូនសំបុត្រតូចមួយ ។ ភ្លាមនោះ លោកគ្រូពេទ្យញ័រដៃ ទទ្រើកតែម្ដង កាលបើបានយល់របស់របរទាំងនេះ ព្រោះលោក ចាំវាច្បាស់ណាស់ គឺជារបស់ដែលលោកធ្លាប់បានទិញចងដៃភរិយា របស់លោកកាលពីទើបរៀបការហើយថ្មីៗ ។ ពេលនោះ បេះដូងក៏ កញ្ជ្រោលឡើង... ភ្នែកក៏ចាប់ស្រវាំងដោយទឹកភ្នែកម្ដងទៀត ។

បន្តិចមក លោកក៏ខំមាត់លេបទឹកភ្នែកទៅក្នុងពោះ ហើយក៏ ចាប់កូនចំណារតូចនោះយកមកលាតអានឡើង ៖

- មិនដឹងថា អោគួររក្សាទុករបស់នេះធ្វើអ្វី កាលបើដួងចិត្តរបស់ ម្ចាស់គេ លែងនៅជាមួយអោតទៅទៀតហើយនោះ... រីឯថ្ងៃស្អែក ដែលអោធ្លាប់ទន្ទឹងរង់ចាំ ក៏បានត្រឹមតែជាថ្ងៃស្អែកក្នុងសុបិនក្លែង ក្លាយមួយ ដែលមិនអាចក្លាយមកជាការពិតបាន... អោបានពលី អ្វីៗដើម្បីថ្ងៃស្អែក រហូតដល់រលាយអស់កម្លាំងចិត្តនឹងពលីតទៅ ទៀត.. ពេលនេះ អោបានក្លាយទៅជាមនុស្សងឺទន់ជ្រាយម្នាក់ដែល មិនអាចរាវរកពន្លឺជីវិតសំរាប់ខ្លួនឯងបាន...

CHANBOKEO.COM

ណៃគ្មានសមត្ថភាព នឹងតស៊ូសំរាប់ថ្ងៃស្អែកតទៅទៀតទេ... បើអូនបានធ្វើអ្វីខុសឆ្គង ចំពោះរូបបងកាលពីអតីតកាល សូមអហោសិកម្មឲ្យណៃផងណា៎...
ណៃគ្មានបំណងបំបាក់ទឹកចិត្តបងឡើយ... ព្រោះអ្វីដែលណៃបានធ្វើ កាលនោះ ក៏គឺដើម្បីតែបងនិងកូនៗជាទីស្រឡាញ់របស់យើងតែ ម្យ៉ាងប៉ុណ្ណោះ...
ឲ្យណៃសុំផ្ញើកូនចៅទាំងអស់ជាមួយបងផងណា៎បង ណា៎...
ពីស្រីម្នាក់ដែលស្រឡាញ់បងចិត្រពេញបេះដូង.. ណៃ!

ពេលនោះ ទោះបីជាលោកគ្រូពេទ្យប្រឹងទប់ចិត្តថា មិនស្រក់ ទឹកភ្នែកមិនបានឡើយ ។ លោកស្រឡាញ់ភរិយារបស់លោកណាស់ ហើយមិនដែលគិតថានឹងបែកចិត្តពីភរិយាម្តងណាឡើយ ថ្វីបើផ្ទាំង ពពកខ្មៅបានហោះកាត់ជីវិត បំបែករូបលោក ចេញពីម្ចាស់បេះដូង របស់លោកអស់យូរឆ្នាំមកហើយក៏ដោយ...

- អូនណៃ! តើអូនកំពុងគិតចង់ធ្វើអ្វីហ្នឹង ? ឬក៏អូនបំរុងនឹងលា បងទៅរហូត ?... អត់ទេ.. មិនទេ... បងមិនអាចបាត់រូបអូនបាន ទេ... បងមិនអោយអូនទៅទេ...ណៃ... បងស្រឡាញ់អូន... បងត្រូវ តែតាមរកអូនមកវិញ... ជីវិតរបស់យើងជាជីវិតតែមួយ បើគ្មាន ណៃ បងក៏គ្មានថ្ងៃស្អែកតទៅទៀតដែរ! ណៃ! កុំគិតផ្តេសផ្តាស ណាអូនណា៎! ចាំបងសិនអូន...!

លោកគ្រូពេទ្យលាន់មាត់ឡើង ហើយក៏ស្រវាខ្ចប់របស់នោះដាក់ ហោប៉ៅ បន្ទាប់មកក៏ហក់យ៉ាងលឿនចុះពីលើផ្ទះ ទាញកង់ចេញ មកបំរុងធាក់ចេញទៅតាមរកមីងណៃរបស់យើង ។ លុះមកដល់ មាត់របង ស្រាប់តែប្រទះនឹងស្នាមគំនូសឈាម ដែលមីងណៃខាំដៃ យកឈាមគូរជារូបផ្កាចំប៉ាញីឈ្មោល រួចចារលើផ្ទាំងទ្វាររបងខាង ក្នុង មានសេចក្តីថា ៖

- ណៃស្រឡាញ់បងចិត្រ! ណៃស្រឡាញ់កូនគ្រប់គ្នា! សូមអោយ យើងបានជួបគ្នាវិញឆាប់ៗនេះ!

លោកគ្រូពេទ្យភ្ញាក់ស្រឡាំងកាំងតែម្តង ៖

- ណៃ... តើអូនបានចារពាក្យនេះពីអង្កាល់ ? ម្តេចក៏បងមិនដែល ឃើញ ?...ឬក៏មកពីបងមិនបានចាប់ភ្លឹក ? នេះបើសិនជាបងបាន ឃើញពីមុនមក ម្ល៉េះសមបងមិនបណ្តោយឲ្យអូនដើរចេញពីជីវិត របស់បងដូចកាលពីម្សិលមិញនេះទេ ។ ពេលនេះ បងយល់ហើយ ចិត្តណៃនៅជាមួយបងដដែល... ណៃ! បងក៏ដូចគ្នាដែរ... មិនថា

CHANBOKEO.COM

អតិតកាលរបស់អូនបានឆ្លងកាត់ភាពល្អក់កករឬក៏យ៉ាងណាទេ បង ក៏នៅតែស្រឡាញ់អូនជានិច្ច...
ព្រោះអូនបានពលីខ្លួនអូនដើម្បីបង.. ដូច្នេះរឿងអ្វីដែលបងពលី ដើម្បីអូនវិញមិនបាន ?

លោកគ្រូពេទ្យក៏ទាញកាំបិតបត់ចេញពីហោប៉ៅអាវម្រាមដៃយក
ឈាមមកគូរជារូបបេះដូងពទ្ធ័លើរូបផ្កាចំប៉ាញីឈ្មោល រួចសរសេរ តបវិញថា៖

- បងចិត្រស្រឡាញ់ណៃតែម្នាក់ ហើយស្រឡាញ់កូនរបស់យើង គ្រប់ៗគ្នា!
ថ្ងៃស្អែករបស់យើងបានមកដល់ហើយ! សូមអូនទទួល បងផងណា៎!

រួចហើយ លោកក៏យកចុងម្រាមដៃមកថើបផ្ដិតលើបបូរមាត់ របស់លោក
ហើយក៏យកទៅផ្តិតលើឈ្មោះណៃ រួចស្រដីថា ៖

-បងចិត្រស្រឡាញ់អូនណៃជានិច្ច! នឹងហើយនៅបណ្តូលចិត្តបង ?

បន្ទាប់មក លោកក៏ឡើងធាក់កង់ចេញទៅ ។ លុះទៅដល់ប៉ុស្តិ៍ យាមនៅចុងស្ពានថ្ម
លោកគ្រូពេទ្យក៏ចុះពីកង់ ទៅរកមេកោយទី នោះ និយាយបារាំងមួយស្របក់ក៏ចេញមកវិញ
ទំនងដូចជាសុំ ច្បាប់អនុញ្ញាត្តិ ។ មួយស្របក់ក្រោយមក លោកបានទៅដល់កំពង់ នរា
ដើរចុះទៅរកទូករបស់នាយសល់ ។ ភ្លាមនោះ លោកប្រទះ
ពូបូរកំពុងអូសឈ្នាងត្រាំឡើងពីស្ទឹងតែម្នាក់ឯងទាំងត្រដេរត្រដរ ។

- ល្បងសុខ ?

ពូបូរលាន់មាត់កាលបើឃើញ លោកគ្រូពេទ្យមកដល់ ។ គាត់ក៏
ទម្លាក់ឈ្នាងចុះហើយរត់រ៉មកដល់ភ្លាមយ៉ាងរហ័ស ។

- ក្មួយសល់យ៉ាងម៉េចទៅហើយ បូរ ? (លោកគ្រូពេទ្យសួរ)
- អូហ៍ ! បានល្បងចាក់ថ្នាំហើយអោយថ្នាំគេលេបកាលពីយប់មិញ
ឃើញថាបានធូរស្រាលច្រើនណាស់ ។ ថ្ងៃនេះ ខ្ញុំឃើញគេឡើង បរិភោគបាយទៀតផង ។
តើគេកើតជំងឺអ្វីដែរទៅ ? មើលទៅ ល្បងសមជាគ្រូពេទ្យសក្តិសិទ្ធិណាស់ ។
មើលជំងឺជាលឿនដូចគេ បេះតែម្តង ។

លោកគ្រូពេទ្យក៏ដើរអោនចូលឃ្លប់ទូក ទៅស្រវាស្ទាបខ្លួននាយ
សល់ដែលកំពុងដើបអង្គុយលើកដៃសំពះសួរលោកគ្រូពេទ្យ ។

- ជាជំងឺគ្រុនសន្និ បរិភោគថ្នាំពីរបីថ្ងៃទៀតជាហើយ (លោកគ្រូ ពេទ្យមានប្រសាសន៍)
តែកុំអាលបរិភោគរបស់រឹងអី... បបរឬ ស្ងោរបន្លែអីបរិភោគសិនទៅទំរាំជាសះស្បើយ ។ នេ៎ះ
ថ្នាំ! ខ្ញុំយក មកផ្ញើមួយចំនួនទៀត ល្មមអាចលេបគ្រប់ រហូតដល់ជាដាច់ ។

CHANBOKEO.COM

ពេលនោះ លោកគ្រូពេទ្យវេភ្នែកបែរចុះឡើង ។ ពូបូរឃើញ ហើយក៏សួរថា ៖

- រកមើលចៅម៉ុំមែនទេ ?

លោកគ្រូពេទ្យងក់ក្បាល ៖

- បាទមែនហើយ ! នាងតូចមិននៅទេហ្ន៎ស ?

ពូបូរធ្វើមុខស្លូតឆ្លើយតបវិញថា ៖

- ល្បងមកពីម្សិលមិញប្រាប់ខ្ញុំថា នាងម៉ុំត្រូវជីដូនមកទទួលយកពី ល្បងទៅហើយ មែនទេ ?

- បាទ ! មែនហើយ !

- ប៉ុន្តែ ទាំងបងណៃ ទាំងចៅម៉ុំ មិនឃើញត្រឡប់មកវិញទេ តាំងពីខ្ញុំជូនបងណៃទៅដល់ប៉ុស្តិ៍ចុងស្ពាននោះកាលពីម្សិលមិញនោះមក មិនដឹងថាគាត់មានដំណើរទៅខាងណាទេ ។ ពេលនេះ ខ្ញុំបារម្ភពី សុវត្ថិភាពរបស់គាត់ណាស់ ។

ឮដូច្នោះ លោកគ្រូពេទ្យជ្រួញចិញ្ចើមតែម្តង ។ មែនហើយ ម្សិលមិញលោកមានចិត្តតក្កហលមីងមាំងភាំងស្មារតីគិតអ្វីមិនចេញ សោះ ។ កុំថាតែរបូតប្រពន្ធមួយនោះ សូម្បីតែកូនស្រីក៏លោកធ្វើឲ្យ របូតបាត់ទៅដែរ ដោយមិនទាំងដឹងថានាងស្នាក់នៅទីណាផង ។ ពេលនោះ បេះដូងរបស់លោកក៏កើតភាពច្របូកច្របល់រំខាន ភ្លាមរួចហើយក៏ក្រោកលាម្ចាស់ទូក ៖

- ខ្ញុំប្រញាប់មានការបន្តិច ។ ពេលណាទំនេរ ចាំខ្ញុំឆ្លៀតមកលេង ទៀត... ហើយសូមផ្តាំទៅយាយណៃនិងចៅផង ថាខ្ញុំមករកគេទាំង ពីរមានការចាំបាច់ជាពិសេស ។

- ការចាំបាច់ជាពិសេស ? (ពូបូរលាន់មាត់)

លោកគ្រូពេទ្យងក់ក្បាលហើយ ក៏ទាញកង់ឡើងច្រាំងត្រឡប់ ទៅវិញទុកអោយពូបូរនិងនាយសល់នៅសម្លឹងមើលមុខគ្នានឹក ងឿងឆ្ងល់ទាំងពីរនាក់ ។

តាមផ្លូវ...

- អូនណៃ... អូនកុំគិតខ្លីអីណា៎... ពេលនេះបងទៅរកអូនហើយ... ចាំបងណា៎អូនណា៎ !

លោកគ្រូពេទ្យជិះកង់បណ្តើរ បន់ព្រះបណ្តើរ តែក្នុងចិត្តនឹក ព្រួយក្រៃណា រកស្មានមិនត្រូវឡើយ ។ ចំណែកកូនស្រីដែលលោក បានជួបគ្នាកាលពីម្សិលម៉្ងៃក៏មិនទាន់មានឱកាសបានសាកសួរអ្វីគ្នាឲ្យ អស់ចិត្តនៅឡើយដែរ ព្រោះចេះតែមានហេតុការណ៍ផ្សេងៗមក ស្ទាក់បង្អាក់ផ្លូវមិនអោយនិយាយគ្នាបាន ។ ពេលនោះ លោកមាន អារម្មណ៍វាយមាយណាស់... មិនដឹងថា ចង់ទៅរកប្រពន្ធគាត់នៅឯ ណាទេ ។

CHANBOKEO.COM

មួយថ្ងៃនេះ លោកគ្រូពេទ្យជិះកង់ទៅមកៗតាមដងស្ទឹង ជាច្រើនសាហើយ
រហូតដល់ពួកទាហានដែលយាមប៉ុស្តិ៍លែងចង់ ស្ទាក់សាកសួរ
ក៏ចេះតែបក់ដៃអោយលោកជិះទៅជិះមកស្រេចតែ ចិត្តទៅ ។

អស់ចិត្តហើយ... លោកក៏បត់កង់ចូលផ្ទះវិញ ទៅអង្គុយសំកុក
ក្រោមដើមឈើតែម្នាក់ឯង...

- ណែ! តើពេលនេះ អូននៅឯណា ? តើអោយបងតាមរកអូន
នៅឯណាទើបឃើញ ?

លោកគ្រូពេទ្យលាកញ្ចប់កន្សែងដៃសាជាថ្មី ទាញប្រអប់បន្តោង
រាងបេះដូងនោះយកមកបើកមើល ឃើញរូបថតរបស់លោកជាមួយ
ភរិយាញញឹមប៉ប្រឹមដូចទើបថតថ្មីៗ... រួចហើយក៏ទាញរូបថតក្រុម
គ្រួសាររបស់លោកចេញមកអង្គុយមើលយ៉ាងយូរ ។ នោះជារូប
ដែលក្រុមគ្រួសាររបស់លោកថតទាំងអស់គ្នា នៅថ្ងៃរៀបមង្គលការ
របស់ស្រីម៉ៅកូនស្រីច្បងរបស់លោកជាមួយប៊ុរី ។ ម្នាក់ៗញញឹម
ស្រស់ស្រាយរីករាយឥតហ្មងសៅ ។ ពេលនេះ កូនប្រុសកូនស្រី របស់លោកព្រាត់ទៅអស់រលីង...
ចំណែកកូននិងប្រពន្ធដែលបាន ជួបគ្នាវិញម្តងហើយ លោកគ្រូពេទ្យគ្មានស្មារតីប្រុងប្រយត្ន័
បែរជា បណ្តោយអោយរបូតពីដៃសាជាថ្មី... ហេតុអ្វី ? ហេតុអ្វីលោកក្លាយ
ជាមនុស្សមានសតិខ្ជីខ្ជាដល់ម្លឹង ? កាលដើមឡើយលោកជាមនុស្ស ធ្វើការមធ្យ័ត
ស្រដីមធ្យ័តណាស់ ពេលនេះ លោកក្លាយជាមនុស្ស ដែលស្ទើរតែគ្មានវិញ្ញាណនៅក្នុងខ្លួន...
នេះតើព្រោះហេតុអ្វីទៅ ?

មែនហើយ! គឺរបបផ្តាច់ការ និងសង្គ្រាមប្រល័យពូជសាសន៍ បានបំផ្លាញសតិមនុស្ស
បំផ្លាញសុភមង្គលគ្រួសារ វង្វេងសាច់ញាតិ បំបាក់កម្លាំងចិត្តពលរដ្ឋទាំងឡាយ
បន្ថយទំនុកចិត្តរវាងគ្នានិងគ្នា កុំឲ្យគេមានចិត្តក្លាហាននឹងតស៊ូក្នុងជីវិតតទៅទៀត... តួយ៉ាងដូចជា
លោកគ្រូពេទ្យនេះជាដើម...

លោកគ្រូពេទ្យអង្គុយគិតយ៉ាងយូរ... នៅទីបំផុត លោកក៏យក
ដៃដូតញើសចេញពីថ្ងាសដ៏ជ្រីវជ្រួញ ហើយដកដង្ហើមយូបន្ធូរទ្រូង សាជាថ្មីម្តងទៀត ។ បន្ទាប់មក
លោកលូកស្រវាក្តាប់ចិញ្ចៀន និង ខ្សែកយ៉ាងណែន
នឹកស្រម័យទៅដល់អតិតកាលរបស់លោកជាមួយ ភរិយា...

CHANBOKEO.COM

លោកធ្លាប់ជួបភរិយារបស់លោកលើកទីមួយ នៅឯវត្ត កណ្ដាល ហើយក៏ធ្លាប់ទៅបែបន់ព្រះនៅទីនោះ ផងស្រួងសូមជួបនាង ចរណៃជាគូ រហូតដល់បានជួបគ្នារៀបការជាគូជីវិតដូចបំណាន់ពិត មែន ។ ពេលនោះ ស្រាប់តែលោកគ្រូពេទ្យភ្ញាក់ព្រើតនឹកឃើញអ្វី ម្យ៉ាង ក៏លាន់មាត់ថា ៖

- វត្តកណ្ដាល ?... ណៃ! អូននៅទីនោះមែនទេ ?

លោកគ្រូពេទ្យខ្ទប់តវ៉ាន់ទុកក្នុងហោប៉ៅវិញ ហើយហក់ឡើង កង់យ៉ាងលឿនតែម្ដង ។ តាមផ្លូវ លោកបានជួបក្រុមទាហានវៀត ណាមដើរល្បាត តែដោយឃើញលោកស្លៀកពាក់ស្រដៀងៗពួកគេ គ្មាននរណាមួយហៅលោកសួរអ្វីទេ គ្រាន់តែឈរមើលធ្វើប្រហើរ ប៉ុណ្ណោះ ។ លោកសង្កេតឃើញអ្នកស្រុកមួយៗ ដើររើសមែកឈើ ស្ងួតយកធ្វើអុសដុត ខ្លះទូលដើមចេក ខ្លះទូលបន្លែព្រៃដូចជាស្លឹក បាស ស្លឹកសាវម៉ាវ ជាដើម ។ ប៉ុន្តែអ្នកស្រុកទាំងនោះសុទ្ធតែជា ស្រីៗនិងកូនក្មេង មិនទាន់ឃើញមានបុរសពេញវ័យមួយទេ មិន ដឹងថាពួកទាហានវៀតណាម មិនអនុញ្ញាត្តិអោយប្រុសៗចូលបេះ ដំណាំ ឬក៏ប្រុសៗក្នុងគ្រួសាររបស់គេត្រូវស្លាប់អស់ដោយស្នាដៃខ្មែរ ក្រហម ឬក៏ត្រូវគេកេណ្ឌធ្វើទាហានច្បាំងឯណាក៏មិនដឹង...

មកដល់ទីធ្លាវត្តកណ្ដាល លោកគ្រូពេទ្យក៏ចុះពីកង់ ដោះមួក ចេញពីក្បាល ដើរដឹកកង់សំដៅព្រះវិហារដែលទ្រុឌទ្រោម ដោយ ត្រូវអ្នកស្រុកបោះបង់ចោលយូរឆ្នាំ ។ រំពេចនោះ មានតាចាស់ម្នាក់ ដើរមកដល់ ស្រែកហៅ ៖

- លោកវិចិត្រ ?

លោកគ្រូពេទ្យភ្ញាក់ព្រើត បែរផាំងរកម្ចាស់សម្លេង ទាំងនឹក ឆ្ងល់ថា តើនរណាស្គាល់ឈ្មោះលោកច្បាស់ដល់ម្លឹង ?

- លោកពេទ្យ! គឺខ្ញុំណា៎... តាខេមប្ដីយាយសឿមនោះអី!

- ពូខេម ?

លោកគ្រូពេទ្យរំភើបចិត្តណាស់ ក៏លើកដៃជំរាបសួរតាចាស់ នោះភ្លាម ។ ការពិតពូខេមនិងយាយសឿមប្រពន្ធគាត់ គឺជាមនុស្ស ចាស់ដែលធ្លាប់រស់នៅថៃស្ទួនថៃផ្ទះនិងដណ្ដាំបាយ អោយគ្រួសារ របស់លោកគ្រូពេទ្យតាំងតែពីលោកគ្រូពេទ្យនៅតូចក្រូចឆ្មារម្លេះ ។

- ពូខេម... ខ្ញុំសប្បាយចិត្តណាស់ដែលដឹងថា ពូនៅរស់... ហើយ ចុះមីងសឿមវិញនោះ ?

CHANBOKEO.COM

- គេស្លាប់ពីរបីឆ្នាំហើយ ចំណែក ពូរស់នៅតែម្នាក់ឯងរហូតមក ។
- អញ្ចឹងពូស្នាក់នៅឯណាពេលនេះ ?
- នៅកុដិចាស់មួយក្នុងវត្តនេះ ។ ពូធ្លាប់បានសាកល្បងត្រឡប់ទៅ
ផ្ទះរបស់លោកចិត្រជាច្រើនដងដែរ តែពួកទាហានរៀតណាមគេ ហាមឃាត់មិនអោយទៅសោះ
ព្រោះគេថាផ្ទះមួយជួរមាត់ស្ទឹងនោះ ទុកសម្រាប់ពួកទាហានប្រើ ។ ហើយចុះលោកចិត្រវិញ
ស្នាក់នៅ ឯណាដែរ ?
- បាទ! គឺនៅផ្ទះចាស់ដដែលហ្នឹងឯង ។
- អូហ៍ ហើយចុះពួកទាហានគេមិនហាមទេ ?
- មានរឿងវែងឆ្ងាយណាស់ ចាំថ្ងៃក្រោយចាំខ្ញុំជំរាប តែពេលនេះ
ខ្ញុំកំពុងតែមកតាមរកអូនណៃ...ពូមិនឃើញគេមកទីនេះទេ ?
- អ្នកគ្រូណៃ ? អត់ឃើញទេ បាទ! ប៉ុន្តែបើទៅសួរម្តុំខាងនោះ
មានស្រីៗប្អូនដប់នាក់គេស្នាក់នៅទីនោះ ក្រែងគេដឹង...

តាខេមលើកដៃចង្អុលទៅរោងមួយ ដែលនៅមិនឆ្ងាយពីនោះ
ប៉ុន្មាន រួចហើយគាត់ក៏ដើរនាំមុខលោកគ្រូពេទ្យទៅ ស្រាប់តែឃើញ
ស្ត្រីពីរបីនាក់នៅតម្កង់ជុំៗ ទំនងកំពុងកោសខ្យល់អោយអ្នកជំងឺ ។
- ក្មួយៗអើយ... មានឃើញស្រីម្នាក់ឈ្មោះណៃមកម្តុំនេះដែរទេ ?

តាខេមស្រែកសួរ ។
- មិនឃើញទេ ឃើញតែអ្នកជំងឺខ្យល់គដេកសន្លប់នៅក្រោមដើម ឈើកៀនព្រះវិហារ
សូមតាជួយមកមើលផង!

តាខេមបែរសម្លឹងលោកគ្រូពេទ្យ ហើយក៏ស្ទុះទៅជួយយក អាសារស្ត្រីអ្នកជំងឺនោះ ។
លោកគ្រូពេទ្យដាក់កង់ផ្អែកដើមឈើ ហើយក៏ស្ទុះចូលទៅរកជួយដែរ
ស្រាប់តែភ្ញាក់ព្រើតព្រោះអ្នកជំងឺ នោះជាអ្នកគ្រូចរណៃប្រពន្ធរបស់លោកនោះតែម្តង ។
- អូនណៃ!

លោកគ្រូពេទ្យខទានឡើងទាំងរន្ធត់ចិត្ត ត្រេកអរផង ភ័យផង ព្រមជាមួយគ្នា ។
គ្រាន់តែឃើញទឹកមុខរបស់ភរិយា លោកក៏ដឹង មុនរួចស្រេចទៅហើយ
ថានោះជាទឹកមុខមនុស្សដែលមិនបានដេក ពួនឬទទួលអាហារគ្រប់គ្រាន់ឡើយ ។

CHANBOKEO.COM

លោកគ្រូពេទ្យក៏ស្ទុះយ៉ាង រហ័សទៅលើកត្រកងប៊ីមីងណៃឡើង ដាក់លើកង់ដើរដឹកចេញទៅ ដោយមានតាខេមដើរជួយទប់ពីម្ខាងទៅផង ។

- អូនណៃ! បងចិត្រមករកអូនវិញហើយ... អូនកុំកើតអីណា៎! ប្រឹងទប់ស្មារតីឡើងអូន... បងនឹងនាំអូនត្រឡប់ទៅផ្ទះយើងវិញ ។

មីងណៃទន់ខ្លួនស្វាយល្អក បើកភ្នែកព្រឹមៗ និយាយលែងរួច ទៅហើយ ឃើញតែតំណក់ទឹកភ្នែកហូរដិតដាមពេញផ្ទៃមុខតែម្យ៉ាង ប៉ុណ្ណោះ ។ លោកគ្រូពេទ្យដើរដឹកកង់បណ្តើរ ទប់ខ្លួនភរិយាបណ្តើរ និយាយបណ្តើរ លើកទឹកចិត្តមីងណៃរហូត ៖

- ណៃ...! កុំកើតអីណា៎អូនណា៎ ! អូនត្រូវតែរឹងប៉ឹងឡើង ដើម្បីរង់ចាំការវិលត្រឡប់របស់កូនប្រុសស្រីរបស់យើង..ប្រឹងឡើងអូន... កុំបណ្តោយទឹកចិត្តអោយទន់ជ្រាយអី... បងចិត្រនៅក្បែរអូនហើយ អូនត្រូវតែជំនះ ជំនះនូវក្តីអស់សង្ឃឹមនិងទុក្ខសោកទាំងឡាយ...

ពិតមែនហើយ លោកគ្រូពេទ្យជាមនុស្សស្ងៀមៗ សំដីតិចតាំង ពីដើមមក តែពេលនេះ លោកបែរជាចង់និយាយ... និយាយច្រើន ណាស់ជាមួយភរិយារបស់លោក... អនិច្ចា! មីងណៃរបស់យើង មានសភាពទ្រុឌទ្រោមទន់ខ្សោយជាទីបំផុត មិនដឹងថាគាត់បានឮនូវពាក្យសំដីទាំងអស់របស់លោកគ្រូពេទ្យឬក៏យ៉ាងណាទេ ។

មួយស្របក់ក្រោយមក...

លោកគ្រូពេទ្យផ្តេកកាយភរិយា ទៅលើគ្រែរនាបក្រាលកន្ទេល កក់នៅក្នុងបន្ទប់ចាស់របស់លោក ។ រួចហើយក៏ស្ទុះម្នីម្នាចេញទៅ ជាន់ខាងក្រោម កកាយធុងយកថ្នាំនិងស៊ីរ៉ាំងមកចាក់អោយមីងណៃ យ៉ាងរហ័ស ។ ឯតាខេមក៏ស្ទុះទៅជួយបង្កាត់ភ្លើងដាំទឹកក្តៅយក មកជូនលោកគ្រូពេទ្យយ៉ាងញាប់ដៃជើងដែរ ។

បន្ទាប់មក លោកគ្រូពេទ្យបានអោយតាខេមខ្ចីកង់ និងបណ្ណ័អភ័យឯកសិទ្ធិសំរាប់បង្ហាញពពួកទាហានយាមប៉ុស្តិ៍ ក្រែងលោមាន គេចាប់នែកឆេរ ដើម្បីត្រឡប់ទៅយកឥវាន់របស់របរគាត់នៅឯវត្ត ត្រឡប់មកនៅជាមួយលោកគ្រូពេទ្យដូចដើមវិញ ។

ពេលវេលាដើរទៅយ៉ាងយឺតៗ...

CHANBOKEO.COM

លោកគ្រូពេទ្យអង្គុយសម្លឹងភក្ត្រដ៏សែនស្គាំងស្គម របស់ភរិយា
លួចនឹកអាណិតមីងណៃតែក្នុងចិត្តម្នាក់ឯង ។ មើលចុះ មីងណៃ ដែលធ្លាប់តែស្រស់ស្អាតផូផង់
ហើយញញឹមបញ្ចេញថ្ពាល់ខួចមិន ដែលដាច់ ពេលនេះ បានក្លាយទៅជាស្ត្រីចាស់ កោរសក់
មុខស្គម ជ្រីវជ្រួញ... ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏រង្វង់ភក្ត្រដ៏ជ្រីវជ្រួញ មួយនេះ
នៅតែមានអនុភាពមហិមាលើកកម្លាំងចិត្តលោកគ្រូពេទ្យ
អោយលោកញញឹមបានជាថ្មីម្តងទៀតក្នុងជីវិត យ៉ាងចំព្រង ។

- ណៃ! គេងសំរាកអោយបានច្រើនណា៎អូន! ពេលអូនមានកម្លាំង
ដឹងខ្លួនមកវិញ បងនឹងមានអ្វីច្រើនណាស់ចង់និយាយជាមួយអូន!

លោកគ្រូពេទ្យខ្ញាំដៃភរិយាយ៉ាងណែន ហើយអង្គុយសម្លឹងមីង ណៃយើងមិនដាក់ភ្នែកឡើយ ។
មួយស្របក់មក លោកក៏បន្ទាប នាសាផ្តិតលើថ្ងាសដ៏ជ្រីវជ្រួញស្លេកស្លាំងរបស់ភរិយា
ដោយដួងចិត្ត ស្នេហាយ៉ាងធំធេង ។ នៅក្នុងអារម្មណ៍ លោកបានផ្តិតភ្ជាប់រូបភាព
នោះទៅនឹងអតិតកាលមួយ ដែលលោកបានជួបនារីឈ្មោះ ចរណៃ
នៅវត្តកណ្តាលនាពេលបុណ្យចូលឆ្នាំខ្មែរឆ្នាំ១៩៥៨ នឹកដល់កំណាព្យ មួយ
ដែលលោកធ្លាប់បានលួចសរសេរឆ្លើយឆ្លងប្តូរគ្នាជាមួយនាង... នឹកដល់ស្នាមញញឹមមួយ
ដែលបង្កប់នូវខ្លួចមន្តស្នេហ៍យ៉ាងផ្អែម ល្ហែម
ធ្វើអោយបេះដូងរបស់លោកវង្វេងលង់ក្តីស្នេហ៍របស់នាងជា យូរឆ្នាំ តស៊ូរង់ចាំចរណៃយ៉ាងយូរ
ទំរាំបានជួបគ្នាចាប់ដៃជាគូជីវិត.. នឹកដល់កូនប្រុសស្រី ដែលធ្លាប់រស់នៅសប្បាយជិតជុំខ្លួន
មិនដែល មានរខិស្ថាន... នឹកដល់គ្រាដែលប្រពន្ធលោកពលីខ្លួន ដើម្បីរក្សា
ជីវិតរបស់លោកអោយរស់រាន...

ទឹកភ្នែកពីរតំណក់ក៏ហូរធ្លាក់ចុះមកតក់ៗ ស្រក់ចុះមកលើរង្វង់ មុខលោកគ្រូពេទ្យ
ហើយក៏ស្រក់ទៅលើថ្ងាសរបស់អ្នកជំងឺ ស្រាប់ តែមីងណៃជ្រួញចិញ្ចើម ប្រែខ្លួនតិចៗ
ហាក់ដូចជាកំពុងបានទទួល អារម្មណ៍ដ៏រំភើបរំជើបរំជួលរបស់លោកគ្រូពេទ្យហើយ ថ្វីបើមីងនៅ
សំរាន្តបិទភ្នែកឈឹងនៅឡើយ ។ ឃើញដូច្នោះ លោកគ្រូពេទ្យ ញញឹមភ្លាមតែម្តង ៖

- អូនណៃ! អូនដឹងខ្លួនវិញហើយ ?

លោកគ្រូពេទ្យរត់រឹង ចុះទៅផ្ទះបាយខាងក្រោម ចាប់ចន្លុះអុជ
បង្កាត់ភ្លើងដណ្តាំបបរអោយមីងណៃយើងយ៉ាងលឿន ទាំងដួងចិត្ត
រីករាយរំភើបសោមនស្សខុសធម្មតា ។

CHANBOKEO.COM

នៅខាងលើផ្ទះ... ក្នុងបន្ទប់លោកគ្រូពេទ្យ...

មីងណៃបើកភ្នែកឡើង បែរមើលជុំវិញខ្លួន...

- តើខ្ញុំនៅឯណា ?...

មីងសួរខ្លួនឯង រួចហើយក៏យកដៃឈ្លីក្បាល ព្រោះនៅព្រិល ភ្នែក ធឹងធោងក្នុងខ្លួននៅឡើយ ។ មួយស្របក់ក្រោយមក ទើប មីងយើងចំណាំបានថា នោះជាបន្ទប់ចាស់របស់គាត់និងលោកគ្រូ ពេទ្យ ។

- ហេតុអ្វីខ្ញុំមកដល់ទីនេះទៀតហើយ ?

មីងណៃសួរខ្លួនឯងតិចៗ បន្ទាប់មកក៏ខិតខំត្រដេរត្រដរក្រោក ឡើង ។ មែនហើយ! មីងចាំបានថា គាត់មិនបានពិសារអាហារ មួយថ្ងៃមួយយប់មកហើយ ហើយក៏មិនបានទទួលទានដំណេកទល់ ភ្លឺដែរ ។ ព្រឹកមិញនេះ មីងបានដើរដល់វត្តកណ្តាល ទៅរកថ្វាយ បង្គំព្រះ ប៉ុន្តែទៅមិនទាន់ដល់ព្រះវិហារផង ក៏ដួលបាត់ស្មារតីទៅ ព្រោះតែអត់បាយ អត់ងងុយ ហើយអស់កម្លាំងចិត្ត...

មីងណៃដើរយកដៃទប់ជញ្ជាំងកុំអោយដួល ហើយបែរមើលជុំ វិញខ្លួន ទំនងហាក់ដូចជាកំពុងចង់រកនរណាម្នាក់ តែមិនឃើញ សោះ ។ គាត់ក៏ទាញក្រមាមកទទូរ រួចចុះជណ្តើរមកក្រោម ហើយ ក៏ដើរចេញទៅក្រៅ ។ គ្រាន់តែដើរមកដល់ក្បែរគល់ចំប៉ា មុខផ្ទះ ស្រាប់តែគាត់មានអារម្មណ៍ថា ងងឹតមុខទៀតហើយ ។ មីងណៃក៏ យកដៃទប់ដើមនឹងដើមចំប៉ាទ្រោបមុខទប់ខ្លួនមួយស្របក់ធំ ក៏ងើប មុខឡើង គិតថានឹងដើរចេញទៅក្រៅ រកបារមីកូនស្រីរបស់មីង តាមដែលនាងបានណាត់កាលពីម្សិល ។ រំពេចនោះ គាត់ដាក់ភ្នែក ទៅចំទ្វាររបងមួយដែលមីងបានខាំដៃ យកឈាមចារពាក្យពេចន៍ សម្តែងអារម្មណ៍ផ្ញើទៅប្តីនិងកូន មានសេចក្តីថា ៖

- ណៃស្រឡាញ់បងចិត្រ! ណៃស្រឡាញ់កូនគ្រប់គ្នា! សូមអោយ យើងបានជួបគ្នាវិញឆាប់ៗនេះ!

ស្រាប់តែមីងបើកភ្នែកធំៗ ព្រោះពេលនោះ គាត់បានឃើញ ចំណារថ្មីមួយ ឆ្លើយតបមកមីងវិញថា ៖

- បងចិត្រស្រឡាញ់អូនណៃ ហើយស្រឡាញ់កូនរបស់យើងគ្រប់ៗ គ្នា! ថ្ងៃស្អែករបស់យើងបានមកដល់ហើយ! សូមអូនទទួលបង ផង ណាអូនណា!

CHANBOKEO.COM

គ្រាន់តែឃើញតួអក្សរទាំងនោះភ្លាម មីងណៃស្គាល់ភ្លាមថា នរណាជាអ្នកសរសេរ ។ ជាពិសេសទៅទៀតនោះគឺ ស្នាមរង្វង់រាង បេះដូងដែលម្ចាស់គេបានគូរព័ទ្ធជុំវិញរូបផ្កាចំប៉ាញីឈ្មោលដែលមីង បានគូរដាក់ទន្ទឹមគ្នា ។ រូបបេះដូងនោះប្រៀបមិនខុសពីឱសថទេព មកប្រោសទុក្ខសោកក្នុងឱរារបស់មីងណៃឡើយ.. មីងញញឹមឡើង ទាំងទឹកភ្នែករលីងរលោង ហើយឧទានខ្សិបៗថា ៖

- បងចិត្រ... ប្ដីសម្លាញ់របស់អូន!

មីងណៃញ័រខ្លួនចំប្រប់ដោយក្ដីរំភើបរំជើបរំជួល ។ ពេលនោះ មីងស្រក់ទឹកភ្នែកទៀតហើយ ។ មនុស្សយើងចម្លែកណាស់ កើត ទុក្ខក៏យំ រីករាយក៏យំ! មីងណៃញញឹមផង ស្រក់ទឹកភ្នែកផង ស្ទុះ ដើរទៅជិតរបង ដើម្បីអោយទៅបានឃើញអក្សរទាំងនោះជិតនឹង ភ្នែក ស្រាប់តែមីងនឹងឆោងជ្រុលខ្លួនទ្រោបទៅលើរបង សាជាថ្មី ម្ដងទៀត ។ ស្រាប់តែ...

- អូនណៃ...!

មីងភ្ញាក់ព្រើតកាលបើឮសម្លេងស្រែកពីក្រោយខ្នង ។ គាត់បែរ ងាកក្រោយយ៉ាងរហ័ស ស្រាប់តែប្រទះនិងបុរសចំណាស់ម្នាក់ ឈរ នៅមាត់ទ្វារផ្ទះ សម្លឹងមករកគាត់ទាំងទឹកមុខញញឹម ៖

- បងចិត្រ! (មីងណៃឧទានខ្សិបៗក្នុងមាត់)

ភ្លាមនោះ លោកគ្រូពេទ្យមានប្រសាសន៍ឡើងថា ៖

- អូនណៃ! បំរុងគេចទៅណាទៀតហ្នឹង ? កុំទៅអីណា៎អូន... ទីនេះជាផ្ទះរបស់យើង... គឺជាផ្ទះរបស់អូននិងបង... ត្រឡប់មក វិញ ណា៎អូនណា៎ !

លោកគ្រូពេទ្យពោលហៅភរិយា ដោយវាចាយ៉ាងស្រទន់ផ្អែម ល្ហែម... ជាពាក្យដែលមីងណៃរង់ចាំទទួលយូរមកហើយ ។ គ្រាន់ តែឮប្រសាសន៍របស់លោកគ្រូពេទ្យភ្លាម ស្នាមញញឹមមួយបាន ផុសអណ្ដែតឡើងលើផ្ទៃមុខដ៏ស្លេកស្លាំងរបស់មីងណៃ លាយឡំនឹង ក្ដីរំភើបយ៉ាងមហិមា ៖

- បងចិត្រ! (មីងណៃឧទានខ្សិបៗម្ដងទៀត)

លោកគ្រូពេទ្យក៏លាតរង្វង់ដៃរបស់លោកត្រដាងឡើងហាក់ដូច ជាកំពុងរង់ចាំទទួលយកមីងណៃ អោយទៅនៅក្នុងលង្វែកទ្រូង របស់លោកដូច្នោះឯង រួចហើយក៏មានប្រសាសន៍ថា ៖

CHANBOKEO.COM

- បេះដូងរបស់បង បានទទួលភាពរងាអស់ជាយូរឆ្នាំហើយ... បង កណ្តោចកណ្តែងណាស់... ថ្ងៃនេះ អោយបងសុំទទួលនូវភាពកក់ ក្តៅពីប្រពន្ធរបស់បងបានខ្លះទេ ណែ... ?

មីងណៃរំជួលចិត្តណាស់ កាលបើឃើញលោកគ្រូពេទ្យបន្ទន់ កិរិយាមករកគាត់យ៉ាងដូច្នោះ ។ មីងទ្រាំមិនបាន ក៏ស្រក់ទឹកភ្នែក ច្រោក ស្ទុះរត់សំដៅរង្វង់ដៃរបស់ស្វាមី យ៉ាងលឿនដូចព្រួញ ។ ថ្វីបើពេលនោះ មីងនៅនឹងឆោងនៅឡើយ តែកម្លាំងចិត្តមួយបាន ជំរុញឲ្យមីងប្រឹងរត់មកដល់ជិតលោកគ្រូពេទ្យហើយ ហើយក៏ដួល ព្រួសទៅក្នុងរង្វង់ដៃ ដែលកំពុងលាតរង់ចាំត្រកងយករូបមីងយ៉ាង ណែនទៅផ្ទាប់នឹងដើមទ្រូងរបស់លោកគ្រូពេទ្យតែម្តង ។ ទាំងគូ ស្រវាអោបគ្នាយ៉ាងអស់ទំហឹង ដោយដួងចិត្តស្នេហានិងក្តីនឹករលឹក ដ៏ធំធេង ឥតព្រំដែន...

- អូនណៃ !

- បងចិត្រ !

លោកគ្រូពេទ្យស្រវាអោបភរិយា អង្អែលផង ថើបផង ទៅ តាមកំសួលនៃចិត្តនឹករលឹកនិងក្តីប្រតិពទ្ធ័គ្មានថ្ងៃបំភ្លេចបាន ។

- ណៃ... បងនឹកអូនណាស់... !

មីងណៃរន្ធត់ចិត្តនិយាយលែងចេញតទៅទៀត គិតតែពីស្រក់ ទឹកភ្នែកខ្សឹកខ្សួលតែម្យ៉ាងប៉ុណ្ណោះ ។ ពេលនោះ មីងមានអារម្មណ៍ ថារបួសដួងចិត្តរបស់មីង កំពុងទទួលឥទ្ធិពលឱសថទេពយ៉ាង វិសេសវិសាលក្រៃលែង ។ ចំណែកលោកគ្រូពេទ្យក៏ដូចគ្នាដែរ ។ លោកមានអារម្មណ៍ថា រូបលោកកំពុងតែអណ្តែតនៅលើស្រឹង្គាដ៏ ល្អស្អាតពណ្ណរាយ ជាមួយភរិយាជាទីស្រឡាញ់របស់លោក តែពីរ នាក់...

បន្តិចមក លោកគ្រូពេទ្យក៏លើកយកដៃឆ្លិតទឹកភ្នែក ចេញពី ថ្ពាល់របស់ភរិយា ហើយស្រដីថា ៖

- បងខានឃើញណៃញញឹមយូរហើយ... បងពិតជានឹកស្នាមញញឹម លើមុខអូនណាស់ ! ណៃញញឹមផង់ះចិត្តនឹករបស់បងបន្តិចណ៎ា !

មីងណៃអត់មិនបាន ក៏ញញឹមឡើងភ្លាម ទាំងទឹកភ្នែកដក់នៅ ក្នុងកែវនេត្រានៅឡើយ រួចហើយមីងក៏សួរវិញថា ៖

- ហើយចុះឯណាស្នាមញញឹមរបស់បងសំរាប់ផ្ញើណៃវិញនោះ ?

CHANBOKEO.COM

- នែ៎ះ! មានច្រើនណាស់... ស្រស់ទេអូន?

លោកគ្រូពេទ្យញញឹមភ្លាម រួចហើយក៏យកដៃមីងណៃទៅផ្ទិតលើថ្ពាល់ដ៏ស្គមជ្រីវជ្រួញរបស់លោក ។ មីងណៃក៏ឆ្លើយវិញយ៉ាងពិរោះស្រទន់ថា ៖

- ថ្ពាល់បងមិនស្រស់ទេ តែស្នាមញញឹមរបស់បងមានស្នេហ៍ណាស់ ណៃឃើញហើយចាំមួយជីវិត ។

ឮដូច្នោះ លោកគ្រូពេទ្យសើចគ្រហាញ ទាំងទឹកភ្នែករលីង រលោងក្នុងនេត្រា ៖

- អញ្ចឹង បងសុំរៀនញញឹមតាមអូនហើយណា៎ ដើម្បីអោយណៃចងចាំអនុស្សាវរីយ៍ដ៏ល្អៗនេះរៀងរហូតទៅ ។

ទាំងគូក៏ញញឹមដាក់គ្នាឡើង... ជាស្នាមញញឹមលើកដំបូង តាំង ពីប្អូនឆ្នាំកន្លងមកហើយ ដែលលោកទាំងពីរគ្មានលទ្ធភាពនឹង ញញឹម ចេញមកអោយអស់ពីដួងចិត្ត ចំពោះគ្នាទៅវិញទៅមក ។ រំពេចនោះ មីងណៃអូសដៃស្វាមីដើរ បំរុងដើរចេញទៅ ។

- ចង់ទៅណាហ្នឹង ណៃ?
- គឺអូនចង់ទៅរកបារមីនិងចៅមុំ...
- អូនស្គាល់ផ្ទះដែលកូនយើងស្នាក់នៅដែរហ្មែ៎ស!
- មិនស្គាល់ទេ តែកូនបានប្រាប់តម្រុយអោយទៅរកហើយ ។
- អញ្ចឹងមិនបាច់ទៅទេ!
- ម៉េចអញ្ចឹង?
- ព្រោះបងបានពឹងពូខេមអោយជិះកង់ទៅតាមមកហើយ ។
- ពូខេម? គាត់នៅទីនេះជាមួយបងដែរ?
- អត់ទេ! បងទើបតែជួបគាត់ព្រឹកមិញនេះដោយចៃដន្យ ពេលបងទៅតាមរកអូននៅវត្តកណ្តាល ។

ភ្លាមនោះ មីងណៃធីងឆោងរកកលនឹងដួលម្តងទៀត ។

- អូនអស់កម្លាំង គួរតែសំរាកសិនទៅណា៎! បន្តិចទៀតកូនចៅ របស់យើងមកដល់ហើយ ។ អូនត្រូវតែមានកម្លាំងញញឹមសំរាប់ការ វិលត្រឡប់របស់ពួកគេណា៎! (លោកគ្រូពេទ្យមានប្រសាសន៍)

CHANBOKEO.COM

វាចាហើយ លោកគ្រូពេទ្យក៏បីភរិយាត្រឡប់ទៅគ្រែវិញ រួចក៏ត្រឡប់ទៅដួសបបរមកអោយភរិយាបរិភោគ មើលទៅមិនខុសពីគូ ស្វាមីភរិយាដ៏ថ្មីថ្មោងនៅក្នុងវេលាសុភមង្គលរាត្រីទឹកឃ្មុំ យ៉ាង ដូច្នោះឡើយ ។ មួយស្របក់ក្រោយមក លោកគ្រូពេទ្យទាញ កញ្ចប់ក្រណាត់ពីហោប៉ៅ លាតយកចិញ្ចៀននឹងខ្សែកចេញមក ៖

- ណៃ! បងមិនដែលដកចិត្តស្រឡាញ់របស់បងពីអូនមកវិញ ម្តង ណាទេ ។ ដូច្នេះ បងក៏គ្មានសិទ្ធិទទួលសំណងទាំងនេះពីអូនដែរ... សូមអូនទទួលយកពាក់វិញទៅ ណា៎អូនណា៎!

ថាហើយ លោកក៏ទាញចិញ្ចៀនយកទៅស៊កម្រាមដៃអ្នកគ្រូ ចរណៃកំពូលដួងចិត្តរបស់លោក រួចហើយក៏លើកខ្សែកបំពាក់ជូន វិញដោយក្តីស្នេហាយ៉ាងធំធេង ។ មីងណៃសម្លឹងមើលតាមឥតមានពាព្រិចទេ រួចក៏អោនទទួល យកទាំងរំភើបចិត្តរហូតរលីង រលោងទឹកភ្នែក ។

- រក្សាទុកចុះណា៎អូន! សូមអោយជីវិតគូស្រករបស់យើងបាន ប្រទះនូវពន្លឺសុភមង្គលត្រចះមកវិញ ចាប់ពីថ្ងៃរៀងទៅ!

មានប្រសាសន៍រួចហើយ លោកក៏ថើបថ្ពាសភរិយាបង្ហាញនូវ សេចក្តីស្រឡាញ់របស់លោកចំពោះភរិយាយ៉ាងជ្រាលជ្រៅ ។

- យល់ចិត្តបងហើយមែនទេ ណៃ?

មីងណៃញញឹមហើយងក់ក្បាល ៖

- ចា៎សបង! ពិភពលោកនេះពិតជាមានអត្ថន័យ គួរអោយចង់រស់ នៅខ្លាំងណាស់ កាលបើអូនមានរូបបងនៅក្បែរ ជាគូជីវិត ។

- ដូចគ្នាដែរ... បងពិតជាមានសំណាងក្រៃលែងដែលបងនៅមាន ឱកាសបានវិលមកសាងសុភមង្គលគ្រួសារ ជាមួយម្ចាស់បេះដូង របស់បង សាជាថ្មីម្តងទៀត...

លោកទាំងពីរនៅសាសងគ្នា សម្តែងនូវក្តីនឹករលឹកដែលលោក មានចំពោះគ្នាទៅវិញទៅមក ហើយក៏ទម្លាយប្រាប់គ្នាផងដែរ នូវ ប្រវត្តិទាំងឡាយដែលលោកបានដើរឆ្លងកាត់ នៅក្នុងឱកាសដែល លោករស់នៅបែកគ្នា ក្រោមរឃ្លៀបរបបអង្គការផ្តាច់ការរបស់ខ្មែរ ក្រហម ។ មីងណៃសំរាន្តកើយលើទ្រូងស្វាមី ទទួលនូវភាពកក់ ក្តៅយ៉ាងរមនាក្សេមក្សាន្តបំផុត...

- ថ្ងៃស្អែករបស់យើងបានមកដល់ហើយ អូនណៃ... ពេលនេះ យើងត្រូវតែត្រៀមខ្លួន តាមរកកូនរបស់យើងគ្រប់គ្នាអោយឃើញ ហើយទទួលយកគេមកផ្ទះយើងវិញ...

CHANBOKEO.COM

- ចាស! កាលបើអូនមានរូបបងជាបង្អែកកម្លាំងចិត្ត អូនអាចពុះ ពារអ្វីសព្វយ៉ាង ដើម្បីសុភមង្គលគ្រួសាររបស់យើង បានជានិច្ច ។

ស្នាមញញឹមថ្មីបានអណ្តែតឡើងម្តងទៀត នៅលើផ្ទៃមុខដ៏ស្គាំង ស្គមជ្រីវជ្រួញនៃគូជីវិតមួយគូ ដែលមានសំណាងយ៉ាងខ្ពស់បំផុត លើសគូជីវិតដទៃទៀតរាប់លាននាក់ ព្រោះលោកបានគេចរួចពីសេចក្តីស្លាប់ និង ការផ្តន្ទាបំផ្លិចបំផ្លាញរបស់អង្គការខ្មែរក្រហម ។ ថ្វីបើពេលនោះ លោកមិនទាន់បានជួបជុំកូនចៅរបស់លោក នៅ ឡើយក៏ដោយ ក៏លោកនៅមានសល់កម្លាំងចិត្តយ៉ាងមុតមាំ ដើម្បី រង់ចាំថ្ងៃស្អែកជួបកូនៗរបស់លោកជាថ្មី ត្បិតលោកទាំងពីរកំពុងតែ បានទទួលកម្លាំងចិត្តពីគ្នាទៅវិញទៅមកយ៉ាងកក់ក្តៅជាទីបំផុត ។

*0000000000000000000*

*00000*

*0*

CHANBOKEO . COM

# វគ្គទី៩
# រន្ទះវាសនា

វាលទ្រា បាត់ដំបង...

ខែឧសភា ១៩៧៥...

ក្នុងសម្លៀកពាក់ខ្មៅ ជួតក្រមាចាស់ៗ លោកគ្រូពេទ្យនិងប៊ុរី នាំគ្នាគេចខ្លួនតម្រង់ទៅរនាម ។ ពេលនោះ លោកធ្វើដំណើរតែ ពេលយប់ទេ ហើយពួនលាក់ខ្លួននៅពេលថ្ងៃ ។ ការពិត លោកមិនស្គាល់ភូមិសាស្ត្រទឹកដីទីនោះប៉ុន្មានទេ គ្រាន់តែដឹងតាមភូមិសាស្ត្រ ក្នុងវិជ្ជាសិក្សាកាលពីនៅរៀនតែប៉ុណ្ណោះ ។

លុះមកដល់តំបន់មួយឈ្មោះកូនកុក...

អ្នកទាំងពីរកំពុងតែដើរលបៗ ឆ្លងដីស្រែធ្វើដំណើរទៅរកទិស ខាងកើតឈៀងខាងជើង ស្រាប់តែប្រទះហ្វូងពួកកងឈ្លបខ្មែរ ក្រហមនាំមុខកងយុវជនយុវនារីធ្វើដំណើរទៅរនាមដែរ ។ កាលបើ ឃើញស្រមោលមនុស្សស្ទុងៗ ពួកនោះក៏លើកពិលឈ្លូលហើយ លើកកាំភ្លើងបាញ់រះឡើងប្រាវៗតែម្តង ។ ស្លន់ពេក លោកគ្រូពេទ្យ សំរេចចិត្តរត់បំបែកផ្លូវគ្នាពីកូនប្រសារ ហោចណាស់បើសិនជា ត្រូវស្លាប់ គឺមិនចង់អោយស្លាប់ទាំងព្រមឡើយ ។ ប៊ុរីក៏ស្ទុះរត់គេច ទៅតាមទិសមួយ ។ ឯលោកគ្រូពេទ្យក៏ចេញទៅតាមទិសមួយ ទៀត ។ សំណាងល្អ លោកមិនមានត្រូវរបួសអ្វីទេ ។ ប៉ុន្តែ ចាប់ពីថ្ងៃនោះមក លោកក៏លែងដឹងដំណឹងពីប៊ុរីកូនប្រសាររបស់ លោកទៅ មិនដឹងថាគេនៅរស់ឬទទួលសុខទុក្ខយ៉ាងណាឡើយ ។

ក្រោយមក លោកបានប្រទះនឹងអ្នកស្រុកប្អូនដប់នាក់ដែល រត់គេចខ្លួនពីអង្គការខ្មែរក្រហមដូចលោកអញ្ចឹងដែរ ។ គេបាននាំ គ្នាបង្កើតឈ្មោះក្រុមគេថាខ្មែរស ។ លោកបានចូលរួមជាមួយពួកគេ ពួនក្នុងព្រៃចាប់ត្រីជាអាហារ

CHANBOKEO.COM

និងលួចស្រូវពោតពីក្នុងស្រែរនាមមក ធ្វើជាអាហារបរិភោគ ។
លោកគ្រូពេទ្យមិនចំណាប់ខាងលួចឆក់ប្លន់ ឬបាញ់នរណាឡើយ ។
លោកបានត្រឹមតែនៅដណ្តាំបាយនិងរក្សាគ្នា ពេលមានអាសន្នអន់ក្រឬធ្វើអ្វីផ្សេងតែប៉ុណ្ណោះ ។
ក្រោយមក ពួក គាត់បានពង្រីកក្រុម ហើយបានបំបែកគ្នាធ្វើចលនាតស៊ូប្រឆាំងនឹង
របបផ្តាច់ការរបស់អង្គការ ។ ថៃដន្យ កងទព័ខ្មែរសនោះតូចពេក
ណាមួយគ្មានបណ្តាញចេញចូលរកជំនួយរកកម្លាំងពីក្រៅផង បាន
ត្រឹមតែរស់ឆក់ប្លន់ពពួកទ័ពខ្មែរក្រហម ដែលធ្វើដំណើរដាច់ប៉ែកតែ ម្យ៉ាង
ម្ល៉ោះហើយពុំមានកម្លាំងធំគ្រប់គ្រាន់សំរាប់ពង្រីកពង្វាតរំដោះ
ជាតិខ្មែរអោយមានសេរីវិញបាននៅឡើយ ។ ប៉ុន្តែទោះជាយ៉ាងណា
ខ្មែរសទាំងនោះបានផឹកទឹកសម្បថសច្ចាស្លាប់រស់នឹងគ្នា ហើយមិន
ព្រមវិលត្រឡប់ចូលភូមិមកបំរើកងទ័ពអង្គការវិញជាដាច់ខាត ។

ក្រោយមក ក្រុមនោះ បានរីកសាយធំឡើងនៅរនាម ឆ្លងទៅ
ខាងជើងរហូតដល់ក្រឡាញ់ព្រៃមាន់ ទៅខាងកើតរហូតដល់កកោះ មោងឬស្សី ។
គួរអនិច្ចាណាស់! កងទ័ពខ្មែរសខ្លះ បានចូលតស៊ូជា មួយនឹងពពួកខ្មែរក្រហម
ហើយបានត្រូវចាញ់ដៃស្លាប់រង្គាល ។ ខ្លះ ទៀតនៅមានរាសីល្អ
អាចរត់គេចខ្លួនរួចរស់ផុតសេចក្តីស្លាប់ រួច ហើយក៏ប្រវេប្រវានាំគ្នាកទ័ពសាជាថ្មី
តាមដែលអាចធ្វើបាន ។ រីឯ អ្នកស្រុកវិញក៏ហាក់ដូចជាមានបំណង អោយពពួកខ្មែរសទាំងនោះ
មានកម្លាំងមករំដោះពួកគេដែរ ព្រោះពួកគេហ៊ានរហូតផ្តាច់បាយ
បបរពីមាត់ឲ្យទព័ខ្មែរសឆីចំអែតគម្លានតាមដែលអាចធ្វើបាន ។

នៅសម័យនោះ អង្គការបានបង្អត់បាយអ្នកស្រុកមិនអោយ បរិភោគឆ្អែតដេកឆ្អែតឡើយ ។
អ្នកស្រុកត្រូវក្រោកធ្វើការតាំងពី មាន់រងាវម្តងរហូតដល់យប់អាធ្រាត សំរាកតែពេលបាយថ្ងៃត្រង់
មួយម៉ោង និងពេលបាយល្ងាចមួយម៉ោង ។ ម្ល៉ោះហើយ ពលរដ្ឋ ជាច្រើនបានត្រូវបាក់កម្លាំង
ដួលដេកស្លាប់បន្តកន្ទុយរៀងរាល់ថ្ងៃ ។
ក្រុមគ្រួសារត្រូវគេបំបែកអស់...ទ្រព្យសម្បត្តិត្រូវគេរិបយករលីង...
ស្រូវអង្ករត្រូវអង្គការប្រមូលខ្ទេចខ្ទី... រីឯពលរដ្ឋធ្វើការទាំងចាស់ ទាំងក្មេងគ្មានសល់
តែគួរអោយឆ្ងល់ណាស់ ប្រទេសខ្មែរបែរជាក្រី
ក្រអត្តខាត់យ៉ាងអណោចអធម្មទៅវិញ...អ្នកស្រុកហុតបបរខៃចម្រូត

CHANBOKFO.COM

យុវជន២០ឆ្នាំមានមុខជ្រីវជ្រួញស្គាំងស្គម ដើរកោងដូចតាចាស់ ។
នារីជំទង់ក្លាយជាដូនជរាមើលមិនយល់... ជនណាដែលបានឆ្លងកាត់ សម័យនោះហើយ
រមែងខ្លាចរអាមិនចង់វិលឃើញភពនរកប្រេត នោះម្តងទៀតឡើយ
ជាពិសេសគឺការកាត់ទោសកាប់សម្លាប់ពលរដ្ឋ ស្លូតត្រង់ដោយស្នាដៃអង្គការ
ដោយមិនចាំបាច់ពន្យល់ហេតុផលឬ មានតុលាការបើកក្តីជំរះ ។

ខែមិនា ១៩៧៦...

ខែប្រាំង ដីបែកក្រហែង មេឃក្តៅស្ទើរឆេះក្បាល... មិនខុស អីពីចិត្តលោកគ្រូពេទ្យ
ដែលឆាបឆេះឆួលអួលណែនចំពោះជីវិត របស់លោក ដែលស្ថិតក្នុងដង្កៀបដ៏ចង្អៀតចង្អល់...
ឥតសេរីភាព.. មិនមានកោះត្រើយ ។ ដោយនឹកប្រពន្ធរបស់លោកពេក ទ្រាំមិន បាន
លោកគ្រូពេទ្យបានធ្វើដំណើរត្រឡប់តាមទន្លេ មករកអ្នកគ្រូ ចរណៃវិញ នៅឯវាលទ្រាបាត់ដំបង ។
លោកបានលាក់ខ្លួននៅក្នុង ជង្រុកអ្នកស្រុកមួយដែលអង្គការរិបអូសយកដាក់ជារបស់រួមហើយ
ជង្រុកនោះ បានត្រូវគេប្រើសំរាប់ផ្ទុកផ្លែគរជំនួសគ្រាប់ស្រូវដែល
ពួកវាបានបារដឹកចេញតាមត្រាក់ទ័រចេញទៅអស់ពីភូមិ យកទៅ ទីណាមិនដឹង ។
លោកចំណាយពេលរង់ចាំអស់ពីរថ្ងៃ ទំរាំស៊ើបដឹង ថា
ប្រពន្ធរបស់លោកត្រូវគេផ្លាស់ប្តូរទីលំនៅទៅនៅខាងណា ។

ថៃ្ងដន្យ លោកក៏បានជួបភរិយាដូចបំណង ប៉ុន្តែពេលវេលានៃ
សេចក្តីសុខរបស់លោកជាមួយប្រពន្ធជាទីស្រឡាញ់ មានរយៈកាល ខ្លីណាស់ ព្រោះ
លោកបានត្រូវគណយោធាឃុំម្នាក់តាមទាន់ហើយ ត្រូវគេបាញ់របួសជើងស្តាំ
តែលោកក៏ត្រូវបានរួចជីវិតមកវិញព្រោះ ប្រពន្ធរបស់គាត់បានលុតជង្គង់ចុះចាញ់បច្ចាមិត្ត
យល់ព្រមរៀបការ នឹងនាយកងគណឃុំ ដែលជាសមាជិកអង្គការខ្មែរក្រហមដ៏មាន
ពិសពុលមួយរូបនោះ ។ ទង្វើនិងការសម្រេចចិត្តរបស់អ្នកគ្រូ ចរណៃនៅថ្ងៃនោះ
បានធ្វើអោយលោកគ្រូពេទ្យរន្ធត់តក់ស្លុតក្នុងចិត្ត មិនអាចទទួលបានឡើយ
ដោយប្រពន្ធជាទីស្រឡាញ់ ត្រូវគេបេះ យកស្រស់ៗដោយចុងកាំភ្លើង ។ ឯលោកវិញ
បែរជាគ្មានលទ្ធភាព ជួយប្រពន្ធរបស់ខ្លួនបានពីឃ្នៀបអង្គការ...

លោកគ្រូពេទ្យឈឺចាប់ក្នុងចិត្ត ស្ទើរតែគាំងបេះដូងស្លាប់ទាំង ជំហរតែម្តង ។
ដោយសារមានរបួសធ្ងន់នៅជើងស្តាំរបស់លោក
លោកដុកទ័រមិនអាចធ្វើដំណើរត្រឡប់ទៅជំរំខ្មែរសវិញបានឡើយ ។ ទីបំផុត

CHANBOKEO.COM

លោកក៏ត្រូវដួលសន្លប់នៅម្តុំណាមិនដឹង ហើយបានត្រូវ អ្នកស្រុកម្នាក់បររទេះមកពីរនាម ប្រទះឃើញក៏ដឹកយកមកភូមិ មួយដែលមានឈ្មោះថា ព្រៃទទឹង ។ បុរសនោះមានវ័យប្រហែល ជាង៦០ឆ្នាំហើយ ឈ្មោះតាចាប មានកូនស្រីម្នាក់ឈ្មោះកាជេន អាយុសាមសិបតែមានសតិមិនសូវគ្រប់លក្ខណៈទេ ។ រីឯប្រពន្ធ របស់គាត់បានស្លាប់ទៅយូរឆ្នាំហើយ ។ ចៃដន្យ តាចាបធ្លាប់ទៅ សំរាន្តនៅមន្ទីរពេទ្យបាត់ដំបងកាលពីសម័យសាធារណរដ្ឋខ្មែរហើយ ធ្លាប់បានទទួលការព្យាបាល ដោយយកចិត្តទុកដាក់ពីលោកគ្រូពេទ្យ វិចិត្រ ។ កាលបើគាត់បានប្រទះលោកគ្រូពេទ្យតាមផ្លូវភ្លាម តាចាប ក៏ចំណាំលោកបានតែម្តង ។

លោកគ្រូពេទ្យបានទទួលការថែរក្សាពីតាចាប អស់ជាយូរខែ ដោយការលួចលាក់ទំរាំតែបានជាសះស្បើយជើងរបស់លោកវិញ ។ សំណាងល្អ តាចាបជាមនុស្សមានថ្វីមាត់ណាស់ហើយក៏មាននិស្ស័យ ជាមួយលោកគ្រូពេទ្យណាស់ដែរ ។ ទីបំផុត តាចាបក៏អាចបញ្ចុះ បញ្ចូលមេកងប្រចាំភូមិ អោយទទួលចុះឈ្មោះលោកគ្រូពេទ្យ ជា សមាជិកកងក្នុងភូមិ មានរបបបរមួយវែក ដូចគេដូចឯង ។ ពេលនោះ លោកគ្រូពេទ្យបានត្រូវតាចាបដូរឈ្មោះទៅជា ពូសុខ ហើយត្រូវជាប្តីក្លែងក្លាយ របស់នាងកាជេន ។ តាចាបធ្វើដូច្នោះ គឺដើម្បីរក្សាសុវត្ថិភាពពូសុខកុំឲ្យអង្គការលើសង្ស័យ ។ ដោយហេតុ លោកគ្រូពេទ្យរបស់យើងមានរបួសជើងទើបនឹងជា មិនអាចធ្វើការ អ្វីធ្ងន់បាន ណាមួយលោកក៏មានសក់ស្កូវល្បាយអាចម៍ខ្លា ត្រូវនឹង រូបរាងស្គាំងស្គមមើលមិនយល់ផងនោះ មេកងនោះក៏សំរេចអោយ លោកគ្រូពេទ្យឬពូសុខជាអ្នកដាំបបរខ្ទះប្រចាំរោងបាយការដ្ឋាន ។

ចាប់តាំងពីថ្ងៃនោះមក លោកគ្រូពេទ្យយើងក៏រស់នៅស្ងាត់ ស្ងៀម ប្រៀមក្តីឈឺចាប់ក្នុងបេះដូងតែម្នាក់ឯងរហូតមក មិនដែល និយាយប្រាប់នរណា មិនរំលឹកពីឈ្មោះប្រពន្ធកូន មិនរំលឹកពីអតីត កាល រស់នៅដូចចម្លាក់ដែលមានតែរូបឥតវិញ្ញាណ ។ ប៉ុន្តែទោះបី ជាយ៉ាងណា លោកគ្រូមិនអាចកាត់ផ្តាច់ដួងចិត្តរបស់លោកពីប្រពន្ធ ដែលលោកធ្លាប់រស់នៅនែបនិត្យរាប់ឆ្នាំជាមួយគ្នានោះឡើយ ។

មើលចុះ ! ថានាងកាជេនទៅ ថាគ្នាមិនគ្រប់លក្ខណៈតាំងពី កំណើតមក ទើបត្រូវរស់ជាមនុស្សវង្វេងវង្វាន់មិនគ្រប់ដប់ ។ តែ ពូសុខថ្មីរបស់យើង

CHANBOKEO.COM

ក៏គ្មានលក្ខណៈអ្វីប្រសើរជាងនាងកាជេនប៉ុន្មាន ដែរ រហូតត្រូវអ្នកស្រុកសើចចំអកទាំងកង ថាអ្នកទាំងពីរសមគ្នា ណាស់ដែលធ្វើជាប្តីប្រពន្ធនឹងគ្នា.. ម្នាក់និយាយច្រើនជ្រុល ស្តាប់មិនដឹងទិសតំបន់ស្អីសោះ ។ ម្នាក់ទៀតស្ងៀមស្ងាត់ដូចមនុស្សគ ហើយភ្លេចច្រើន ប្រាប់ក៏មិនចាំ ហៅក៏មិនឮ និយាយរកក៏មិនឆ្លើយ គឺធ្វើព្រងើយ មើលមេឃធ្វើធ្មឹងៗតែម្នាក់ឯងអញ្ចឹងទៅ ។

សំណាងដែរ ដោយសារតែហេតុនេះហើយទើបគេយល់ច្រឡំ ថាលោកគ្រូពេទ្យជាមនុស្សមិនគ្រប់សតិ ហើយក៏គ្មាននរណាសូវរវី វល់តាំងពីពេលនោះមក ។ គេច្រើនតែហៅប្រើជួយដៃជើងគេ បន្តិចបន្តួចនៅការដ្ឋានរោងបាយដូចជាពុសអុស ដាំបបរ និងលាង ចានលាងឆ្នាំងបំរើពួកកងឈ្លបតែប៉ុណ្ណោះ ។

រៀងរាល់យប់ លោកគ្រូពេទ្យតែងតែដើរទៅសំកុកនៅមាត់ ស្រះក្រោមដើមឆ្លង់ដ៏ធំត្រឈឹងត្រឈៃមួយ សំរាន្តមើលមេឃមើល ផ្កាយទល់ៗភ្លឺ ។ លោកមិនដែលចូលសំរាន្តក្នុងផ្ទះជាមួយគ្រួសារតា ចាបទេ ថ្វីបើតាហៅឡើងអោយទៅសំរាន្តទីនោះក៏ដោយ ។ បើសិនជាយប់ណាមានភ្លៀងវិញ លោកសុខចិត្តធ្វើបាបខ្លួនទទូរ ស្បូវកណ្តុប អង្គុយហាលភ្លៀងទល់ភ្លឺតែម្នាក់ឯង ។ លោកគ្រូពេទ្យ ធ្វើបាបខ្លួនឯង អោយឈឺចាប់ផ្លូវកាយ ដើម្បីអោយលោកបាន បំភ្លេចក្តីឈឺចាប់នៅក្នុងចិត្តរបស់លោក ។ លោកមិនអាចទទួល យកបានទេ ពេលណាដែលលោកគិតទៅដល់ប្រពន្ធរបស់លោក ដែលលោកធ្លាប់បីបមថ្នាក់ថ្នមប្រលែង... បែរក្លាយទៅជាប្រពន្ធ របស់អ្នកដទៃ...មានគេគ្រប់គ្រងនាងជំនួសរូបលោក... មិនដឹងថា តើនាងនឹងបានទទួលក្តីសុខ ឬក៏នាងបានទទួលសេចក្តីទុក្ខដូចជារូប លោកដែរឬយ៉ាងណា..

នៅក្រោមដើមឆ្លង់លើគ្រែរនាបឫស្សីមួយ...

លោកគ្រូពេទ្យសម្លឹងមើលទៅមេឃ និយាយរកផ្កាយតែម្នាក់ ឯងយ៉ាងសោកាត្រមង់ត្រមោច ៖

- អូនណែ..! ពេលនេះ អូនមានសុខទុក្ខយ៉ាងណា ? អូនរស់នៅ សុខសប្បាយជាមួយគូថ្មី ឬក៏អូនត្រូវគេធ្វើបាបវេទនាបែបណាទៅ វិញ ? បងខំកាត់ចិត្តណាស់ថាមិននឹកអូន... តែបងធ្វើមិនបាន... បងនឹកអូនណាស់ ណែ... បងពិតជានឹកអូនណាស់! ! កូនសម្លាញ់ របស់ប៉ាអើយ... តើកូនទាំងអស់នៅឯណាដែរ ? សុខទុក្ខម្តេចម្តា ទៅហើយ ? តើធ្វើម៉េចនឹងអោយប៉ាបានដឹងដំណឹងពីកូន ? ឬក៏ យើងត្រូវបែកគ្នារហូតទៅ គ្មានថ្ងៃវិលវិញ ?

CHANBOKEO.COM

លោកគ្រូពេទ្យយកដៃផ្ទិតទឹកភ្នែក.. មែនហើយ! ជាតិជាបុរស ស៊ូស្រក់ឈាមមិនអោយស្រក់ទឹកភ្នែក តែលោកគ្រូពេទ្យធ្វើមិនបាន ទេ! លោកជាមនុស្សលោក មានបេះដូង មានអារម្មណ៍ មានក្តី ស្រឡាញ់ពេញដើមទ្រូង ។
កាលបើមនុស្សជាទីស្រឡាញ់ត្រូវព្រាត់ ទៅ តើនរណាមិនរំជួលចិត្តនោះ ?
សូម្បីព្រះវេស្សន្តរដែលមានចិត្ត សទ្ធាយ៉ាងណា
ក៏មិនអាចទ្រាំបាននឹងតាជូជកដែលវាយអូសកូនចៅ របស់លោកចេញទៅ
រហូតលោកហ៊ានលើកធ្នូប៉ងយាយីព្រាហ្មណ៍ ដើម្បីការពារបុត្រ... ចុះទំរាំបើលោកគ្រូពេទ្យ ដែលត្រឹមតែជា បុថុជ្ជនសាមញ្ញម្នាក់ រឿងអ្វីដែលលោកគ្រូពេទ្យគ្មានសិទ្ធិរំជួលចិត្ត ស្រក់ទឹកភ្នែកដោយការព្រាត់ប្រាសប្រពន្ធកូនទាំងបង្ខំនោះ ?

ការពិត ការសម្រក់ទឹកភ្នែកចេញមកមិនមែនជាសក្ខីភាពនៃ
ភាពទន់ខ្សោយរបស់បុរសស្ត្រីណាម្នាក់ទេ... ការសម្រក់ទឹកភ្នែកគឺ
ជាមធ្យោបាយដ៏ត្រជាក់បំផុតដែលអាចពន្លត់ចិត្តមនុស្ស ពីក្តៅរោល រាលមកត្រជាក់វិញបាន ដោយគ្រាន់តែបណ្តោយអោយគេយំអោយ អស់ចិត្តតែប៉ុណ្ណោះ ។ បើមិនដូច្នោះទេ ទឹកភ្នែកដែលមិនអាចហូរ ចេញមកក្រៅបាននឹងក្លាយជាបូសកំហឹងឃ្នាន់ខ្នាញ់ក្នុងចិត្ត អាចបង្ក បង្កើន ជាគំនុំសងសឹកគ្នាគ្មានថ្ងៃស្ងើយរសាយឡើយ...

រំពេចនោះ សតិមួយបានលេចធ្លោឡើងមកដាស់អារម្មណ៍របស់ លោកគ្រូពេទ្យយើង អោយនឹកគិតសាជាថ្មី ៖

- ទេ! លោកមិនត្រូវអស់សង្ឃឹមទេ... មានតែលោកទេ ដែល អាចជួយខ្លួនលោកបាន ។ លោកត្រូវតែរឹងប៉ឹង ត្រូវតែម៉ឺងម៉ាត់ ហើយរកមធ្យោបាយជួយកូនចៅលោកអោយផុតពីមរណា និងការ យាយីរបស់ពពួកទមិឡឥតសាសនាទាំងនោះ ។ លោកអាចបាត់បង់ ភរិយាទៅមែន តែកូនរបស់លោកនៅតែត្រូវការរូបលោកជានិច្ច! លោកត្រូវតែនៅរស់
រស់ដើម្បីទៅតាមរកពួកគេមកវិញ រស់ដើម្បី ការពារជីវិតរបស់គេ
និងជួយថែរក្សាគេអោយសុខសប្បាយ... ណៃ
របស់លោកប្រហែលជាអាចក្លាយជាប្រពន្ធរបស់គេមែន ប៉ុន្តែនាង ក៏នៅមានប្រាជ្ញាស្មារតី ប្រហែលជានាងអាចដោះស្រាយយករួច ជីវិតរបស់នាងបាន...
តែបើប្រសិនជានាងបានក្លាយជាប្រពន្ធគេ រស់មានសេចក្តីសុខ
នោះលោកក៏ត្រូវតែជួយត្រេកអរនាងផងទៅ ហោចណាស់ ក៏នាងមិនបានរស់នៅរងទុក្ខវេទនា...

CHANBOKEO.COM

សេចក្ដីស្នេហា ពិតគឺត្រូវតែចេះលះបង់... បើថ្ងៃស្អែកនៅមាន ព្រះអាទិត្យគង់នឹង
យាងរះថ្មីម្ដងទៀត... នោះជីវិតយើងក៏នឹងបានភ្លឺស្វាង សាជាថ្មីម្ដង ទៀតដែរ...
មានតែក្ដីសង្ឃឹមប៉ុណ្ណោះដែលនាំរូបយើង អោយបាន
ដល់ថ្ងៃស្អែក... ថ្ងៃស្អែកដែលមានព្រះអាទិត្យរះបំព្រង!

លោកគ្រូពេទ្យក៏សួរសតិវិញថា ៖

- តើអោយខ្ញុំសាងក្ដីសង្ឃឹមយ៉ាងណា បើមនុស្សជាទីស្រឡាញ់បាន
ព្រាត់ពីខ្ញុំទៅអស់រលីងយ៉ាងនេះ ? ពេលនេះ ខ្ញុំពិតជាបាក់ទឹកចិត្ត
លែងមានកម្លាំងចិត្តនឹងតស៊ូដើម្បីថ្ងៃស្អែកទៀតហើយ...

សតិក៏តបវិញថា ៖

- បើសិនជាអ្នកបាក់ទឹកចិត្ត នឹងអស់កម្លាំងចិត្តតស៊ូពិតមែន គឺមាន ន័យថា
អ្នកកំពុងទទួលស្គាល់របបផ្ដាច់ការរបស់ខ្មែរក្រហមហើយ...
ព្រោះពួកគេបានធ្វើចលនាបំបែកបំបាក់គ្រួសារ បំបាក់ទឹកចិត្តពល រដ្ឋ
បានសំរេចដូចបំណងរបស់គេ ។ នោះមិនខុសពីលើកទង់ជ័យ សបន្ទាបខ្លួនឲ្យសត្រូវឡើយ ។
តែបើអ្នកស្អប់របបនោះ មិនចង់ឲ្យ វាមានកម្លាំងបាន អ្នកត្រូវតែសាងទឹកចិត្ត
និងក្ដីសង្ឃឹមមកវិញ.. តស៊ូម្ដងទៀត... រកមធ្យោបាយជួយខ្លួន ជួយកូន ជួយនរណាទាំង
អស់ដែលជាញាតិរបស់យើង អោយគេសាងក្ដីសង្ឃឹម សាងកម្លាំង ចិត្ត សាងសេចក្ដីស្រឡាញ់
និងការមានទឹកចិត្តចំពោះមនុស្សជាតិ ដូចគ្នា
នោះអ្នកនឹងមានជ័យជំនះដោយសន្តិវិធីហើយមានប្រសិទ្ធិ
ភាពបំផុតទៀតផង...អ្នកនឹងអាចបង្ហាញថា សេចក្ដីស្នេហារបស់អ្នក ធំធេងណាស់
សូម្បីតែរបបកុម្មុយនីស្តដ៏សាហាវ ទាំងអាណាចក្រ
ក៏មិនអាចមានប្រសិទ្ធលើរូបអ្នកនិងគ្រួសារអ្នកសូម្បីបន្តិច...

លោកគ្រូពេទ្យលូកដៃរាវរកខ្សែកអំបោះក្រហម បន្តោងផ្កាចំប៉ា ដែលលោកពាក់ជាប់នឹងខ្លួន
តាំងពីថ្ងៃដែលលោកបានទទួលចរណៃ ជាភរិយាមក មិនដែលដោះទេ ។
នៅពេលដែលខ្សែអំបោះរិចរិល ប្រពន្ធរបស់លោកតែងតែវេញអំបោះ
មកផ្លាស់ថ្មីជូនលោកពាក់វិញ ជានិច្ច ។ ពេលនេះ...

- ឱ ខ្សែកបន្តោងចំប៉ាអើយ... តើម្ចាស់អ្នកនៅទទួលស្គាល់រូបខ្ញុំ
ជាគូជីវិតរបស់គេតទៅទៀតដែរទេ ? ណៃ... បងចង់ដឹងណាស់ ថាពេលនេះ ដួងចិត្តរបស់អូន

CHANBOKEO.COM

គិតយ៉ាងណាដែរចំពោះបង ? តើ
បងគួរសាងក្ដីសង្ឃឹមសំរាប់ថ្ងៃស្នេហ៍របស់យើងទាំងពីរនាក់រួមគ្នា ឬ ក៏យ៉ាងណា... ?
ដែលបងព្រួយសោកាបំផុតនោះ...គឺក្ដីសង្ឃឹមក្លែង ក្លាយ... ខ្លួចបងបានត្រឹមតែគេងរង់ចាំ
ចាំថ្ងៃស្នេហ៍រវាងយើងទាំង ពីរដែលមិនអាចមកដល់ដូចបំណងដែលបងសង្ឃឹមទុក...
　　លោកគ្រូពេទ្យយកដៃជ្រោងសក់ ងើយមើលមេឃ ដង្ហោយ
ហៅម្ចាស់ចិត្តឱ្យបៗតែម្នាក់ឯងទាល់ភ្លឺ... រាល់ថ្ងៃមិនដែលខានមួយ វេលាណា ។
　　នៅរដូវវស្សា ឆ្នាំ១៨៧៧...
　　មុននឹងតាចាបទទួលអនិច្ចកម្មទៅ ដោយរោគជរា តាបានផ្ដាំ
ផ្ញើនាងកាដេននឹងលោកគ្រូពេទ្យអោយជួយមើលថែរក្សានាង ត្បិត
តាចាបគ្មានសាច់ញាតិរស់នៅម្ដុំៗភូមិជាមួយគ្នាទេ មានតែប្អូនស្រី
គាត់ម្នាក់រស់នៅម្ដុំវាលបែកចានបាត់ដំបង ។ លោកគ្រូពេទ្យក៏ ទទួលពាក្យរបស់តាចាប
ហើយក៏ទុកដាក់សពរបស់គាត់ដោយដៃ លោកផ្ទាល់ ។ ចាប់តាំងពីថ្ងៃនោះមក
លោកក៏មើលថែរក្សានាង កាដេនតាមតែដំណើរអញ្ចឹងទៅ... គឺមនុស្សពីរនាក់ មានសតិមិន
ពេញដូចគ្នា ។ ម្នាក់ខ្វះតាំងពីកំណើត.. ម្នាក់ទៀតវង្វេងព្រោះតែ
ខ្លួនលោកត្រូវគំនៀបស្ថានការណ៍ស្រុកទេស កៀបសង្កត់ផ្លូវចិត្ត ។
ចំណែកកិច្ចការបររទេះរបស់តាចាប ត្រូវដឹកបាយអោយអ្នកភូមិ នៅស្រែ ដឹកកណ្ដាប់សន្ទូង
ឬដឹកកណ្ដាប់ស្រូវបញ្ជូនក៏ត្រូវធ្លាក់មក ជាកិច្ចការរបស់លោកគ្រូពេទ្យវិចិត្រដោយស្វ័យប្រវត្តិ ។
　　ថ្ងៃមួយ...
　　ពូសុខ (លោកគ្រូពេទ្យ) បររទេះដឹកកណ្ដាប់ពីថ្នាលសំណាប
ដឹកសន្ទូងទៅអោយគេស្ទូងនៅស្រែថ្មី ស្រាប់តែគាត់ប្រទះនឹងកង យុវនារីមួយបង រាងស្គមៗ
ប្រហែល៥០នាក់ បានទទួលការចាត់ តាំងអោយមកជួយធ្វើការក្នុងភូមិនោះមួយរដូវ ។
ពូសុខបានប្រទះ ឃើញក្មេងស្រីម្នាក់អាយុប្រហែល១៧ឆ្នាំ កំពុងឈរអោបកណ្ដាប់
ស្រូវសម្លឹងលោកមិនដាក់ភ្នែកពីក្នុងស្រែមក ។ គ្រាន់តែឃើញមុខ នាងភ្លាម
ពូសុខក៏ចំណាំបានភ្លាមដែរ ៖
- ម៉ី កូនស្រីប៉ា ?
　　ពេលនោះ ពូសុខបានឃើញស្នាមញញឹមមួយនៅលើផ្ទៃមុខ
របស់នាងមករកគាត់យ៉ាងបំព្រង ។ មែនហើយ... នាងមានមុខ មាត់ដូចម្ដាយរបស់នាងណាស់...

CHANBOKEO.COM

ធ្វើអោយពូសុខនឹកដល់ប្រពន្ធគាត់ ភ្លាមតែម្តង ។ ពូសុខរអួលដើមក និយាយមិនចេញ ។ ពុទ្ធោអើយ! ហេតុអ្វីក៏ដូច្នោះកើត ? ឪពុកនឹងកូនជួបគ្នាហើយ មិនអាចនិយាយ គ្នាបាន... ឪពុកមិនអាចរត់អោបកូនបង្ហាញនូវក្តីនឹករលឹកចំពោះគ្នា បានទេ... ពូសុខត្រូវតែលាក់ខ្លួន មិនចង់អោយអង្គការដឹងប្រវត្តិ ត្បិតគាត់អាចស្លាប់ទាំងកូនទាំងឪពុក បើសិនជាអង្គការដឹងថាពូសុខជាអតិតវេជ្ជបណ្ឌិតកាលសម័យមុន ។ នៅក្នុងរបបខ្មែរក្រហម គ្រាន់តែមានវិជ្ជាខ្ពង់ខ្ពស់ ឬគ្រាន់តែជានិស្សិតពាក់វ៉ែនតាមីញ៉ូប ក៏ក្លាយជាបច្ចាមិត្រឬជាឧក្រិដ្ឋជនរបស់អង្គការដោយឯកឯង រួចត្រូវ ទទួលទោសដល់ស្លាប់ ដោយមិនអាចតវ៉ាអ្វីមួយម៉ាត់បានឡើយ ។

រាល់ថ្ងៃបារមីតែងតែមកឈររង់ចាំមើលមុខពូសុខនៅកាច់ជ្រុងស្រែមួយដែលពូសុខតែងតែបររទេះកាត់ ហើយតែងតែញញឹម ដាក់គាត់មិនឈប់ទេ រហូតដល់ពូសុខបររទេះហួសទៅ ។ រីឯ ពូសុខវិញក៏លួចខ្ចប់ត្រាវស្ងោរ ដំឡូងស្ងោរ ឬអ្វីៗដែលគាត់អាច រកបានដោយកម្លាំងកាយនិងប្រាជ្ញារបស់គាត់ យកមកបោះទំលាក់ក្នុងស្មៅកៀនភ្លឺស្រែធ្វើកូនស្រីរាល់ព្រឹកដែរ ។ ថ្វីបើពូសុខមិនដែលបាននិយាយអ្វីជាមួយកូនស្រីមួយម៉ាត់ក៏ដោយ ប៉ុន្តែពន្លឺនេត្រាដ៏ភ្លឺថ្លា របស់នាងបារមីហាក់ដូចជាមានន័យគ្រប់គ្រាន់ជំរាបពូសុខវិញថា នាងត្រេកអរណាស់ដែលនាងបានជួបនឹងពូសុខនៅរដូវធ្វើស្រែ មួយនោះ ។

មិនយូរប៉ុន្មាន កូនស្រីរបស់លោកក៏ត្រូវអង្គការចាត់តាំងនាទីអោយចល័តទៅបំរើនៅតំបន់មួយទៀត ។ ពូសុខក៏ខកខានលែងបានឃើញកូនស្រីតទៅទៀតតាំងពីពេលនោះមក ។

ថ្វីបើពូសុខខិតខំបំភ្លេចប្រពន្ធគាត់យ៉ាងណាក៏ដោយ ក៏ពូសុខមិនអាចទ្រាំនឹងការនឹករលឹកចំពោះមីងណៃបានដែរ ជាពិសេសពេលកូនស្រីគាត់បែកទៅ...ពូសុខរិតតែនឹកប្រពន្ធឡើង រហូតទ្រាំមិនបានក៏លួចរត់ចេញពីភូមិព្រៃទទឹង ធ្វើដំណើរទៅវាលទ្រាសាជា ថ្មីម្តងទៀត ។ លើកនេះពូយើងហាក់ដូចជាចេះបត់បែនខ្លួនជាងពី មុនច្រើនណាស់ សមនឹងសម្បុររាងស្រអែមបន្តិចផងសក់ស្កូវ បន្តិចផង ស្គមជ្រីវជ្រួញបន្តិចផង គេគ្រប់គ្នាច្រឡំថាពូសុខជាអ្នក ស្រែរស់នៅម្ដុំៗនោះម្ល៉េះហើយក៏គ្មាននរណាសួរអីដែកអីសួរអី រហូតគាត់ទៅដល់វាលទ្រាតែម្តង ។

CHANBOKEO.COM

សំណាងមិនល្អ... ពូសុខស៊ើបរកមីងណៃមិនឃើញទេ ។ តា ចាស់អ្នកស្រុកម្នាក់ប្រាប់ពូសុខថា ពួកមេខ្មែរក្រហមបក្សពាយព្យ័ ទាំងនោះ បានត្រូវគេសម្លាប់អស់ហើយ ចំណែកពួកតូចតាច បាន ត្រូវផ្លាស់ទៅកន្លែងដទៃទៀតអស់រលីង ។ សព្វថ្ងៃនេះ អ្នកដែល នៅកាន់កាប់គឺពួកខ្មែរក្រហមបក្សនិរតីជាក្រុមផ្សេងប្លែកពីពួកមុនៗ ហើយនិយាយខ្មែរទំនងប៉ៃឡាំបន្តិច ។ លុះពូសុខប្រឹងសួរបញ្ជាក់ពី គណៈឃុំដែលឈ្មោះគ្រេងនោះ តាចាស់នោះគ្រវីក្បាលប្រាប់ថាគាត់ មិនចាំឈ្មោះមេភូមិមេឃុំខ្មែរក្រហមណាទេ ។ ចំណែកឈ្មោះមីង ណៃឬស្រីម៉ៅអីនោះ ក៏តាចាស់នោះប្រកែកថាមិនស្គាល់ដែរ ។ ពូសុខក៏ក្លាយជាខកសង្ឃឹម អន្ទះសាកន្ទះរាក្នុងចិត្តសាជាថ្មី ដែលគាត់ មិនបានដឹងដំណឹងថាប្រពន្ធគាត់សុខសប្បាយយ៉ាងណា ។ លុះលួច សួរដំណឹងពីអ្នកស្រុកពីរបីនាក់ទៀត ក៏មិនបានការដដែល ពូសុខ សំរេចចិត្តត្រឡប់មកព្រៃទទឹងវិញទាំងអស់កម្លាំងចិត្ត ។

តាមផ្លូវ ពូសុខដើរបន់ក្នុងចិត្តតែម្នាក់ឯង ៖

- ណៃ...! អូននៅឯណា ? សុខសប្បាយទេអូន ? ចុះកូនម៉ៅវិញ សុខទុក្ខយ៉ាងម៉េចដែរ ? សូមអោយអូននិងកូនចៅទាំងអស់ សុខ សប្បាយ...ចៀសផុតនូវទុក្ខភ័យផងទាំងពួងកុំបីខាន ។

អស្ចារ្យណាស់! ថ្វីបើដឹងថា មីងណៃរៀបការប្តីថ្មីហើយក៏ដោយ ក៏ចិត្តពូសុខនៅតែប្រកាន់ថា មីងណៃជាប្រពន្ធរបស់គាត់ដដែលឥត មានផ្លាស់ប្តូរទេ ។ គាត់នៅតែស្រឡាញ់ នៅតែនឹក នៅតែខ្វាយ ខ្វល់ មិនដាច់ចិត្ត មិនដាច់អារម្មណ៍ពីប្រពន្ធរបស់គាត់ឡើយ ។

ដើមខែមករា១៩៧៩...

ពូសុខបរទេះដឹកនាងកាជេននិងអ្នកជំងឺមួយហ្វូងពីស្រែ ម៉្តុំភូមិ ត្រោះ ស្រាប់តែឮសូរគ្រាប់កាំភ្លើងធំតូចខ្ទររខ្ទាំង ។ អ្នកភូមិអ្នក ស្រុកទាំងឡាយផ្អើលឈូឆរឡើង ។ ពពួកខ្មែរក្រហមដែលនៅ កាន់កាប់ស្រុកទាំងអំបាលម៉ាន ក៏ប្រមូលកម្លាំងធ្វើដំណើរឡើងទៅ លិច សំដៅផ្លូវជាតិលេខប្រាំ ។ ពូសុខបររទេះទម្លាក់អ្នកស្រុកនៅ ភូមិរួចក៏បររទេះសំដៅវាលទ្រា ភ្នែករេមើលទៅហ្វូងមនុស្សដែល កំពុងរត់ខ្សៀវខ្សា ក្រែងលោអាចប្រទះឃើញមីងណៃនិងស្រីម៉ៅ ។ គ្រាប់កាំភ្លើងលាន់ឮខ្ទ័រខ្ទាររអស់ជាច្រើនថ្ងៃ តែមិនបានធ្វើឲ្យពូសុខ ភិតភ័យឡើយ ។ គាត់បែរជាមានចិត្តក្លាហាន ដើររកប្រពន្ធកូន វីរវក់ក្នុងចំណោមអ្នកស្រុក ដែលភិតភ័យរត់ចលាចលពាសពេញ ស្រុកទាំងនោះទៅវិញ ។

CHANBOKEO.COM

ពូសុខបររទេះមកជិតដល់ថ្នល់ជាតិលេខ៥ ឃើញពួករទេះតង់
កងទាហានវៀតណាមបរលើថ្នល់ជាតិផងតាមស្រែផង បាញ់ប្រឡូក
ដៃគ្នាជាមួយពួកខ្មែរក្រហមយ៉ាងជ្រែងជើងរៀងខ្លួន ។

ចៃដន្យ គ្រាប់កាំភ្លើងធំមួយ បានធ្លាក់ផ្ទុះលាន់ក្ទាំង ក្បែរសត្វ
គោមួយក្បាលរបស់ពូសុខដួលស្លាប់មួយរំពេច ។ ពូសុខកំពុងតែ
សំរាកយកកម្លាំងនៅគល់ឈើមួយ មិនឆ្ងាយពីរទេះគោប៉ុន្មានទេ ។ ទ្រាំមិនបាន
ពូក៏ដើបចេញធ្វើដំណើរបន្តទៅទៀតដោយជើងទទេ ។ ភ្លាមនោះ
ស្រាប់តែពូសុខប្រទះនឹងអ្នករបួសម្នាក់ អាយុក្បែរៗ ហាសិបអត់មានអាវមានតែខោខ្លី
កំពុងព្រមៀលខ្លួនរកជំនួយ ។ ពូសុខក៏រត់ទៅជួយគ្រាហ៍ឡើង ។ ចៃដន្យ ពេលនោះ នាងកាជេន
លេចមកពីខាងណាមិនដឹង ដើរសើចហៃ៎សៗមកដល់ដែរ ។ ពូ សុខក៏ស្រែកហៅ ៖

- ជេនអើយ! មកនេះ ជួយពូបន្តិច!
- ចា៎ស! ហើយចុះ អានេះ អាណាគេ? (ចន្ទនីសួរ)
- កុំហៅគាត់ថាអានេះ គាត់ចាស់ហើយ អាយុ៉សសៃហាហើយណា៎ ត្រូវហៅថាពូ ឮហើយនៅ?
- ចា៎ស! ហើយពូហ្នឹង អាណាគេ? (កាជេនស្ទុះមកជិតហើយ ជួយលើកគ្រាហ៍បុរសនោះឡើង)
- គឺអ្នករបួស មិនឃើញទេ? ហើយចុះម៉េចក្មួយឯង ម៉េចមិននៅ ភូមិ? មកទីនេះ
គ្រោះថ្នាក់ណាស់ ដឹងទេ?
- មកពីខ្ញុំឃើញពូសុខបររទេះ ចុះឡើងៗម្តុំនេះ ពីរបីថ្ងៃមកហើយ
ដូចជាល្អមើលពេក បានជាខ្ញុំមកអង្គុយមើលលេងទៅ ។
- មកអង្គុយមើលលេង? មិនខ្លាចគ្រាប់កាំភ្លើងទេ?
- ខ្លាចស្អី? មិនដែលឮផង ឮម្តង ប្លែកត្រចៀកណាស់ ។

ពូសុខហួសចិត្តដែលនាងកាជេននិយាយដូច្នោះ ។ បន្ទាប់មក
ពូសុខនិងកាជេនក៏គ្រាហ៍បុរសនោះមកដល់ផ្ទះអ្នកស្រុកមួយ ដែល
ម្ចាស់បានរត់គេចបាត់អស់ដោយខ្លាចគ្រាប់កាំភ្លើង ។

ពូសុខដោះក្រមារបស់គាត់យកជូតឈាមហើយចងរុំរបួសបុរស នោះហើយក៏ស្រដីថា ៖

- ទ្រាំឈឺបន្តិចទៅណា៎ ចាំទៅរកចាប់គោសិន រួចខ្ញុំនឹងដាក់រទេះ
នាំប្អូនទៅរកគេជួយនៅឯភូមិ ។

តែបុរសនោះធ្វើងងើ ស្រាប់តែគេនិយាយបារាំងតបវិញថា ៖

CHANBOKEO.COM

- លោកចេះបារាំងទេ ? ខ្ញុំចេះនិយាយបារាំងតែមិនចេះខ្មែរទេ ។

ពូសុខភ្ញាក់ព្រើត បែរសម្លឹងបុរសនោះ ។ កាជេនក៏ដូចគ្នាដែរ ធ្វើភ្នែកឡឹងឡង់ព្រោះស្តាប់មិនបាន ៖

- ពូសុខ! ហេតុអីពូម្នាក់នេះ និយាយស្ទីស្តាប់អត់បានអញ្ចឹង ?

- ប្រហែលជាវង្វេងសតិវង្វេងវាយហើយ ។

ស្រាប់តែ បុរសនោះនិយាយបារាំងបន្តទៀតថា ៖

- លោកឈ្មោះ សួន វិចិត្រ មែនទេ ?

ភ្លាមនោះ ពូសុខរិតតែភ្ញាក់ផ្អើលខ្លាំងណាស់ទៅទៀតដែល បុរសនោះស្គាល់ឈ្មោះពិតប្រាកដរបស់គាត់ ។ ពូសុខមិនទាន់ ឆ្លើយអ្វីផង ស្រាប់តែបុរសនោះនិយាយទៀតថា ៖

- ខ្ញុំជាមិត្តរបស់លោក រៀនជាមួយគ្នាកាលនៅបារាំង ចាំទេ ? ខ្ញុំ ឈ្មោះ ង៉ោ ហាន និស៊ៀតមេដឹសាំង...

ពូសុខអង្គុយសង្កេតបុរសម្នាក់នោះយ៉ាងយូរ ទើបចំណាំគេបានថាពិតជាមិត្តធ្លាប់រៀនជាមួយគ្នាពិតមែន ។ ពូសុខញញឹមឡើងសួរជាបារាំងវិញ ៖

- ហើយចុះម្តេច លោកមកមានរបួសនៅឯស្រុកខ្មែរនេះទៅវិញ ? លោកជាពលទាហានកងទ័ពវៀតណាម មែនទេ ?

- ខ្ញុំជាពេទ្យទាហាន ត្រូវរដ្ឋាភិបាលវៀតណាមបញ្ជូនមកធ្វើការនៅ ស្រុកខ្មែរ ។ ពេលប្រយុទ្ធគ្នាពីព្រឹកមិញនេះ ពួកខ្មែរក្រហមពទ្ធ័ ចាប់ពួកយើង តែខ្ញុំបានរត់រួចបានមកវិញ រួចក៏ត្រូវបង្ខំចិត្តស្រាត ខោអាវចោល ដើម្បីកុំអោយពួកគេចំណាំបានថាខ្ញុំជាពលទាហានវៀតណាម ។

ពូសុខអង្គុយអេះក្បាលមិនដឹងថា ត្រូវឆ្លើយយ៉ាងណាទេ ។ ខ្មែរ ក្រហម ក៏លោកស្អប់ ។ ទព័បរទេសលុកលុយស្រុកខ្មែរក៏លោក មិនចូលចិត្តដូចគ្នា ។ ការធ្វើសង្គ្រាម គឺមិនមានស្អីឡើយក្រៅពី ការសម្លាប់មនុស្ស និងការដណ្តើមអំណាចគ្នាសោយរាជ្យលើទឹកដី តែម្យ៉ាងប៉ុណ្ណោះ ។ ឯអ្នកដែលរងគ្រោះគឺអ្នកស្រុកស្លូតត្រង់ទាំង ឡាយរួមទាំងរូបលោកផង ។ កំពុងតែគិត ស្រាប់តែមានទាហាន វៀតណាមលើកទ័ពមកដល់ឈូធរតែម្តង ។ ពួកនោះភ្ជង់ពូសុខនិង កាជេនព្រោងព្រាត ស្រាប់តែបុរសនោះនិយាយយួនទៅគ្នាគេថា ៖

CHANBOKEO . COM

- លែងពួកគេទៅ! គេជាអ្នកជួយសង្គ្រោះខ្ញុំតើហ៎!

បន្តិចមក ពួកគេក៏នាំពេទ្យយោធានោះចេញទៅ ។ ពូសុខ ដកដង្ហើមមួយបន្ទូរទ្រូង ត្បិតឃើញពួកគេទៅអស់ មិនរំខានជីវិត ពូនិងនាងកាជេន ។ ស្រាប់តែពួកទាហានវៀតណាមនោះត្រឡប់ មកវិញស្រ៊ូស្រ ។ មានពលម្នាក់និយាយបារាំងដាក់ពូសុខថា ៖

- ពូធ្លាប់ធ្វើជាដុកទ័រមែនទេ ? យើងត្រូវការអោយពូ តាមយើង ប្រញាប់ ។

ដោយខ្លាចចុងកាំភ្លើងដែលភ្ជង់មកលើពូសុខយ៉ាងចម្រូងចម្រុះ នោះ ពូសុខក៏សុខចិត្តចេញទៅតាម ដោយនាំកាជេនទៅតាមផង ។ ពួកគេនាំពូសុខទៅដាក់នៅមន្ទីរពេទ្យធំ ក្រុងបាត់ដំបង អោយជួយ មើលថែកូនទាហានរបួសជាច្រើន ។ នៅទីនោះ ពូសុខបានជួបអ្នក ធ្វើការពីរបីនាក់ចេះខ្មែរផង ចេះយួនផង មិនដឹងថាគេជាជាតិយួន ចេះខ្មែរឬជាតិខ្មែរចេះយួនទេ ។ ពូសុខក៏ត្រូវបង្ខំចិត្តធ្វើការទាំង ទើសទាល់ ព្រោះគាត់គ្មានផ្លូវជ្រើសរើសទៀតឡើយ ។

ប្រហែលពីរអាទិត្យក្រោយមក ពេទ្យយោធានជិះឡានហ្ស៊ីប ទាហាន ត្រឡប់មកជួបពូសុខធ្វើការនៅឯមន្ទីរពេទ្យ ។ រំពេចនោះ ពូសុខភ្ញាក់ព្រើត ព្រោះពេទ្យយោធាននោះស្លៀកពាក់ជានាយ ទាហានឧត្តមសេនីយ៍ដ៏សំខាន់មួយរូបក្នុងកងទព័វៀតណាម ។

ក្រោយពីសំណេះសំណាលជាមួយពូសុខមួយស្របក់ ពេទ្យយោ ធាន សួរពូសុខថា ៖

- ខ្ញុំគួរតែអោយលោកទៅស្នាក់កន្លែងសមគួរជាងនេះបន្តិច ព្រោះ យើងមិនចង់អោយមានមនុស្សស្រី មកដេកស្នាក់នៅក្នុងមន្ទីរពេទ្យ នេះ ពេលយប់ ។

ពូសុខយល់ភ្លាម ថាគេចង់និយាយពីនាងកាជេន ។ ពូក៏សុំគេ ទៅនៅផ្ទះចាស់របស់លោក ។ លោកយោធានងក់ក្បាល ហើយក៏ ហុចបណ្ណ័មួយអោយទៅពូសុខ សំរាប់បង្ហាញទាហានឆ្មាំប៉ុស្តិ៍ ពេល ធ្វើដំណើរចេញចូលក្រុងបាត់ដំបង ។ លោកយោធានបានដាក់នាមថ្មី អោយពូសុខថា សុខហុង ។ ថ្ងៃបន្ទាប់មក ពូសុខក៏បានវិលមក ដល់ផ្ទះចាស់របស់គាត់វិញបានដូចបំណង ។

នៅទីនោះ ពូសុខមិនមានឃើញអ្វីប្លែកទេ ក្រៅពីបាត់របស់ របរសេនាសនភណ្ឌ័និងគ្រឿងតុបតែងរបស់គ្រួសារគាត់តែប៉ុណ្ណោះ ចំណែកសំបកផ្ទះ និង ដើមឈើទាំងឡាយនៅឈរដង្កើង ត្រឈឹង ត្រឈៃស្តុកស្តម្ភដដែល ឥតផ្លាស់ប្តូរ ។

CHANBOKEO.COM

យូរម្តងៗ ពូសុខត្រូវគេបញ្ជាអោយទៅជួយលីឥវ៉ាន់ចូលឃ្លាំង ក្នុងមន្ទីរពេទ្យ តែមិនដឹងជាឥវ៉ាន់អ្វីទេ ព្រោះសុទ្ធតែជាប្រអប់ឃ្លុំ ជិតឈឹង ។ នៅថ្ងៃអាទិត្យ គេអោយពូសុខសំរាកធ្វើការមួយថ្ងៃ ។ ចំណែកនាងកាជេននៅចាំផ្ទះតែម្នាក់ឯងម៉ង់ៗ ជួនកាលក៏ដើរឡប់ ឡើបាត់ទៅណាពីរបីថ្ងៃ ជួនត្រឡប់មកវិញដើរសើចដើរច្រៀង រួច ហើយក៏ទៅបាត់ទៀត ។ នាងកាជេនមានជំងឺ មិនចេះភ័យ មិន ចេះឈឺចាប់មិនចេះព្រួយរឿងអីទេ គឺចេះតែល្ងមៗធម្មតាអញ្ចឹង ទៅ ។ ទោះបីជាយ៉ាងណា នាងស្តាប់ពូសុខច្រើន ព្រោះពូសុខមិន សូវចូលចិត្តសម្លុតនាង ឬក៏សើចចំអកអោយនាងដូចជាអ្នកភូមិ ទូទៅឡើយ ។ គាត់ចូលចិត្តណៃនាំរូបនាង នូវអ្វីល្អៗជាជាង ។

នៅតាមបណ្តោយដងផ្លូវជួរផ្ទះពូសុខនោះ មានខ្មែរនៅពីរបីគ្រួ ដែរ សុទ្ធតែជាមនុស្សចំណូលថ្មីមកពីខេត្តក្រៅ ។ ពូសុខមិនស្គាល់ គេទេ ហើយមិនដែលនិយាយរកគេផង ព្រោះលោកជាមនុស្សមាន ទម្លាប់ស្ងៀមស្ងាត់ មិននិយាយមិនស្តីតាំងពីដើមមកទៅហើយ ទើប គ្មាននរណាគេស្គាល់ថាលោកជាខ្មែរជាជាតិវៀតណាមទេ ។

ទោះបីជាយ៉ាងណា ពូសុខមិនដែលលះបង់ការតាមរកប្រពន្ធ កូនរបស់គាត់ទេ ។ គាត់តែងសុំច្បាប់ពួកទាហានធ្វើដំណើរទៅវាល ទ្រាវល់ថ្ងៃសំរាក ដើរសុើបសួរអ្នកស្រុក រកមីងណៃ នាងម៉ៅ និង កូនៗដទៃទៀត តែក៏មិនបានលទ្ធផលអ្វីទាំងអស់ ។

ដោយលោកយល់ថា ម្តុំផ្ទះលោកនោះមានការហាមឃាត់ពីក្រុម ទាហានប៉ុស្តិ៍ចុងស្ពានមិនអោយចេញចូល ពូសុខគិតថា សមាជិក ក្រុមគ្រួសារពិតជាមិនអាចចូលរកលោកឃើញឡើយ ។ ពូក៏ជិះកង់ ទៅរកសាមេតដែលជាមិត្តរបស់ប៉ុរីនៅដូនទាវ បំរុងផ្តាំផ្ញើឲ្យគេ ជួយរកប៉ុរីអោយផង ។ លុះជិះកង់មកដល់ស្លាកែត ស្រាប់តែពូសុខ ឃើញស្ត្រីម្នាក់ទូលត្រីដើរដូរអង្ករតាមផ្ទះអ្នកស្រុក មានមុខមាត់ដូច មីងណៃណាស់ ។ គាត់ក៏ដាក់កង់ចុះរត់តាមភ្លាម ស្រាប់តែប្រទះមីង ណៃនិងពូបូកំពុងជួយគ្នាចាប់ត្រីថ្លឹងដូរអង្ករ ។ កិរិយាដ៏ស្និទ្ធស្នាល និងការយកចិត្តទុកដាក់របស់ពូបូរចំពោះមីងណៃ បានធ្វើអោយពូ សុខយើងយល់ច្រឡំថា ពូបូរគឺជាប្តីថ្មីរបស់មីងណៃ ។ គាត់ក៏បាក់ ទឹកចិត្តគ្រហែតតែម្តង ។ ប៉ុន្តែ គាត់មិនដាច់ចិត្តដើរចេញទៅវិញ ឡើយ...

CHANBOKEO.COM

ពូសុខនៅឈរក្រោយគល់ដូងលួចមើលមីងណៃពីចម្ងាយ មិនព្រមដាក់ភ្នែក ។ ឯបេះដូងក៏រិតតែញាប់ញ័រឡើងគគ្រឹក ដោយ ក្តីប្រចណ្ឌ ខឹងខកចិត្តយ៉ាងធំធេង ។ ពូសុខឈរពួនលេបទឹកភ្នែក លួចអួលអាក់ក្នុងឱរាតែម្នាក់ឯង ។

បន្តិចមក ពូបូរក៏ដើរបែកពីមីងណៃ វែកត្រីទៅដោះដូរបន្ត ទៀត ។ ពូបូរក៏ប្រាប់មីងណៃអោយត្រឡប់ទៅទូកមុន ។ លុះមីង ដើរបំរុងដើរទៅកំពង់វិញ ស្រាប់តែប្រទះក្រសៃភ្នែកនឹងពូសុខ កំពុងឈរលបលួចមើលគាត់ពីចម្ងាយ ។ មីងណៃក៏ទំលាក់កញ្ច្រែង ត្រីចោល ហើយស្ទុះរត់ហៅពូសុខភ្លាម ។ តែកាលនោះពូយើងអន់ចិត្តណាស់ ត្បិតមិនអាចទ្រាំនឹងទំហំនៃក្តីប្រចណ្ឌដែលពុះកញ្ជ្រោល នៅក្នុងបេះដូងរបស់គាត់បាន ក៏ទាញកង់ហក់រឹងធាក់ចេញទៅ យ៉ាងលឿន ទុកឲ្យមីងណៃរត់តាមក្រោយស្រែកហៅពូសុខខ្ញើយៗ ទាំងដួងចិត្តខ្លោចផ្សាជាទីបំផុត...

ពូសុខត្រឡប់មកផ្ទះវិញអង្គុយសំកុកអស់ពេលយ៉ាងយូរ ។ ថ្ងៃ នោះ ពូសុខធ្វើការភ្លេចភ្លាំង ត្រូវពួកនាយទាហានសម្លុតអោយ ត្រឡប់ទៅដេកពួនយកកម្លាំងវិញ... ចៃដន្យ បើកុំតែគេយោគយល់ មុខពូសុខ ដែលធ្លាប់ជួយសង្គ្រោះជីវិតលោកឈៅហាន កុំអី "ឆ្ក..." ស្រេចបាត់ទៅហើយក៏មិនដឹង ព្រោះគាត់ចាក់ថ្នាំខុសអោយពល ទាហានប្រកាច់ប្រកិនជាច្រើននាក់ ។

យប់នោះ ពូសុខបានតាមទៅលប មើលមីងណៃដល់ទូកនាយ សល់ ឃើញពូបូរលាងជើងលាបថ្នាំអោយមីងណៃ យ៉ាងស្និទស្នាល ធ្វើអោយភ្លើងប្រចណ្ឌឆាបឆេះពេលទ្រូបពូសុខ សាជាថ្មី ។ ប៉ុន្តែ ពូសុខក៏សង្កេតឃើញផងដែរ ថាមីងណៃបានរក្សាថៃទាំចៅស្រី របស់គាត់យ៉ាងដិតដល់ គ្រាន់តែពូមិនដឹងនាងម៉ៅជាម្តាយនាងមុំ នោះមានសុខទុក្ខយ៉ាងណាទៅហើយទេ ។

ថ្ងៃដដែលនោះ លោកក៏បានជួបបារមីនៅចុងស្ពានដូចគ្នា តែក៏ មិនបាននិយាយគ្នាប៉ុន្មានដែរ ព្រោះពួកទាហានដេញលោកគ្រូពេទ្យ អោយទៅជួយបំរើមនុស្សរបួសនៅមន្ទីរពេទ្យ ។ លោកគ្រូពេទ្យក៏ ផ្តាំកូនអោយទៅរកលោកនៅផ្ទះនៅថ្ងៃបន្ទាប់ ។

លុះថ្ងៃបន្ទាប់មក ពូសុខបានប្រទះមីងណៃនៅក្បែរប៉ុស្តិ៍យាម ចុងស្ពាន តែមិនអាចនិយាយអ្វីបានព្រោះលោកកំពុងជិះលើរថយន្ត ទាហានដឹកឥវ៉ាន់មកពីវាលបែកចានយកទៅដាក់មន្ទីរពេទ្យ ។ ពូក៏

CHANBOKEO.COM

បែកពីមីងណៃទៅដោយចង្អៀតចង្អល់ចិត្ត ។ នៅរាត្រីថ្ងៃដដែល ពេលធាក់កង់ចេញពីធ្វើការ ប្រហែលជាម៉ោង៧យប់ ពូសុខក៏បាន ប្រទះនឹងមីងណៃដួលដេកស្តូកស្តឹង តែម្នាក់ឯងលើផ្លូវថ្នល់ មិនដឹង ថាមានរឿងហេតុអ្វី ។ ដោយក្តីបារម្ភផង ចិត្តមិនដាច់ផង ពូសុខ ក៏លើកមីងដាក់លើកង់ ចូលសុំអនុញ្ញាតិនាយទាហានប្រចាំការទី នោះ យកមីងណៃទៅផ្ទះរបស់គាត់ ហើយមើលថែទាំមីងទល់ភ្លឺ ។ ការពិត មីងណៃមានជំងឺស្រេកឃ្លាមក្រហមដោយ សារកង្វះជីវជាតិអាហារ និងការធ្វើការហួសកម្លាំង មិនសូវបានទទួលទាន ដំណេកគ្រប់គ្រាន់ ។

ព្រហាមឡើង ពូសុខក៏ដណ្តាំបាយទុកអោយមីង ហើយក៏ជិះកង់ ទៅរកចៅស្រីឯទូក បំណងទៅសុំយកចៅស្រីមកអោយមីងណៃ ដើម្បីកុំអោយមីងបារម្ភ ។ ថៃដន្យ មីងបានដឹងខ្លួនមុនហើយក៏ បានដើរចេញទៅ ឃ្លាងដំណើរគ្នាជាមួយពូសុខមិនបានជួបគ្នារហូត ទល់ថ្ងៃល្ងាចទើបជួបគ្នាម្តងទៀតសាជាថ្មី ។ ចិត្តសង្ស័យ និងភ្លើង ប្រចណ្ឌក៏ពុះពោរឡើង ក្នុងបេះដូងពូសុខមីងណៃ តែរៀងៗខ្លួន មិនមាននរណាហ៊ានហើបសួរនរណាមុនទេ... ម្នាក់រង់ចាំអោយម្នាក់ទៀតបើកទ្វារដួងចិត្តបំភ្លឺគ្នាជាមុន តែលុះអាល័យតែភន្តច្រឡំ មិន ទុកចិត្តគ្នាទៅវិញទៅមក រួចប្រកាន់យកតែក្តីសង្ស័យក្នុងចិត្តជាធំ និងដោយសារខ្វះសេចក្តីក្លាហាននឹងសាកសួរការពិត ពូសុខនិង មីងណៃក៏បែកផ្លូវគ្នាទៅ ទាំងឱរាឈឺចាប់យ៉ាងមហិមា ។

នៅគ្រាដែលមីងណៃដឹកដៃចៅស្រី ដើរចេញពីផ្ទះទៅដោយ មិនមានស្តីអ្វីមួយម៉ាត់មករកគាត់ ពូសុខឈឺចិត្តណាស់ ចង់តែទាញ កំបិតចាក់សម្លាប់ខ្លួនអោយក្ស័យនៅថ្ងៃនោះតែម្តងទៅហើយ តែ ពូសុខធ្វើមិនបាន ព្រោះពូនៅតែមានចិត្តអាល័យមីងណៃ មិនអស់ មិនហើយ ។

យប់នោះ ពូសុខទ្រាំក្នុងចិត្តមិនបាន ក៏ចេញតាមរកមីងនៅទូក នាយសល់ ដើម្បីទៅសាកសួរប្រពន្ធអោយអស់ចិត្ត ។ ថៃដន្យ ពេលពូសុខទៅដល់ ពូមិនបានប្រទះមីងណៃនិងចៅស្រីទេ ហើយ បារមីក៏មិនបានស្នាក់នៅទីនោះដែរ ឃើញតែពូបូរនិងនាយសល់តែ ប៉ុណ្ណោះ ។ ពូសុខក៏ឲ្យថ្នាំព្យាបាលដល់នាយសល់ ហើយបាននៅអង្គុយសំណេះសំណាលជាមួយពូបូរ ទើបដឹងថា ពូបូរមិនមែនជាប្តី របស់មីងណៃដូចដែលគាត់គិតស្មានច្រឡំនោះឡើយ ។ ពូសុខក៏រត់ តាមរកមីងណៃទាំងយប់ តែមិនដឹងជាទៅតាមរកឯណាទេ បាន ត្រឹមតែជិះកង់ទៅមកតាមដងស្ទឹង ឈ្លួលពិលធ្វើដំណើរចុះឡើង រហូតពួកទាហានយាមទាំងនោះវាធុញទ្រាន់ ក៏ដេញអោយពូសុខចូលដេកពួន មិនអោយគាត់នៅជិះកង់បន្ទីសបន្ទើសផ្លូវការយាម ល្បាតរបស់គេតទៅទៀត ។

CHANBOKEO COM

នៅក្នុងផ្ទះ ពូសុខតប់ប្រមល់ណាស់ សំរាន្តក៏មិនលក់សោះ ក៏ស្ទុះទៅយកថ្នាំគេងលក់មកពិសារ...ដាក់ពីរគ្រាប់ហើយមិនងងុយ ពូសុខក៏ថែមពីរគ្រាប់ទៀត... ដាក់អស់រហូតទៅដល់៨គ្រាប់ រួច ហើយក៏វង្វេងស្មារតីទន់ខ្លួនដួលខ្ពាក ទៅលើគ្រែលែងដឹងខ្លួនទៅ...

រាត្រីនោះ ពូសុខយល់សុបិនដ៏អស្ចារ្យមួយ...គឺពូសុខបានក្លាយ ជាទេវបុត្រដ៏សង្ហានៅនាស្ថានត្រៃត្រឹង្ស បានជួបនឹងទេពធិតាដ៏ ប្រិមប្រិយមួយរូបឈ្មោះចរណៃ រួចក៏កើតក្តីប្រតិពទ្ធ័លើរូបទេវីឥត ឧបមា ។ គូស្នេហ៍ទាំងទ្វេក៏បានប្រគល់ដួងចិត្តស្នេហាចំពោះគ្នាទៅ វិញទៅមក ។ កំស្ទួលនៃចិត្តបេតីប្រតិពទ្ធ័រវាងទេវបុត្រយើងនិង ទេពធិតាចរណៃបានក្លាយទៅជាភ្លើងកាមារម្មណ៍យ៉ាងស្រើបស្រាល បណ្តាលឲ្យគូស្នេហ៍ទាំងទ្វេហាទទួលរួមរក្ស៍មេត្រី ជាមួយគ្នាយ៉ាង ភ្លើតភ្លើន... ថៃដន្យ ព្រានកំណាចម្នាក់ក៏បានយកកាំភ្លើងមកយាយី ជីវិតរបស់អ្នកទាំងពីរអោយរលត់សង្ខារ...

លុះដល់ ពូសុខភ្ញាក់ឡើង ក៏បាត់ខោបាត់អាវពីខ្លួនអស់រលីង សល់តែខោខ្លីមួយគត់ជាប់នឹងចង្កេះ...

ooooooooooooooooooooo<br>ooooo<br>o

CHANBOKEO . COM

# វគ្គទី១០
# ដល់ក តដៃ

វាលទ្រា បាត់ដំបង

ចុងខែមិនា ឆ្នាំ១៩៧៦...

នៅមុខរោងសហករណ៍ មីងណៃឈរតម្រង់ជួរជាមួយហ្វូងនារី និងស្ត្រីប្រហែលហាសិបនាក់ រង់ចាំស្តាប់អង្គការហៅឈ្មោះអោយ ឡើងចាប់ដៃបុរសដែលអង្គការតម្រូវមកធ្វើជាស្វាមីរបស់ខ្លួន... គ្រា នោះ មីងណៃសង្កេតឃើញថា មិនមែនមានតែមីងម្នាក់ទេ ដែល ឈរធ្វើមុខក្រៀមហៀមទឹកភ្នែកនៅក្នុងចិត្តស្ងាត់ៗនោះ សូម្បីតែ នារីនិងស្ត្រីសែហាសិបនាក់ទៀតនោះ ក៏មិនមានឃើញនរណា ញញឹមចេញម្នាក់ដែរ ។ នោះគឺជាពិធីមង្គលការដ៏សោះកក្រោះមួយ ដែលមីងមិនដែលធ្លាប់បានប្រទះក្នុងជីវិតរបស់មីងឡើយ ។ នារី ខ្លះនៅក្មេងៗក្នុងវ័យយ៉ាងច្រើន១៥-១៦ឆ្នាំ បានត្រូវអង្គការចាប់ផ្គូ ឲ្យទៅជាប្រពន្ធរបស់ពពួកយោធាខ្មែរក្រហមពិការដោយសង្គ្រាម ។ ស្ត្រីនិងនារីទាំងអស់នោះ មើលទៅសុទ្ធតែត្រូវចាប់បង្ខំអោយរៀប ការជាមួយគូដែលខ្លួនមិនដែលស្គាល់ពីមុនមក តែត្រូវបង្ខំចិត្តធ្វើ តាមអង្គការដើម្បីរក្សាជីវិតរបស់ខ្លួន ។

ពេលនោះ មីងណៃនឹកភ្នកចង់រកមធ្យោបាយរត់គេចខ្លួនពី ស្ថានការណ៍ដែលកៀបសង្កត់ចិត្តមីងពេលនោះណាស់ តែមីងមិន អាចធ្វើបាន ព្រោះមីងអាណិតស្រីម៉ៅនិងកូនស្រីតូចរបស់នាងដែល ទើបតែមានវ័យមួយខួប ។ ស្រីម៉ៅស្គាំងស្គមណាស់ មានជំងឺទាស់ ឈឺខេះៗជាប្រចាំ ។ បើសិនមីងរត់ទៅ ស្រីម៉ៅច្បាស់ជាអស់ទី ពំនាក់ ហើយប្រាកដជានឹងត្រូវស្លាប់ ទាំងម្តាយទាំងកូន មិនខាន

CHANBOKEO.COM

បើមិនស្លាប់ដោយជំងឺឬអត់បាយ ក៏ស្លាប់ដោយភាពគម្រាមកំហែង របស់អង្គការដែរ ។ ដោយគិតឃើញដូច្នេះហើយ ទើបមីងណៃ សំរេចចិត្តមិនរត់គេចពីគំនៀបអង្គការហើយស៊ូទ្រាំតស៊ូប្រឈមមុខ នឹងពួកវាតទៅទៀត ដើម្បីនៅជួយរក្សាជីវិតកូនស្រីនិងចៅតូចមិន ទាន់ដឹងក្តី...

មីងណៃឈរលេបទឹកភ្នែកទាំងលំបាក... មីងមិនហ៊ានសម្រក់ ទឹកភ្នែកទេ... នរណាក៏មិនហ៊ានសម្រក់ទឹកភ្នែកដែរ ព្រោះអង្គការ ទើបតែបាញ់សម្លាប់នារីពីររូបអំបាញ់មិញនេះស្រស់ៗ នៅកណ្តាល ទីធ្លាប្រជុំ **ចាប់ដៃរៀបគ្រួសារ** (ជាពាក្យប្រើសម័យខ្មែរក្រហមមាន ន័យថា រៀបការ) ។ នារីទាំងពីរនោះបានយំស្រែកមិនព្រមទទួល ចាប់ដៃបុរសដែលអង្គការរៀបចំអោយ ហើយក៏ត្រូវទទួលទោស ដោយការបាញ់ប្រហារព្រោះប្រឆាំងនឹងបទបញ្ជារបស់អង្គការ ។

នារីក្មេងៗដើរឡើងម្តងមួយៗ ទៅចាប់ដៃបុរសដែលខ្លួនមិន ដែលស្គាល់ ទទួលយកធ្វើជាគូជីវិត ។ បែរទៅទឹកមុខរបស់គេ ម្នាក់ៗ ស្លេកស្លាំងប្រកបដោយការភិតភ័យរន្ធត់តក់ស្លុតនៅក្នុងចិត្ត មហិមា មិនមានពាក្យអ្វីអាចបរិយាយអោយសក្តិសមបានឡើយ ។ មែនហើយ! ពិធិរៀបការរបស់ខ្មែរសម័យមុនៗ ជាពេលវេលាដ៏ សែនសប្បាយរីករាយរបស់គូស្រករ និងក្រុមគ្រួសារ មានភ្លេង ភ្លាត់ មានញាតិសន្តានសើចរីករាយក្អាកក្អាយ ជូនពរកូនប្រុស កូនស្រីដែលស្លៀកសម្លៀកល្អស្អាតពណ្ណរាយ ដូចទេវបុត្រនិងទេព ធិតា ។ ប៉ុន្តែពិធីរៀបគូស្រករជំនាន់ឆ្នាំ១៩៧៦នេះ ជាពេលវេលា ដ៏ស្ងៀមស្ងាត់គ្មានភ្លេងភ្លាត់ គ្មានសំណើចក្អាកក្អាយ ។ និយាយឲ្យ ចំទៅ ពេលនោះមិនខុសពីពេលដែលសាមីខ្លួននិងក្រុមគ្រួសារ កាន់មរណទុក្ខឡើយ ព្រោះម្នាក់ៗស្លៀកខ្មៅពាក់ខ្មៅ សង្រួមឥរិយា ធ្វើទឹកមុខក្រៀមក្រំ... នោះគឺដំណើរធ្លាក់នរកទាំងភ្នែកស្រស់របស់ ពពួករងគ្រោះ ត្បិតពួកគេគ្មានលទ្ធភាពណាអាចជួយខ្លួនឯងបាន ឡើយ ។

បន្តិចមក អង្គការក៏ហៅឈ្មោះមីងណៃអោយទៅបង្ហាញខ្លួន ចាប់ដៃជាមួយគណៈឃុំឈ្មោះ មិត្តគ្រេង ដែលមានរូបសែនសង្ហា អនិច្ចាតែគេមានភ្នែកក្រហម ហាក់ដូចជាចង់ហុតឈាមមនុស្សទាំង រស់ និងបេះដូងរបស់គេដែលពោរពេញទៅដោយធាតុបិសាច គ្មាន

CHANBOKEO.COM

ព្រះណាអាចយាងមកប្រោសបាន ។ មីងណៃខ្ចើមបាតដៃមួយនោះ ណាស់...
ដៃដែលកំពុងស្រវាខ្វាំម្រាមដៃរបស់មីង ដែលធ្វើឲ្យគាត់ មានមានអារម្មណ៍ថា ជាតិពិសយ៉ាងល្វីងជូរចត់កំពុងជ្រួតជ្រាបមក បំផ្លាញវិញ្ញាណនឹងរូបកាយរបស់គាត់ទាំងរស់... មីងឈរខមសម្លឹង មុខបុរសនោះដោយឥតព្រឺខ្លាចរអា ហាក់ដូចជាចង់ប្រាប់ថា មីងមិនព្រមចុះចាញ់បុរសម្នាក់នោះងាយៗឡើយ ។

ចៃដន្យ បុរសនោះស្តាប់ភាសាក្រសៃភ្នែករបស់មីងណៃ មិន យល់ទេ ព្រោះគេជាមនុស្សកម្លៅ ។ គេបែរជាយល់ច្រឡំថា មីង កំពុងតែពេញចិត្តចំពោះរូបគេ ទើបសម្លឹងមុខគេមិនដាក់សោះ ។ បុរសនោះញញឹមយ៉ាងពព្រាយតែម្តង ធ្វើអោយមីងណៃខ្ពាញ់សឹង តែស្ទុះទៅច្របាច់កបុរសនោះអោយស្លាប់នៅនឹងកន្លែងតែម្តង ។

- ព្រោះតែអ្នកហើយ... ទើបខ្ញុំត្រូវព្រាត់ប្តីជាទីស្រឡាញ់របស់ខ្ញុំ! ព្រោះតែអ្នកនេះហើយ ទើបជីវិតខ្ញុំត្រូវធ្លាក់ក្នុងអវិចីទាំងរស់...! ព្រោះតែអ្នកនេះហើយ ទើបដួងចិត្តខ្ញុំឈឺចាប់រកទីបំផុតគ្មាន ។ ខ្ញុំ ពិតជាមិនអោយអ្នករួចខ្លួនងាយៗឡើយ ។

មីងណៃលួចប្រទេចផ្តាសាមិត្តគ្រេងមួយរូបនោះ តែក្នុងចិត្ត ។ ពេលវេលាចាប់ដៃរៀបគ្រួសារក៏បានចប់សព្វគ្រប់ទៅ ។ មីងណៃក៏ បំបែកជួរដើរលាយឡំគេឯងត្រឡប់មកផ្ទះវិញ ស្រាប់តែ ៖

- មិត្តអូនទៅណា ?

មីងណៃបែរក្រោយឃើញមិត្តគ្រេងស្រែកសួរហើយដើរតាមមក ពីក្រោយមីងផង ។

- ខ្ញុំទៅផ្ទះ ! (មីងណៃឆ្លើយ)
- ទៅធ្វើអី ? ទៅផ្ទះយើងដែលអង្គការរៀបទុកឲ្យឯណោះវិញ!
- តែ... ខ្ញុំគិតថាទៅយកខោអាវ ។

តាមពិតមីងណៃមានគម្រោងចាំនាំស្រីម៉ៅនិងចៅរត់គេច...

- មិនបាច់ទេ ។ ចាំបងសុំអង្គការអោយកាត់ខោអាវខ្មៅថ្មីៗឲ្យមិត្ត អូនពាក់វិញ សមរម្យធ្វើជាប្រពន្ធគណៈឃុំផង កុំអោយអាពួកតូច តាចវាមើលងាយ ។

មីងណៃមិនរំភើបនឹងការយកចិត្តរបស់បុរសនោះទេ ។ ភ្លាម នោះ គេនិយាយបន្តទៀតថា ៖

- មិត្តអូនដឹងទេ ? កាលបើមិត្តអូនក្លាយជាប្រពន្ធបង មិត្តអូនអាច មានអំណាចកាន់កាំភ្លើង ហើយរស់នៅស្រណុកសុខស្រួលជាអ្នក ភូមិឆ្ងាយណាស់ មានដឹងខ្លួនទេ ?

CHIANBOKEO.COM

មីងណៃមិនឆ្លើយទេ គិតតែប្រឹងដើរទៅផ្ទះតែម្យ៉ាង ។ តើឲ្យ មីងរំភើបយ៉ាងណាទៅ កាលបើកាំភ្លើងនោះ បានយាយីប្តីរបស់គាត់ អោយរបួស មិនដឹងថាពេលនេះ លោកគ្រូពេទ្យមានសុខទុក្ខយ៉ាង ណាហើយក៏មិនដឹង ។ រំពេចនោះ មីងណៃរលីងរលោងទឹកភ្នែក...

- ពុទ្ធោ! រំភើបចិត្តឬមិត្តអូន បានជាញាប់ញ័រដល់ម្លឹង ?

មិត្តគ្រេងនោះស្រដីឡើង កាលបើឃើញមីងណៃភ្នែកក្រហម ចង់ស្រក់ទឹកភ្នែក ។ គេបានដើរតាមក្រោយមីងណៃរហូតដល់ខ្ទម ធ្វើអោយមីងអាក់ខានគម្រោងការបបួលកូនស្រីរត់គេចខ្លួនពីភូមិ នោះ ។ ទីបំផុត មីងក៏ត្រូវបង្ខំចិត្តវេចខោអាវមួយបន្លាស់យកតាម ខ្លួនដើរត្រឡប់ទៅជាមួយមិត្តគ្រេងវិញ ។ ស្រីម៉ៅឈរពាកូនមើល តាមម្តាយដោយក្តីអាណិតខ្លោចប្រមាត់ ប៉ុន្តែ តើនរណាមួយយំចេញ ទៅ បើស្ថានការណ៍គ្រួសារចេះតែដុនដាបទៅរាល់ថ្ងៃយ៉ាងនេះ ?

លុះដើរបានបួនដប់ជំហាន មីងណៃលួចបែរក្រោយ មិចភ្នែក ដាក់ស្រីម៉ៅ ហើយក៏ដើរទៅមុខទៀត ។ ភ្លាមនោះ ស្រីម៉ៅភ្ញាក់ ព្រើត ចាប់ភ្លឹកភ្លាមថា ម្តាយនាងកំពុងមានគម្រោងការអាថ៌កំបាំង អោយនាងត្រៀមខ្លួនសំរាប់អ្វីហើយ ។

ព្រលប់ថ្ងៃដដែល...

នៅក្នុងផ្ទះគណៈឃុំដែលអង្គការខ្មែរក្រហមសង់អោយ យ៉ាងល្អ ប្រណីតលើសលំនៅអ្នកស្រុកធម្មតា ឆ្ងាយសែនឆ្ងាយ...

នោះគឺជាផ្ទះដែលធ្វើពីឈើល្អៗ ដែលពួកយោធាអង្គការបានរុះ រើផ្ទះស្តុកស្តម្ភរបស់អ្នកស្រុក មកសាងសង់ជាថ្មី យកធ្វើជាលំនៅ ដ្ឋានរបស់ពួកអង្គការខ្មែរក្រហម ។ មិត្តគ្រេងបានដេញពួកកងឈ្លប ក្មេងៗទាំងនោះចេញឆ្ងាយអស់ ព្រោះយប់នោះជាយប់រាត្រីទឹកឃ្មុំរបស់គេនិងមីងណៃ មិនចង់អោយក្មេងៗវាព្រើលលួចមើល ។

- មិត្តអូន... (គណៈឃុំនោះហៅមីងណៃ)
- ចាស!
- ចង់រៀនប្រើកាំភ្លើងទេ ?
- មិនចង់ទេ!
- ហ្ន៎ក! ម៉េចក៏អញ្ចឹង ? ស្រីៗដែលបំរើអង្គការសុទ្ធតែចេះបាញ់ កាំភ្លើងគ្រប់គ្នាណា៎ ដឹងទេ ?
- តែខ្ញុំមិនចង់ចេះទេ ។

CHANBOKEO.COM

- កុំប្រកែក! ពេលនេះ បងចង់អោយមិត្តអូនរៀន ។

មិត្តគ្រេងពោលបង្ខំមីងណៃ ។ ឃើញទឹកមុខមិត្តគ្រេងឡើង ក្រហម មីងណៃក៏ឈប់ហ៊ានប្រកែកហើយនឹកគិតក្នុងចិត្តថា ៖

- ខ្ញុំត្រូវតែរស់ ត្រូវតែចេះរកមធ្យោបាយការពារជីវិតខ្លួន មិនត្រូវបណ្តោយអោយខ្លួនត្រូវស្លាប់ដោយអាសារបង់ឡើយ ។ ខ្ញុំត្រូវតែរកពន្លឺជំនះក្នុងជីវិតអោយឃើញ... មិនត្រូវចាញ់គំនៀបពួកវាទេ... ខ្ញុំត្រូវតែឈ្នះ...ឈ្នះដើម្បីរក្សាជីវិតអោយបានទៅជួបប្តីនឹងកូនវិញ ។

មីងណៃក៏សម្រេចចិត្តរៀនបាញ់កាំភ្លើងនោះ ។ មិត្តគ្រេងបានចិត្តក៏បង្ហាញកាំភ្លើងគ្រប់យ៉ាងដែលគេមាន យកមកអោយមីងណៃ មើល ហើយប្រាប់នូវវិធីប្រើទាំងឡាយ ។ មីងសម្លឹងកាំភ្លើង ហើយ សម្លឹងមុខមិត្តគ្រេង...

បន្តិចមក មិត្តគ្រេងដោះអាវចូលដំណេក ។

- មិត្តអូន ឡើងមកច្របាច់ជើងអោយបងបន្តិចមក៍!

មីត្តគ្រេងហៅមីងណៃអោយទៅបំរើ តែមីងមិនព្រមក្រោកទៅ ជិតទេ បែរជាអង្គុយធ្វើមិនដឹង ។

- មិត្តណៃ! អង្គុយភ្លឹកអីហ្នឹង ? ឆាប់មកបំរើប្តីបន្តិចមើល៍!

មីងណៃមិនងើបងដែល ។ បុរសនោះទ្រាំមិនបានក៏ងើបឡើង គំហកអោយមីង ៖

- ម៉េច ? ចង់ងាប់ណាស់ហ្អែស បានជាមិនស្តាប់បញ្ជាយើង ? នេះយប់ហើយវើុយ មិនចង់ចូលដេកទេហ្អែស ?

អស់ពីទន់ភ្លន់ មិត្តគ្រេងក៏ចេញក្រឡាចាស់របស់ខ្លួនជាមនុស្ស កាចសាហាវមកសម្លុតមីងណៃ ។ តែមីងលែងខ្លាចហើយ ។ គាត់ អង្គុយធ្វើព្រងើយ ហាក់មិនបានឮសំដីមិត្តគ្រេងទេ ។ ទ្រាំមិនបាន មិត្តគ្រេងក៏ស្ទុះរឹងទៅកញ្ឆក់មីងណៃអូសដៃឡើងគ្រែ ៖

- យើងប្រាប់ហើយ ថាអោយឡើងដេក!

តែមីងណៃរលាស់ដៃយ៉ាងរហ័ស ។ មិត្តគ្រេងភ្ញាក់ព្រើតបើក ភ្នែកគ្រលួងតែម្តង ៖

- ម៉េចចង់តដៃយើងឬស្រីល្អ ?

CHANBOKEO.COM

មិត្តគ្រេងស្ទុះទៅស្រវាចាប់មីងណៃ គ្រវែងអស់ទំហឹង ។ មីង យើងក៏ដួលខ្ទាក
បោកក្បាលចំសសរកន្លោងផ្ទះ បែកថ្ងាសជាំមួយ រំពេច ។ មីងណៃឈឺណាស់
ទ្រាំមិនបានក៏ងើបឡើងស្រវាកាំភ្លើង ដែលមិត្តគ្រេងបង្ហាញអំបាញ់មិញមកភ្ជង់មិត្តគ្រេងភ្លាម ។

- ហ្អ៊ក! កុំលេងនឹងបងអញ្ចឹងមិត្តអូន! យើងជាប្ដីប្រពន្ធ និងគ្នា
លេងអីសុទ្ធតែកាំភ្លើងយ៉ាងហ្នឹង ?

មិត្តគ្រេងធ្វើជាបន្ទន់ពាក្យបន្លប់ស្មារតីមីងណៃ អោយគាត់ភ្លេច ខ្លួន
រួចហើយក៏ស្ទុះរឹងទៅកញ្ឆក់កាំភ្លើងមីងណៃ ។ តែគេស្មានខុស សោះ!
មីងណៃមិនបានអោយបុរសម្នាក់នោះឆក់កាំភ្លើងពីដៃគាត់ ងាយៗឡើយ ។
គាត់ហក់ថយក្រោយគេចយ៉ាងរហ័ស ហើយក៏ គាស់កៃផាំង! ភ្លាមនោះ
មិត្តគ្រេងយកដៃខ្ទប់ដើមទ្រូងដែលកំពុង បាញ់ឈាមព្រលឡើង
រួចហើយដួលគ្រេងទៅលើក្តារផ្ទះបាត់មាត់ ឈឹងតែម្តង ។ មីងណៃតក់ស្លុតណាស់
ក៏រត់ចេញទៅទាំងយប់ ស្ទាត់ដោយក្តីភិតភ័យតក្កមា ត្បិតមីងបានក្លាយខ្លួនជាឃាដករ..ប៉ុន្តែ
តើអោយមីងធ្វើយ៉ាងណា បើស្ថានការណ៍វាជំរុញមីងអោយទាល់ ច្រកដូច្នេះទៅហើយនោះ ?
បើមិនសម្លាប់គេទេ គឺមីងច្បាស់ត្រូវ គេសម្លាប់វិញជាក់ជាមិនខាន!! នេះឯងហើយ
ដែលចាស់លោក តែងពោលថា ដល់ក! ពេលឆ្កែទាល់ច្រក វាត្រូវតែបែរខាំវិញ...! ពេលនេះ
មីងណៃយើងឆ្អែតចិត្តនោះ ឆ្អែតដល់កហើយ ។ រឹងទឹក ភ្នែករបស់មីងវិញ
ក៏ស្ងួតអស់រលីងពីរង្វង់ភ្នែកតែម្តង ។

ភ្លាមនោះ គាត់ស្ទុះដើរលបៗរត់គេចយ៉ាងរហ័ស ទាំងបេះដូង រន្ធត់ក្តុកៗដោយការភិតភ័យ
ដែលមីងណៃទាល់ច្រក ហ៊ានលើកដៃ បាញ់សម្លាប់មនុស្សដោយឥតរួញរា...

- ម៉ៅ! ភ្ញាក់ឡើងកូន!
- ចា៎សម៉ែ!
- ឯណាឥវាន់របស់កូន ?
- កូនរៀបទុកក្នុងសាកាដូហើយ ។ ម៉ែគិតនាំកូនទៅណាហ្នឹង ?
- យើងមិនអាចនៅទីនេះយូរបានទេកូន... យើងត្រូវតែគេចខ្លួន សិនហើយ ។

មីងណៃលើកចៅស្រីដែលកំពុងតែគេងលក់ ដាក់លីលើស្មា ធ្វើដំណើរចេញទៅភ្លាម ។
ចំណែកស្រីម៉ៅ ក៏ស្ពាយសាក់កាដូរត់ តាមពីក្រោយ ។ ខណៈនោះ

CHANBOKEO.COM

មីងឮសូរគ្រាប់កាំភ្លើងផ្ទុងផាំងឡើងពី ក្រោយខ្នងមីងកិតៗ ព្រមទាំងសំរែកឡើយៗស្រែកមកថា ៖

- បាញ់វាចោល កុំទុកវាអោយនៅ វាបានសម្លាប់គណាឃុំយើង...!

មីងលីចៅលើស្មាម្ខាង កាន់ដៃកូនស្រីនៅដៃម្ខាង ឆ្មេចភ្នែករត់ ទាំងភិតភ័យតក់ស្លុតមិនដឹងថា ត្រូវរត់គេចទៅទិសណាទេ ។ នៅ ទីបំផុត គាត់សម្រេចចិត្តថា រត់ទៅទិសខាងកើតតាមដែលប្តីរបស់ មីងធ្លាប់មានប្រសាសន៍ ក្រែងលោពួកវាមិនបានចាប់ភ្លឹកតាមរក ។

ភ្លឺស្រាងៗ មីងណៃបានមកដល់វាលស្រែម្តុំភូមិវត្តសោមនស្ស បាត់ដំបង ។ ចំណែកថង់បាយកាតាក (បាយហាល) ដែលស្រីម៉ៅ ដាក់មកតាមខ្លួននោះធ្លាយជ្រុះបាយអស់ ។ ឯស្រីម៉ៅវិញ ក៏គ្រុន សន្ធំយ៉ាងខ្លាំង ដោយការនឿយហត់ផង ដោយនាងមានជំងឺទាស់ ស្រាប់ផង ព្រោះនាងធ្វើការហួសកម្លាំងពេលសរសៃខ្ចី ហើយមិន ដែលបានបរិភោគឬមានថ្នាំសង្កូវរក្សាខ្លួនគ្រប់គ្រាន់ ។ ឃើញកូន ស្រីទន់ដៃទន់ជើងដើរមិនរួច មីងណៃក៏នាំស្រីម៉ៅឡើងទៅសំរាក នៅជីទួលកណ្តាលវាលស្រែមួយ ។

- សំរាកទីនេះសិនទៅកូន ។

ស្រីម៉ៅមិនទឹកមុខកាន់តែស្លេកខ្មៅទៅៗហើយ ។ មីងណៃភិត ភ័យពេក ក៏ឱ្យបប្រាប់កូនថា ៖

- កូនឆ្មេចភ្នែកគេងសិនទៅ ចាំម៉ែចូលទៅភូមិ ដូរអង្ករ ដូរថ្នាំ យកមកអោយកូនញុំា ។

ថាហើយ មីងក៏លាតអាវដៃវែងមួយដណ្តប់អោយកូនស្រី រួចក៏ រលាក់យកក្រវិលមាសរបស់គាត់មួយគូចេញមក ។ បន្តិចមក មីង ក៏ពចៅដើរសំដៅទៅភូមិ លួចឱ្យបដូរអង្ករនិងថ្នាំគ្រុន ។ ប្រហែល មួយម៉ោងក្រោយមក គាត់ក៏ដើរត្រឡប់មកជីទួលចាស់ ឯកណ្តាល វាលស្រែដដែលនោះវិញ ។ ថៃដន្យ នាងម៉ៅកូនស្រីរបស់គាត់បាន បាត់ស្រមោលពីទីនោះទៅហើយ មិនដឹងថានាងដើបទៅណាទេ ។ មីងណៃភិតភ័យណាស់ ក៏ពចៅរត់ពេញស្រែ រត់ចុះរត់ឡើង កួក ហៅរកស្រីម៉ៅ ។ តែអនិច្ចា...! មីងបានត្រឹមតែរត់កួកហៅតែ ប៉ុណ្ណោះ ។ ស្រីម៉ៅមិនបាននៅទីជិតៗនោះឆ្លើយតបនឹងពាក្យម្តាយ ហៅសោះឡើយ...

អ្នកស្រុកអ្នកភូមិ នាំគ្នាផ្អើលឆោឡោមកមើលស្ត្រីវិកលចរិត

CHANBOKEO.COM

ម្នាក់ដែលពចៅស្រី រត់ចុះរត់ឡើងតែម្នាក់ឯង មិនព្រមឈប់ រហូត
ដល់ដួលសន្លប់បាត់មាត់នៅលើភ្លឺស្រែមួយ ។ លុះមីងណៃភ្ញាក់
ស្មារតីឡើង ឃើញអ្នកស្រុកនាំគាត់ទៅដាក់ផ្ញើមន្ទីរពេទ្យមួយក្នុងវត្ត
សោមនស្សជាមួយនឹងចៅស្រីដែលអង្គុយយំរកម្ដាយរហាម ។ មន្ទីរ
ពេទ្យជំនាន់នោះ គឺជាកន្លែងដាក់មនុស្សរង់ចាំសេចក្ដីស្លាប់ ព្រោះ ពេទ្យគ្មានថ្នាំព្យាបាលទេ
ក្រៅពីថ្នាំអាចម៍ទន្សាយធ្វើពីត្រួយត្របែក បុកលាយម្សៅ
លុញជាគ្រាប់ហើយហាលថ្ងៃតែម្យ៉ាងប៉ុណ្ណោះ ។

ចាប់តាំងពីថ្ងៃនោះមក អ្នកស្រុកម្ដុំនោះក៏ហៅគាត់ថា យាយ ង៉ោលរិកលចរិត
ហើយគេអោយគាត់នៅបេះបន្លែនៅរោងការដ្ឋាន បាយមួយប្រចាំភូមិ
ព្រោះគាត់បានក្លាយជាមនុស្សរស់ឥតវិញ្ញាណ ដើរឱបតែចៅស្រីមិនព្រមលែង
ហើយក៏មិនព្រមនិយាយរកនរណា ទាំងអស់ ក្រៅតែពីបង្ហូរទឹកភ្នែកដូចនាងបដាចារ...

មីងណៃបានរស់នៅក្នុងអន្លង់ទុក្ខរាប់ខែរាប់ឆ្នាំ រហូតដល់ខែត្រ
បាត់ដំបងបានជួបនឹងស្ថានការណ៍ថ្មីមួយទៀតនៅខែមករា១៩៧៩ ។ ពេលនោះឯងហើយ
ដែលគាត់នាំចៅរត់មកផ្ទះចាស់របស់គាត់នៅ បាត់ដំបង
រំពឹងក្រែងលោមានសមាជិកគ្រួសាររបស់គាត់វិលត្រឡប់ មកទីនោះវិញ ។ ក្រោយមក
គាត់ក៏បានមករស់នៅជាជីវិតសាមញ្ញ លើទូកនាយសល់ ជាមួយម្ចាស់ទូក
និងពួបួរដែលជាជនរងគ្រោះ រសាត់អណ្ដែតមិនខុសពីគាត់ប៉ុន្មានដែរ...

នៅរាត្រីដែលគាត់អង្គុយម្នាក់ឯងឯកលអំពិលនាមាត់ស្ទឹងសង្កែ មិនឆ្ងាយប៉ុន្មានពីផ្ទះរបស់គាត់
បន្ទាប់ពីបារមីពចៅរបស់គាត់ចេញ ទៅ មីងណៃបាននឹកគិតឆ្ងើផ្ដេសផ្ដាស ពីរបីដង ។
គាត់បានដើរចុះ ទៅក្បែរមាត់ទឹក សម្លឹងខ្សែទឹកហូរនៅក្នុងស្ទឹង ។ ចិត្តគាត់ប្រាប់ថា
ត្រូវលោតទម្លាក់ខ្លួនទៅអោយស្លាប់ ព្រោះទ្រាំនឹងការឈឺចាប់ក្នុង ដើមទ្រូងមិនបាន
ស្រាប់តែសតិលេចឆ្លោមករំលឹកគាត់ថា គាត់នៅ មានកូនច្រើននាក់
ដែលប្រហែលជាកំពុងមានដំណើរត្រឡប់មកផ្ទះ មករកម្ដាយឪពុកវិញ ដូច្នោះ
គាត់ត្រូវតែប្រឹងខាំមាត់តស៊ូនឹងការ ឈឺចាប់តទៅទៀត ដើម្បីកូនរបស់គាត់គ្រប់គ្នា ។
មីងណៃឈរយំ ឡើងអស់ចិត្តអស់ចង់ ទើបដើរថយក្រោយឡើងច្រាំងមកខាងលើ វិញ ។

ក្រោមពន្លឺខែរះសច្លាពីផ្ទៃមេឃខ្មៅថ្លាយង់ មីងណៃឈរឆ្មឹងដូច រូបចម្លាក់
សម្លឹងដំបូលផ្ទះរបស់គាត់តែម្នាក់ឯង កណ្ដាលរាត្រីដ៏ សែនស្ងាត់...

CHANBOKEO.COM

- ឱ ! ណៃអើយ ហេតុអ្វីក៏ខ្លួនអ្នកមានវាសនាដុនដាបដល់ម្លឹង ?

មីងណៃលើកដៃផ្ដិតទឹកភ្នែក ស្រាប់តែភ្ញាក់ព្រឺត ព្រោះមីង ឃើញស្រមោលលោកគ្រូពេទ្យ ឆ្លុះនឹងភ្លើងចង្កៀង ដើរចុះ ដើរ ឡើង ឯខាងលើផ្ទះ ។ ចំណែកទ្វាររបងវិញក៏ចំហធ្លុង... មីងណៃ នឹកពិភាល់ក្នុងចិត្តយ៉ាងណាមិនដឹងទេ ។ ថៃដន្យ ស្រមោលលោក គ្រូពេទ្យ ដែលឆ្លុះនៅលើជញ្ជាំងផ្ទះ បានខាបយកវិញ្ញាណមីងណៃ ទៅភ្លាមយ៉ាងរហ័ស ធ្វើអោយគាត់បោះជំហានដើរត្រុយ ចូលទៅ ក្នុងរបងដោយមិនដឹងខ្លួន ។

ចម្លែកណាស់ ! សូម្បីតែទ្វារផ្ទះក៏ចំហដែរ មិនឃើញបិទទ្វារ ដាក់គន្លឹះអ្វីទេ ។ មីងណៃមិនឃើញមានស្រមោលមនុស្ស ឬនរណា មួយភ្ញាក់ មកសួរមីងសោះ ។ បន្តិចមក គាត់ក៏ដើរឡើងទៅដល់ ខាងលើឡៅ លួចមើលលោកគ្រូពេទ្យតាមបង្អួច ឃើញលោកកំពុង តែក្រហល់ក្រហាយ រួចហើយក៏ដួលខ្ពោកទទឹងគ្រែ ទំនងដូចជា កំពុងស្រវឹងជោគ ។ ទ្រាំឈរមើលនឹងភ្នែកមិនបាន មីងណៃក៏ ស្ទុះចូលទៅជួយលើកខ្លួនលោកគ្រូពេទ្យឡើង ដើម្បីអោយលោក បានសំរាន្តលើខ្នើយស្រួលបួល ស្រាប់តែលោកគ្រូពេទ្យក្អួតវ៉កៗ ប្រឡាក់ខោអាវអស់រលីង ។ មីងក៏ស្ទុះដោះខោអាវលោកចេញយក ទៅបោក ហើយក៏ត្រឡប់មកនៅអង្គុយថែទាំលោកគ្រូពេទ្យ ដោយ យកចិត្តទុកដាក់បំផុត ត្បិតឃើញលោកមមើមមាយនិយាយអ្វីស្ដាប់ មិនបាន ។ ដោយដួងចិត្តរបស់មីងដែលស្រឡាញ់ប្ដី ទប់មិនបាន មីងក៏ឡើងអង្គុយក្បែរ ច្របាច់ដៃច្របាច់ជើងជូនលោកគ្រូពេទ្យ រហូតឃើញលោកគ្រូពេទ្យបិទភ្នែកសម្ងំស្ងៀម ទំនងហាក់ដូចជា បានធូរស្រាលក្នុងខ្លួនមកវិញ ។ បន្តិចក្រោយមក គាត់ក៏លាតផ្ទាំង ផាហ៊ុំកញ្ញាស់មួយដែលនៅក្បែរនោះដណ្ដប់ប្ដី ហើយអង្គុយសម្លឹង លោកយ៉ាងយូរ ៖

- បងចិត្រ ! នេះប្រហែលជាលើកចុងក្រោយហើយដែលណៃអាច នៅបំរើបងបាន ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ... អូនសូមចង ចាំរាត្រីនេះ រហូតដល់ថ្ងៃអូនលាលោកនេះទៅវិញ ។

មីងណៃក៏ទាញក្រដាសមួយសន្លឹកសរសេរខ្សៀកៗ រួចក៏ស្រវា លាចង្កេះ សំពត់ទាញកញ្ចប់ក្រណាត់មួយចេញមក ។ លុះគាត់បត់ សំបុត្រទុកក្នុងកញ្ចប់ក្រណាត់ហើយ មីងក៏យកកញ្ចប់នោះទៅសិក នៅក្រោមខ្នើយរបស់លោកគ្រូពេទ្យថ្នមៗ ។ បន្ទាប់មក មីងក៏អោន ឈ្ងោកថើបថ្ពាល់ដ៏ខ្ចង់ជ្រីវជ្រួញរបស់លោកគ្រូពេទ្យ ទាំងទឹកនេត្រា រលីងរលោងព្រោះក្ដីរំជួលញាប់ញ័រនៅក្នុងដួងចិត្ត ។

CHANBOKEO.COM

- សូមបងនៅឲ្យបានសុខ ណា៎ប្តីសម្លាញ់! អូនសូមផ្ញើកូនរបស់ យើងទាំងអស់ជាមួយបងផង!

ភ្លាមនោះ ស្រាប់តែលោកគ្រូពេទ្យលូកដៃស្រវាត្រកងអោបខ្លួន មីងណៃផ្អោបនឹងដើមទ្រូងលោកយ៉ាងណែន រួចពោលហៅខ្សិបៗ ដាក់ត្រចៀកមីងថា ៖

- ចរណៃ កំពូលដួងចិត្តរបស់បង...!

មីងភ្ញាក់ព្រើត ភើតក្នុងឱរា បេះដូងលោតខុសចង្វាក់ភិបៗ ភ័យអរៗរកស្មានមិនត្រូវ... ភ្លើងស្នេហ៍ដែលឆាបឆេះងំក្នុងបេះដូង របស់មីងជាយូរមកហើយនោះ ក៏រិតតែកើនអនុភាពថែមទៀតទ្វេ ឡើង ។ មីងណៃទប់អារម្មណ៍រំភើបលែងបាន ក៏បណ្តោយខ្លួនឲ្យ ស្វាមីអោបរិតត្រកងថើបមថ្នាក់ថ្នមរូបមីង ទៅតាមកំសួលខ្លាំងក្លានៃ កាមារម្មណ៍ដ៏មានរសជាតិជ្រាលជ្រៅឥតព្រំដែន ។ ពេលនោះ មីង ណៃមានអារម្មណ៍ថា មីងបានក្លាយទៅជាទេពធិតាដ៏ស្រស់ស្អាតបវរ មួយរូប កំពុងហោះហើរនៅស្ថានត្រៃត្រឹង្សស្រីង្គា ពីរនាក់ទេវបុត្រ កំពូលស្នេហ៍របស់មីង គឺលោកដុកទ័រ សួន វិចិត្រ...

នៅក្នុងរង្វង់ដៃដ៏កក់ក្តៅរបស់ស្វាមី មីងណៃគេងគិតខ្វល់ខ្វាយ ក្នុងចិត្តរារែកមិនដឹងថាត្រូវគិតយ៉ាងណាធ្វើយ៉ាងណា អោយសមរម្យ ចំពោះស្ថានការណ៍ដែលមីងកំពុងប្រឈមមុខនៅគ្រានោះ ។ ភ្លាម នោះស្រាប់តែលោកគ្រូពេទ្យយកដៃច្រានខ្លួនមីងហើយស្រែកថា ៖

- ចៀសចេញមើស៍...! កុំរំខានជីវិតយើងនិងប្រពន្ធរបស់យើង!

មីងណៃភ្ញាក់ព្រើតប្រហោងពោះឆ្លុង ខកចិត្តរលីងឆេងតែម្តង កាលបើឮប្រសាសន៍របស់លោកគ្រូពេទ្យដូច្នោះ ។ ពេលនោះ មីង ហាក់ដូចជាអស់ទឹកចិត្ត ស្រកក្តីសង្ឃឹមរលីងតែម្តង ពីបេះដូងដែល កំពុងតែត្រដរដើបប្រឹងដុះពន្លក មុននេះបន្តិច ។ មីងបែរសម្លឹង ទៅលោកគ្រូពេទ្យ មិនឃើញលោកពាក់ខ្សែកអំបោះក្រហមបន្តោង ផ្កាចំប៉ាឈ្មោល ដែលលោកតែងតែពាក់តាំងពីលោកបានរៀបការជា មួយមីងមកនោះ តទៅទៀតឡើយ ។

- បងបានផ្តាច់ចំណងរវាងយើងទាំងពីរហើយឬ បងចិត្រ ? បង លែងស្រឡាញ់ណៃដូចមុនទៀតហើយ មែនទេ ប្តីសម្លាញ់ ?

មីងក៏ស្ទុះដើររត់ចេញទៅ ទាំងទឹកភ្នែកជោគជាំ សាជាថ្មី ។ ពេលនោះ មីងមិនដឹងថាគាត់ចង់ធ្វើអ្វីតទៅទៀតទេ ព្រោះគាត់ កំពុងតែវិលវិលសតិស្មារតីម្តងទៀតហើយ...

CHIANBOKE9.COM

មីងណៃដើរទៅដើរមកលើមាត់ស្ទឹងសង្កែ ហាក់ចង់លោត ទឹកសម្លាប់ខ្លួនម្តងៗទៅហើយ ប៉ុន្តែពេលណាមីងសំរេចចិត្តថានឹង ធ្វើដូច្នេះ មីងតែងតែឮសំនៀងកូនៗស្រែកហៅអោយគាត់ត្រឡប់ថយក្រោយវិញជានិច្ច ។ ទីបំផុត គាត់ក៏សំរេចចិត្តដើរទៅវត្ត កណ្តាល រកកោរសក់កាន់ធម៌អាចិកាត់ចិត្តពីលោកីយ៍ ដើម្បីរង់ចាំ កូនប្រុសកូនស្រីរបស់មីងដែលនឹងត្រឡប់មកនៅថ្ងៃណាមួយ ។

មីងណៃដើរមកដល់ទីធ្លាវត្ត ដែលមានស្មៅដុះស៊ុបទ្រុប ដោយ គ្មានមនុស្សថែយូរឆ្នាំស្រាប់តែមីងមានអារម្មណ៍ថា ងងឹតមុខ ធីងធោងក្នុងខ្លួនណាស់ ។

គាត់ខំប្រឹងដើររហូតជិតដល់វិហារ ទើប ទន់ជង្គង់ដួលប្រូសលើដីដើបលែងរួចតែម្តង ៖

– ប្តីសម្លាញ់អើយ...! ណៃសូមលាបងត្រឹមណេះហើយ... ត្រា! បារមី! សាល! ចៅមុំ ស្រីម៉ៅ បុរី... កូនមាសម្តាយ... ម្តាយ ប្រហែលជាគ្មានវាសនាបានឃើញកូនជាចុងក្រោយ មុនម្តាយបិទភ្នែកលាលោកនេះទេ មើលទៅ... សូមព្រះជាម្ចាស់តាមថែកូនម៉ាក់ គ្រប់គ្នាផង!... បងចិត្រ... អូនស្រឡាញ់បងណាស់... ស្រឡាញ់បង ជានិច្ច... និងរៀងរហូតទៅ...

មីងណៃដង្ហោយហៅប្តី ហៅកូនខ្សិបៗក្នុងមាត់ខ្សោយៗ រហូតដល់អស់កំស្លួលនឹងដង្ហោយហៅតទៅទៀត...

*ooooooooooooooooooooooooo*

CHANBOKEO . COM

# វគ្គទី១១
# ស្អែក..ថ្ងៃណា ?

ក្រុងបាត់ដំបង ខែមិនា ១៩៧៩...

លោកគ្រូពេទ្យស្រវាំអោបភរិយាដោយក្តីអាណិតអាសូរ ពេញ បេះដូងរបស់លោក ៖

- ណៃ... អោយបងសូមទោសណា៎ ដែលបងគិតមិនល្អ... ធ្វើអោយ អូនបាក់ទឹកចិត្តដោយសារបង...

អ្នកគ្រូចរណៃរបស់យើងញញឹមហើយតបវិញថា ៖

- ឈប់រំលឹករឿងអាក្រក់ៗក្នុងអតិតកាលនោះទៅ... យើងមកគិត រឿងថ្មីល្អៗរបស់យើងវិញ ។ ណៃមិនបន្ទោសបងទេ ព្រោះយើង ជាជនរងគ្រោះទាំងពីរនាក់ រងគ្រោះដោយគំនៀបរបបផ្តាច់ការខ្មែរ ក្រហម ។ ស្ថានការណ៍ទាំងឡាយជុំវិញភ្លើងសង្គ្រាម នៅកម្ពុជា បានបណ្តាលអោយប្រជាពលរដ្ឋ ឆ្លងកាត់ជីវិតទុក្ខវេទនា យ៉ាង អណោចអធម្មបំផុត តួយ៉ាងដូចជាគ្រួសាររបស់យើងនេះតែម្តង ។

- មែនហើយ..! ពេលនេះ យើងគួរសម្លឹងទៅមុខបន្តទៀត... យើងត្រូវតែសាងក្តីសង្ឃឹម និងផ្តល់កម្លាំងចិត្តអោយគ្នាទៅវិញទៅ មក ។ មានតែកម្លាំងចិត្តទេដែលអាចនាំយើងឲ្យមានក្តីសង្ឃឹម ។ ការមានក្តីសង្ឃឹមធ្វើអោយយើងមានចិត្តតស៊ូតទៅទៀត ។ ពេល នេះ បងត្រេកអរណាស់ណៃ ដែលហោចណាស់ អូនមិនបានគិតខ្លី រកផ្លូវផ្តាច់ជន្មាខ្លួនឯង តែបែរជាប្រឹងតស៊ូរហូតអូនអាចស្វែងរក ឃើញពន្លឺជីវិតសាជាថ្មី... រីឯដួងចិត្តស្នេហាដ៏ស្មោះស្មគ្រ័ភក្តីរបស់ អូនក៏បានដឹកដៃអោយយើងជួបគ្នាវិញដោយល្អបំផុត...

- បងក៏ដូច្នេះដែរ ។ បើសិនជាបងមានកំហឹង មិនអត់ធ្មត់ មិនរង់ ចាំអូន... ម្ល៉េះសមណៃមិនបានជួបបងដូចគ្នា ។ អរគុណណាស់ប្តី សម្លាញ់ ដែលបងនៅតស៊ូរង់ចាំអូនរៀងរហូតមក...

CHANBOKEO.COM

- បងប្រាប់អូនជាច្រើនដងហើយតើហ៍ តាំងពីយើងរៀបការនឹងគ្នា មក ថាជាតិនេះ
បងមានប្រពន្ធតែម្នាក់ទេ គឺអូន...!

- ពិតមែនហ្អែស ? ហើយចុះនាងកាជេនវិញនោះ ?

លោកគ្រូពេទ្យជ្រួញចិញ្ចើម បំរុងនឹងឆ្លើយតបទៅហើយស្រាប់
តែមានសម្លេងស្រីឆ្លើយតបជំនួសថា ៖

- នាងកាជេនក៏ជាប្រពន្ធពូសុខដែរ!

លោកគ្រូពេទ្យនិងភរិយា ក៏បែរយ៉ាងលឿន រកម្ចាស់សម្លេង
ឃើញនាងកាជេនដើរចូលមកក្នុងផ្ទះ ថែមទាំងបូញមាត់យកម្រាម ចង្អុលដៃទប់
ហើយនិយាយខ្សិបៗថា ៖

- ស៊ូច! កុំធ្វើមាត់ឮពេក ឮហើយនៅ! ប្រយត្ន័អង្គការលើគេឮ គេចាប់យកវាយចោល
ងាប់អស់ទៅ ។ ការពិត ពូសុខជាប្ដីក្លែង ក្លាយរបស់កាចេនទេ ។ ឯប្ដីកាជេនមែនទែនវិញនោះ
គាត់រស់នៅ ស្ថានលើ ខ្ពស់ជាងអង្គការលើទៅទៀត ។ ពុកចាបប្រាប់ថា ទៅ ជួបអង្គការលើ
គេជិះកង់ តែបើចង់ទៅលេងស្ថានលើវិញ ទាល់ តែឡើងជិះកប៉ាល់ហោះឯណោះ ទើបដល់...
ឡូយណាស់!

លោកគ្រូពេទ្យសម្លឹងមុខភរិយា តែមិននិយាយអ្វីទេ ត្បិត លោកដឹងថា
អ្នកគ្រូចរណៃបានកាត់យល់ស្ថានការណ៍ដោយខ្លួនឯង បានយ៉ាងច្បាស់រួចទៅហើយ ។
អ្នកគ្រូចរណៃក៏ញញឹមឡើង មើល មុខលោកគ្រូពេទ្យ ហើយបែរឆ្លើយទៅកាជេនវិញថា ៖

- ពេលនេះ អង្គការលើលែងមានហើយ ។ ក្មួយអាចប្រាប់គេបាន
ហើយថាកាជេនមិនមែនប្រពន្ធពូសុខទេ ។ រីឯប្រពន្ធពូសុខពិត ប្រាកដនោះគឺ ឈ្មោះចរណៃ ។
នាងចាំបានហើយនៅ ?

- ចរណៃ ? ហើយចរណៃហ្នឹង អាណាគេ ?

- ចរណៃហ្នឹង គឺជាមីងណៃ មីងណៃដែលកំពុងអង្គុយជាមួយ ពូសុខពេលនេះអី
ឃើញហើយនៅ ?

- អូហ៍ អាមួយហ្នឹងហ្អ៎ែស ឈ្មោះចរណៃ ? ស្លាប់ហើយ ត្រងោល ហើយចាស់បែបហ្នឹង
ម៉េចក៏មានឈ្មោះឡូយម៉េះ ?

នាងកាជេនបូញមាត់ដាក់មីងណៃយើង ហើយញាក់មុខទំនង មិនអស់ចិត្ត ។
លោកគ្រូពេទ្យញញឹមហើយស្រដីកាត់ភ្លាម ដើម្បីកុំ ឲ្យប្រពន្ធបាក់ទឹកចិត្ត ៖

CHANBOKEO.COM

- មីងណៃកោរសក់ស្មាលារបបអង្គការលើ ។ បន្តិចទៀត ពេល សក់ដុះវែងម្ដងទៀត មីងច្បាស់ជាស្រស់ស្អាតដូចឈ្មោះរបស់មីង វិញហើយ ។ ក្មួយកាដេនកុំខកចិត្តអីណា៎! មីងណៃរបស់កាដេននឹង ស្រស់សោភាដូចក្មួយកាដេនចង់បានអញ្ចឹង នឹងហើយនៅ ?

- ចា៎សៗ! នឹងហើយពូសុខ! អញ្ចឹង កាដេនទៅរកកោរសក់ ស្មាលាអង្គការលើដែរសិន ព្រោះអាពួកអស់ហ្នឹងវាចូលចិត្តពាក់ខោ អាវខ្មៅណាស់មើលតែនាំគ្នាទៅហៃខ្មោច... កាដេនស្អប់អើយស្អប់!

ថាហើយ នាងកាដេនក៏ដើរតាំងៗចេញទៅបាត់ ទុកអោយគូ ស្វាមីភរិយាទាំងពីរញញឹមដាក់គ្នាទៅវិញទៅមក យ៉ាងរំភើប មិន ខុសប៉ុន្មានពីកម្លោះក្រមុំដែលភពប្រសព្វគ្នា នៅរាត្រីទឹកឃ្មុំថ្ងៃដំបូង នោះឡើយ ។

បន្តិចក្រោយមក...

- អូនណៃ!
- ចា៎សបង!
- អូនធ្មេចភ្នែកសិនទៅ! បងមានអ្វីសំខាន់ផ្ញើអូនណា៎!
- អ្វីទៅបងចិត្រ ?
- អូនបិទភ្នែកទៅចាំបងប្រាប់ ។

អ្នកគ្រូចរណៃបិទភ្នែកនៅអង្គុយស្ងៀមលើគ្រែឬស្សី ក្នុងបន្ទប់ ដំណេករបស់លោកគ្រូពេទ្យ ។

- បើកភ្នែកបានហើយ អូនណៃ (លោកគ្រូពេទ្យស្រដី)

អ្នកគ្រូយើងបើកភ្នែក ក៏ឃើញមនុស្សពីរនាក់ឈរញញឹមដាក់ យ៉ាងគ្រហាញតែម្ដង ៖

- បារមី ? ចៅមុំ ?
- យាយ! ម៉ាក់! (ទាំងពីរនាក់ឧទានព្រមគ្នាឡើង)

ទាំងបីនាក់ក៏ស្រវាអោបគ្នាឡើងយ៉ាងរំភើប បន្ទាប់មកក៏សើច កក្អឹកដាក់គ្នាទៅវិញទៅមក ជាសំណើចសុភមង្គលមួយដែលអ្នកគ្រូ ចរណៃមិនដែលនឹកគិតថានឹងអាចវិលវិញបាន... លោកគ្រូពេទ្យ ដាក់ខ្លួនចុះ បបោសខ្នងភរិយានឹងកូនចៅ សម្ដែងនូវសោមនស្ស រីករាយដែលលោកមានឱកាស ស្គាល់រសជាតិសុភមង្គលគ្រួសារ សាជាថ្មី ។ ប៉ុន្តែមួយចំណែកក្នុងបេះដូងរបស់លោកនៅមានពពក អព្ទ័បិទបាំងនៅឡើយ នោះគឺ កូនប្រុសទាំងពីរ ស្រីម៉ៅនិងកូន ប្រសាររបស់លោកមិនទាន់មានដំណឹងថាយ៉ាងណានៅឡើយ ។

CHANBOKEO.COM

នៅថ្ងៃនោះ លោកគ្រូពេទ្យបានចូលរួមបរិភោគអាហារជាមួយ ក្រុមគ្រួសារជាលើកដំបូង ។ ទាំងអស់គ្នាញញឹមដាក់គ្នាទៅមកមិន ដាច់ សូម្បីតែនាងតូចមុំក៏ទទួលអារម្មណ៍នឹងថា ជីដូនរបស់នាង មានចិត្តរីករាយស្រស់ថ្លាខុសធម្មតា ធ្វើអោយនាងតូចមានកម្លាំងចិត្ត ឡើងច្រៀងរាំបង្អួតតាយាយយ៉ាងសប្បាយតែម្តង ។

បរិភោគបាយមិនទាន់រួចស្រួលបួលផង ស្រាប់តែមានរថយន្ត ហ្ស៊ីបមួយបរចូលមកដល់ ដោយមានដឹកបុរសបួននាក់មកផង ។ បុរសអ្នកបើកបរក៏ចុះគំនាប់បើកទ្វារជូប បុរសទីមួយដែលស្ថិតនៅ ក្នុងសម្លៀកបំពាក់ទាហានវៀតណាមជាន់ខ្ពស់ ។ លោកគ្រូពេទ្យភ្ញាក់ព្រើត ស្គាល់ភ្លាមថាជាឧត្តមសេនីយ ងោ ហាន ។

- លោកមានការអ្វីប្រើខ្ញុំមែនទេ ? (លោកគ្រូពេទ្យនិយាយបារាំង)

ឲ្យខ្ញុំសុំទោសផងដែលខានទៅធ្វើការពីរបីថ្ងៃ ។

- ខ្ញុំមិនបានមករឿងហ្នឹងទេ! (លោកងោហានឆ្លើយ)

- អូហ៍! អញ្ចឹងរឿងអ្វីទៅវិញ ?

- គឺរឿងនេះ !

លោកងោហានគប់បណ្ណ័ពណ៌មាសមួយខ្ទាច់ ចំទ្រូងលោកគ្រូ ពេទ្យ ហើយស្រដីថា ៖

- ខ្ញុំអោយកាតនេះសំរាប់លោកប្រើតែម្នាក់ឯង តែហេតុអ្វីក៏ហ៊ាន ចែកអោយគេឯងប្រើដែរ ?

លោកគ្រូពេទ្យភ្ញាក់ព្រើត ឆ្លើយវិញថា ៖

- ខ្ញុំសូមទោសលោកផង ដែលខ្ញុំហ៊ានធ្វើដូច្នោះ ព្រោះខ្ញុំពឹងគេឲ្យ ទៅតាមរកប្រពន្ធនិងកូនរបស់ខ្ញុំ មិនមានបំណងអ្វីក្រៅពីហ្នឹងទេ សូមតេជគុណអភ័យទោស ។

លោកងោហាននៅស្ងៀម សម្លឹងមុខភរិយាលោកគ្រូពេទ្យ ។ គ្រាន់តែឃើញក្រសែភ្នែករបស់លោកងោហាន ទៅលើភរិយារបស់ លោក លោកគ្រូពេទ្យងាកយកទ្រូងបាំងភ្លាម ៖

- សង្ឃឹមថាលោកអភ័យទោសអោយខ្ញុំចំពោះកំហុសលើកទីមួយ !

ស្រាប់តែលោកងោហានញញឹមឡើង ៖

- លោកនឹកប្រពន្ធកូនរបស់លោក ។ ខ្ញុំក៏នឹកប្រពន្ធកូនរបស់ខ្ញុំ ដែលនៅឯស្រុកដូចគ្នា តែខ្ញុំមិនអាចត្រួតស្ពានការណ៍ប្រទេសជាតិ និងរដ្ឋាភិបាលបានទេ គឺបានត្រឹមតែទទួលបញ្ជាពីគេប៉ុណ្ណោះ ។ អូហ៍... កុំនិយាយប្រាប់នរណាថាខ្ញុំនិយាយយ៉ាងនេះ

CHANBOKEO.COM

ព្រោះខ្ញុំអាច ទទួលទោសបាន ។ ពេលនេះ ខ្ញុំក៏នាំមនុស្សពីរបីនាក់ទៀត អោយ មកជួបផងដែរ ព្រោះគេទទូចសុំថាមកជួបលោកទីនេះ ។

បុរសបីនាក់ចេញពីក្នុងឡានមកស្រុំស្រ ។ នោះគឺតាខេម ពូបូរ និងនាយសល់ ។ លោកងោហានក៏ស្រដីបន្តថា ៖

- មេបញ្ជាការកងធំបានអនុញ្ញាត្តអោយបើកចរាចរផ្លូវ ប្រឋស្ទឹង ត្រើយខាងកើតនេះហើយ ។ ដូច្នេះ បន្តទៅនេះ លោកមិនត្រូវការ កាតអភ័យឯកសិទ្ធិទៀតទេ សំរាប់ធ្វើដំណើរម្តុំនេះ ប៉ុន្តែលោកត្រូវ ប្រើវានៅពេលចេញចូលធ្វើការ នៅក្នុងមន្ទីរពេទ្យធំ ។

លោកងោហានក៏ដើរចេញទៅ ។ មុននឹងចូលរថយន្ត លោក ក៏បែរប្រាប់បន្ថែមថា ៖

- កុំភ្លេចទៅជួយធ្វើការផង ព្រោះនៅពេទ្យ ត្រូវការមនុស្សជួយ ច្រើនណាស់ ។

ថាហើយ លោកងោហានក៏ហក់ឡើងឡានចេញទៅ ។ តាខេម ស្ទុះមកជិតអ្នកគ្រូចរណៃ ៖

- អ្នកគ្រូ! បានធូរស្រាលវិញហើយមែនទេ?

- ចាស! មិនអីទេពូ! ចុះពូសុខសប្បាយទេ?

- ដូចដែលឃើញហ្នឹងឯង អ្នកគ្រូអើយ ។

ពូបូរឈរនៅចំហៀងៗនោះ លួចមើលអ្នកគ្រូ និងលោកគ្រូ ពេទ្យភ្លៀកៗ រួចហើយលួចជ្រួញចិញ្ចើម ។ ឃើញដូច្នោះ អ្នកគ្រូក៏ មានប្រសាសន៍ភ្លាម ៖

- បូរ! បងណៃមិនស្រួលខ្លួនពីរថ្ងៃនេះទើបមិនបានត្រឡប់ទៅទូក វិញ ។ បងសូមទោសណាដែលធ្វើអោយប្អូនបារម្ភ ។

ពូបូរញញឹមស្ងួត មិនស្រដីតបអ្វីទេ ។

- សល់! បានគ្រាន់បើហើយហ្ស៎ កូន? (អ្នកគ្រូសួរ)

- បាទ ស្រួលបន្តិចហើយ តែបាត់មីងពីរថ្ងៃ សល់នឹកមីងណាស់!

- អឺ! មីងក៏នឹកឯងដែរ ។ ម៉ោះចូលមកក្នុងសំរាកសិនទៅកូន ។

តាខេមក៏មកជួយដើរទប់នាយសល់ចូលទៅក្នុងផ្ទះ ។ អ្នកគ្រូក៏ បែរមកណែនាំលោកគ្រូពេទ្យ ៖

- បូរ! នេះបងចិត្រ ប្តីរបស់បង!

ពូបូរបើកភ្នែកគ្រលួង កាត់ស្មានជាមុនថាដូច្នោះ តាំងពីពេល គាត់មកដល់ភ្លាមម្ល៉េះ ព្រោះឃើញលោកគ្រូពេទ្យចេញមុខការពារ ភរិយាគាត់ មិនខុសពីមេមាន់ការពារកូននោះឡើយ ។

CHANBOKEO.COM

ពូបូរលួច នឹកខកចិត្តបន្តិចដែរ ត្បិតនៅក្នុងជំរៅចិត្ត គាត់បានលួចសម្លឹងមីង ណៃ
លួចគិតប៉ងសង្ឃឹមតិចៗខ្លះទៅហើយ... ថៃដន្យ មីងណៃ
មិនមែនជាមនុស្សទំនេរដូចគាត់គិតផ្សេងនោះឡើយ ។ ពូបូរដក
ដង្ហើមមួយយូបន្ទរទ្រូងចោលមួយសិន ទើបស្រដីតបថា ៖
- អោយប្អូនជួយត្រេកអរបងទាំងពីរផង ដែលបានជួបគ្នាវិញ ។
សង្ឃឹមថាប្អូនក៏នឹងមានរាសីល្អដូចបងដែរ ។

លោកគ្រូពេទ្យយកដៃទះស្មាពូបូរ ដោយទឹកចិត្តរាប់អាន ៖
- បងអរគុណប្អូនណាស់ ដែលជួយថែរក្សាប្រពន្ធនិងចៅរបស់បង បានយ៉ាងល្អ ។ អរគុណណាស់
ចំពោះទឹកចិត្តដ៏ល្អនេះ ថ្វីបើពួកខ្មែរ
ក្រហមខំបំពាក់បំប៉នលទ្ធិពួកគេអោយខ្មែរយើងលែងចេះស្រឡាញ់ គ្នា
លែងចេះមានសមានចិត្តចំពោះគ្នាក៏ដោយ ក៏ប្អូនមានចិត្តរឹងប៉ឹង ក្លាហាន មិនទទួលយកលទ្ធិនេះ
ហើយបានបញ្ជាក់បង្ហាញ ដោយ កិរិយានិងការប្រព្រឹត្តថា
ធាតុពិតប្រាកដរបស់ខ្មែរគឺការសាងអំពើល្អ ចំពោះមនុស្សជាតិដូចគ្នា ។ ដូច្នេះ បងសង្ឃឹមថា
ពលរដ្ឋខ្មែរទាំង ឡាយនឹងមានចិត្ត មានស្មារតី មានឧត្តមគតិរឹងប៉ឹងដូចប្អូនគ្រប់ៗ គ្នា
គឺមិនព្រមទទួលយកលទ្ធិខ្មែរក្រហម ហើយមកបំផ្លាញខ្មែរគ្នា
ឯងអោយបរទេសឆ្លៀតឱកាសពីលើយើងបានឡើយ ។

ពូបូរញញឹម លួចនឹកសរសើរលោកគ្រូពេទ្យក្នុងចិត្ត ៖
- មើលទៅគាត់ សាមញ្ញៗសោះ តែមានគំនិតជ្រៅជ្រះណាស់តើ!
អញ្ចឹងតើទើបអាចទប់ប្រាជ្ញបងណៃបាន ។

បន្តិចមក គេទាំងអស់ក៏ដើរចូលទៅក្នុងផ្ទះ ស្រាប់តែបាត់បារមី
ទៅណាមិនដឹងឃើញតែនាងមុំនៅលេងជាមួយនាយសល់ ។ តា ខេមភ្ញាក់ព្រើតខំជួយដើររក
ក៏ឃើញនាងពួននៅក្នុងបន្ទប់លោក គ្រូពេទ្យ ។ តាខេមក៏ហៅនាំបារមីចុះមកក្រោម ។
អ្នកគ្រូចរណៃក៏ មានប្រសាសន៍ថា ៖
- មុំ ! មកខាងនេះមកកូន! ម៉ាក់ប៉ាមានរឿងពិគ្រោះគ្នាបន្តិច!

បារមីដើរឱនៗទៅអង្គុយជិតម្តាយ តែមិនហ៊ានងើបមុខមើល នរណាទេ
ជាពិសេសគឺនាយសល់តែម្តង ។ ចំណែកនាយសល់វិញ កាលបើឃើញមុខនារី
ភ្លាមក៏ខំញញឹមដាក់ តែបែរជាខកព្រោះនាង មិនបានញញឹមតបវិញទេ

CHAUBOKEO.COM

តែបែរជាធ្វើទឹកមុខស្ងួតយ៉ាងចម្លែក ។ គេក៏ជ្រួញចិញ្ចើមឡើងនឹកឆ្ងល់ក្នុងចិត្តមិនស្ដី ។ ភ្លាមនោះ
អ្នកគ្រូក៏
សួរនាយសល់ថា ៖
- សល់ ! យើងស្គាល់គ្នាជាញាតិយូរហើយ តែយើងមិនដែលមាន
ឱកាសបានសាកសួរប្រវត្តិផ្ទាល់ទេ ។ ពេលនេះ ក្រុមគ្រួសារមីង បានជួបគ្នាខ្លះមកវិញ
ថ្វីបើនៅបាត់សមាជិកខ្លះក៏ដោយ ។ ប៉ុន្តែ ចំពោះសល់ មីងមិនដែលគិតថាកូនជាអ្នកដទៃទេ ។
មីងគិតកូន ដូចជាកូនចៅម្នាក់ដែរ ។ អ្វីដែលមីងមិនទាន់ច្បាស់នោះគឺជីវប្រវត្តិ របស់កូន ។
ការពិត ដែលកូនសួរថា មីងធ្លាប់ធ្វើគ្រូនៅវិទ្យាល័យ នេតយ៉ង់នោះ
គឺមីងធ្លាប់ធ្វើការនៅទីនោះមែន កាលពីសម័យមុន ខ្មែរក្រហមចូលស្រុក ។ ពេលនេះ
មីងក៏ចង់ដឹង ពីក្រុមគ្រួសារ របស់កូនដែរ ។ តើអាចប្រាប់មីងបានទេ ?

នាយសល់ញញឹមហើយឆ្លើយថា ៖

- ខ្ញុំបន់អោយមីងសួរខ្ញុំយូរណាស់ហើយ ។ លាក់រឿងទុកនៅក្នុង ចិត្តច្រើន វាចង្អៀតទ្រូងណាស់
ជួនកាលធ្វើអោយខ្ញុំគេងមិនលក់ ទៀតផង ។ ការពិត ឪពុកម្ដាយខ្ញុំជាអ្នកវាលទ្រា
រកស៊ីធ្វើស្រែធ្វើ ចំការ ។ ពុកឈ្មោះណាត ម្ដាយឈ្មោះថន ឯជិតភ្នែក...
- ពុទ្ធោ !

អ្នកគ្រូចរណៃនិងលោកគ្រូពេទ្យ ឧទានឡើងដំណាលគ្នាតែម្ដង កាលបើឮដូច្នោះ ។
នាយសល់នឹកឆ្ងល់ក៏សួរថា ៖

- មីងពូស្គាល់ពុកម៉ែរបស់ខ្ញុំឬ បានជាលាន់មាត់ភ្ញាក់ផ្អើលដូច្នេះ ?
- មែនហើយ (អ្នកគ្រូងក់ក្បាល) គាត់ទាំងពីរជាអ្នកមានគុណ
របស់មីងដែលផ្ដល់ជំរកអោយយើងស្នាក់នៅ កាលសម័យរបបខ្មែរ ក្រហមនោះអី ។
ហើយចុះឯងមានបងប្អូនដែរទេ ?
- បាទមានពីរនាក់ ! បងប្រុសឈ្មោះកោសិន្យ អាយុប្រហែល២៣ ឆ្នាំហើយ ។ កាលនោះ
គាត់ប្រឡងបាក់អងធ្លាក់ ក៏រត់ចូលព្រៃធ្វើ ខ្មែរក្រហមទៅ ។ ចំណែកខ្ញុំវិញ ឈ្មោះពិតគឺ កោសល្យ
រស់នៅ វត្តដំរីស នៅរៀនតែម្នាក់ឯង រហូតដល់ស្រុកធ្លាក់ចូលជំនាន់ពួក អាវខ្មៅនោះទៅ
មិនដែលមានឱកាសបានទៅជួបពុកម៉ែនៅឡើយ ទេ តាំងពីឆ្នាំ១៩៧៤មកម្ល៉េះ ។

ភ្លាមនោះ អ្នកគ្រូស្រក់ទឹកភ្នែកច្រោកតែម្ដង ៖

- ពុទ្ធោ កូនសល់អើយ !

CHANBOKEO.COM

ថាហើយ គាត់ក៏ស្រវាអោបនាយសល់ដែលធ្វើមុខមិងមាំងមិន យល់ហេតុការណ៍ ។ បន្តិចមក អ្នកគ្រូក៏យកដៃជូតទឹកភ្នែករួចទើប មានប្រសាសន៍បន្តថា ៖

- បងណាតនិងបងថនបានអនិច្ចកម្មទៅហើយ ហើយមីងនេះឯង ជាអ្នកដែលបានបញ្ចុះសពគាត់ដោយផ្ទាល់ដៃ ។

គ្រាន់តែឮដូច្នោះ នាយសល់មុខស្លេកតែម្តង ។ គេនៅអង្គុយ សំកុកយ៉ាងយូរ ទំរាំដាច់ចិត្តនិយាយចេញមក ៖

- ខ្ញុំក៏ធ្លាប់គិតទុកជាមុនហើយដែរថា ប្រហែលជាគាត់មិនអាចឆ្លង ផុតសង្គមខ្មៅងងឹតនោះបានទេ...

អ្នកគ្រូយកដៃបបោសខ្នងនាយសល់ដោយក្តីអាណិតអាសូរ ៖

- បើកូនមិនយល់ទាស់ទេ មីងក៏មិនកំណាញ់នឹងទទួលកូនជាកូន មីងទេ ព្រោះមីងស្រឡាញ់កូន ឃើញកូនមានគំនិតមារយាទល្អ ហើយជាពិសេសនោះ គឺកូនមានជាមនុស្សមានទឹកចិត្តបំផុត ។ មីង វិញគ្រាន់តែចង់សុំឱកាស បានសម្តែងនូវទឹកចិត្តជាការសងគុណ កូននិងឪពុកម្តាយរបស់កូនតែប៉ុណ្ណោះ ។

នាយសល់ងើបមុខឡើង សម្លឹងអ្នកគ្រូនិងស្វាមីមួយស្របក់ ក៏ ញញឹមឡើងហើយស្រដីថា ៖

- ខ្ញុំក៏មានបំណងចង់សុំមីងជាម្តាយយូរហើយ តែខ្ញុំមិនហ៊ាន ព្រោះ ខ្ញុំនឹកខ្មាស ខ្លាចមីងចំអន់អោយថា ខ្ញុំធំហើយមិនព្រមប្រព្រឹត្តខ្លួន ជាមនុស្សធំ... ការពិត ខ្ញុំខ្វះសេចក្តីកក់ក្តៅពីឪពុកម្តាយយូរហើយ ជួនកាលនឹកដល់រង្វង់ដៃដ៏កក់ក្តៅ និងពាក្យលើកទឹកចិត្តរបស់គាត់ ណាស់ តែខ្ញុំមិនដឹងធ្វើដូចម្តេច ក៏ចេះតែបៀមសេចក្តីទុក្ខក្នុងចិត្ត ម្នាក់ឯងតែអញ្ចឹងទៅ ។

- អញ្ចឹង មកណេះមក៍ អោយម្តាយសុំអោបបន្តិច នោះកូននឹងបាន ទទួលការកក់ក្តៅក្នុងចិត្តដូចកូនចង់បានហើយ ។

នាយសល់ឮហើយ ក៏ស្ទុះទៅលំទោនកាយទទួលយកនូវរង្វង់ ដៃដ៏កក់ក្តៅពីអ្នកគ្រូភ្លាម ។ អ្នកគ្រូក៏មានប្រសាសន៍បន្ត៖

- មនុស្សយើងណា៎! មិនថាវ័យណាទេ តែងតែត្រូវការសេចក្តីកក់ ក្តៅក្នុងចិត្ត ពីរង្វង់គ្រួសារជានិច្ច ។ តែបើខ្វះភាពកក់ក្តៅហើយ មនុស្សយើងតែងតែបាក់កម្លាំងចិត្ត អស់សេចក្តីក្លាហាននឹងតស៊ូពុះ ពារឧបសគ្គក្នុងជីវិតតទៅទៀត ។

CHANBOKEO.COM

ពេលនេះគ្រួសារម៉ាក់បានទទួល ភាពកក់ក្ដៅវិញហើយ ដូច្នេះ ម៉ាក់ក៏ចង់អោយកូនបានទទួលភាពកក់ក្ដៅនោះព្រមគ្នាជាមួយក្រុមគ្រួសាររបស់ប៉ាម៉ាក់ដែរ ។

លោកគ្រូពេទ្យក៏មានប្រសាសន៍បន្ថែមទៀតថា ៖

- គេថា ស្គាល់គ្នានៅគ្រាក្រ នោះទើបដឹងថា នរណាជាមិត្តដ៏ល្អ របស់យើងពិតប្រាកដ ។ រីឯល្បងណាតនិងប្រពន្ធគាត់ ពិតមែនតែ ក្រីក្រ
តែទឹកចិត្តរបស់គាត់ថ្លៃថ្លាទូលំទូលាយរកគ្មានទេ ។ បើកុំ តែបានល្បងណាតនិងបងស្រី
ម៉្លេះសមក្រុមគ្រួសាររបស់ប៉ារងទុក្ខ វេទនាប៉ុនណាទេ នាគ្រាមួយនោះ ។
ថ្វីបើល្បងបានចែកឋានទៅ មែន តែអំពើល្អរបស់គាត់បានរស់នៅរវើកក្នុងចិត្តរបស់ពួកយើងគ្រប់គ្នា... ហើយប៉ាក៏សប្បាយចិត្ត ព្រោះប៉ាមានឱកាសបានសង គុណគាត់វិញ
ដោយការផ្គត់ផ្គង់រូបកូនអោយមានជីវិតកក់ក្ដៅ គ្មាន មន្ទិលនិងការទើសទាល់ចិត្តឡើយ ។

នាយសល់ញញឹមទទួលយកនូវរង្វង់ដៃដ៏កក់ក្ដៅរបស់លោកគ្រូពេទ្យនិងភរិយាសាជាថ្មីម្ដងទៀត ។

- លោកប៉ា! ម៉ាក់! (នាយសល់ពោលហៅលោកទាំងពីរ)

- កូនសល់!

ទាំងអស់គ្នាដែលនៅអង្គុយតម្កង់ទីនោះក៏បានចូលរួមការទទួលសមាជិករបស់ក្រុមគ្រួសាររបស់លោកគ្រូពេទ្យយ៉ាងរីករាយបំផុត ។ លុះឃើញពូបូរនៅស្ងាត់ស្ងៀម អ្នកគ្រូក៏មានប្រសាសន៍ថា ៖

- បូរ! បងមិនដែលមានប្អូនប្រុសទេ បើសិនជាបងមានប្អូនម្នាក់ ដែលល្អស្មើៗនឹងរូបប្អូន ប្រហែលជាបងមានមោទនភាពបំផុត ។

ស្រាប់តែពូបូរញញឹមឡើងយ៉ាងស្រស់ថ្លាតែម្ដង ៖

- អញ្ចឹង បងទទួលយកបូរម្នាក់ទៀតបានទេ?

លោកគ្រូពេទ្យនិងភរិយាសម្លឹងមុខគ្នាហើយងក់ក្បាល ៖

- បងទាំងពីរមិនដែលនិយាយពាក្យថា ទេ ម្ដងណាឡើយ ចំពោះ ញាតិសន្ដានដ៏ល្អដូចបូរនេះ (លោកគ្រូពេទ្យយកដៃទះស្មាពូបូរ) ហោចណាស់យើងមានគ្នាជួយអូសឈ្នាងក្នុងស្ទឹងយកត្រីមិនសូវ នឿយធ្វើតែម្នាក់ឯងដូចមុនទៀតផង ។

ពូបូរក៏សើចគ្រហាញឡើង ៖

- រាងស្គមៗដូចល្បង អូសឈ្មោងរួចដែរ ? មើលតែខ្ញុំចុះ សាច់ដុំ ប៉ុនៗហ្នឹងហើយ នៅធ្វើមិនទាន់សមផង...

- ដំបូងៗ ប្រហែលឆ្គងបន្តិច តែយូរទៅគង់តែឡើងសាច់ដុំទេ ជាពិសេសបើមានប្រពន្ធធ្វើអាហារឆ្ងាញ់ៗប៉ូវកម្លាំង បងហ៊ានធានាថា មិនអោយចាញ់ប្អូនឯងឡើយ ព្រោះកាលពីក្មេង បងក៏ជាអ្នកកីឡា មួយរូបយ៉ាងចំណាននៃរណា៎!

ទាំងអស់គ្នាក៏សើចឡើងយ៉ាងរីករាយ ។ បរិយាកាសគ្រួសារក៏ ប្រែធូរស្រាលមកវិញ ។ បន្តិចមក អ្នកគ្រូក៏ណែនាំកូនចៅ ៖

- សល់! នេះ បារមី កូនស្រីរបស់ម៉ាក់ ត្រូវជាប្អូនរបស់កូនដែរ ។

នាយសល់ញញឹមដាក់នាងភ្លាម តែផិតានៅសំដែងកិរិយាហាក់ដូចជានៅខ្លាចៗនាយនៅឡើយ ។ អ្នកគ្រូក៏និយាយរឿងសង្ខេបឲ្យ នាយសល់ស្តាប់ ដើម្បីអោយគេបានយល់ថា ហេតុអ្វី បារមីបាក់ ស្បាតស្មារតីពេលឃើញនាយសល់ម្តងៗ ។ លុះយល់ស្ថានការណ៍ នាយសល់គេនៅធ្វើញញឹមមិនសូវហ៊ានស្រដីអ្វីទេ ដើម្បីកុំអោយរំខានចិត្តប្អូនស្រីថ្មីរបស់គេ ។

ស្អែកឡើង...

លោកគ្រូពេទ្យធាក់កង់ទៅធ្វើការដូចធម្មតា ។ អ្នកគ្រូចរណៃ ចេញទៅជាមួយតាខេម ទៅជួបអ្នកស្រុកដែលបានជួយសង្គ្រោះ អ្នកគ្រូកាលពីម្សិល ។ ចំណែកពូប្លូក៏ចេញទៅរកត្រីដូចទម្លាប់វិញ ដែរ ទុកអោយនាយសល់ចាំផ្ទះព្រោះគិតថា នរៈមិនទាន់មានកម្លាំង ស្រួលបួលនៅឡើយ ។ នាយសល់ក្រោកពីដំណេក ឃើញបារមីរែក ទឹកស្ទឹងចាក់ពាងទាំងតតេះតតះ ក៏ស្ទុះទៅរកជួយ ៖

- ទុកឲ្យបងជួយធ្វើវិញណា៎ម៉ី! ប្អូនទៅដាំបាយទុកជូនម៉ាក់ប៉ាទៅ!

បារមីមើលមុខនាយសល់ហើយដើរគេចទៅម្ខាង តែនាយមិន សុខចិត្តទេ ក៏ដើរតាមពីក្រោយហើយស្រដីបន្តថា ៖

- ខ្លាចបងធ្វើអី ម៉ី ? បងជាមនុស្សផ្សេងគ្នាពីមិត្តស៊ិននោះតើហ៎!

បារមីបែរភ្លែតនិយាយថា ៖

- គឺ... ខ្លាចកាត់រកគ្នានោះអី ព្រោះអីមិត្តស៊ិននោះជាមនុស្សអាក្រក់ ណាស់! មុខដូចគ្នាយ៉ាងនេះ ច្បាស់ជាចិត្តក៏ដូចគ្នាដែរហើយ...

ស្រាប់តែ កោសល្យសើចកខឹកឡើង ៖

CHANBOKEO.COM

- មិនកាត់រកទេ ព្រោះឈើពីរមែកនោះ បានញែកផ្លូវចេញពីគល់ របស់គេ តាំងពីយូរហើយ សល់គឺសល់ ស៊ិនគឺស៊ិន ។
- ចុះនរណាទៅដឹង ? បងប្អូននឹងគ្នា តែងតែកាត់រកគ្នាហើយ ។
- អូហ៍ ក្រែងម៉ីនិងបងជាបងប្អូននឹងគ្នាហើយតើហ៍ មិនមែនទេ ? អញ្ចឹង យើងដូចគ្នាហើយ គឺយើងស្រឡាញ់ម៉ាក់ប៉ា ហើយស្រឡាញ់ បងប្អូន... មិនមែនស្អប់ដើរគេចមុខចេញពីគ្នាដូច្នេះទេ ។
- នែ៎! កុំចេះ! ម៉ីមិនធ្វើបងប្អូនជាមួយនរណាឡើយ ។
- យី! ម៉ី សំដីជាណាស់តើហ៍ ថៃដន្យ ចិត្តម៉ី មិនក្លាហានសោះ!
- នរណាថា ម៉ីចិត្តមិនក្លាហាន ?
- គឺបងសល់ថានេះអី!
- និយាយតែផ្តាស!
- ចុះបើវាមែន! ម៉ីជាមនុស្សមិនក្លាហាន... បានឡូយតែមាត់!
- នែ៎! ម៉ីមិនដែលខ្លាចនរណាទេ! កុំចេះតែថា!
- គឺមែនណា៎ ប្អូនម៉ីខ្លាចបងសល់! ម៉ីអន់ណាស់!
- មិនខ្លាច! មិនខ្លាចទេ! កុំចេះតែថា !
- មែនហើយ ម៉ីខ្លាចបងសល់ ម៉ីមិនក្លាហាន...
- មិនខ្លាចទេ កុំចេះ! ហ៊ានថាទៀត ម៉ីជះទឹកអោយទទឹកឥឡូវ..

តែនាយសល់មិនព្រមឈប់ទេ នៅតែលលេងប្អូនស្រីមិនឈប់ សោះ ។ ទ្រាំមិនបានបារមីស្រវាផ្តិល ដងទឹកជះលើនាយសល់ រត់ អោយវិរ ឯខាងក្រោយផ្ទះ ស្រាប់តែនាយសល់ដួលព្រួស ប្រឡាក់ ដីស្រមក ធ្វើអោយនាងតូចមុំសើចកក្អៀក ទះដៃហ៊ោរយ៉ាងសែន សប្បាយ ។ ទាំងអស់គ្នាក៏អស់សំណើចសើចតាមនាងតូចដែរ ។ ពេលនោះ បារមីមានអារម្មណ៍ថា នាយសល់ពិតជាមនុស្សផ្សេងគ្នា ពីមនុស្សម្នាក់ទៀតដែលនាងបានស្គាល់ពីមុនមក ព្រោះគេរួសរាយ មានទឹកចិត្តទូលាយណាស់ គិតល្អ និយាយល្អ ជាពិសេសទៀតនោះ គឺគេរាប់រកនាងដូចជាប្អូនស្រីរបស់គេម្នាក់ គ្មានក្នុងគ្មានក្រៅគួរឲ្យ សង្ស័យ ។ រីឯចំណងតឹងតែងផ្លូវចិត្តរបស់បារមីចំពោះកោសល្យ ក៏បានធូរស្រាលមកវិញជាលំដាប់ ។

ពីរបីថ្ងៃក្រោយមក...

បារមីឃើញឪពុកម្តាយរៀបចំខ្លួន ហាក់ដូចជាបំរុងចេញដំណើរ

CHANBOKEO.COM

ទៅណា ក៏សួរថា ៖
- ម៉ាក់ប៉ាអញ្ជើញទៅណាហ្នឹង ?
- គឺប៉ាម៉ាក់គិតថាជិះកង់ទៅវាលទ្រា ក្រែងលោអាចទៅបាន ។ បើ សិនទៅរួច ម៉ាក់ចង់ទៅស៊ើបសួរដំណឹងកូនត្រា កូនសាល ស្រីម៉ៅ និងប៊ុរី ។
រួចហើយ អ្នកគ្រូក៏ងាកមកផ្តាំតាខេម ៖
- ជួយមើលក្មេងៗផង ពូ! ល្ងាចខ្ញុំមកវិញហើយ ។
រួចអ្នកគ្រូក៏ងាកមកផ្តាំនាយសល់ដែលនៅឈរក្បែរនោះ ៖
- ពេលប៉ាម៉ាក់រកកន្លែងឃើញហើយ ចាំយើងនាំកូនទៅធ្វើបុណ្យ ជូនពុកម៉ែនៅទីនោះណាំសល់ ។
- បាទ ម៉ាក់! (នាយសល់ឈរលើកដៃវាពីចម្ងាយ)
អ្នកគ្រូក៏ឡើងទំពីក្រោយកង់ អោយលោកគ្រូពេទ្យឌុបចេញ ទៅ ។ តាមផ្លូវ មានទាហានចាប់លោកគ្រូពេទ្យនិងភរិយាឆែកសួរ ជាច្រើនដងតែគេមិនថាអ្វីទេ ចេះតែបើកផ្លូវអោយទៅតែរហូតដល់ ក្បាលស្ពានអូរតាគី ស្រាប់តែលោកប្រទះឃើញមានប៉ុស្តិ៍ឆែកឆេរ ធំមួយមានដងរនាំងដាក់បាំងផ្លូវហើយមានទាហានវៀតណាមកុះករ ព្រមជាមួយអ្នកស្រុកដែលនៅរវ៉េឈរមើលរហង់ ។ អ្នកគ្រូកេះ លោកគ្រូពេទ្យសួរ ៖
- មានការអ្វីមិនស្រួលទេដឹង បង ? កុំទៅជិតពេក ប្រយត្ន័គ្រោះ ថ្នាក់! យើងឈរនៅឆ្ងាយៗ ឯនេះបានហើយ ។
លោកគ្រូឈប់កង់ចុះដឹកដើរទៅជិត ឃើញសាកសពអ្នកស្រុក ដេកស្លាប់លើដីរប៉ាត់រប៉ាយនៅលើស្ពាន ។ លោកគ្រូក៏កេះសួរអ្នក ស្រុកដែលឈរមើលម្តុំនោះ ៖
- មានរឿងអ្វីហ្នឹង ក្មួយ ?
- បាទ! ទាហានវៀតណាមហាមមិនអោយអ្នកស្រុកឆ្លងស្ពាន ទៅ ត្រើយម្ខាងទេ តែអ្នកស្រុកនោះចេះតែទទូច សំអាងថាទៅរកបង ប្អូននៅខាងមុខ ។ ខ្លះចេះតែត្បុលមុជក្រោមដងឬស្សីរនាំងបាំងផ្លូវ នោះទើបត្រូវទាហានបាញ់សម្លាប់ទៅ ។ ពួកទាហានថា នៅម្ខាង ទៀតមានខ្មែរក្រហមច្រើនមិនទាន់សំអាតអស់ ទើបមិនឲ្យអ្នកស្រុក ដើររកេតរកូតទៅជ្រៀតជ្រែកការបោសសំអាតរបស់គេ ។
ស្រាប់តែម្នាក់ទៀតនិយាយកាត់ថា ៖

CHANBOKEO . COM

- មិនមែនទេ! គឺពួកទាហានមិនចង់អោយពួកយើងចេញទៅរត់ពន្ធដឹកនាំឥវ៉ាន់ពីថៃចូលស្រុកខ្មែរ ។

ពេលនោះ អ្នកស្រុកទីបីបែរជានិយាយថា ៖

- ខុសហើយ! ការពិត គេការពារមិនអោយខ្មែររត់ភៀសខ្លួនពី ស្រុកទៅទល់ដែនតើហ៎! មើលចុះ ម្ល៉េៗ មនុស្សរត់គេចសង្គ្រាម ចូលដីថៃ យកទៅណាអស់! ឯស្រុកយើងវិញបាត់មនុស្សរលីង ។

អ្នកស្រុកទីបួនក៏ស្រដីបន្ថែមថា ៖

- ទីក៏អ្នកស្រុកមិនរត់ ព្រោះនៅទល់ដែនមានកាកបាទក្រហមដើរ ចែកអង្ករចែកថ្នាំអោយអ្នកស្រុកដែលមានជំងឺ ។ បើនៅក្នុងស្រុក អត់បាយ អត់ថ្នាំសង្កូវយ៉ាងនេះ មិនអោយអ្នកក្រទុរគតរត់គេច ភៀសខ្លួនយ៉ាងម៉េច លោកអើយ...!

អ្នកស្រុកទីប្រាំកាន់តែមានគំនិតប្លែកឆ្ងាយជាងបួននាក់មុន ៖

- អឺ! គេមិនអោយចេញចូល ព្រោះគេខ្លាចខ្មែរក្រហមបង្កប់ខ្លួន ចេញចូលយកការណ៍... យី! ប៉ុនហ្នឹងក៏មិនដឹងដែរឌី!!

លោកគ្រូពេទ្យនិងភរិយាក៏សម្លឹងមុខគ្នា... ទីបំផុតក៏សម្រេច ចិត្តបកក្រោយវិញ ។ លោកបានធ្វើបែបនេះ រៀងរាល់ថ្ងៃដែលបាន ឈប់សំរាកពីជាកិច្ចការនៅពេទ្យ ។ ប៉ុន្តែនៅរៀងរាល់ដង លោក ត្រូវអាក់ដំណើរជានិច្ច មិនដែលបានទៅដល់វាលទ្រាទេ ជួននៅទើរត្រឹមភូមិក្បាលខ្មោច ជួនដល់អូរតាគី តែមិនដែលបានទៅហួស ហ្នឹងសោះ ជិតពីរអាទិត្យមកហើយ ។

ថ្ងៃមួយ...

លោកគ្រូពេទ្យជិះកង់ឌុបប្រពន្ធត្រឡប់ក្រោយ ទៅបាត់ដំបង វិញជិតដល់ភូមិចំការចេកស្រាប់តែមានក្មេងប្រុសម្នាក់ស្រែកហៅ លោក ពីដីចំការដែលមានស្មៅដុះទ្រុបទ្រុលមកថា ៖

- ប៉ា! ម៉ាក់!

លោកគ្រូពេទ្យឈប់កង់ ងាកក្រោយឃើញ ក្មេងប្រុសម្នាក់ សម្បុរស្រអែម ស្គមខ្ពស់ មានកំពស់កំពមិនចាញ់លោកគ្រូពេទ្យទេ ឯខោអាវដាចរយ៉ៃមើលមិនយល់ កំពុងតែដើរដឹកគោញីចាស់មួយ សំដៅមកលោកយ៉ាងលឿន ។

- ត្រា ? (លោកគ្រូពេទ្យលាន់មាត់ហៅ)

- បាទ ប៉ា! នេះ កូនសាល មិនមែនបងត្រាទេ!

CHANBOKEO.COM

- កូនសាល ?

អ្នកគ្រូឃើញហើយ រត់យ៉ាងលឿនស្ទេវទៅរកកូន ស្រវាអោប ផង ថើបផង ដោយក្ដីនឹករលឹក ។ លោកគ្រូពេទ្យក៏អង្អែលក្បាល កូនប្រុសធ្វើទឹកភ្នែករលីងរលោង ហើយសម្លឹងកូនមិនដាក់ភ្នែក ដែលឃើញគេផ្លាស់ប្ដូរពីក្មេងតូចទៅជាយុវជនជំទង់ខ្ពស់ស្រឡះ...

- ប៉ាត្រេកអរណាស់កូនដែលកូនរបស់ប៉ានៅមានជីវិត!

វិសាលយកដៃជូតទឹកភ្នែក ហើយលើកដៃសំពះឪពុកម្ដាយ ៖

- កូនក៏រំភើបចិត្តណាស់ដែរ ដែលលកូនបានជួបម៉ាក់ប៉ាវិញ ។ ចុះបងត្រា បងម៉ី បងម៉ៅ បងវៃនោះ យ៉ាងម៉េចហើយ ?

ឮសំនួរនោះភ្លាម លោកទាំងពីរក៏យល់ភ្លាមថា វិសាលមិនបាន ជួបគេទាំងនោះឡើយ ។

- បងម៉ីនៅចាំឯផ្ទះ តែបងៗដទៃ មិនទាន់មកដល់ផ្ទះវិញទេកូន! ប៉ាម៉ាក់គិតថាគេកំពុងតែរកផ្លូវធ្វើដំណើរត្រឡប់មកផ្ទះហើយ ។

អ្នកគ្រូស្រដីទាំងរលីងរលោងទឹកភ្នែក ។ បន្តិចមក ទាំងអស់ គ្នាក៏ដើរត្រឡប់ទៅបាត់ដំបងវិញ ដោយមានទាំងគោញីចាស់មួយ ជូនដំណើរផង ។ តាមផ្លូវ អ្នកគ្រូដើរកាន់ដៃកូនមិនរបេះដោយការ នឹករលឹកកូនព្រោះបែកគ្នាជិតបួនឆ្នាំមិនដែលឃើញមុខម្ដងណា...

តាមផ្លូវ លោកសំណេះសំណាលសួរ អំពីជីវិតបួនឆ្នាំកន្លងមក របស់កូន... ការវិលត្រឡប់របស់វិសាលដោយសុខសប្បាយ បានធ្វើ អោយលោកគ្រូពេទ្យនិងភរិយាចាប់ផ្ដើមមានកម្លាំងចិត្ត និងមាន សេចក្ដីសង្ឃឹមមកវិញជាខ្លាំងថា ថ្ងៃណាមួយ សាច់ញាតិដែលបាន បាត់ខ្លួនទៅដោយឥតដំណឹងនោះ ប្រហែលជាអាចមានឱកាសវិល ត្រឡប់មករកក្រុមគ្រួសារវិញ ជាក់ជាមិនខាន ជាពិសេសពេលណា ដែលស្រុកទេសសាន្តបានត្រាណស្រួលបួលឡើងវិញ ។

នៅក្នុងបន្ទប់ដំណេករបស់លោកគ្រូពេទ្យ...

អ្នកគ្រូចរណៃកំពុងអង្គុយច្របាច់ដៃច្របាច់ជើងជូនស្វាមី ដែល កំពុងសម្រាន្តសណ្ដូកជើង ក្រោយពីធ្វើការនឿយហត់មួយថ្ងៃកន្លង មក ស្រាប់តែឃើញកូនចៅទាំងអស់គ្នាព្រមទាំងតាខេម នាយសល់ កាដេន និងពូបូរ ដើរមកដល់មាត់ទ្វារញញឹមយ៉ាងស្រស់តែម្ដង ។ លោកគ្រូពេទ្យឃើញអ្នកទាំងអស់ភ្លាម ក៏ក្រោកអង្គុយរួចសួរថា ៖

- ទាំងអស់គ្នាមានការអ្វីហ្នឹង ?

CHANBOKEO.COM

ភ្លាមនោះ បារមីនិងវិសាលកាន់ផ្កាចំប៉ាមួយផ្ដិល ដើរចូលមក ដល់ ថែមទាំងស្រដីថា ៖

- ពួកយើងឃើញដើមផ្កាចំប៉ាមុខផ្ទះរបស់យើងបានលាស់ផ្កាសាជា ថ្មី ហើយគិតថា លោកប៉ានិងម៉ាក់ជាគូស្រករដ៏កក់ក្ដៅបំផុតនៅលើ លោកនេះ ទើបពួកយើងបេះផ្កាមកជូនពរ សូមឲ្យលោកប៉ានិងម៉ាក់ មានសេចក្ដីសុខបរិបូរណ៍ពីថ្ងៃនេះរហូតតទៅ ។

គេក៏នាំគ្នាលុតជង្គង់ជូនផ្ដិលផ្កាជូនប៉ាម៉ាក់របស់គេភ្លាម រួចក៏ នាំគ្នាថ្វាយបង្គំរូបលោកក្បាលដល់កម្រាលតែម្ដង ។

- ព្រះអើយ! កូនសម្លាញ់ម្ដាយ! ម៉ាក់អរគុណណាស់ ចំពោះការ ដែលកូនបានមកជួយលើកទឹកចិត្តប៉ាម៉ាក់ យ៉ាងខ្ពង់ខ្ពស់បែបនេះ! សូមអោយកូនអាយុវែងហើយសុខសប្បាយណា៎កូនណា៎ ។

អ្នកគ្រូនិងស្វាមីញញឹមដាក់កូនចៅ និងសាច់ញាតិទាំងអស់ យ៉ាងត្រកាល ទទួលយកនូវសុភមង្គលមួយ ដែលកំពុងចាប់ផ្ដើម ដុះពន្លកជាថ្មីក្នុងគ្រួសាររបស់លោក ។ គេទាំងអស់គ្នាក៏ទះដៃហ៊ោរ ឡើង ជូនពរលោកគ្រូពេទ្យនិងភរិយាម្នាក់មួយម៉ាត់ រួចក៏នាំគ្នាថយចេញទៅ ។ លោកគ្រូពេទ្យបែរមើលទៅអ្នកគ្រូហើយញញឹម ។

- មានការអ្វីហ្នឹង បងចិត្រ បានជាមើលមុខអូនមិនឈប់ ?
- គឺបងមានអារម្មណ៍ ហាក់ដូចខ្លួនបងនេះ ជាកូនកម្លោះ ដែល ទើបរៀបការចូលផ្សំដំណេករាត្រីទឹកឃ្មុំថ្ងៃដំបូងអញ្ចឹង!
- យី! បានទទួលកម្លាំងចិត្តពីកូនចៅភ្លាម ស្រាប់តែចង់ក្លាយខ្លួន ជាក្មេងកម្លោះភ្លាមតែម្ដង បងចិត្រនេះ!
- គឺមែនណា៎ បងពិតជាមានអារម្មណ៍ដូច្នោះមែន ។

អ្នកគ្រូញញឹម មួយស្របក់មក ក៏លួចបែរមើលទៅលោកគ្រូពេទ្យ ឃើញលោកនៅតែសម្លឹងមុខអ្នកគ្រូញញឹមដដែល ៖

- បង! ថ្ងៃនេះយ៉ាងម៉េចហ្នឹង បានជាសម្លឹងអូនភ្លឹកៗ... ?
- គឺបងចេះតែស្រម័យឃើញទេពធិតាដ៏សោភាមួយអង្គនោះ ចុះពី ស្ថានសួគ៌មកកំដរថ្នាក់ថ្នមបងនោះអី!
- មែនហ្អែស ? ទេពធិតាណាទៅ បង ?

CHANBOKEO.COM

- គឺ... នរណាគេម្នាក់នោះ ដែលមកបំរើនាបងយប់មួយនោះ ដោះខោដោះអាវរបស់បងអស់រលីងពីខ្លួន... បងចង់អោយនាងចុះមក បំរើបងដូច្នោះទៀតរាល់ថ្ងៃតែម្តង មិនអោយខានទេ ។

- អូហ៍...ចុះនរណាគេមានសន្តានចិត្តចំពោះបងម្លឹង ?

- គឺទេពធិតាចរណៃរបស់បងនោះអី  តើមាននរណាទៀត ? ចេះ ធ្វើពើដាក់បងកើតអូនឯងនេះ !

- ម៉េចក៏បងដឹង ? បងបន្លំធ្វើពើជាមមើមមាយមែនទេ ?

- អត់ទេ... គឺបងពុលថ្នាំតើហ៍ ។ អូនណៃដឹងទេ ? យប់នោះ បង នៅអង្គុយរង់ចាំផ្លូវអូន... បងចង់អោយអូនត្រឡប់មកវិញណាស់... ថែមទាំងបានបើកទ្វារចំហរង់ចាំទទួលរូបអូនទៀតផង... តែលុះចាំ យូរទៅ មិនឃើញអូនវិលត្រឡប់មករកបង ទើបបានជាបងតប់ប្រមល់ក្នុងចិត្តនៅមិនសុខ ក៏យកថ្នាំមកលេបបំបាត់ទុក្ខ តែចៃដន្យបងបានលេបលើសកម្លាំងបន្តិច ទើបក្លាយជាពុលមមើមមាយ...

- បើមមើមមាយមែន ម៉េចបងដឹងកើតថាស្រីនោះជាណៃ... ?

- ចឺមិនដឹង បើបងធ្លាប់ថ្នាក់ថ្នមប្រពន្ធបងរាប់ឆ្នាំមកហើយនោះ ? គ្រាន់តែច្រមុះប៉ះថ្ពាល់គឺស្គាល់ភ្លាមតែម្តង ថាជាអូនណៃ ដោយមិន ចាំបាច់បើកភ្នែកមើលទេ ។

- ប៉ុន្តែ... ចុះហេតុអីកាលនោះ  ម៉េចបងបែរជាច្រានអូនចេញថែមទាំងគំហកដេញអូនផងនោះ ?

- ប្រហែលជាបងមមើហើយ ត្បិតកាលនោះបងមមើមមាយឃើញមានគេមករំខានបងនិងប្រពន្ធដែលកំពុងថ្នាក់ថ្នមគ្នា... អូហ៍...មកពី អញ្ចឹងទេដឹង បានជាអូនខឹងងង៉ក់ ហើយរត់ចេញដួលសន្លប់នៅវត្តកណ្តាល ថ្ងៃនោះ ?

ភ្លាមនោះ អ្នកគ្រូធ្វើមុខស្មើ ឈ្ងោកមុខព្រិចភ្នែកយ៉ាងញាប់ទំនងដូចជាបំរុងស្រក់ទឹកភ្នែកអាណិតខ្លួនសាជាថ្មី ។ ឃើញដូច្នោះលោកគ្រូពេទ្យក៏ប្រញាប់ស្រដីលួងលោមភរិយាភ្លាម ៖

- ឈប់តូចចិត្តទៅណៃ ! ពេលនេះអូនដឹងច្បាស់ហើយតើហ៍ ថាប្តី ស្រឡាញ់ណៃណាស់ស្រឡាញ់គ្មានថ្ងៃបំភ្លេចបានទេ ។ ម្តេចអូននៅ ស្រក់ទឹកភ្នែកធ្វើអីទៀត ?

CHANBOKEO.COM

លោកគ្រូពេទ្យក៏អង្អែលកេសាភរិយា បង្ហាញនូវដួងចិត្តស្នេហា
ដែលលោកមានចំពោះអ្នកគ្រូមិនដែលរសាយមួយវេលាណា ស្រាប់
តែអ្នកគ្រូងើបមុខឡើងសួរវិញថា ៖

- បើបងពិតជានៅស្រឡាញ់ណែជាប្រពន្ធមែន ហេតុអ្វីក៏បងលែង
ពាក់ខ្សែកអំបោះក្រហមបន្តោងចែកាច់រូបផ្កាចំប៉ាឈ្មោលនោះតទៅ ទៀត ? ណែចាំបានថា
បងតែងតែពាក់វាជានិច្ច តាំងពីយើងបាន រៀបការនឹងគ្នាមក
ព្រោះវត្ថុនោះជាចំណងភ្ជាប់រវាងយើងទាំងពីរ ជាគូជីវិតនឹងគ្នា ។

លោកគ្រូពេទ្យក៏ញញឹមឡើង យកដៃអង្អែលបន្តោងផ្កាចំប៉ាញី ដែលភរិយាកំពុងពាក់
ហើយឆ្លើយថា ៖

- នរណាថាបងមិនពាក់នោះ ? ផ្កាចំប៉ាមួយគូរបស់យើងមិនអាច បែកគ្នាបានទេ ។
បងបានពាក់ជាប់ខ្លួនរៀងរហូត តាំងពីថ្ងៃយើង រៀបការនឹងគ្នាមក ។ ចៃដន្យ
ខ្សែអំបោះនោះវាចាស់ផុយ ហើយក៏
ដាច់ជ្រុះចេញពីករបស់បង ។ បងក៏រើសយកទុក រង់ចាំអូនវិលមក
វេញអំបោះ បំពាក់អោយបង ម្តងទៀតសាជាថ្មីនោះអី !
- តើខ្សែកនោះដាច់ខ្លួនឯង ឬក៏បងបណ្តាច់វាព្រោះខឹងនឹងអូន ?
- សួរអីអញ្ចឹងទេ ណែ ! បងពិតជាបានដោះទុកមែនណា៎អូន !
- អញ្ចឹង បងលាក់ទុកនៅឯណា ? អូនបានឆែកខោអាវរបស់បង
ដែលអូនយកទៅគក់នៅថ្ងៃនោះហើយ មិនឃើញខ្សែកនោះទេ ។
- នរណាគេទៅទុកនៅជាមួយខោអាវក្រៅខ្លួនអញ្ចឹងនោះ ? ទុក នៅអាវក្រៅ
គេអាចលួចបានណា៎ ។
- អញ្ចឹង បងទុកខ្សែកនោះនៅឯណាទៅ ?
- គឺបងខ្មាស់ទុកក្នុងហោប៉ៅខោខ្លីបងឯណោះ ព្រោះជាកន្លែងផ្ទាល់ ខ្លួន
មិនមាននរណាងាយលួចយកបានស្រួលៗនោះអី ។ មនុស្ស
ស្រីចេះលាក់របស់មានតម្លៃតាមខ្លួនបាន រឿងអីបុរសលាក់ទ្រព្យ សំណព្វតាមខ្លួនខ្លះ
មិនបាននោះ ?

ថាហើយ លោកគ្រូពេទ្យក៏ចាប់ដៃភរិយា អោយលូកយកដោយ ខ្លួនឯង ។

- នេ៎ះ ! ចង់ឃើញ អូនលូកយកចេញមក !

CHANBOKEO.COM

អ្នកគ្រូពេទ្យសម្លឹងមុខស្វាមី រួចពន្លាត់ហោប៉ៅខោខ្លីរបស់លោក ស្រវាបានខ្សែកពិតមែន ថែមទាំងឃើញទៀតផងថាខ្សែនោះចាស់ រេចរិលដាច់ដូចលោកគ្រូពេទ្យមានប្រសាសន៍ប្រាប់ដូច្នោះឯង ។

- ជឿបងហើយនៅ អូនណែ ? មួយជីវិតនេះ បងមិនដែលភូត ណែ សូម្បីតែមួយម៉ាត់ឡើយ ។

អ្នកគ្រូរំភើបចិត្តពេកក៏រលីងរលោងទឹកភ្នែកម្តងទៀត ៖

- អោយអូនសូមទោសផង ដែលបានគិតខុសពីបង...
- មិនអីទេ ណែ! ពេលនេះ យើងយល់ចិត្តគ្នាវិញហើយតើហ៍! ឈប់យំទៀតទៅណាំ ហើយញញឹមដាក់គ្នាវិញ ដូចដែលយើងធ្លាប់ ធ្វើចំពោះគ្នាពីមុនមក... កុំពេលវេលាល្អៗរបស់យើងកន្លងហួសទៅ ដោយមិនបានញញឹមដាក់គ្នា ណាំអូន!

អ្នកគ្រូញញឹមឡើង ហើយលើកដៃស្រវាអោបលោកគ្រូពេទ្យ យ៉ាងណែនពេញរង្វង់ដៃ ៖

- ព្រោះតែបងទន់ភ្លន់ហើយថ្នាក់ថ្នមចិត្តណែយ៉ាងនេះហើយ ទើប ណែមិនដែលភ្លេចបងមួយវេលាណាទេ ។ ណែស្រឡាញ់បងណាស់.. ប្តីសម្លាញ់របស់អូន!

លោកគ្រូពេទ្យក៏លាតរង្វង់ដៃត្រកងភរិយា អង្អែលខ្នងបន្ថើរៗ ថ្នាក់ថ្នមដោយក្តីស្រឡាញ់ រួចហើយក៏មានប្រសាសន៍បន្ថែមថា ៖

- ណែ! បងក៏ស្រឡាញ់អូនដូចគ្នា! យើងស្រឡាញ់គ្នាទៅវិញ ទៅមកតើហ៍ ទើបយើងមានសេចក្តីសុខពេញលក្ខណៈណាំអូន!
- ចាស៎បង! ហើយយើងនឹងស្រឡាញ់គ្នាតរៀងទៅ ។

ទាំងគូក៏ស្រវាត្រកងគ្នាសាជាថ្មីដោយដួងចិត្តរំភើបមានន័យ ។

បន្តិចមក លោកគ្រូពេទ្យយកដៃអង្អែលសក់ភរិយាដែលទើប តែដុះខ្លីៗ រួចមានប្រសាសន៍ថា ៖

- អូនណែឈប់កោរសក់ទៀតទៅ... បងស្រឡាញ់សក់វែងណាស់! ទុកសក់អោយវែងវិញណាំ ព្រោះបងចង់អោយប្រពន្ធរបស់បងនៅ តែស្រស់ស្អាតដូចកាលពីដើមអញ្ចឹង!

ឮវាចានេះ អ្នកគ្រូងើបមុខឡើងញញឹមតែម្តង ៖

- ចាស ឲ្យតែបងចិត្រនៅជួបជុំជាមួយណែរហូត នោះណែមិនកោរ សក់ទៀតទេ ។ ចាំណែទុកសក់វែងជូនបងណាំ!
- បងមិនទៅណាទេ ព្រោះបងស្រឡាញ់ប្រពន្ធបងសឹងអី! ណែ ទុកសក់វិញហើយថែខ្លួនអោយស្រស់ស្អាតដូចពីដើមវិញណាំអូន!

CHANBOKEO.COM

បន្តិចមក លោកក៏ទាញដៃប្រពន្ធអោយទំរេតលើខ្នើយគេង រួច ហើយក៏អោនថើបយ៉ាងញើញក់ខុសធម្មតា ។

- បងចិត្រ កំពុងគិតរឿងអីហ្នឹង ?
- អត់ទេ! គឺបងកំពុងតែពុលពិសមន្តស្នេហ៍របស់អូនណោ...
- ពុទ្ធោ ណែចាស់ហើយ មានពិសមន្តស្នេហ៍អីទៀត ?
- មិនទាន់ចាស់ទេ! អូនកំពុងស្ថិតនៅក្នុងវ័យមាំមួនតើហ៍ ។

ថាហើយ លោកក៏ឈ្ងោកថើបប្រពន្ធម្តងទៀត ។

- បងចិត្រ! ឈប់មើល ប្រយត្ន័កូនគេឃើញ ខ្មាសកូន!
- ខ្មាស់ធ្វើអី ? បងចង់បានកូនមួយទៀត បើអាល័យតែខ្មាស ម៉េចនឹងបានសម្រេច ?
- ថាម៉េចហ្នឹង បងចិត្រ ? បងចង់បានកូនទៀត ?
- មែនណា៎! ឲ្យបងសុំមួយ សុំពីរ សុំបីនាក់ទៀត បានទេណែ ?
- បងចិត្រ! អត់ទេ! ណែចាស់ហើយ...
- ចាស់អី! ទើបតែសែសិបប្រាំតើហ៍... ណែសាច់ចាំដល់ម្លឹង យ៉ាងណាក៏អូនមិនទ្រុឌទ្រោមដែរ ។ ហើយបងក៏ជាគ្រូពេទ្យទៀត! បង សូមសន្យាថា នឹងថែរក្សាសុខភាពប្រពន្ធរបស់បង អោយស្រស់ ត្រកាលជានិច្ច អោយបុរសណាៗក៏ច្រណែននឹងបងចិត្រដែរ ដែលមានប្រពន្ធសាច់ចាំហើយស្រស់ស្អាតរៀងរហូតទៅ ។
- បងចិត្រ ស្រម័យអីវែងឆ្ងាយម្ល៉េះ ?
- បងមិនស្រម័យទេ គឺបងកំពុងនិយាយពិត គឺបងចង់បានកូន ថែមទៀត ព្រោះយើងមានកូនតិចពេក ។ ពេលគ្មានរូបគេនៅក្បែរ បងត្រមង់ត្រមោចណាស់ ។
- ស្អែកៗ យើងរកកូនត្រា កូនម៉ៅ និងប្តីរបស់គេ ឃើញមកវិញ នោះយើងនឹងមានចៅៗជាច្រើន...
- ហើយចៅៗនោះក៏នឹងបានរត់លេងជាមួយកូនតូចៗរបស់យើង..
- បងចិត្រ!និយាយម៉េចអញ្ចឹងទេ...ណែស្តាប់មិនបានសោះ ។
- ម៉េចព្រមឬមិនព្រម ? ឲ្យបងសុំតែពីរនាក់ទៀតក៏បានដែរ...
- មិនទេ...

CHANBOKEO.COM

- ព្រមទៅណា៎អូន ណា៎ ណា៎ ណា៎ ណៃព្រលឹងមាសបង! មើល៍ ឆ្លើយ ចា៎ស
ដាក់បងម៉ាម៉ាត់មើលអូនណៃ៎...

- មិនឆ្លើយទេបើបងចិត្រលៃងបង្ខំអូនអញ្ចឹង ?

- មិនបង្ខំទេ បងសុំត្រង់ៗទេតើហ៎!

- អ៊ូយ! កុំលេងអញ្ចឹងមើស៍ បងចិត្រ... ណៃអត់សុខចិត្តទេ ។ មនុស្សចាស់ស្ទី
មានអារម្មណ៍ស្រើបស្រាលដូចក្មេងកម្លោះ ?

- សុំធ្វើក្មេងម្តងម៉ាយាមមិនបានទេអី ប្រពន្ធសម្លាញ់ ? ណ្ហើយ....
បងសុំត្រឹមតែថ្នាក់ថ្នមអូនបន្តិចណា៎... កុំប្រកែកអីព្រលឹង! មាន កូនឬមិនមាន
ស្នេហ៍ៗគង់តែដឹងស្នាដៃរបស់បងទេ...

- ចា៎ស! ចាស៎! ចាំស្នេហ៍ចាំយើងគិតទៀតចុះណា៎ តែពេលនេះ យប់ហើយ...
បងគួរសំរាន្តយកកម្លាំងទៅធ្វើការស្នេហ៍វិញទៅ ។

- ហើយ អូនឯងកុំលួចគេងលក់មុនបងណា៎! បងមិនចូលចិត្តនៅ ត្រមង់ត្រមោចតែម្នាក់ឯងទេ...
រងាបេះដូងណាស់!

- ពុទ្ធោ! រឿងបែបហ្នឹង នរណាទៅឃាត់បាន ?

សូរសំណើចសុភមង្គលបានលាន់ឮឡើងរអឹក ចេញពីគេហដ្ឋាន
របស់លោកគ្រូពេទ្យសាជាថ្មីម្តងទៀត ក្រោយពីស្ងៀមស្ងាត់បាត់
សម្លេងអស់រយៈបួនឆ្នាំកន្លងមក ។ ភពអន្ធការបានរសាត់ចេញទៅ បន្តិចម្តងៗ
ពីជីវិតរបស់គូគាប់ទាំងទ្វេហា ។ ពេលនេះ លោក កំពុងបោះជំហាន នាំជីវិតគ្រួសារ
ធ្វើដំណើរឆ្ពោះទៅអនាគតមួយ ដែលពោរពេញដោយក្តីសង្ឃឹមសាជាថ្មី ។

សូរគ្រាប់កាំភ្លើងនៅផ្ទុះលាន់ឮជាបន្តៗរៀងរាល់ថ្ងៃ តាមតំបន់
ព្រំប្រទល់ខែត្របាត់ដំបង ខែត្របន្ទាយមានជ័យ និងប្រទេសថៃ ជាសង្គ្រាមរវាងខ្មែរក្រហម
កងទ័ពវៀតណាម និងកងទ័ពសេរីការ រំដោះជាតិ ។
សៀងក្ងងក្លាំងរបស់គ្រាប់កាំភ្លើងធំតូចប្រហារជីវិត ពលរដ្ឋខ្មែរទាំងឡាយ
មិនខុសឡើយពីភាពញាប់ញ័ររន្ធត់នៅក្នុង បេះដូងលោកគ្រូពេទ្យនិងភរិយា
ដែលរង់ចាំដំណឹងស្លាប់រស់របស់ កូនទាំងបីនាក់
មិនដឹងថាពេលនេះគេមានសុខទុក្ខយ៉ាងណាឡើយ...
មានតែថ្ងៃស្នេហ៍ប៉ុណ្ណោះដែលអាចរកចម្លើយជូនលោកទាំងពីរបាន...

CHANBOKEO.COM

ប៉ុន្តែ... បើសិនជានៅមានថ្ងៃស្អែក... លោកគ្រូពេទ្យនិងភរិយា
មិនព្រមលះបង់ក្តីសង្ឃឹមនិងការព្យាយាមរបស់លោក ក្នុងការស្វែង
រកកូនប្រុសកូនស្រីទាំងបីនាក់នោះឡើយ ។ រីសេចក្តីស្នេហាដ៏ជ្រាល
ជ្រៅធំធេងរវាងលោកទាំងពីរ ក៏បាននាំនូវសុខសុភមង្គលយ៉ាងកក់
ក្តៅដល់កូនចៅនិងញាតិសន្តានទាំងឡាយ ដែលរស់នៅជុំវិញរូប លោក នាគ្រានោះដែរ ។
គេទាំងអស់បានរស់នៅយ៉ាងសុខសាន្ត រមនាជាគ្រួសារតែមួយ
ថ្វីបើគេនៅបាត់សមាជិកគ្រួសារខ្លះៗនៅ ឡើយ ហើយក៏រស់នៅអត្តខាត់បន្តិចក៏ដោយ ។
សេចក្តីស្រឡាញ់ ការយល់ទុក្ខធុរៈ និងការមានសន្តានចិត្តចំពោះគ្នាទៅវិញទៅមក
ជាកត្តានាំឲ្យទាំងអស់គ្នាក្នុងក្រុមគ្រួសារបានទទួលសេចក្តីសុខយ៉ាង ពេញលក្ខណៈ ។
នោះហើយជាស្ថានសួគ៌សុភមង្គល ដែលជាផ្លែផ្កា តបឆ្លើយចំពោះទង្វើដ៏ល្អរបស់គេ
ព្រោះគេមិនចាំបាច់ត្រូវស្លាប់អស់ ជីវិតសិន
មុននឹងអាចអោយព្រលឹងចេញហោះហើរស្វែងរកស្ថាន
សួគ៌សុភមង្គលនៅឯនិព្វានសំរាប់រូបគេនោះឡើយ ។៚

# ចប់

CHANBOKEO . COM

# វាចាចុងក្រោយ

- សុភមង្គលគ្រួសារជាប្រភពនៃកម្លាំងចិត្តរបស់បុគ្គលនិមួយៗ ។
- មនុស្សយើង មិនថាវ័យណាទេ តែងតែត្រូវការសេចក្ដីកក់ក្ដៅក្នុង ចិត្តពីរង្វង់គ្រួសារជានិច្ច ។
- **សេចក្ដីសុខរមែងកើតឡើងពីក្ដីស្រឡាញ់ និងការយល់ទុក្ខធុរៈ រវាងគ្នានិងគ្នា ។ កាលបើមានសេចក្ដីស្រឡាញ់ហើយ ភាពកក់ក្ដៅ ក្នុងចិត្តមនុស្សក៏នឹងកើតមានឡើង ។ ឯកម្លាំងចិត្តក៏កើនអនុភាព ពង្វាតឥទ្ធិពលទៅតាមនោះដែរ ។ កម្លាំងចិត្តជាកត្តានាំឲ្យមនុស្សមាន ចិត្តក្លាហាន ហ៊ានពុះពារអ្វីៗទាំងអស់ក្នុងជីវិត ។**
- ក្ដីសង្ឃឹមកើតមានដោយសារកំស្ទួលកម្លាំងចិត្ត ។ កម្លាំងចិត្តកើត មានដោយសារភក្ដីភាពនិងជំនឿទុកចិត្តរវាងគូស្រករ ។ បើសិនខ្វះ កម្លាំងចិត្តហើយ បុគ្គលណាក៏ដូចបុគ្គលណាដែរ ច្បាស់ជាថមថយ ភាពរឹងប៉ឹងផ្លូវចិត្ត សំរាប់ពុះពារអ្វីៗទាំងអស់ក្នុងជីវិតរបស់គេ ។
- ការបំបាក់កម្លាំងចិត្តដោយបំផ្លាញសុភមង្គលក្នុងគ្រួសារ អាចកាត់ បន្ថយនូវភាពរឹងប៉ឹងនិងការព្យាយាមរបស់ពលរដ្ឋ ហើយអាចញ៉ាំង ឲ្យប្រទេសមួយទាំងមូលថមថយការចំរើនវិវត្តន៍ ដោយស្វ័យប្រវត្តិ ។
- ថ្ងៃស្អែកនៅតែមានជានិច្ចសំរាប់យើង ដរាបណាយើងនៅមានក្ដី សង្ឃឹម និងការប៉ុនប៉ងប្រាថ្នា ។
- ជីវិតមនុស្សតែងជួបនឹងព្យុះភ្លៀងខ្លះៗ ។ ថ្វីបើជីវិតត្រូវព្យុះបោក បក់កំទេចខ្ទេចខ្ទាំខ្លះក៏ដោយ យើងមិនគួរផ្ដេកផ្ដួលមិនងើបវិញនោះ ឡើយ ។ មើលទៅរុក្ខជាតិចុះ ទោះបីជាព្យុះបក់បោកដាច់ស្លឹកយ៉ាងណា លុះព្រះសុរិយាយាងរះចាំងពន្លឺ រុក្ខជាតិក៏រីកស្រស់លាស់ស្លឹកជាថ្មីយ៉ាង បំព្រងមកវិញដដែល ។ ជាតិជាមនុស្ស មានសតិ មានប្រាជ្ញ ហេតុអ្វី
ត្រូវចាញ់រុក្ខជាតិផង ?
- ការដែលបុរសបន្ទន់តិរិយាបថចំពោះស្ត្រី មិនមែនមានន័យថាបង្អាប់ បង្អោនខ្លួនឯងទេ តែក៏គឺជាការសម្ដែងភាពថ្លៃថ្នូររបស់បុរស ក្នុងការ ផ្ដល់កម្លាំងចិត្តទៅនារីដែលគេស្រឡាញ់ ។ កាលបើគូជីវិតទាំងទ្វេយល់ចិត្តគ្នាច្បាស់លាស់ ភាពរមនាក្នុងគ្រួសារក៏កើតមានឡើង ។ ឯគូ ជីវិតទាំងពីរក៏មានកម្លាំងចិត្តខ្លាំងក្លា អាចប្រឈមមុខពុះពារឧបសគ្គ ទាំងឡាយក្នុងជីវិតបានយ៉ាងរឹងប៉ឹងក្លាហាន ។ រីកូនចៅទាំងឡាយក៏ បានទទួលសេចក្ដីសុខក្នុងដួងចិត្តរបស់គេគ្រប់ៗគ្នាដែរ ។
- ការសម្រក់ទឹកភ្នែកចេញមក មិនមែនជាសក្ខីភាពបង្ហាញភាពទន់ ខ្សោយរបស់បុរសស្ត្រីណាម្នាក់ទេ... តែគឺជាមធ្យោបាយដ៏ត្រជាក់បំផុត ដែលអាចពន្លត់ចិត្តមនុស្សពីក្ដៅរោលរាល អោយមកត្រជាក់រលត់វិញ បានដោយគ្រាន់តែបណ្ដោយអោយគេយំអោយអស់ចិត្តតែប៉ុណ្ណោះ ។ បើមិនដូច្នោះទេ ទឹកភ្នែកដែលមិនអាចហូរចេញមកក្រៅបាននឹងក្លាយជាបួសកំហឹងដ៏ឃ្លាន់ខ្លាញ់ក្នុងចិត្ត អាចបង្កបង្កើនជាគំនុំសងសឹកគ្នា គ្មានថ្ងៃស្បើយរសាយឡើយ...
- ការបែកបាក់រវាងមេគ្រួសារ ធ្វើឲ្យសមាជិកគ្រួសាររស់នៅ ក្រហល់ ក្រហាយ លែងមានសេចក្ដីសុខ ព្រោះម្ដាយឪពុកមិនចុះសម្រុងនឹង គ្នា ។ ដូចគ្នានេះដែរ ការបែកបាក់រវាងមេដឹកនាំជាតិ ធ្វើឲ្យពលរដ្ឋ រស់នៅក្ដៅក្រហាយលែងមានសេចក្ដីសុខ ព្រោះមេកោយមិនចុះ សម្រុងនឹងគ្នា ។

អ្នកស្រីកែវចន្ទ័បូរណ៍
អ្នកនិពន្ធ

CHANBOKEO.COM